# សង្កេតការណ៍

# ១៥

## ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម



ខែកញ្ញា ឆ្នាំ២០១២

### មាតិកា


សវនាការសួរដេញដោលសាក្សី

រចឹម គុន ២

សួង ស៊ីគឿន ២២

អ៊ុង ចុងហឿង ៤០

ស សៀក ៦៥


**ក្រុមសង្កេតការណ៍ :**

ឆាយ ឈុនលី, លឹម ជ័យទ័ត្ត,

ឌី សុជាតា និង ចាន ប្រាថ្នា

អៀង សារី

មុនពេលចាប់ខ្លួនបញ្ជូនទៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

(ថតដោយ : ឆាំង យុ, ឆ្នាំ១៩៩៩)


មជ្ឈមណ្ឌលឯកសារកម្ពុជា◆ស្វែងរកការពិតដើម្បីការចងចាំនិងយុត្តិធម៌◆www.dccam.org



អៀង សារី ទទួលស្វាគមន៍គណៈប្រតិភូបរទេស (រូបភាពមជ្ឈមណ្ឌលឯកសារកម្ពុជា)

# សវនាការលើសំណុំរឿង០០២
# ស្តីពីរចនាសម្ព័ន្ធរដ្ឋបាល ប្រព័ន្ធទំនាក់ទំនងការងារ និងគួនាទីជនជាប់ចោទ
# ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ
## ថ្ងៃទី២៥ ខែកក្កដា ដល់ថ្ងៃទី២១ ខែសីហា ឆ្នាំ២០១២

*ឌី សុជាតា, ចាន ប្រាថ្នា, ឆាយ ឈុនលី និង លឹម ជ័យទ័ត្ត*

### សេចក្តីផ្តើម

ចាប់ពីថ្ងៃទី២៥ ខែកក្កដា ដល់ថ្ងៃទី២១ ខែសីហា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបើកសវនាការសួរដេញដោលសាក្សីចំនួន៤រូប ដែលភាគច្រើននៃសក្ខីកម្មរបស់អ្នកទាំងនោះមានជាប់ទាក់ទងនឹងជនជាប់ចោទ អៀង សារី ។ សាក្សីទាំង៤រូបរួមមាន លោក រចឹម តុន ហៅ ភី ភួន ឬជៀម ជាអតីតកងការពាររបស់ ប៉ុល ពត និងធ្លាប់បម្រើការងារជាបុគ្គលិកជាន់ខ្ពស់នៃក្រសួងការបរទេស នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ លោក សួង ស៊ីគឿន ជាអតីតកម្មាភិបាលខ្មែរក្រហមបម្រើការនៅក្រសួងការបរទេសក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ លោក អុង ថុងហឿង ជាអតីតបញ្ញាជនដែលបាន ជាប់ឃុំនៅមន្ទីរបឹងត្របែក និងមន្ទីរផ្សេងៗទៀតនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ និងលោកស្រី ស សៀក អតីតបុគ្គលិកបម្រើការនៅក្រសួងឃោសនាការក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ នៅក្នុងអំឡុងពេលសវនាការនេះ មានការចូលរួមតាមដានពីសំណាក់ប្រជាជនកម្ពុជាដែលមកពីតាមបណ្តាខេត្តនានាដែលភាគច្រើនជាប្រជាកសិករ ។



អៀង សារី នៅក្នុងសាលសវនាការ (រូបភាពអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា)

# សវនាការសួរដេញដោលសាក្សី រចឹម គុន ហៅ ភី ភួន ឬ ជាម

ចាប់ពីរសៀលថ្ងៃទី២៥ ខែមិថុនា ដល់ថ្ងៃទី២ ខែសីហា ឆ្នាំ២០១២ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបន្តសវនាការសួរដេញដោលសាក្សីមួយរូបទៀតជាអតីតកងការពាររបស់ ប៉ុល ពត និងជាបុគ្គលិកជាន់ខ្ពស់នៃក្រសួងការបរទេសក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ការសួរដេញដោលសាក្សី រចឹម គុន ធ្វើឡើងបន្ទាប់ពីបញ្ចប់ការស្តាប់សក្ខីកម្មរបស់សាក្សីជំនាញលោក ដេវីឌ ឆេនដល័រ ។ នៅក្នុងអំឡុងពេលសួរដេញដោលសាក្សី រចឹម គុន ជនជាប់ចោទ អៀង សារី ដោយសារតែស្ថានភាពសុខភាពកាន់តែទ្រុឌទ្រោម អៀង សារី តែងតែស្នើសុំអង្គជំនុំជម្រះទៅសម្រាកនៅបន្ទប់ខាងក្រោម និងចូលរួមសវនាការដោយប្រយោល ។ ដូចគ្នានេះដែរ ជាប់ចោទ នួន ជា បានចូលរួមសវនាការដោយផ្ទាល់តែមួយព្រឹក ហើយស្នើសុំចូលរួមសវនាការដោយប្រយោលនៅបន្ទប់ខាងក្រោមនៅពេលរសៀល ។ ចំពោះជនជាប់ចោទ ខៀវ សំផន ធ្លាប់តែមានស្ថានភាពសុខភាពប្រសើរ និងបានចូលរួមនៅក្នុងសវនាការជាប្រចាំ ប៉ុន្តែនៅអំឡុងពេលស្តាប់ចម្លើយសាក្សី រចឹម គុន ជនជាប់ចោទក៏បានស្នើសុំ ទៅចូលរួមសវនាការដោយប្រយោលនៅបន្ទប់ខាងក្រោមដែរ ដោយសារអាការក្អកខ្លាំង ។ ការស្តាប់សក្ខីកម្មនេះបានផ្តោតទៅលើការប្រជុំមួយចំនួននៅមុនពេលខ្មែរក្រហមចូលទីក្រុងភ្នំពេញនៅឆ្នាំ១៩៧៥ និងទំនាក់ទំនងការងារក្នុងក្រសួងការបរទេស ។ តាមនីតិវិធី អង្គជំនុំជម្រះតែងតែសួរអំពីទំនាក់ទំនងសាច់ញាតិរវាងសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ឬភាគីណាមួយ ព្រមទាំងណែនាំពីសិទ្ធិមួយចំនួនរបស់សាក្សីក្នុងការផ្តល់សក្ខីកម្ម ។ មុននឹងប្រគល់វេទិកាជូនភាគី លោកប្រធានអង្គជំនុំជម្រះ និល ណុន បានសាកសួរអំពីប្រវត្តិសាវតាររបស់សាក្សីដើម្បីបញ្ជាក់អំពីអត្តសញ្ញាណឲ្យបានច្បាស់លាស់ និងអនុញ្ញាតឲ្យសាក្សីមានមេធាវីប្រឹក្សាមួយរូប ដើម្បីធានាអំពីសិទ្ធិក្នុងការមិនឆ្លើយដាក់បន្ទុកលើខ្លួនឯង លើកលែងតែសាក្សីចេតនាឆ្លើយដោយខ្លួនឯង ។

ឆ្លើយតបនឹងសំណួររបស់អង្គជំនុំជម្រះ លោកសាក្សីបានជម្រាបជូនលោកប្រធានអង្គជំនុំជម្រះថាលោកមានឈ្មោះ រចឹម គុន ហៅ ភី ភួន ឬ ជៀម មានអាយុ៦៥ឆ្នាំ រស់នៅភូមិដូង ឃុំម៉ាល័យ ស្រុកម៉ាល័យ ខេត្តបន្ទាយមានជ័យ និងមានមុខរបរជាអ្នកធ្វើស្រែចម្ការ ។ ឪពុករបស់លោកឈ្មោះ រចឹម ប៉ាំទូតក្អែក ម្តាយឈ្មោះ រចឹម ប៉ែច និងមានប្រពន្ធឈ្មោះ ស្រេង គីមលី មានកូនបួននាក់ ។ លោក រចឹម គុន បានបញ្ជាក់ថា លោកគឺជាជនជាតិចារាយ មានស្រុកកំណើតនៅភូមិកែប ឃុំតាឡាវ ស្រុកអណ្តូងពេជ្រ ដែលពីមុនគឺស្រុកអណ្តូងមាស ខេត្តរតនគិរី ។ សាក្សីបានទទួលស្គាល់ថាលោកធ្លាប់បានប្រើប្រាស់ឈ្មោះថា វី ជាម ហើយក្នុងរបបកម្ពុជាប្រជាធិបតេយ្យគេហៅលោកថា សមមិត្ត ជាម ។



ចៅក្រម និល ណុន, ប្រធានអង្គជំនុំជម្រះសាលាដំបូង

### ១) ការសួរសាក្សីដោយសហព្រះរាជអាជ្ញា

លោកតំណាងសហព្រះរាជអាជ្ញាជាតិ សេង ប៊ុនឃាង បានចាប់ផ្តើមសួរសាក្សី រចឹម គុន អំពីការចូលរួមក្នុងចលនាបដិវត្តខ្មែរក្រហម ។ លោកសាក្សីបានបញ្ជាក់ថា លោកបានចូលរួមក្នុងចលនាបដិវត្តតាមរយៈបងថ្លៃរបស់លោក ដែលបានណែនាំឲ្យជនជាតិភាគតិចជាច្រើនផ្សេងទៀតឲ្យចូលរួមដែរ ។ ចាប់តាំងពីឆ្នាំ១៩៦៣ រហូតដល់ឆ្នាំ១៩៦៨ លោកបានទទួលការណែនាំឲ្យចូលរួមនៅក្នុងសម្ព័ន្ធយុវកក តាមរយៈឈ្មោះ ម៉ាន(អតីតប្រធានតំបន់នៅព្រះវិហារ

ដែលស្លាប់នៅឆ្នាំ១៩៧(៨) និងក្រោយមកឈ្មោះ សូ ហុង បានណែនាំឲ្យចូលបដិវត្ត ហើយលោកបានក្លាយជាបក្ខជននៅឆ្នាំ១៩៧១ ។ ការណ៍ដែលលោកត្រូវបានអនុញ្ញាតឲ្យចូលរួមនៅក្នុងចលនាបដិវត្ត ហើយក្រោយមកក្លាយជាបក្ខជន និងមានសិទ្ធិដឹកនាំនៅក្នុងបក្ស គឺដោយសារការបំពេញកិច្ចការប្រចាំថ្ងៃបានល្អ ។

### ១.១) ការអប់រំ

សាក្សី រចឹម គុន បានបញ្ជាក់ថា លោកធ្លាប់បានទទួលការអប់រំពីបក្សជាបន្តបន្ទាប់ដូចជា សូ ហុង, ម៉ាន និង យ៉ែម បានបង្រៀនលោកអំពីការចូលបដិវត្តចំនួនបីថ្ងៃនៅអូរកប ។ បន្ទាប់មក មានវគ្គរៀនសូត្រផ្សេងទៀតដែលអ្នកបង្រៀនមានដូចជា ប៉ុល ពត និងប្រពន្ធរបស់គាត់ ។ នៅឆ្នាំ១៩៦៧ សាក្សីបានទទួលការណែនាំបណ្តុះបណ្តាលពី អៀង សារី អស់រយៈពេលកន្លះខែនៅភូមិកា ស្រុកបរកែវ ខេត្តរតនៈគិរី ។ ក្រោយពេលរំដោះទីក្រុងភ្នំពេញ សាក្សីធ្លាប់បានចូលរៀនជាមួយ នួន ជា នៅវិហារព្រះកែវ និង ខៀវ សំផន នៅសាលាបច្ចេកទេសសូវៀត ។ ការរៀននោះ គឺនិយាយអំពីទស្សនសភាពការណ៍រួមនៅក្នុង និងក្រៅប្រទេស ការធ្វើបដិវត្តប្រជាជាតិប្រជាធិបតេយ្យ ការធ្វើជីវទស្សនបដិវត្តនិងការចិញ្ចឹមជីវិតខ្លួនឯង ។ ខ្លឹមសាររួមនៅក្នុង និងក្រៅប្រទេស គឺការខ្ទេចខ្ទីនាមឲ្យស្គាល់ពីប្រទេសដែលឧបត្ថម្ភដល់បដិវត្តប្រទេសប្រឆាំងបដិវត្ត និងប្រទេសអព្យាក្រឹត្យ ។ ចំណែកនៅក្នុងសភាពការណ៍ក្នុងប្រទេស គឺខ្ទេចខ្ទីនាមពីស្ថានភាពនយោបាយ ការចូលរួមរបស់ប្រជាជនក្នុងសកម្មភាពនយោបាយ និងការប្រមូលកម្លាំងប្រជាជននៅក្នុងប្រទេសដែលជាស្នូលដើម្បីប្រឆាំងនឹងសត្រូវរួម ព្រោះបក្សមានហេតុផលថា បើមានប្រជាជន គឺមានកម្លាំងយោធា និងកម្លាំងសេដ្ឋកិច្ច ។ សាក្សីបានជម្រាបថា នៅក្នុងពេលប្រជុំនីមួយៗមានឯកសារចែកជូនមួយចំនួនដូចជា សភាពការណ៍ក្រៅប្រទេស ចលនាខាងនយោបាយដែលប្រជាជនគាំទ្រ និងឯកសារទង់បដិវត្តមុនពេលរំដោះ ប៉ុន្តែឈ្មោះឯកសារទាំងនោះ គឺមិនមានអ្វីទេគ្រាន់តែសរសេរដាក់កាបោន ហើយចែកគ្នាប៉ុណ្ណោះ ។ លុះចាប់ពីឆ្នាំ១៩៧៦តទៅ ទើបមានការបោះពុម្ពជាទង់បដិវត្ត ទង់យុវជន និងយុវនារីបដិវត្តន៍ និងទង់រណសិរ្ស ។

### ១.២) ទំនាក់ទំនងជាមួយបុគ្គលសំខាន់ៗ

នៅឆ្នាំ១៩៦៧ ខណៈដែលសាក្សី រចឹម គុន កំពុងស្នាក់នៅខេត្តរតនគិរី ពេលនោះលោកបានជួប ម៉ាន និងក្រោយមកបានជួប អៀង សារី រួចនាំសំបុត្រពី អៀង សារី ទៅប្រទេសវៀតណាម ។ សាក្សីបានបញ្ជាក់ថា នៅពេលដែលខ្លួននាំសំបុត្រទៅដល់ដំបូង លោកកត់សម្គាល់ឃើញថា អ្នកនៅទីនេះមិនសូវយកចិត្តទុកដាក់ជាមួយលោកទេ លុះក្រោយពេលទទួលបានសំបុត្រ ទើបលោកទទួលបានការរាក់ទាក់ ។ រហូតដល់ខែធ្នូឆ្នាំ១៩៦៧ លោកបានជួប ប៉ុល ពត ដែលពេលនោះ ប៉ុល ពត មានជម្ងឺ ហើយលោកបានជូនទៅមន្ទីរពេទ្យនៅប្រទេសវៀតណាម ។ ក្រោយពេលជាសះស្បើយ ប៉ុល ពត បានមកស្នាក់នៅមន្ទីរ១០០ ចំណែក អៀង សារី ស្នាក់នៅមន្ទីរ១០២ ។ លោកស្គាល់អ្នកទាំងពីរនេះតាមរយៈឈ្មោះ ឡើន ដែលនៅធ្វើការជាមួយគ្នា ។

### ១.៣) បទពិសោធពេលចូលបដិវត្តន៍

ឆ្លើយតបនឹងសំណួររបស់លោកតំណាងសហព្រះរាជអាជ្ញាជាតិ សេង ប៊ុនឃាង សាក្សី រចឹម គុន បានជម្រាបថា ក្នុងរយៈពេលមួយខែដែលខ្លួនជូន ប៉ុល ពត ទៅព្យាបាលជម្ងឺគ្រុនចាញ់នៅប្រទេសវៀតណាម ខ្លួនពិតជាមិនបានដឹងពីមូលហេតុលម្អិតក្រៅពីការព្យាបាលជម្ងឺនោះទេ ។ លោកគ្រាន់តែមានតួនាទីជូន ប៉ុល ពត ទៅតែប៉ុណ្ណោះ ហើយស្នាក់នៅទីនោះមួយខែទើបលោកត្រលប់មកវិញ ។ លោកបានបន្តថា នៅពេល អៀង សារី ស្នាក់នៅមន្ទីរ១០២ ខាងត្បូងទន្លេសេសាន ប៉ុល ពត ស្នាក់នៅមន្ទីរ១០០ ខាងជើងទន្លេសេសាន ដែលស្ថិតនៅចម្ងាយពីគ្នាប្រហែល៣គីឡូម៉ែត្រ ។ ពេលនោះសាក្សីមាននាទីជានីសារឲ្យមេដឹកនាំទាំងពីរ ដោយបញ្ជូនសំបុត្រទៅមនុស្សជាច្រើន ។ សាក្សីបានបន្តថា ការងារដាក់ស្តែងមួយចំនួនរបស់ ប៉ុល ពត គឺសរសេរសំបុត្រទៅកន្លែងផ្សេងៗ ដើម្បីអប់រំ និងផ្ញើជូនថ្នាក់តំបន់ ។ លោកបាននិយាយថា នៅពេលនោះ មេដឹកនាំទាំងពីររូបនេះមានកងការពារប្រហែល១០០នាក់ សុទ្ធតែបងប្អូនជនជាតិភាគតិចទាំងអស់ ។ សាក្សីបានសង្កេតឃើញថា ទំនាក់ទំនងរវាង អៀង សារី និង ប៉ុល ពត នៅពេលនោះ គឺស្រលាញ់គ្នាដូចជាបងប្អូន ។ អ្នកទាំងពីរតែងតែចែករំលែកគ្នានៅពេលមានអាហារហូបចុក ហើយលោកគិតថានេះគឺជាគំរូដ៏ល្អមួយ ។ សាក្សីបានជម្រាបជូនអង្គជំនុំជម្រះថា នៅពេលដែល ប៉ុល ពត ចេញទៅក្រៅប្រទេសម្តងៗ ដូចជា ប្រទេសវៀតណាម និងប្រទេសចិន (ទីក្រុង

ប៉េកាំង) គឺ អៀង សារី ជាអ្នកមើលការខុសត្រូវជំនួស ។ នៅឆ្នាំ១៩៦៩ តំបន់ដែល អៀង សារី និង ប៉ុល ពត ស្នាក់នៅ គឺចាប់ផ្តើមមានមេដឹកនាំខ្មែរក្រហមផ្សេងៗ ទៀតចេញចូលធ្វើកិច្ចការ ។ សាក្សីបានឃើញ នួន ជា ទៅទីនោះប្រហែល១០ថ្ងៃ ដើម្បីប្រជុំជាមួយ ប៉ុល ពត, អៀង សារី, កុយ ធួន និងមេដឹកនាំមួយចំនួនទៀត ។ ក្រោយពេលជួបប្រជុំនោះ ប៉ុល ពត បានហៅក្រុមការងាររបស់ រចឹម គុន ទាំងអស់ រួមទាំង ប៉ង់ មកប្រជុំដើម្បីប្រាប់ពីសភាពការណ៍នៅជុំវិញប្រទេស និងដើម្បីបង្កើនសមត្ថភាពទទួលខុសត្រូវ ។ នៅក្នុងពេលប្រជុំនោះសាក្សីបានឮ ប៉ុល ពត ចាត់ចែងឲ្យ ប៉ង់ ជាអ្នកទទួលខុសត្រូវនៅមន្ទីរ១០០ខាងផ្នែករដ្ឋបាល ហើយពេលនោះលោកដឹងថា សុន សេន ទើបតែមកដល់ ។ សាក្សីបានបន្តទៀតថា អ្នកដឹកនាំនៅរតនគិរីនៅ ពេលនោះរួមមាន ម៉ាន, ប៉ុល ពត, អៀង សារី និង សុន សេន ។ រហូតដល់ចុងឆ្នាំ១៩៦៩ សាក្សីបានឃើញមានការផ្លាស់ប្តូរ គឺ ប៉ុល ពត និងប្រពន្ធបានទៅវៀតណាម, ម៉ាន ទៅខេត្តព្រះវិហារ, អៀង សារី និង សុន សេន នៅទីនោះដដែល ។

នៅខែឧសភា ឆ្នាំ១៩៧០ ប៉ុល ពត ត្រឡប់មកខេត្តរតនគិរីវិញ ។ សាក្សីបានមកទទួលគាត់នៅកន្ទុយនាគ (ជាតំបន់ដែលមានរាងដូចជាកន្ទុយនាគស្ថិតនៅក្នុងខេត្តរតនគិរីជាប់នឹងព្រំដែនប្រទេសឡាវ និងវៀតណាម) មកតាមខេត្តកំពង់ចាម ហើយលោកបានបញ្ជាក់ថា ពីកន្ទុយនាគមកដល់ខេត្តកំពង់ចាម គឺត្រូវចំណាយពេលអស់៧ខែ និងបានផ្លាស់ប្តូរទីតាំងថ្មី។ បន្ទាប់ពីការផ្លាស់ប្តូរនេះ ប៉ុល ពត បានប្រាប់ថា ស្ថានភាពកាន់តែប្រសើរឡើង ហើយកម្លាំងខ្មែរក្រហមមួយចំនួនចេញទៅក្រៅដើម្បីរកជំនួយ ។ សាក្សី រចឹម គុន បានបំភ្លឺថា ទីតាំងថ្មីដែលបានផ្លាស់ប្តូរនោះគឺមន្ទីរស-៧១ ជាមន្ទីរដែលមានតួនាទីសំខាន់។ ក្រោយពេលមានរដ្ឋប្រហារកម្លាំងទាំងអស់បានប្រមូលផ្តុំនិងប្រជុំគ្នានៅទីនោះ ។ នៅមន្ទីរស-៧១ សាក្សីបានជួប ខៀវ សំផន លើកទីមួយ ដែលពីមុនលោកធ្លាប់តែឮសម្លេង ខៀវ សំផន តាមវិទ្យុតែប៉ុណ្ណោះ ។ សាក្សីសង្កេតឃើញថា ខៀវ សំផន តែងតែសរសេរទាំងថ្ងៃទាំងយប់ និងថាជនជាប់ចោទរូបនេះជាមនុស្សពូកែទាំងភាសាខ្មែរ និងបរទេស ។ ទាក់ទងនឹងរណសិរ្សរួបរួមជាតិកម្ពុជា លោកបានបន្តថា លោកបានឮការផ្សព្វផ្សាយតាមវិទ្យុអំពីរណសិរ្សរួបរួមជាតិកម្ពុជា ហើយពេលខ្លះ ខៀវ សំផន បានបង្រៀនពីកម្លាំងរណសិរ្ស និងណែនាំពីការប្រមូលកម្លាំងឲ្យបានច្រើន ទាំងកម្លាំងបញ្ញវន្ត និងកម្លាំងផ្សេងទៀតឲ្យបានគ្រប់ប្រភេទ ។

លោកតំណាងសហព្រះរាជអាជ្ញា សេង ប៊ុនឃាង បានបន្តសំណួររបស់ខ្លួនទាក់ទងនឹងសមរភូមិ ។ សាក្សី រចឹម គុន បានឆ្លើយតបថា ប៉ុល ពត ធ្លាប់ទៅសមរភូមិដើម្បីលើកទឹកចិត្តដល់កងទ័ពដោយផ្ទាល់ដូចជាកន្លែងរបស់ វ៉ន វ៉េត នៅសមរភូមិភូមិភាគពិសេស កន្លែងតាម៉ុក នៅភូមិភាគនិរតី ។ ចំណែក សុន សេន និង កុយ ធួន


តំណាងសហព្រះរាជអាជ្ញាជាតិ សេង ប៊ុនឃាង

នៅខាងភូមិភាគខេត្តកំពង់ធំដូចគ្នា ។ ឆ្លើយតបនឹងសំណួរបន្ទាប់ សាក្សីបានពន្យល់អំពីពាក្យថា "សមរភូមិ" មានន័យថា ជាកន្លែងហ្វឹកហ្វឺនយោធា ។ សាក្សីបានបំភ្លឺជូនអង្គជំនុំជម្រះថា ក្នុងចំណោមមេដឹកនាំខ្មែរក្រហមនៅមន្ទីរស-៧១ ដែលមានដូចជា នួន ជា, ខៀវ សំផន និង អៀង សារី គឺមានតែ ប៉ុល ពត ម្នាក់ប៉ុណ្ណោះ ដែលបានផ្តល់ការលើកទឹកចិត្តដល់កងទ័ពនៅសមរភូមិ ចំណែក នួន ជា និង ខៀវ សំផន គឺគ្រាន់តែធ្វើការនៅកន្លែងប៉ុណ្ណោះ ។ ប៉ុន្តែនៅឆ្នាំ១៩៧២ នួន ជា បានធ្វើដំណើរទៅសំឡូត ដើម្បីជួបប្រជុំជាមួយប្រធានភូមិភាគពាយ័ព្យ ដូចជា តាស៊ូ, តាម៉ាញ និង ហ៊ូ យន់ ។

### ១.៤) មុខងាររបស់ អៀង សារី

ទាក់ទងនឹងជនជាប់ចោទ អៀង សារី សាក្សីបានជម្រាប

ជូនអង្គជំនុំជម្រះថា នៅពេលបក្សធ្វើការផ្លាស់ប្តូរទីតាំងនៅឆ្នាំ ១៩៧០ អៀង សារី មិនបានចូលរួមទេគឺលោកជាប់ប្រចាំការនៅខេត្តរតនគិរីដដែល ។ នៅដើមឆ្នាំ១៩៧១ អៀង សារី បានធ្វើដំណើរទៅវៀតណាម និងប៉េកាំងរហូតដល់ពេលរំដោះភ្នំពេញថ្ងៃទី ១៧ ខែមេសា ឆ្នាំ១៩៧៥ ទើប អៀង សារី បានត្រលប់មកវិញ ។ នៅឆ្នាំ១៩៧១ សាក្សីបានឮវិទ្យុរបស់ទីក្រុងប៉េកាំងផ្សាយជាភាសាខ្មែរថា អៀង សារី ទៅប៉េកាំងក្នុងនាមជាបេសកជនពិសេសរបស់ចលនាតស៊ូ និងអមសម្តេច នរោត្តម សីហនុ ដើម្បីបំពេញការងារការទូតនៅក្រៅប្រទេស ប៉ុន្តែសាក្សីបញ្ជាក់ថា លោកមិនបានដឹងពីមូលហេតុដែល អៀង សារី ទៅអមសម្តេចសីហនុនោះទេ លោកគ្រាន់តែដឹងថា តាំងពីពេលនោះមក គឺមានផ្សាយវិទ្យុជាបន្តបន្ទាប់ ។ លោកតំណាងសហព្រះរាជអាជ្ញា សេង ប៊ុនឃាង បន្តសួរទាក់ទងនឹងការចាយលុយ ហើយសាក្សីបានបញ្ជាក់ថា នៅចន្លោះឆ្នាំ១៩៦៧-១៩៧៥គឺនៅមានការបើកប្រាក់ខែនៅឡើយ ដូច្នេះលោកជឿថាពិតជាមានការចាយប្រាក់នៅពេលនោះ ។ ទាក់ទងនឹងខ្មាំងរបស់បដិវត្ត លោកបានបញ្ជាក់ថា សហរដ្ឋអាមេរិក និងជនក្បត់បក្ស គឺត្រូវបានចាត់ទុកថាជាខ្មាំងរបស់បដិវត្ត ។

### ១.៥) កិច្ចប្រជុំ

ទាក់ទងនឹងកិច្ចប្រជុំរបស់មជ្ឈិម ឬប្រជុំសន្និបាតបក្សនៅពេលដែលបក្សបានផ្លាស់ទីតាំងមកកាន់មន្ទីរស-៧១ នៅស្រុកស្ទឹងត្រង់ ចន្លោះឆ្នាំ១៩៧១ដល់ឆ្នាំ១៩៧៥ លោកបានឃើញជាក់ស្តែង គឺនៅឆ្នាំ១៩៧១ មានប្រជុំរួមម្តងរវាងសមាជិកមជ្ឈិមទាំងអស់ដែលធ្វើឡើងក្នុងរយៈពេល៣ ឬ៤ឆ្នាំម្តង ។ ចំពោះការប្រជុំតូចៗគឺមានជាអចិន្ត្រៃយ៍ស្ទើរគ្រប់រដូវកាលដែលមានអ៊ំទី១ (ប៉ុល ពត) និងអ៊ំទី២ (នួន ជា) តែងតែចូលរួម ។ សាក្សីបានបន្តថា ការប្រជុំនៅឆ្នាំ១៩៧១មានពីរផ្នែកដែលមានកម្មាភិបាលមកពីទូទាំងប្រទេសចូលរួម ។ ការប្រជុំលើកទីមួយគឺធ្វើនៅជិតស្ទឹងជីនិតដែលមានគណៈតំបន់ គណៈស្រុក និងសមាជិកស្រុកមកជុំគ្នានៅភូមិភាគ៣៨ ដែលមានអ្នកទទួលខុសត្រូវ... 

មជ្ឈិមមកពីគ្រប់ភូមិភាគនៅទូទាំងប្រទេសមកចូលរួមដូចជា ខាងយោធា និងស៊ីវិលរយៈពេលជាង១សប្តាហ៍ ។ លោកបានបន្តថា ចាប់ពីឆ្នាំ១៩៧១ ដល់ឆ្នាំ១៩៧៣ អៀង សារី មិនមានវត្តមាននៅក្នុងអង្គប្រជុំទេ ដោយសារពេលនោះ អៀង សារី កំពុងបំពេញការងារនៅបរទេស ។ នៅឆ្នាំ ១៩៧៣ ដដែល អៀង សារី បានត្រលប់មកពីការអមដំណើរសម្តេចនរោត្តម សីហនុ យាងទតសហករណ៍នៅតំបន់រំដោះរួចក៏ត្រលប់ទៅបរទេសវិញ ។ ក្រោយមក អៀង សារី


សាក្សី រចឹម គុន ហៅ ភី ភួន

មានវត្តមាននៅក្នុងកិច្ចប្រជុំធំមួយនៅខែមិថុនា ឆ្នាំ១៩៧៤ ដែលធ្វើនៅមាត់ទន្លេមេគង្គនៅក្នុងភូមិមាយ ដែលការប្រជុំនោះមិនខុសពីការប្រជុំនានាកន្លងមកនោះទេ គឺមានណែនាំអំពីទស្សនៈសភាពការណ៍នៅក្នុង និងក្រៅប្រទេស ការរំដោះនៅតាមតំបន់មួយចំនួន និងការធ្វើជីវទស្សនៈបដិវត្ត ។ សាក្សីបានដឹងពីខ្លឹមសារនៃការប្រជុំដោយសារនៅពេលនោះលោកគឺជាអ្នកយាម ប៉ុន្តែលោកបានព្យាយាមយកចិត្តទុកដាក់លើការប្រជុំនោះ ។ម្យ៉ាងទៀតអ្នកដែលចូលរួមប្រជុំនៅឆ្នាំ១៩៧៤ គឺមានចំនួនតិចជាងអ្នកចូលរួមប្រជុំនៅឆ្នាំ១៩៧១ ។ សាក្សី រចឹម គុន បានជម្រាបជូនអង្គជំនុំជម្រះថា ការប្រជុំនោះមានការសរសេរគូសវាសលើក្តារខៀន និងមានជាឯកសារចែកជូនអ្នក ចូលរួមទៀតផង ។

### ១.៦) មន្ទីរប-៥

លោកតំណាងសហព្រះរាជអាជ្ញាជាតិ សេង ប៊ុនឃាង បានបន្តសួរដោយលើកយកប្រធានបទទាក់ទងនឹងមន្ទីរប-៥ ដែលសាក្សីបានបញ្ជាក់ថា មន្ទីរនេះជាកន្លែងបញ្ជាសមរភូមិទូទាំងប្រទេស ដើម្បីវាយរំដោះទីក្រុងភ្នំពេញនៅឆ្នាំ១៩៧៥ ហើយមានទីតាំងនៅភូមិតាំងពោន ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង និងបើកដំណើរការដំបូងនៅឆ្នាំ១៩៧៣ ។ គួរបញ្ជាក់ថា មន្ទីររបស់ សុន សេន ក៏នៅក្បែរមន្ទីរប-៥ដែរ ។ សាក្សីបានបញ្ជាក់ថា ប៉ុល ពត បានស្នាក់នៅមន្ទីរប-៥ ជាអចិន្ត្រៃយ៍ ប៉ុន្តែនៅចុងឆ្នាំ១៩៧៤ ប៉ុល ពត បានស្នាក់នៅមន្ទីរប-៥ នៅរដូវប្រាំង ហើយស្នាក់នៅមន្ទីរស-៧១ នៅរដូវវស្សា ហើយពេលខ្លះក៏មានវត្តមានរបស់ នួន ជា និង ខៀវ សំផន នៅមន្ទីរប-៥ ដែរ ។ សាក្សីបានបន្តថា ពេលមានប្រជុំម្តងៗ កម្មាភិបាលនៅតាមសមរភូមិមកចូលរួមនៅទីនោះមាន ដូចជា សុន សេន, តាម៉ុក, វ៉ន វ៉េត, ចេង អន, កុយ ធួន, កែ ពក, សោ ភឹម, តាភួង និង តាទុំ ។ ការជួបប្រជុំគ្នានោះធ្វើឡើងក្នុងរយៈពេលពី៥ថ្ងៃទៅ ១០ថ្ងៃឬកន្លះខែគឺអាស្រ័យលើសភាពការណ៍សមរភូមិ ។ សាក្សីបានរៀបរាប់បន្តថា មន្ទីរប-៥ បានបើកការប្រជុំនៅដើម ខែមេសា ឆ្នាំ១៩៧៥ ដែលមានការចូលរួមពី ប៉ុល ពត, នួន ជា, ខៀវ សំផន, តាម៉ុក, សុន សេន, កុយ ធួន, វ៉ន វ៉េត, ចេង អន និង សោ ភឹម ដែលនិយាយពីការជម្លៀសប្រជាជន ហើយនៅក្នុងនោះមានឯកសារមួយចំនួន ដូចជា ផែនទីប្រទេសកម្ពុជា និងផែនទីសមរភូមិជាដើម ។ សាក្សីបានបញ្ជាក់ថា លោកបានឮអ្នកដឹកនាំទាំងនោះនិយាយគ្នាថា “លន់ នល់ មិនអាចទប់យើងបានទេ តែប៉ុណ្ណោះយើងជាន់មួយរយៗហើយ ។ ហ្នឹងពេលហ្នឹងគឺអ៊ីចឹងហើយសភាពការណ៍វាអនុគ្រោះឲ្យយើងហើយ ។ ដល់មករាយការណ៍តាមសមរភូមិ ឃើញថាវាជាន់គ្រប់កន្លែង ហើយវាគ្មានទៅហក់រួចទេ នៅតែថ្ងៃចាញ់យើងតែប៉ុណ្ណឹង” ។ សាក្សីបានបន្តថា ផែនការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញត្រូវបានកំណត់តែមួយអាទិត្យប៉ុណ្ណោះ ព្រោះបើនៅមានប្រជាជននៅក្នុងទីក្រុងនឹងនាំឲ្យមានការលំបាកក្នុងការគ្រប់គ្រង ។ នៅពេលនោះ នួន ជា និង ខៀវ សំផន បានឯកភាពភ្លាមចំពោះការជម្លៀស ហើយក្រោយមក ប៉ុល ពត ក៏បានដាក់វិធានការក្នុងការអនុវត្ត ។

បន្ទាប់មកលោក ឌុល លីសាក់ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិបានបន្តការសាកសួរពីលោក សេង ប៊ុនឃាង ។ ឆ្លើយតបនឹងសំណួរដែលទាក់ទងនឹងមន្ទីរប-៥ នោះសាក្សីបានរៀបរាប់ថា នៅឆ្នាំ១៩៧២ ខ្លួនបានទៅមន្ទីរប-៥ ដែលកាលនោះស្ថិតនៅច្រកស្តេចដែលជាទីតាំងនៅឆ្ងាយពិបាកធ្វើដំណើរ ប៉ុន្តែក្រោយមកបក្សបានប្តូរទីតាំងមន្ទីរប-៥មកភូមិតាំងពោនវិញ ។ នៅឆ្នាំ១៩៧៤ដល់ឆ្នាំ១៩៧៥ នៅខាងលិចមន្ទីរនោះ គឺមានមន្ទីររបស់ភូមិភាគ និរតី ដែលគ្រប់គ្រងដោយ តាម៉ុក ហើយ សុន សេន ក៏នៅជិតនោះដែរ ។ ក្រៅពីនោះ បក្សមានមន្ទីរពេទ្យសម្រាប់យោធាដែលគ្រប់គ្រងដោយ ដួន ជឿន និងបន្ទាប់មក ហ៊ុង នៅប្រចាំនៅទីនោះ ។

ចំណែកនៅភូមិភាគពិសេស មានអ្នកគ្រប់គ្រងបីនាក់គឺ វ៉ន វ៉េត, ចេង អន និងម្នាក់ទៀតបានស្លាប់ ។ តំណាងសហព្រះរាជអាជ្ញាបានបន្តសំណួរទាក់ទងនឹងការប្រជុំរបស់មេដឹកនាំនៅមន្ទីរប-៥ ដោយសាក្សីបានរៀបរាប់ថា មេដឹកនាំទាំងនោះមិនមកទាំងអស់គ្នាទេ ដោយសារប-៥ជាកន្លែងបញ្ជាសមរភូមិមុខ ។ ចំណែកសមរភូមិក្រោយ គឺជាមន្ទីរសម្រាប់ចល័ត ដែលមានលេខសម្គាល់ដូចជា លេខ២៤, ៣៥, ៧៤, ប-១៧, ប-១៩ និង ប-២០ជាដើម ។ សាក្សីបានរៀប រាប់ថា ខ្លួនធ្លាប់ការពារ នួន ជា ទៅស្រុកសំឡូតនៅឆ្នាំ១៩៧៣ ហើយបានចូលទៅភូមិកំណើតរបស់ប្រពន្ធ នួន ជា នៅក្នុងភូមិស្រែអណ្តូងដែរ ។ នៅពេលរំដោះខេត្តុង ប៉ុល ពត ស្នាក់នៅមន្ទីរប-៥ ហើយបានចាត់តាំងខ្លួនឲ្យទៅមើលសភាពការណ៍នៅតាមផ្លូវ និងនាំយកសំបុត្រឲ្យ កុយ ធួន នៅបាធាយ និង នួន ជា នៅមន្ទីរ៧៤ ដែលស្ថិតនៅស្ទឹងមាយ ជិតស្ទឹងត្រង់ ។

លោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិបានបន្តសួរអំពីការសម្ភាសន៍ជាមួយលោក ហ៊ីលីព ស្សូត ។ ទាក់ទងនឹងបញ្ហានេះសាក្សីបានបញ្ជាក់ថា ខ្លួនត្រូវបានសម្ភាសន៍ដោយលោក ហ៊ីលីព ស្សូត និងបានទទួលឯកសារមួយចំនួន ប៉ុន្តែលោកមិនចាំថាជាភាសាខ្មែរ ឬអង់គ្លេសនោះទេ ។ លោកតំណាងសហព្រះរាជអាជ្ញាបានអានសេចក្តីសម្រង់នៅក្នុងសៀវភៅរបស់លោក ហ៊ីលីព ហ្សូត ដែលមានអត្ថន័យថា “នៅទីបំផុត នៅខែមីនា ឆ្នាំ១៩៧៤ មានការជម្លៀសប្រជាជនចេញពីឧត្តុង្គ ។ តាមសម្តីរបស់ជំនួយការ

ប៉ុល ពត គឺ ភី ភួន និយាយថា មិនមានបញ្ហាធំដុំអ្វីចំពោះពួកយើង ក្នុងការជម្លៀសប្រជាជនចេញពីខត្តក្តទៅរស់នៅជនបទទេ ។ ចំពោះពួកគេវិញ ពួកគេរស់នៅទីក្រុងក៏មិនបង្កឲ្យមានការលំបាកអ្វីខ្លាំងដែរ ។ នេះគឺជាដំណោះស្រាយដំបូងដែលត្រូវបានបង្កើតដើម្បីតទល់នឹងការប៉ុនប៉ងណាមួយពីសំណាក់ខ្មាំងសត្រូវ ដើម្បីធ្វើឲ្យជ្រួលច្របល់ដល់កងម្លាំងរបស់យើង ហើយជាមួយគ្នានេះដែរវាក៏ជាវិធានការផ្ទៃក្នុងដែរ...» ។ ចំពោះការដកស្រង់នេះ សាក្សីបានទទួលស្គាល់ និងបានអះអាងថា រូបថតដែលតំណាងសហព្រះរាជអាជ្ញាបានបង្ហាញនោះមាន ប៉ុល ពត, យ៉ា, នួន ជា, កុយ ធួន, តាម៉ុក និង សោ ភឹម នៅពេលប្រជុំសន្និបាតបក្ស ដែលកាលនោះ ប៉ង់ ជា អ្នកថត ។



អៀង សារី រួមដំណើរជាមួយកម្មាភិបាលខ្មែរក្រហម (រូបភាពមជ្ឈមណ្ឌលឯកសារកម្ពុជា)

សាក្សី រចឹម តុន បានរៀបរាប់ថា នៅពេលប្រជុំដែលនិយាយពីការជម្លៀសប្រជាជន លោកឃើញមានវត្តមានសមាជិកបក្សពីគ្រប់ភូមិភាគ ប៉ុន្តែមិនច្រើនដូចកាលប្រជុំនៅឆ្នាំ១៩៧១ទេ ។ បន្ទាប់មក លោកតំណាងសហព្រះរាជអាជ្ញាបានលើកឡើងពីឈ្មោះ ប្រសិទ្ធ នៅកោះកុង ដែលមានសរសេរនៅសៀវភៅរបស់លោក ហ៊ីលីពហ្វុត ។ សាក្សីបានរៀបរាប់ថា ពេលប្រជុំរាល់ដងគឺតែងតែមានវត្តមានរបស់ ប្រសិទ្ធ ប៉ុន្តែលើកក្រោយនេះមិនឃើញ ប្រសិទ្ធ មកចូលរួមទេ ។ សាក្សីបានបន្តថា ទាក់ទងនឹងការជម្លៀសប្រជាជនចេញពីទីក្រុងនោះ លោកបានឮគេនិយាយប្រាប់ថា ហ៊ូ យន់ បានជំទាស់នឹងផែនការនោះ ប៉ុន្តែក្រោយមកលោកមិនបានដឹងព័ត៌ច្រើនទាក់ទងនឹង ហ៊ូ យន់ទេ ។ លោកតំណាងសហព្រះរាជអាជ្ញាបានបន្តសំណួររបស់ខ្លួនទាក់ទងនឹងការយល់ដឹងរបស់សាក្សីអំពីការជម្លៀស ហើយសាក្សីបានរៀបរាប់ថា លោកបានដឹងតាមរយៈ សុន សេន និងតាមរយៈវិទ្យុទាក់ទងមួយដែលលោករកបានពេលវាយនៅខត្តុង ។ សាក្សីបានបញ្ជាក់ថា ខ្លួនដឹងតាមរយៈវិទ្យុទាក់ទងគ្នាតាមតំបន់នីមួយៗ ដែលកាលនោះ លោកមានលទ្ធភាពស្តាប់វិទ្យុទាក់ទងនោះ ស្ទើរតែពេញ២៤ម៉ោង ។ សាក្សីបានបន្ថែមទៀតថា បន្ទាប់ពីភ្នំពេញត្រូវបានរំដោះនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ពីរថ្ងៃក្រោយមក លោកបានធ្វើដំណើរ មកទីក្រុងភ្នំពេញតាមការចាត់តាំងរបស់បក្ស ជាមួយ សុន សេន, តាម៉ុក, វន វេត, កុយ ធួន និង ប៉ុល ពត ។ លោកបានឃើញប្រជាជនធ្វើដំណើរចេញពីទីក្រុងភ្នំពេញតាម

ផ្លូវជាតិលេខ៤ និងឃើញមានសាកសពនៅតាមផ្លូវ ហើយពេលនោះ សុន សេន បានបញ្ជាក់ថា «នៅតាមផ្លូវបើអ្នកណារឹងទទឹងប្រឡេះខ្វះទៅ កុំឲ្យទើសដៃទើសជើង» ។ នៅថ្ងៃទី២០ ខែមេសា មេដឹកនាំបានមកជួបជុំគ្នានៅវ៉ារទេះភ្លើង រួមទាំងយុទ្ធជនជាច្រើននាក់ ទាំងវរសេនាតូច ធំ ដែលមានដូចជា កុយ ធួន, នួន ជា, សោ ភឹម, វន វ៉េត, ចេង អន និង តាម៉ុក មកជុំគ្នាទាំងអស់នៅទីនោះប្រហែលជិតមួយសប្តាហ៍ ហើយសាក្សីមានតួនាទីជាអ្នកយាមទាំងយប់ទាំងថ្ងៃ។ លោកបានបន្តថា អៀង សារី បានត្រលប់មកពីបរទេស ហើយមកដល់



មេដឹកនាំខ្មែរក្រហម ដឹកនាំគណៈប្រតិភូបរទេសទៅតាមការដ្ឋាន (រូបភាពមជ្ឈមណ្ឌលឯកសារកម្ពុជា)

ភ្នំពេញក្រោយពេលរំដោះប្រហែលមួយសប្តាហ៍ ។ ក្រោយមក មេដឹកនាំ និងយុទ្ធជននៅវ៉ារទេះភ្លើងបានប្តូរទីតាំងមកនៅក្រសួងពាណិជ្ជកម្ម ដែលនៅជិតអគ្គសេនាធិការសព្វថ្ងៃនេះក្នុងរយៈពេលប្រហែលពីរសប្តាហ៍ ។ តាមរយៈការងារជាអ្នករក្សាសន្តិសុខជូនមេដឹកនាំទាំងនោះ សាក្សីបានជម្រាបជូនអង្គជំនុំជម្រះថា លោកបានសង្កេតឃើញ ប៉ុល ពត, នួន ជា, អៀង សារី និងខៀវសំផន ធ្វើការប្រជុំគ្នាយ៉ាងមមាញឹកទាំងថ្ងៃទាំងយប់ពេលនៅវ៉ារទេះភ្លើង និងក្រសួងពាណិជ្ជកម្មចាស់ ។ គួរកត់សម្គាល់ថា នៅត្រង់ចំណុចនេះ មេធាវីអន្តរជាតិការពារក្តីជនជាប់ចោទ អៀង សារី គឺលោក ម៉ៃឃើល ការណាវ៉ាស បានជំទាស់នឹងសំណួររបស់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ដោយសំអាងហេតុផលថា នៅក្នុងអំឡុងពេលនោះ កូនក្តីរបស់ខ្លួន អៀង សារី មិនមានវត្តមាននៅស្ថានីយរទេះភ្លើងនោះទេ ។ លោកបានស្នើថា សូមកុំឲ្យតំណាងសហព្រះរាជអាជ្ញាព្យាយាមទាញអំណះអំណាងឲ្យឃើញថាអ្នកទាំងនោះនៅជាមួយគ្នា ។ ភ្លាមនោះ លោកតំណាងសហព្រះរាជអាជ្ញាបានឆ្លើយតបថា សំណួររបស់លោក គឺមានបំណងចង់ឲ្យសាក្សីបញ្ជាក់ពីបញ្ហានេះ ។ ឆ្លើយតបនឹងសំណួររបស់លោកតំណាងសហព្រះរាជអាជ្ញា សាក្សីបានបន្តរៀបរាប់ថា ខ្លួនបានឃើញ ប៉ុល ពត, នួន ជា, ខៀវ សំផន, និង អៀង សារី នៅធ្វើការជាមួយគ្នាជាប់ជានិច្ច ។ ចំណែកបុគ្គលមួយចំនួនដែលនៅកន្លែងដាច់ដោយឡែកតាមទីតាំងរៀងៗខ្លួននោះមានដូចជា សុន សេន, តាម៉ុក, វន វ៉េត, កុយ ធួន និង សោ ភឹម ដែលមានក្តាប់កម្លាំងទ័ពទៀតផង ។ លោកបានបន្តថា ចំពោះ អៀង សារី នៅពេលត្រលប់មកពីក្រៅប្រទេសវិញ គឺបានចាប់ផ្តើមរៀបចំកន្លែងសម្រាប់ទទួលភ្ញៀវទាំងផ្នែកសន្តិសុខ និងការរៀបចំម្ហូប

អាហារនៅខាងក្រោយរាំង ។ ក្រោយមកមេដឹកនាំទាំងនោះបានផ្លាស់ទៅនៅមន្ទីរក-៣ ពេលនោះសាក្សីមិនបានទៅបំពេញការងារជាអ្នកយាមទៀតទេ ដោយលោកបានផ្លាស់ប្តូរការងារមកធ្វើជាអ្នករៀបចំទទួលភ្ញៀវវិញ ។ ប៉ុន្តែសាក្សីនៅចាំបានថា ក្នុងខែឧសភា មេដឹកនាំទាំងនោះបានមកជួបជុំគ្នាពីគ្រប់ភូមិភាគទាំងអស់នៅវិហារព្រះកែវមរកត ដើម្បីរៀនសូត្រក្នុងរយៈពេល១០ថ្ងៃ ហើយថ្ងៃខ្លះសាក្សីក៏មានវត្តមាននៅក្នុងវគ្គរៀនសូត្រនៅទីនោះ ។ ការប្រជុំគ្នានេះក្នុងគោលបំណងរៀបចំផែនការបដិវត្តសង្គមនិយម និងឈានទៅរកកុម្មុយនីស្ត ដែលរបៀបនៃការប្រជុំលើកនេះមិនខុសគ្នាពីកិច្ចប្រជុំមុនៗទេ គឺខ្ទេសនាមសភាពការណ៍ក្នុង និងក្រៅប្រទេសការធ្វើជីវទស្សនៈបដិវត្ត និងការលើកទិសដៅផែនការអនុវត្តបន្តលើមាគ៌ាសំខាន់ៗ ។ ប៉ុន្តែសាក្សីមិនចាំថាតើមានឯកសារអ្វីខ្លះដែលប្រើប្រាស់នៅក្នុងការប្រជុំនេះទេ ហើយការជម្លៀសប្រជាជននៅភ្នំពេញ ការចាយប្រាក់ និងការបិទវត្តអារាម លោកមិនបានឮនរណាម្នាក់លើកឡើងនៅក្នុងកិច្ចប្រជុំលើកនេះទេ ។

### ១.៦) ការងារនៅក្រសួងការទេស

សាក្សីបានបញ្ជាក់ថា លោកចាប់ផ្តើមការងារជាអ្នករៀបចំទទួលភ្ញៀវនៅក្រសួងការបរទេសជាមួយ អៀង សារី ចាប់ពីខែឧសភា ឆ្នាំ១៩៧៥ ហើយការទទួលភ្ញៀវមានស្ទើររាល់សប្តាហ៍រហូតដល់ចុងឆ្នាំ១៩៧៨ដើមឆ្នាំ១៩៧៧ ទើបលោកប្តូរមករៀបចំទទួលភ្ញៀវនៅមន្ទីរប-១ ដែលជាមន្ទីរសម្រាប់ទទួលភ្ញៀវ និងខាងកិច្ចការបរទេសវិញ ។ សាក្សី គឺជាប្រធានមន្ទីរប-១ ទទួលខុសត្រូវខាងការងាររដ្ឋបាលនិងគ្រប់គ្រងកម្លាំងនៅទីក្រុងភ្នំពេញ និងជាអ្នកគ្រប់គ្រងទាំងផ្នែកនយោបាយ សតិអារម្មណ៍ការចាត់តាំង និងមន្ទីរទទួលភ្ញៀវនៅតាមខេត្តដូចជា ខេត្តព្រះសីហនុ, សៀមរាប, បាត់ដំបង, ពោធិ៍សាត់, កំពង់ឆ្នាំង, កំពង់ចាម ដែលមានទីតាំងនៅតាមមន្ទីរខេត្តនីមួយៗ ។ លោកបានបញ្ជាក់ថា លោករាយការណ៍អំពីស្ថានភាពការងារជូន អៀង សារី រដ្ឋមន្ត្រីទទួលបន្ទុកខ្ពស់បំផុតនៅក្រសួងការបរទេស ដែលមានបុគ្គលិកប្រហែល១,០០០នាក់នៅចុងឆ្នាំ១៩៧៨ ។ ចំពោះការជ្រើសរើសបុគ្គលិកនៅមន្ទីរប-១ នេះបើថ្នាក់កម្មាភិបាលត្រូវជ្រើសរើសដោយមន្ទីរ៨៧០ ។ មន្ទីរ៨៧០គ្រប់គ្រងដោយ ប៉ង់ ដែលទទួលការណែនាំពី ប៉ុល ពត ហើយមន្ទីរនេះទាក់ទងទៅគ្រប់ភូមិភាគអំពីចំនួនបុគ្គលិក ដែលមន្ទីរនេះចង់បាន និងមានការជ្រើសរើសដោយផ្ទាល់ពី ប៉ង់ ។ ចំពោះបុគ្គលិក ដែលធ្វើការនៅក្នុងក្រសួងការបរទេស គឺ អៀង សារី ជាអ្នកណែនាំ ហើយសាក្សីគ្រាន់តែមើលការអនុវត្តជាក់ស្តែង និងនាំបុគ្គលទាំងនោះមកដើម្បីណែនាំជាក្រុម ជាកងថាអ្នកណានៅផ្នែកណាតែប៉ុណ្ណោះ ។ នៅឆ្នាំ១៩៧៧ សាក្សីបានចូលរួមជ្រើសរើសបុគ្គលិកមកពីបុរីកីឡា ហើយតម្រូវឲ្យបុគ្គលិកទាំងនោះមកធ្វើការនៅក្រសួងការបរទេសក្រោមបញ្ជាពីមន្ទីរ៨៧០ ជាអ្នកបង្គាប់ឲ្យលោកចាត់ចែងលើបុគ្គលទាំងនោះ ។ លក្ខខណ្ឌដែលកំណត់ពីមន្ទីរ៨៧០ គឺវណ្ណៈភាពដែលចេញពីត្រកូលកសិករក្រីក្រមិនជំពាក់អ្វីទាំងអស់ និងមិនមានជាប់និន្នាការអ្វីឡើយ គឺប្រកបធ្វើស្រែចម្ការដោយលំបាក ។ បក្សបានចាត់ទុកអ្នកទាំងនេះជាកម្លាំងស្នូលបដិវត្ត ។ ដើម្បីដឹងពីវណ្ណៈភាពរបស់បុគ្គលម្នាក់ៗ គឺត្រូវទៅទាក់ទងអ្នកធ្វើការនៅបុរីកីឡាដែលមានប្រវត្តិរូបសង្ខេបរួចយកបញ្ជីនោះទៅហៅឈ្មោះបុគ្គលទាំងនោះ និងជ្រើសរើសអ្នកមានរូបរាងសមរម្យដើម្បីទៅធ្វើការនៅបរទេស ប្រសិនបើចាំបាច់ ។ ពេលទៅជាមួយ អៀង សារី តាមភូមិភាគលោកបាន


តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ខេល លីសាក់

សង្កេតឃើញថា ស្ថានភាពប្រជាជននៅតាមផ្លូវមានសាច់ឈាមមិនសូវរីករាយដោយសារប្រជាជនមានការងារច្រើនដូចជា ធ្វើស្រែ ជីកប្រឡាយ និងមានកន្លែងខ្វះ ការហូបចុកមិនគ្រប់គ្រាន់ទេ ។ សាក្សីបានបន្តថា លោកជាអ្នករត់ឯកសារជូន អៀង សារី ឬនាំពី អៀង សារី ទៅឲ្យ ប៉ន់ និងពេលខ្លះលោកធ្វើការពិភាក្សាជាមួយ អៀង សារី ផ្ទាល់ទៀតផង ។ ពេលខ្លះសាក្សីក៏នាំយកសំបុត្រទៅឲ្យ សុន សេន នៅក្រសួងការពារជាតិដែរ និងនាំសំបុត្រទៅឲ្យ ខៀវ សំផន នៅមន្ទីរ៨៧, នៅមន្ទីរក-៣ និងនៅក-១ ដែរ ។

ទាក់ទងនឹងមន្ទីរ៨៧០ លោកបានបញ្ជាក់ថា ពីមុនមាន ប៉ន់ ជាអ្នកដឹកនាំ ប៉ុន្តែក្រោយពេល ប៉ន់ បាត់ខ្លួន ទើបជំនួសដោយ ឌឿន ។ ក្រោយមកនៅឆ្នាំ១៩៧៨ ខៀវ សំផន បានមកជំនួសតំណែង ឌឿន ហើយលោកដឹងអំពីការជំនួសនេះតាមរយៈ អៀង សារី ។ លោកតំណាងសហព្រះរាជអាជ្ញាបានបន្តសំណួរថា តើលោកធ្លាប់និយាយជាមួយ ខៀវ សំផន ផ្ទាល់ឬទេ អំពីការទទួលខុសត្រូវនៅមន្ទីរ៨៧០? ឆ្លើយតបនឹងបញ្ហានេះ លោកបានបញ្ជាក់ថា លោកធ្លាប់បាននិយាយជាមួយ ខៀវ សំផន ហើយមានពេលខ្លះមានការបញ្ជូនសារទៅភូមិភាគដែរ ។ លោកបានបន្តថា លោកធ្លាប់នាំសំបុត្រឆ្លើយឆ្លងគ្នារវាង អៀង សារី និង ខៀវ សំផនប៉ុន្តែលោកមិនបានដឹងពីខ្លឹមសារសំបុត្រនោះទេ ព្រោះលោកគ្រាន់តែយកសំបុត្រទៅប៉ុណ្ណោះ ដោយមិនបានពិភាក្សាពីបញ្ហាណាមួយនៅក្នុងសំបុត្រទេ ។ ក្នុងចំណោមសំបុត្រដែលនាំទៅមន្ទីរ៨៧០ គឺមានសំបុត្រខ្លះទាក់ទងនឹង អៀង សារី ឧទាហរណ៍ដូចជា ឯកសារពាក់ព័ន្ធនឹងរឿងទទួលភ្ញៀវ ។ ប៉ុន្តែសាក្សីបានបន្តថា ខ្លួនមិនដឹងពីរបៀបនៃការបញ្ជូនសារ ឬសំបុត្រពីភូមិភាគនីមួយៗមកភ្នំពេញដោយរបៀបណានោះទេ ។ ទាក់ទងនឹងមន្ទីរក-៧ លោកបានរៀបរាប់ថា មន្ទីរក-៧គឺជាសាខារបស់មន្ទីរ៨៧០ ដែលមានមុខងារទទួលការទំនាក់ទំនងពីគ្រប់ភូមិភាគនៅពេលភូមិភាគនីមួយៗទាក់ទងមកមន្ទីរ៨៧០ ។ លោកអះអាងថា លោកស្គាល់គណៈអចិន្ត្រៃយ៍តាមរយៈការស្តាប់វិទ្យុតែប៉ុណ្ណោះ ដូច្នេះលោកមិនបានស្គាល់បុគ្គលជាក់លាក់នោះទេ ។ បន្ទាប់មកលោកតំណាងសហព្រះរាជអាជ្ញាបានបន្ត ដោយអាននូវអត្ថបទសម្រង់ដែលសាក្សីបានផ្តល់ជូនសហចៅក្រមស៊ើបថា “បញ្ហានេះមកពី ប៉ុល ពត និង នួន ជា គឺមកពីមន្ទីរ៨៧០ ដែលបញ្ជូនព័ត៌មាន និងបញ្ហាទាំងនោះមកពីសមាជិកគណៈអចិន្ត្រៃយ៍ និងគណៈមជ្ឈិមដែលប្រចាំការនៅភ្នំពេញមានដូចជា ប៉ុល ពត, នួន ជា, វន វេត, អៀង សារី និង សុន សេន ។ ខៀវ សំផន នៅជិតគណៈនេះដែរ ប៉ុន្តែគាត់មិនមែនជាសមាជិកអចិន្ត្រៃយ៍ទេ” ។ សាក្សីក៏បានទទួលស្គាល់ចំពោះអត្ថបទសម្រង់នេះ ហើយលោកបានបន្ថែមថា លោកបានដឹងពីបញ្ហានេះតាមរយៈ អៀង សារី ។

នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យពេល អៀង សារី ធ្វើដំណើរទៅក្រៅប្រទេសម្តងៗ ក្រសួងការបរទេសស្ថិតក្រោមការគ្រប់គ្រងរបស់មន្ទីរ៨៧០ ដែលមាន ប៉ុល ពត ឬ នួន ជា ឬ ខៀវ សំផន ជាអ្នកមើលការខុសត្រូវលើកិច្ចការធំៗ ហើយកិច្ចការបន្ទាប់


អៀង សារី (ទី៤រាប់ពីស្តាំទៅឆ្វេង) ជួបជាមួយគណៈប្រតិភូបរ

បន្សំគឺគ្រប់គ្រងដោយ សូ ហុង ។ សាក្សីក៏បានទទួលស្គាល់ដែរចំពោះអត្ថបទសម្រង់ដែលនិយាយថា “នៅពេល អៀង សារី នៅក្រៅប្រទេស ហុង ជាអ្នកជំនួស ប៉ុន្តែ ហុង មិនអាចធ្វើសេចក្តីសម្រេចបានទេ ។ ពេលនៅក្រៅប្រទេស អៀង សារី បានទាក់ទងមកមន្ទីរ៨៧០ និងទាក់ទងជាមួយមន្ទីរប-១ ដែរ ។ ពាក់ព័ន្ធនឹងសេចក្តីសម្រេចដែលធ្វើឡើងនៅពេលដែល អៀង សារី នៅក្រៅប្រទេសនោះ គឺ

ត្រូវឲ្យខាងមន្ទីរប-១ ដែលមាន សូ ហុង ជាអ្នកទាក់ទងទៅ អៀង សារី តាមរយៈមន្ទីរ៨៧០" ។ សាក្សី រចឹម តុន បានធ្វើទស្សនកិច្ចទៅប្រទេសចិនជាមួយ អៀង សារី ម្តងនៅឆ្នាំ១៩៧៦ រយៈពេលជាងកន្លះខែ ។ គណៈប្រតិភូដែលទៅធ្វើទស្សនកិច្ចនៅពេលនោះមានដូចជា ប៉ុល ពត, អៀង សារី, ឌឿន, រស់ ញឹម និងរូបលោក ។ ការបំពេញការងារក្នុងក្រសួងការបរទេសនោះជាទូទៅ គឺពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ រយៈពេលពី១៥នាទីទៅកន្លះម៉ោង ។ សាក្សីបានបញ្ជាក់ថា ថ្ងៃណាដែលខ្លួននាំភ្ញៀវទៅតាមខេត្ត លោកតែងតែរាយការណ៍ជូន អៀង សារី នៅពេលត្រលប់មកវិញនៅបន្ទប់សំណាក់របស់ អៀង សារី ផ្ទាល់ ។ ក្រៅពីរបាយការណ៍ជាប្រចាំធ្វើឡើងដោយផ្ទាល់មាត់ និងជាលាយ



...ណៈប្រតិភូបរទេស (រូបភាពមជ្ឈមណ្ឌលឯកសារកម្ពុជា)

លក្ខណ៍អក្សរ ។ ចំពោះការរៀនសូត្រនៅក្រសួងការបរទេសវិញ មានដូចជា ការប្រជុំរៀនសូត្រប្រជុំដកពិសោធជារៀងរាល់ខែ ដែលមាន អៀង សារី ជាអធិបតី ហើយពេលខ្លះមាន សូ ហុង ។ ការប្រជុំទិតៀន និងស្វ័យទិតៀនធ្វើក្នុងរយៈពេលបីខែម្តង ។ ការប្រជុំនោះ គឺប្រមូលបញ្ញាជនឲ្យមកជួយធ្វើការនៅក្រសួងការបទេស ។ សាក្សីក៏បានបញ្ជាក់ទៀតថា កាលនោះពាក្យ "បញ្ញវន្ត" មិនត្រូវបានគេប្រើប្រាស់ទេ ។

លោកបានបន្តថា បក្សបានណែនាំ និងហាមឃាត់បុគ្គលនៅក្នុងក្រសួងមិនឲ្យរើសអើងបញ្ញាជនទាំងនោះឡើយ ហើយម្យ៉ាងទៀតបញ្ញាជនខ្លះមានបទពិសោធខាងការទូតទៀតផង ។ ពេលប្រជុំម្តងៗ គឺមាន សូ ហុង ជាអ្នកធ្វើកំណត់ហេតុ ។ សាក្សីបានបន្តថា លោកបានចូលរួមមតិនៅក្នុងពេលបិទវគ្គចុងក្រោយ គឺនៅខែធ្នូ ឆ្នាំ១៩៧៦ដែរ ។ លោកបានចូលរួមរៀនសូត្រ ប្រជុំស្វ័យទិតៀន និងធ្វើជីវទស្សនបដិវត្តដែលមាន អៀង សារី ជាអ្នកផ្តល់យោបល់ ។ នៅក្នុងកំណត់ហេតុសន្និបាតបក្សថ្ងៃទី១៨ ខែមករា ឆ្នាំ១៩៧៧ មានបញ្ជីចាត់តាំងបុគ្គលិកនៅក្រសួងការបរទេសដូចជា វ៉ាន់ ជាលេខា, ហុង ជាអនុលេខា, រឿន ជាសមាជិក, វ៉ែន ជាសមាជិក និង ជៀម (សាក្សី) ជាសមាជិក ។ នៅក្នុងក្រសួង នេះមានគណៈសាខាក្រសួងសម្រាប់គ្រប់គ្រងផ្ទៃក្នុងបក្ស ។ កិច្ចប្រជុំនោះមានអ្នកចូលរួមមានប្រហែល៣០នាក់មកពីក្រសួង និងធ្វើឡើងក្នុងរយៈពេល២ទៅ៣ថ្ងៃ ដែលមានអ្នកធ្វើបទឧទ្ទេសនាមគឺ អៀង សារី និង សូ ហុង ។ នៅក្នុងសន្និបាតនេះបានឧទ្ទេសនាមពីសភាពការណ៍ខ្មាំងដោយ អៀង សារី ។ លោកព្រះរាជអាជ្ញាបានលើកឡើងទាក់ទងនឹងទំនាស់ផ្ទៃក្នុងបក្ស និងទំនាស់បដិបក្ខ ។ សាក្សីបានឆ្លើយថាចំណុចនេះ អៀង សារី បានវែកញែកយ៉ាងច្បាស់ថា បើមានទំនាស់បដិបក្ខហើយ គឺមិនអាចនៅជាមួយគ្នាបានទេត្រូវមានវិធានការនាំទៅអប់រំ ឲ្យទៅវាយថ្មជាដើម ព្រោះបើទុកនៅ គឺនាំឲ្យបដិវត្តដួលរលំ ។ សាក្សីបានបន្ថែមទៀតថា អៀង សារី បានធ្វើបទឧទ្ទេសនាមពីផែនការសាខាក្រសួងការបរទេសនៅឆ្នាំ១៩៧៧ ដែរថា សាខាត្រូវយកចិត្តទុកដាក់ និងមានការប្រុងប្រយ័ត្នខ្ពស់ចំពោះបដិវត្ត និងមានម្ចាស់ការជាមុនលើខ្មាំងសត្រូវទាំងក្នុង និងក្រៅ ប៉ុន្តែក្នុងបទឧទ្ទេសនាមនោះមិនមានចែកឯកសារដល់អ្នកចូលរួមទេ ។

ចំពោះមាគ៌ាថ្នាក់ដឹកនាំ ដែលនិយាយពីការណែនាំដោយ អៀង សារី នៅឆ្នាំ១៩៧៧ សាក្សីបានបញ្ជាក់ថា ចំណុចផ្ទៃក្នុងមិនអាចដឹងជាទូទៅទេ គឺដឹងតែក្នុងក្របខ័ណ្ឌចង្អៀតនៃថ្នាក់ដឹកនាំសំខាន់ៗនៅក្នុងក្រសួងការបរទេសប៉ុណ្ណោះ ។ មាគ៌ាថ្នាក់ដឹកនាំ ដែលនិយាយពីការណែនាំដោយ អៀង សារី ។ ការសម្រេចផ្ទៃក្នុងលើបញ្ហាទូទៅដែលត្រូវរក្សាការសម្ងាត់មិនឲ្យកម្មាភិបាលផ្សេងនៅក្នុងក្រសួងដឹងនោះមានដូចជា ៖

១- ផ្នែកឃោសនាអប់រំ

២- ផ្នែកមន្ទីរ

៣- ផ្នែកបង្កើនផល

៤- ផ្នែកនយោបាយ ទទួលខុសត្រូវដោយ អៀង សារី និងបន្ទាប់មកគឺ សូ ហុង

៥- ផ្នែកពិធីការ

៦- ផ្នែកលេខាដ្ឋានរដ្ឋការ ទទួលខុសត្រូវដោយ ដួន ប្រសិទ្ធ

៧- ផ្នែកអាកាសចរណ៍ស៊ីវិលផ្នែកសម្ងាត់ ។ ផ្នែកសម្ងាត់នៅក្រសួងការបរទេសចំពោះភ្ញៀវមានពីរប្រភេទ គឺភ្ញៀវចំហរ និងភ្ញៀវសម្ងាត់ ។

ចំពោះការបោសសម្អាតខ្សាំងវិញ គឺមានការឯកភាពគ្នាថា ខ្មាំងនៅមិនទាន់អស់ពីក្រសួងនៅឡើយ ដូច្នេះ អៀង សារី ឈរលើមូលដ្ឋានដែលរាយការណ៍នេះបានសរុបថា ត្រូវបន្តបោសសម្អាតខ្មាំងឲ្យអស់ ហើយមនុស្សខ្លះនៅក្រសួងនេះក៏មានជាប់ពាក់ព័ន្ធខាងទស្សនៈខាងគោលជំហរខាងសតិអារម្មណ៍ ។ សាក្សីបានលើកឡើងថា ទាក់ទងនឹងជនក្បត់របស់បក្សដែលមានសេ.អ៊ី.អា, កា.ហ្សេ.បេ និងយួននោះខ្លួនបានអានឯកសារនេះ ដែលនិយាយពីការកម្ទេចជនទាំងនោះដែរ គឺមានឯកសារនោះមែន ។ អ្នកខុទ្ទេសនាមនៅក្នុងសន្និបាតអំពីឯកសានោះ គឺមាន អៀង សារី ហើយ សូ ហុង គឺជាអ្នកសរុប ។ ខណៈដែលការសួរដេញដោលកំពុងតែប្រព្រឹត្តទៅនៅក្នុងបន្ទប់សវនាការដែលមានអ្នកចូលរួមច្រើនរយនាក់លោកមេធាវី សុន អារុណ បានស្នើសុំអង្គជំនុំជម្រះដើម្បីអនុញ្ញាតឲ្យកូនក្តីរបស់ខ្លួន នួន ជា ទៅសម្រាកនៅបន្ទប់ខាងក្រោមដោយសំអាងហេតុផលថា នួន ជា មានអាការឈឺក្បាលខ្លាំងមិនអាចតាមដានសវនាការដោយផ្ទាល់បាន និងសូមឲ្យវេជ្ជបណ្ឌិតធ្វើការពិនិត្យផងដែរ ។ ភ្លាមនោះ លោកប្រធានបានអនុញ្ញាតតាមសំណើ និងបានណែនាំទៅមេធាវីវិញថា ភាគីនៃរឿងក្តីមិនគប្បីកាត់ផ្តាច់ការសួរសំនួររបស់ភាគីម្ខាងទៀតបែបនេះទេ យ៉ាងហោចណាស់ក៏ទុកឲ្យបញ្ចប់សំណួរមួយឲ្យចប់សិន ។

ជាកិច្ចបន្តនីតិវិធី លោកតំណាងសហព្រះរាជអាជ្ញាបានសួរទាក់ទងនឹងការចាប់ខ្លួនបុគ្គលណាម្នាក់នៅក្នុងក្រសួងការបរទេស ។ សាក្សីបានឆ្លើយថា មានការចាប់ខ្លួនកម្មាភិបាលនៅអំឡុងឆ្នាំ១៩៧៧ដល់ឆ្នាំ១៩៧៨រួចបញ្ជូនទៅឲ្យធ្វើការបង្ករបង្កើនផលនៅតាខ្មៅ ដែលជាកន្លែងបង្ករបង្កើនផលរបស់ក្រសួងនេះ ។ ប៉ុន្តែកម្មាភិបាលនៅក្រសួងការបរទេសមិនត្រូវបានចាត់ចែងឲ្យទៅធ្វើការនៅការដ្ឋានយន្តហោះនៅកំពង់ឆ្នាំងនោះទេ ។ កំហុសដែលគេត្រូវបញ្ជូនទៅតាខ្មៅនោះមិនមែនជាកំហុសធំដុំឡើយ គឺកំហុសមិនសកម្មក្នុងការបំពេញការងារ និងធ្វើការងារមិនបានល្អជាដើម ។ លោក ឌេល លីសាក់ បានសួរសាក្សីទៀតថា តើ អៀង សារី បានទទួលមកពីមន្ទីរ៨៧០នូវចម្លើយសារភាពរបស់ស-២១ ដែលមានឈ្មោះកម្មាភិបាលក្នុងក្រសួង ហើយអ្នកទោសនៅស-២១នោះឆ្លើយដាក់ដែរឬទេ? ទាក់ទងនឹងករណីនេះ សាក្សីបានឆ្លើយតបវិញថា មន្ទីរ៨៧០ពិតជាបានទទួលចម្លើយទាំងនោះពិតមែន ។ ទាក់ទងនឹងមន្ទីរនៅបឹងត្របែកវិញ សាក្សីបានបញ្ជាក់ថា ខ្លួនបានទៅមន្ទីរនោះញឹកញាប់បន្ទាប់ពីមន្ទីរនោះត្រូបានផ្ទេរមកក្រសួងការបទេសដោយសារបញ្ហាជីវភាព គឺតម្រូវឲ្យលោកពិនិត្យមើលស្រូវអង្ករជាដើម ។ សាក្សីបានទៅជាមួយ អៀង សារី និង សូ ហុង ប្រហែល៣ដង និងឃើញមនុស្សនៅក្នុងមន្ទីរបឹងត្របែកជាច្រើន ។ អៀង សារី បានទៅបង្រៀននៅមន្ទីរបឹងត្របែកស្តីអំពីសភាពការណ៍លើពិភពលោក និងសភាពការណ៍ក្នុងប្រទេសបំភ្លឺពីការធ្វើបដិវត្តការធ្វើការទិតៀន និងស្វ័យទិតៀនជាដើម ។

## ២) ការសួរសាក្សីដោយមេធាវីដើមបណ្តឹងរដ្ឋប្បវេណី

បន្ទាប់ពីបញ្ចប់ការសាកសួរដោយតំណាងសហព្រះរាជអាជ្ញាមក លោកមេធាវី ឡោ ជុនធី បានសួរទាក់ទងនឹងការចូលបដិវត្តន៍របស់សាក្សី ។ សាក្សីបានចូលបដិវត្តន៍នៅឆ្នាំ១៩៦៣ ហើយបានចាកចេញពីផ្ទះដើម្បីចូលរួមតស៊ូនៅឆ្នាំ១៩៦៨ កាលនោះមានអាយុប្រហែល១៦ឆ្នាំ ។ សាក្សីបានបន្តថា នៅឆ្នាំ១៩៦៣ដល់ឆ្នាំ១៩៦៧ នៅក្នុងការសម្រេចគោលដៅបដិវត្តន៍បក្សបានណែនាំលោកក៏ដូចជាអ្នកចូលបដិវត្តន៍ផ្សេងទៀតឲ្យស្គាល់ពីការធ្វើបដិវត្តដែលយកគំរូតាម ម៉ាក្សលេនីន និង ស្តាលីន ជាដើមថា នៅពេលខាងមុខកម្ពុជានឹងជួបប្រទះការធ្វើបដិវត្តន៍ ហើយបក្សក៏បានអប់រំពីការជិះជាន់នៅក្នុងសង្គម និងការទម្លាក់គ្រាប់បែកជាច្រើនសន្ធឹកសន្ធាប់នៅពេលនោះ ដែលធ្វើឲ្យលោកមានចិត្តចង់ធ្វើបដិវត្តកាន់តែខ្លាំងឡើងនិងមានការប្តេជ្ញាខ្ពស់ ។ លោកបានបញ្ជាក់ថា ការចូលរួមបដិវត្តន៍នោះ គឺធ្វើទៅតាមគំរូរបស់ពូ និងឪពុករបស់លោក ។

ពាក់ព័ន្ធនឹងទំនាក់ទំនងមេដឹកនាំនៃរបបខ្មែរក្រហម សាក្សី រចឹម គុន បានជម្រាបជូនអង្គជំនុំជម្រះថា នៅចន្លោះឆ្នាំ១៩៧១ដល់ ១៩៧៤ ប៉ុល ពត និង ខៀវ សំផន ជួបគ្នាញឹកញាប់ ដោយអ្នកទាំងពីរ នៅមន្ទីរដាច់ពីគ្នាក្នុងរយៈពេលខ្លី ហើយក្រោយមកស្នាក់នៅជាមួយគ្នា ដែលពេលខ្លះ គឺ ប៉ុល ពត, នួន ជា និង ខៀវ សំផន ស្នាក់នៅជាមួយគ្នាទាំងបីនាក់ធ្វើការជាមួយគ្នា និងពេលខ្លះក៏ធ្វើការនៅផ្ទះរៀងខ្លួន ។ ចំណែក ខៀវ សំផន ធ្លាប់បានធ្វើការអំពាវនាវដោយចំហតាមវិទ្យុដល់ទាហាន លន់ នល់ និងប្រជាជនកុំឲ្យមានការបង្ហូរឈាមគ្នាឯង ដែលកាលនោះ ខៀវ សំផន គឺជាអគ្គមេបញ្ជាការ ។


មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ឡោ ជុនធី

លោកមេធាវី ជុនធី បានបន្តសំណួរទាក់ទងនឹងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ។ សាក្សីបានបញ្ជាក់ថា បទពិសោធដែលជម្លៀសនៅខត្តុង្គ គឺជាបទពិសោធមួយក្នុងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញទៅតាមសហករណ៍ ឬតាមមូលដ្ឋានតំបន់ ។ សាក្សីបានបន្តទៀតថា បើយើងជម្លៀសប្រជាជនចេញអស់គឺមានភាពងាយស្រួលក្នុងការគ្រប់គ្រង បើទោះជាមានខ្មាំងបង្កប់ក៏មិនមានអ្វីពិបាកនោះទេ ។ ការកសាងសហករណ៍ជឿនលឿនធ្វើក្រោយពេលរំដោះ និងធ្វើនៅស្ទើរគ្រប់មូលដ្ឋាន ដោយផ្អែកលើការធ្វើបដិវត្តប្រជាជាតិប្រជាធិបតេយ្យ ការធ្វើបដិវត្តសង្គមនិយម ដើម្បីឈានទៅរកកុម្មុយនីស្តនិយម គឺយកសហករណ៍ ដែលមានការហូបចុករួមគ្នានេះសម្រាប់ពង្រឹងគោលដៅ ។ គោលនយោបាយហូបរួមកើតមានតាំងពីឆ្នាំ១៩៧៣ គឺមុនរំដោះភ្នំពេញ ដែលឃើញមាននៅតំបន់រំដោះខ្លះ លុះពេលរំដោះភ្នំពេញរួច ទើបកើតមានសហករណ៍ជឿនលឿននេះ ។ សាក្សីបានរំឭកថា ក្រោយរំដោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ លោកបានដឹងក្នុងក្របខ័ណ្ឌចង្អៀតថា មានការត្រៀមឲ្យចាយលុយដែលលុយទាំងអស់បានតម្កល់ទុកនៅជិតវត្តភ្នំ ប៉ុន្តែក្រោយពេលរំដោះមិនមានការចាយលុយនោះឡើយ ហើយខ្លួនលោកផ្ទាល់ក៏មិនដឹងពីមូលហេតុយ៉ាងណានោះដែរ ។ លោកមេធាវីបានសួរសាក្សីពីផែនការជម្លៀសថា តើបក្សមានការគិតគូដល់ចំណុចគ្រោះថ្នាក់របស់ប្រជាជននៅពេលជម្លៀសឬទេ? សាក្សីបានរៀបរាប់ថា លោកមិនបានឮការនិយាយពីការលំបាកនៅក្នុងអង្គប្រជុំនោះនិយាយពីផលវិបាកនៅពេលជម្លៀសនោះទេ ហើយនៅពេលជម្លៀសនោះ សាក្សីបានឃើញប្រជាជនធ្វើដំណើរព្រោងព្រាត និងបានឃើញប្រជាជនខ្លះរែកលុយជាច្រើនឃើញ ដូច្នេះលោកបានប្រាប់ទៅអ្នករែកលុយនោះថា នៅតំបន់រំដោះមិនមានចាយលុយនោះទេ ។ ឮដូច្នេះ អ្នករែកលុយនោះទ្រហោយំភ្លាម ។ សាក្សីបានបន្ថែមទៀតថា លោកបានឃើញប្រជាជនខ្លះហូបបបរលាយជាមួយត្រកួនដូចជានៅភូមិភាគពាយ័ព្យនៅពេលនោះលោកបានធ្វើការជំទាស់ភ្លាមថា ការធ្វើបដិវត្តន៍ គឺដើម្បីភាពស្មើគ្នាបើកឲ្យប្រជាជន ហូបមិនស្មើគ្នាបែបនេះគឺមិនកើតទេ ។ ការរាយការណ៍ជាទូទៅ ពេលត្រលប់មកពីខេត្តវិញ លោក រចឹម គុន បានរាយការណ៍ជូន អៀង សារី ចំណែក ប៉ុល ពត វិញ លោកបានរាយការណ៍តែពេលណាដែល ប៉ុល ពត សួរប៉ុណ្ណោះ ។ ចំពោះបញ្ហាប្រជាជនហូបបបរនេះ ពេលត្រលប់មកវិញលោកបានរាយការណ៍ជូន ប៉ុល ពត តែ ប៉ុល ពត ថាចាំធ្វើស៊ុយទិគៀន ចំណែក អៀង សារី វិញថា ខិតខំធ្វើតែការងាររបស់ខ្លួនឲ្យបានល្អទៅ ។ ការកសាងសហករណ៍ជឿនលឿន គឺក្រោយពេលរំដោះសហករណ៍ គឺយើងធ្វើបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យគឺធ្វើបដិវត្តន៍សង្គមនិយមមានការហូបចុក ការស្លៀកពាក់ ការរស់នៅស្មើគ្នាទាំងអស់ ។ គោលនយោបាយហូបរួមកើតតាំងពីរដ្ឋប្រហារនៅឆ្នាំ១៩៧៣ រហូតដល់ពេលរំដោះភ្នំពេញ ទើបកើតមានជាសហករណ៍ជឿនលឿន ។

ចំពោះការចាយប្រាក់វិញ សាក្សីបានបំភ្លឺថា ក្រោយពីរំដោះនៅឆ្នាំ១៩៧៥ បក្សមានគម្រោងចាយប្រាក់ ហើយក្រដាសប្រាក់ទាំងនោះបានរៀបចំទុកតាំងពីចុងឆ្នាំ១៩៧៤នៅឃ្លាំងមួយជិតវត្តភ្នំ ។ នៅក្នុងរយៈពេលបីឆ្នាំនៃរបបនេះមិនបានចាយប្រាក់ទេ ព្រោះមិនទាន់ដល់ពេល ហើយផ្សារក៏មិនទាន់បើកនៅឡើយ ។ មូលហេតុដែលមិនចាយលុយ គឺមិនដឹងទេគ្រាន់តែដឹងថាទីផ្សារមានហើយ តែមិនទាន់ចាយលុយ ។


សហមេធាវីនាំមុខអន្តរជាតិ អេលីហ្សាប៊ែត ស៊ីម៉ូណូហ្វុត

លោកស្រីមេធាវី អេលីហ្សាប៊ែត ស៊ីម៉ុណូហ្វុត បានបន្តសំណួរពីសហភាគរបស់លោកស្រី ដោយចោទសួរសាក្សីអំពីហេតុការណ៍លំបាកនៅពេលប្រជាជនធ្វើដំណើរចេញពីទីក្រុងភ្នំពេញ ។ សាក្សីបានលើកឡើងថា ប្រជាជនដែលត្រូវជម្លៀសហ្នឹងមានការលំបាកដោយសារអ្នកទាំងនោះធ្លាប់តែជិះឡាន ជិះម៉ូតូ មានកង្ហារម៉ាស៊ីនត្រជាក់ការហូបចុកគ្រប់គ្រាន់ ។ សាក្សីបានបញ្ជាក់អំពីកម្លាំងបង្កប់នៅក្នុងផ្ទះថា កម្លាំងធំគឺចាញ់ហើយ ដូច្នេះកម្លាំងបង្កប់ក្រោយៗនៅតាមផ្ទះត្រៀមគ្រាប់បែក ត្រៀមកាំភ្លើង ត្រៀមអាវុធសព្វគ្រប់ ។ សាក្សីបានបន្តថា បើទុកកម្លាំងនេះ វានឹងងើបឡើងនាំឲ្យមានបញ្ហាវឹកវរ ។ បើធ្វើបដិវត្តន៍ គឺត្រូវម្ចាស់ការលើសភាពការណ៍ជាមុនកុំដើរតាមកន្ទុយសភាពការណ៍ព្រោះនាំឲ្យបរាជ័យ ។ លោកបានរៀបរាប់ថា ជារូបភាព គឺខាង លន់ នល់ ចាញ់មែន ប៉ុន្តែខ្លឹមសារ គឺមិនចាញ់ទេ ដូច្នេះត្រូវតែមានការប្រុងប្រយ័ត្ន ។ លោកបានបន្តទៀតថា បើមិនមានការបោសសម្អាតខ្មាំងទេ នោះបដិវត្តន៍មិនអាចឈរជើងបានជាងបីឆ្នាំនោះឡើយ ។ លោកមានការព្រួយបារម្ភនៅពេលដែលបក្សតម្រូវឲ្យធ្វើប្រវត្តិរូបម្តងទៀតនៅឆ្នាំ១៩៨៧ ប៉ុន្តែ ពេលនោះ សូម្បី តែ អៀង សារី និង សូ ហុង ក៏ត្រូវធ្វើប្រវត្តិរូបសារជាថ្មីដែរ ។ លោកបានគិតថា លោកលះបង់ ដើម្បីបដិវត្តន៍អ្នកស្នេហាជាតិ ប្រជាជនបដិវត្ត ដូច្នេះបើទោះជាមានរឿងអ្វីកើតឡើងចំពោះ លោកក៏លោកមិនស្តាយដែរ ហើយនៅពេលនោះមានការបាត់ខ្លួនជាបន្តបន្ទាប់ដូចជា សោ ភឹម, កុយ ធួន, វន វ៉េត, ចេង អន, ប៉ង់, ឡឿន, ហ៊ូយន់និង ហ៊ូ នឹម ជាដើម ។ សាក្សីបានឆ្លើយតបនឹងសំណួរបន្ទាប់ថា ខ្លួនធ្លាប់គ្រប់គ្រងនៅមន្ទីរបឹងត្របែកមួយរយៈពេលខ្លី ហើយពលដែលនោះលោកសង្កេតឃើញថា មិនមានការបាត់ខ្លួនកម្មាភិបាលនៅមន្ទីរនេះទេ ។ លោកបានបន្តទៀតថា នៅពេលបក្សកុម្មុយនីស្តកម្ពុជាដួលរលំនៅថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ លោកមិនដឹងថា កម្មាភិបាលនៅមន្ទីរនេះគេចខ្លួនទៅទីណាខ្លះទេ តែលោកចាំបានថា លោកបានជួបលោក ហោ ណាំហុង ដែលពេលនោះកំពុងរត់គេចខ្លួនជាមួយប្រជាជនទៅប្រទេសបារាំង ។

### ៣) ការសួរសាក្សីដោយចៅក្រម ហ្សង់ម៉ាក ឡាវ៉ឺញ

បន្ទាប់ពីបញ្ចប់សំណួរដោយក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី លោកចៅក្រម ហ្សង់ម៉ាក ឡាវ៉ឺញ បានលើកយកសំណួរមួយចំនួនទៅកាន់សាក្សី ដោយចាប់ផ្តើមពីទំនាក់ទំនាក់ទំនងរវាងសាក្សីនិងជនជាប់ចោទ ខៀវ សំផន នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ សាក្សីបានជួប ខៀវ សំផន ដំបូងនៅឆ្នាំ១៩៧១ ពេលនោះអ្នកទាំងពីរគ្រាន់តែសួរសុខទុក្ខគ្នាប៉ុណ្ណោះ ។ នៅពេលនោះ លោកមិនដឹងថា ខៀវ សំផន ជាសមាជិករបស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា(ហ្រ្គុង) នោះទេ ព្រោះកន្លងមកលោកស្គាល់ ខៀវ សំផន តាមរយៈវិទ្យុតែប៉ុណ្ណោះ ។ នៅអំឡុងចុងឆ្នាំ១៩៦៨ដល់ឆ្នាំ១៩៧០ទាក់ទងនឹងប្រមុខមេបញ្ជាការកងទ័ពរំដោះជាតិកម្ពុជា ឬកងទ័ពបដិវត្តនោះ សាក្សី បានបញ្ជាក់ថា ជារូបភាពជាក់ស្តែងកាល គឺ អៀង សារី មកធ្វើការនៅមន្ទីរ ក-៧ ហើយពេលនោះមិនទាន់ហៅថា កងទ័ពនៅឡើយទេ អៀង សារី ហៅកងនោះថាកងចល័តនៅខេត្តរតនគិរី ។

សាក្សីបានបញ្ជាក់ជូនលោកចៅក្រមអន្តរជាតិថា លោកបានដឹងពុំពីការប្រជុំទាំងឡាយដោយខ្លួនឯងដោយមិនមានអ្នកណានិយាយប្រាប់លោកទេ ។ នៅក្នុងពេលប្រជុំជាច្រើនដងនោះ លោកបានឃើញមេដឹកនាំទាំងនោះសហការគ្នាយ៉ាងខ្លាំងមិនដែលមានទំនាស់ ឬការខ្វែងយោបល់គ្នាឡើយ ។ សាក្សីបានជម្រាបជូនអង្គជំនុំជម្រះទៀតថា ក្រោយពីរំដោះទីក្រុងភ្នំពេញខ្លួនបានឮការផ្សព្វផ្សាយតាមវិទ្យុប្រជាជនកម្ពុជា និងអន្តរជាតិ ថាគ្រប់មុខព្រួញទាំងអស់គឺនៅម៉ោងប្រាំបួនកន្លះព្រឹកបានរំដោះទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ មានការជួបជុំគ្នានៅកណ្តាលទីក្រុងភ្នំពេញ ។ លោកចៅក្រមបានសួរលម្អិតអំពីរការប្រជុំ ដែលផ្តើមដោយបទបង្ហាញអំពីបទពិសោធន៍របស់មេដឹកនាំម្នាក់ៗទាក់ទងនឹងការ



ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែរីញ

ជម្លៀសចេញពីទីក្រុង ។ ការប្រជុំនោះគឺមានការពិភាក្សាគ្នានៅលើក្តារខៀនពណ៌ខ្មៅ និងបានគូសគំនូសបំព្រួញ និយាយពីការជម្លៀសប្រជាជន ។ តាមគោលការណ៍ គឺមានការកំណត់មុខសញ្ញាតាមភូមិភាគ និងកងពលលម្អិតតាមគោលដៅនីមួយៗ ។ ក្រោយរដ្ឋប្រហារ លោកបានទៅធ្វើស្រែនៅមន្ទីរមួយ ដែលកាលនោះកងទ័ពត្រូវបានគេហៅថាកងចល័ត ហើយកងចល័តទាំងនោះប្រហែល១៥០នាក់បានមកជួយធ្វើស្រែប្រជាជន ។ សាក្សីបានបន្តថា នៅតាមផ្លូវចន្លោះអណ្តូងមាស និងគីឡូលេខ៩មានខ្មាំងវាតត្បាត ដូច្នេះកងចល័តទាំងនោះបានមកជួយការពារមន្ទីរស៧១ ដែលនៅឆ្នាំ១៩៧៣ មន្ទីរស-៧១គឺជាមន្ទីរមូលដ្ឋាន ។ មធ្យោបាយទាក់ទងគ្នារបស់មេដឹកនាំខ្មែរក្រហមទោះនៅក្នុងប្រទេស ឬក្រៅប្រទេស គឺតាមរយៈទូរលេខ ១៥វ៉ាត់ និង២វ៉ាត់ ដែលមានតាំងពីឆ្នាំ១៩៧៣មកម្ល៉េះ ។ ដំណើររបស់សម្តេចនរោត្តម សីហនុ នៅឆ្នាំ១៩៧៣ពេលសម្តេចមកទស្សនកិច្ចតំបន់រំដោះលោកបានទៅការពារផ្ទាល់ចាប់ពីពេលយានមករហូតដល់ពេលយានត្រលប់ទៅវិញ ។ សមាជជាតិពិសេសមួយនៅខែកុម្ភៈ ឆ្នាំ១៩៧៥ដែលមាន ខៀវ សំផន ជាអធិបតី ។ សាក្សីបានជម្រាបជូនអង្គជំនុំជម្រះអំពីការផ្សារផ្សាយវិទ្យុរបស់ ខៀវ សំផន ដែលផ្សាយជូនជនរួមជាតិ និងអន្តរជាតិដូចជាការផ្សាយនៅពេលរំដោះទីក្រុងភ្នំពេញ និងពេលធ្វើសមាជជាតិនៅថ្ងៃទី២៣ ដល់ទី២៥ ខែកុម្ភៈ ឆ្នាំ១៩៧៥ ។

សាក្សី រចឹម តុន បានជម្រាបជូនអង្គជំនុំជម្រះទៀតថា មន្ទីរប្រាំងចំរេះ ដំបូងស្ថិតនៅក្រោមការគ្រប់គ្រងរបស់ កុយ ធួន ប៉ុន្តែក្រោយមកត្រូវបានប្រគល់ជូនមន្ទីរប-១ ដែលមានសាក្សីផ្ទាល់ជាអ្នកមើលខុសត្រូវរួមនៅក្នុងមន្ទីរនេះ ។ ក្រោយពេលប្រគល់ជូនមន្ទីរប-១អ្នកនៅប្រចាំការជាអចិន្ត្រៃយ៍នៅមន្ទីរប្រាំងចំរេះគឺឈ្មោះ សឹម ។ សាក្សីបានបន្តថា មន្ទីរនេះមិនមែនសម្រាប់តែអប់រំកែប្រែប៉ុណ្ណោះទេ ប៉ុន្តែជាកន្លែងសម្រាប់ចិញ្ចឹមត្រី មាន់ ទា និងធ្វើស្រែ ។ ជារៀងរាល់ចុងសប្តាហ៍ បុគ្គលិកមកពីមន្ទីរប-១ រួមទាំង អៀង សារី និង សូ ហុង បានមកលេងនៅមន្ទីរនេះ ។

## ៤) ការសួរសាក្សីដោយមេធាវីការពារក្តីទាំងបីក្រុម

### ៤.១) ក្រុមមេធាវីការពារក្តី នួន ជា

បន្ទាប់មកអង្គជំនុំជម្រះផ្តល់វេទិកាជូនក្រុមមេធាវីការពារក្តីជនជាប់ចោទ នួន ជា ក្នុងការសួរដេញដោលសាក្សី រចឹម តុន បន្តទៀត ។ លោកមេធាវី សុន អរុណ បានចាប់ផ្តើមតាំងសំណួរទាក់ទងនឹងទង់បដិវត្ត ។ ឆ្លើយតបទៅនឹងសំណួររបស់លោកមេធាវី សាក្សីបានបញ្ជាក់ថា នៅអំឡុងឆ្នាំ១៩៧៧ លោកបានអានសៀវភៅទស្សនាវដ្តីទង់បដិវត្ត និងទង់យុវជន ដែលមានពណ៌ក្រហម ហើយសរសេរដោយដៃ ។ សាក្សីបានបញ្ជាក់ទៀតថា សៀវភៅនេះ

ចេញរៀនរាល់ខែ និងចែកជូនគ្រប់ក្រសួងទៀតផង ដែលឯកសារទាំងនោះពិភាក្សាអំពីចលនាជាក់ស្តែងក្នុងប្រទេស ការកសាងបក្ស និងការធ្វើទស្សនកិច្ចរបស់គណៈប្រតិភូ ។



មេធាវីការពារក្តី សុន អរុណ

លោកមេធាវី សុន អរុណ បានសួរទាក់ទងនឹងការទម្លាក់គ្រាប់បែកដោយសហរដ្ឋអាមេរិកមកលើកម្ពុជាក្នុងអំឡុងទសវត្សឆ្នាំ៧០ ។ សាក្សីបានបញ្ជាក់ថា ការទម្លាក់នោះធ្វើឡើងជាប់ជាបន្តបន្ទាប់ ដែលធ្វើឲ្យមានការខូចខាតយ៉ាងខ្លាំងដល់អាយុជីវិត ទ្រព្យសម្បត្តិ សត្វពាហនៈ ហេដ្ឋារចនាសម្ព័ន្ធ វត្តអារាម ប៉ះពាល់ដល់ជីវភាពប្រចាំថ្ងៃរបស់ប្រជាជនកម្ពុជានាសម័យនោះ ហើយបានបង្ខំឲ្យប្រជាជនរត់គេចខ្លួនទៅក្នុងព្រៃ ។ ចំពោះមូលហេតុនៃការទម្លាក់គ្រាប់បែកវិញ សាក្សី រចឹម តុន បានបញ្ជាក់ថា តាមអ្វីដែលខ្លួនបានដឹង គឺដោយសារការដេញតាមពួកយៀកកុង ហើយពេលនោះប្រជាជនវៀតណាមភាគច្រើនបានចូលមកទឹកដីខ្មែរ ទើបមានការទម្លាក់គ្រាប់បែក ។ សាក្សីបានរំឭកឡើងវិញពីការចូលបដិវត្តនៅឆ្នាំ១៩៦៣ថា នៅពេលលោកចូលបដិវត្តភ្លាម លោកមិនទាន់បានកាន់អាវុធទេ រហូតដល់ចុងឆ្នាំ១៩៦៧ ទើបលោកមានកាំភ្លើងកាន់ ដែលកាំភ្លើងទាំងនោះ គឺបានមកពីការដោះដូរម្ហូបអាហារជាមួយទាហានវៀតណាម ។ លោកមេធាវីបានបន្តសំណួរទាក់ទងនឹងតួនាទីរបស់ សុន សេន នៅខេត្តរតនគិរី ហើយសាក្សីបានអះអាងថាកាលនោះនៅខេត្តរតនគិរីមានការផលិតកាំភ្លើងដោយដៃ ដែលហៅថាកាំភ្លើងកាត់ ហើយនៅភូមិភាគនោះ គឺស្ថិតក្រោមការដឹកនាំរបស់ វ៉ន វ៉េត ចំណែក សុន សេន កាន់កាប់ខាងទ័ព ។

នៅក្នុងការសួរជាកងការពារ ប៉ុល ពត សាក្សីមិនមែនការពារតែ ប៉ុល ពត ម្នាក់នោះទេនៅឆ្នាំ១៩៧២ លោកក៏ធ្លាប់បានការពារ នួន ជា ទៅធ្វើការនៅភូមិភាគបស្ចិម ភូមិភាគនិរតី និងភូមិភាគពាយ័ព្យក្នុងស្រុកសំឡូតទៀតផង ។ សាក្សីបានបន្ថែមថា លោកហៅ ប៉ុល ពត និង នួន ជា ថាបងទី១ និង ទី២ គឺដោយសារលោកបានឮ ប៉ង់ ហៅដូច្នេះលោកក៏ហៅតាម ចាប់ពីឆ្នាំ១៩៧៤ បន្ទាប់ពីរំដោះបានទីប្រជុំជននៅឧត្តុង ។ សាក្សីបានលើកឡើងបន្តទាក់ទងនឹងអត្តចរិករបស់ នួន ជា ថាចាប់តាំងពីបានស្គាល់ នួន ជា មកលោកចាត់ទុក នួន ជា ជាមេដឹកនាំមួយរូបដែលលោកគោរពស្រលាញ់ និងបម្រើអស់ពីចិត្ត ។ តាមអាកប្បកិរិយាបុកពារ នួន ជា ជាអ្នកចេះដឹងរៀនសូត្របានខ្ពង់ខ្ពស់សុភាពរាបសារ និងយល់ដឹងពីធម៌អាថ៌ជ្រៅជ្រះ ។ ប៉ុន្តែសំណួរបន្ទាប់ដែលលោក សុន អរុណ បានសួរឲ្យសាក្សីធ្វើការសន្និដ្ឋានទៅលើអត្តចរិករបស់សាក្សីបន្ថែមទៀតនោះ អង្គជំនុំជម្រះបានបង្គាប់មិនឲ្យសាក្សីឆ្លើយ ដោយសំអាងលើហេតុផលថា សាក្សីមិនមានភារកិច្ចក្នុងការធ្វើសេចក្តីសន្និដ្ឋានតបនឹងសំណួរដែលនាំឲ្យសាក្សីបង្ហាញគំនិត និងការយល់ឃើញផ្ទាល់ខ្លួនទេ ព្រោះសាក្សីមិនមែនជាអ្នកជំនាញឡើយ ។ លោកមេធាវី សុន អរុណ បានសួរដេញដោលបន្តទាក់ទងនឹងការទំនាស់ដែលបានកើតឡើងរវាងកម្ពុជា និងវៀតណាមនៅរបបខ្មែរក្រហម ។ សាក្សីបានលើកឡើងថា តាមការយល់ដឹងរបស់ខ្លួននៅពេលនោះដោយសារលោកមានបងថ្លៃម្នាក់ជាសមាជិកនៅភូមិភាគឦសាននោះបានឲ្យដឹងថា នៅពេលនោះវៀតណាមបានសុំដីរបស់ប្រទេសកម្ពុជានៅមុំកន្ទុយនាគ ក្រោយមកវៀតណាមមិនបានសងកម្ពុជាវិញ ទើបមានចម្បាំងកើតឡើង ហើយវៀតណាមមិនបានប្រគល់មកឲ្យខ្មែរវិញរហូតដល់សព្វថ្ងៃ ។

បន្ទាប់មកលោកមេធាវីអន្តរជាតិ អ៊ីនូហ្សិ បានបន្តការសាកសួររបស់ខ្លួនទាក់ទងនឹងសមាជិកដែលធ្វើការនៅមន្ទីរប-១

ឈ្មោះ មុត ។ ចំពោះឈ្មោះនេះសាក្សីបានបញ្ជាក់ថាបុគ្គលនោះមានឈ្មោះជាផ្លូវការសព្វថ្ងៃ គឺឯកឧត្តម គាត ឈន់ ។ នៅក្នុងរបបខ្មែរក្រហម លោក គាត ឈន់ មានមុខនាទីជាអ្នកសរសេរសុន្ទរកថាទទួលស្វាគមន៍គណៈប្រតិភូធ្វើការចរចា និងការធ្វើកំណត់ហេតុ ។ សាក្សីបានបន្ថែមទៀតថា ចំពោះការចរចា គឺមិនពាក់ព័ន្ធនឹងរឿងព្រំដែនទេ គឺពាក់ព័ន្ធនឹង រឿងការទូតដូចជាការថ្លែងសុន្ទរកថានៅអង្គការសហប្រជាជាតិ និងនៅប្រទេសមិនចូលបក្សសម្ព័ន្ធជាដើម ។ តាមចម្លើយរបស់សាក្សី លោក គាត ឈន់ គឺជាកម្មាភិបាលជាន់ខ្ពស់មួយរូបនៅក្នុងក្រសួងការបរទេសទទួលបន្ទុកខាងកិច្ចការ


មេធាវីការពារក្តី អេនខ្រូ អ៊ីនូហ្ស៊ី

នយោបាយក្រៅប្រទេស និងមានបទពិសោធន៍ច្រើនខាងការងារការទូត ។ លោកមេធាវីអន្តរជាតិ អេនខ្រូ អ៊ីនូហ្ស៊ី បានសួរសាក្សីបន្តអំពីការបដិសេធរបស់លោក គាត ឈន់ ក្នុងការផ្តល់សក្ខីកម្មជូនអង្គជំនុំជម្រះ ។ ប៉ុន្តែសំណួរនេះត្រូវបានបង្អាក់ទៅវិញពីសំណាក់លោកប្រធានអង្គជំនុំជម្រះដោយលោកសំអាងលើហេតុផលថាសាក្សីមិនមានភារកិច្ចក្នុងការឆ្លើយតបសំណួរបែបនេះទេ ហើយនីតិវិធីនៃការកោះហៅបុគ្គលណាមួយមកសួរដេញដោលក៏មិនមែនជាភារកិច្ចរបស់សាក្សីនោះឡើយ ។ លោកមេធាវីអន្តរជាតិបានបន្តការសួរដេញដោលរបស់ខ្លួនអំពីលោក ហោ ណាំហុង ។ សាក្សីបានបំភ្លឺ ថា នៅចុងឆ្នាំ១៩៧៨ ខ្លួនបានឃើញ ហោ ណាំហុង, គាត ឈន់ និង ជួន ប្រាសិទ្ធ ធ្វើការនៅក្នុងក្រុមជាមួយគ្នានៅមន្ទីរប-១ ។ ចំណែកមន្ទីរប-៣២ជាកន្លែងសម្រាប់ចល័តក្នុងក្រុមមេដឹកនាំ ។ សាក្សី រចឹម គុន បានទទួលស្គាល់ថា តាមលោកចាំលោក ហោ ណាំហុង គឺជាអគ្គរដ្ឋទូតប្រចាំនៅប្រទេស គុយបា និងធ្វើការមន្ទីរប-១ រយៈពេលខ្លី ប៉ុន្តែបានគ្រប់គ្រងនៅមន្ទីរបឹងត្របែក រយៈពេលយូរ ។

លោកមេធាវីបានសួរនាំអំពីការផ្តល់បទសម្ភាសន៍កន្លងមកជាមួយសហចៅក្រមស៊ើបអង្កេត និងមជ្ឈមណ្ឌលឯកសារកម្ពុជា ។ សាក្សីបានទទួលស្គាល់ថា ខ្លួនបានផ្តល់សម្ភាសន៍ជាមួយចៅក្រមស៊ើបអង្កេតពិតមែន ប៉ុន្តែលោកមិនធ្លាប់ធ្វើបទសម្ភាសន៍ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជានោះទេ បើទោះបីជាលោកមេធាវីបានបង្ហាញឯកសារដែលសាក្សីបានផ្តល់សម្ភាសន៍ជាមួយបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាឈ្មោះ ឡុង ដានី ក៏ដោយ ។ លោកមេធាវីបានអានអត្ថបទសម្រង់ដែលសាក្សីសម្ភាសន៍ជាមួយលោក ឡុង ដានី ដែលបញ្ជាក់ថា តាម៉ុក គឺជាមនុស្សឃោរឃៅ ប៉ុន្តែសាក្សីបាននិយាយថា ខ្លួនមិនចាំឯកសារនោះទេ តែទោះជាយ៉ាងណាលោកបានទទួលស្គាល់ថា ខ្លួនមិនចូលចិត្ត តាម៉ុក ទេដោយសារ តាម៉ុក បានមើលងាយគាត់ថាជាជនជាតិភាគតិច ទើបលោកថា តាម៉ុក គឺជាជនជាតិខ្មែរមួយរូបដែលចាប់កម្មាភិបាលជនជាតិខ្លួនឯងទៅសម្លាប់ជាច្រើន ។ សាក្សីបានបន្តថា កម្មាភិបាលមកពីភូមិភាគនិរតីសម្លាប់មនុស្សសាហាវណាស់លោកសន្និដ្ឋានផ្ទាល់ខ្លួនថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យមនុស្សអាក្រក់ជាងគេ គឺតាម៉ុក ។ សាក្សីបានចាត់ទុក តាម៉ុក ជាស្តេចគ្រាញ់ដែលគ្រប់គ្រងភូមិភាគបានកាប់សម្លាប់មនុស្សជាច្រើននាក់ និងមានកម្មាភិបាលច្រើនទៀត ។

លោកមេធាវីបានលើកឡើងអំពីឯកសារមួយដែលសាក្សីបាននិយាយអំពីនយោបាយឈ្នះឈ្នះរបស់នាយករដ្ឋមន្ត្រីនៃរដ្ឋាភិបាលកម្ពុជា ។ សាក្សីបានឆ្លើយតបចំណុចនេះថា នយោបាយឈ្នះឈ្នះ គឺបង្កើតឡើងមិនមានអ្នកចាញ់ទេ គឺឈ្នះទាំងអស់គ្នាដោយសារតែឈ្នះទាំងអស់គ្នានេះហើយ ទើបធ្វើឲ្យមានសន្តិភាពរហូតដល់សព្វថ្ងៃនេះ ។ លោកមេធាវីបានបន្តសំណួរទៀតថាចំណុចសំខាន់នៃនយោបាយនោះគឺថា ដើម្បីកប់ចោលនូវអតីតកាលរបស់ខ្មែរក្រហមទាំងអស់

រាប់ទាំងមេដឹកនាំដែលកំពុងទទួលរងការជំនុំជម្រះសព្វថ្ងៃនេះផង ។ តើសាក្សីយល់ស្របអញ្ចឹងដែរឬទេ? ប៉ុន្តែសំណួរនេះត្រូវបានជំទាស់ដោយតំណាងសហព្រះរាជអាជ្ញា ។ សេចក្តីជំទាស់ត្រូវបានគាំទ្រដោយអង្គជំនុំជម្រះដោយសំអាងលើហេតុផលថា សំណួររបស់មេធាវីគឺស្ថិតនៅក្រៅអង្គហេតុមិនពាក់ព័ន្ធនឹងការចោទប្រកាន់ទេ ។

## ៤.២) ក្រុមមេធាវីការពារក្តី អៀង សារី

លោក ម៉ៃឃើល កាណាវ៉ាស មេធាវីអន្តរជាតិការពារក្តីជនជាប់ចោទ អៀង សារី បានចាប់ផ្តើមតាំងសំណួរទៅសាក្សី រចឹមគុន



មេធាវីការពារក្តី ម៉ៃឃើល កាណាវ៉ាស

គុន នៅរសៀលថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១២ ។ សំណួរដំបូងទាក់ទងនឹងការចងចាំនូវបទសម្ភាសន៍ដែលសាក្សីផ្តល់ជូនសហចៅក្រមស៊ើបអង្កេតចំនួនពីរលើក គឺលើកទីមួយនៅឆ្នាំ២០០៧ និងលើកទីពីរនៅឆ្នាំ២០០៨ ។ លោក កាណាវ៉ាស បានសួរពីបទសម្ភាសន៍ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយសាក្សីបានបញ្ជាក់ថា លោកមិនចាំថាលោកបានផ្តល់បទសម្ភាសន៍ ឬអត់នោះទេ ។ បន្ទាប់មក លោក កាណាវ៉ាស បានអានអត្ថបទសម្រង់អត្ថបទមួយដែលសាក្សីបានឆ្លើយជាមួយ ឡុង ដានី បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាថា កាលនៅក្រសួងការបរទេសនោះ គឺ ប៉ុល ពត ជាអ្នកចាត់តាំងឲ្យលោកធ្វើការជាមួយ អៀង សារី ។ ប៉ុន្តែ សាក្សីបានបញ្ជាក់ជាថ្មីថា លោកមិនចាំពេលវេលាដែលផ្តល់សម្ភាសន៍នោះទេ ។ លោកមេធាវី កាណាវ៉ាស បានលើកឡើងភ្លាមថា "ដូច្នេះដើម្បីឲ្យបានច្បាស់ គឺអង្គជំនុំជម្រះសាលាដំបូងនៅពេលនេះបានយល់ច្បាស់ ហើយនៅពេលដែលសហព្រះរាជអាជ្ញាសួរលោកអំពីព្រឹត្តិការណ៍៣០ជាងហើយ គឺលោកអាចឆ្លើយបានដោយមានភាពជាក់លាក់ ដូចជាកិច្ចប្រជុំនៅទីណាអ្នកណាចូលរួមនៅក្នុងអង្គប្រជុំ ប៉ុន្តែការសម្ភាសន៍នេះទើបតែធ្វើមិនដល់ពីរឆ្នាំផង ។ តើនេះគឺអ្វីដែលលោកចង់ឲ្យអង្គជំនុំជម្រះនាពេលនេះជឿលោកយ៉ាងម៉េចបើមិនដល់ពីរឆ្នាំផងលោកភ្លេច? " សាក្សីបានបញ្ជាក់ថា លោកឆ្លើយតាមតែអ្វីដែលលោកចងចាំប៉ុណ្ណោះ ។ លោកនៅតែអះអាងថា ក្រុមដែលស្វែងរកការពិតនោះ គឺលោកមិនធ្លាប់ជួបសោះ និងបន្ថែមទៀតថា បើតុលាការមានឯកសារដែលថា ប៉ុល ពត ចាត់តាំងឲ្យលោកនៅជាមួយ អៀង សារី នៅក្រសួងការបរទេស លោកក៏ទទួលស្គាល់ថាបែបនោះតែម្តងទៅ ។ ត្រង់ចំណុចនេះលោកប្រធានអង្គជំនុំជម្រះបានធ្វើអន្តរាគមន៍ ដោយពន្យល់ទៅសាក្សីបញ្ជាក់ថា សាក្សីដើម្បីឲ្យយល់ច្បាស់ទំនងអាចមានការភន្តច្រឡំ ពីព្រោះខាងមេធាវីក៏មិនបានសួរបញ្ជាក់ឲ្យបានច្បាស់លាស់ដែរដោយលោកពន្យល់ថា ឯកសារសម្ភាសន៍នោះ មានសរសេរឈ្មោះអ្នកសម្ភាសន៍ហើយ ប៉ុន្តែមិនមានស្នាមមេដៃរបស់សាក្សីដូចកំណត់ហេតុដែលធ្វើដោយសហចៅក្រមស៊ើបអង្កេតទេ ប៉ុន្តែលោកបានបន្ថែមថា ឯកសារនេះគ្រាន់តែជាមូលដ្ឋានក្នុងការសួរ ដូច្នេះសាក្សីអាចឆ្លើយតបនឹងសំណួរដែលសួរនោះបាន ។ ទាក់ទងនឹងសំណួរបន្ទាប់សាក្សីបានជម្រាបជូនអង្គជំនុំជម្រះថា ខ្លួនស្គាល់លោក សូ ហុង និងធ្លាប់បានពិភាក្សាជាមួយគ្នាអំពីការផ្តល់សក្ខីកម្មរបស់ សូ ហុង នៅចំពោះមុខតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ប៉ុន្តែលោកមិនបានតាមដានការផ្តល់សក្ខីកម្មនោះទេ ។ លោក សូ ហុង បានផ្តល់ចម្លើយថា ពេល ជាម នៅក្រសួងការបរទេស ជាម ស្ថិតនៅក្រោមបង្គាប់របស់ ប៉ង់ ។ ប៉ុន្តែនៅក្នុងសវនាការនេះ សាក្សីបានបដិសេធថា ខ្លួនមិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់ ប៉ង់ ទេ គឺស្ថិតនៅក្រោម សូ ហុង និង អៀង សារី ។ នៅក្នុងការសួរដេញដោលដែលមានលក្ខណៈតានតឹងរវាងសាក្សី និងលោកមេធាវី

ការពារក្តីនេះ លោកមេធាវី កាណាវ៉ាស បានបញ្ជាក់ម្តងហើយម្តងទៀតថា នៅក្នុងការផ្តល់សក្ខីកម្មដោយមានសម្បថនេះ តើសាក្សីនៅតែពិតជាមិនធ្វើការងារផ្នែកសន្តិសុខទេ? សាក្សីបានឆ្លើយថា ខ្លួនមិនធ្វើការងារផ្នែកសន្តិសុខទេនៅក្រសួងការបរទេស ប៉ុន្តែខ្លួនទទួលខុសត្រូវខាងផ្នែករដ្ឋបាល ។ អៀង សារី ជាអ្នកក្តាប់រួមលើការងារសន្តិសុខ ។ ឆ្លើយតបនឹងសំណួរបន្ទាប់ លោកបានបន្តថា លោកមិន ស្គាល់មន្ទីរស-២១ទេ ហើយលោកក៏មិនធ្លាប់បាន ជួប ឌុច ដែរ ។ លោកធ្លាប់នាំយកមនុស្សមួយចំនួនទៅមន្ទីរ៨៧០ តែប៉ុណ្ណោះ ហើយមន្ទីរ៨៧០បញ្ជូនទៅណាទៀតលោកមិនបានដឹងទេ ។ លោក កាណាវ៉ាស បានសួរនាំផ្តោតទៅលើការសម្ភាសរបស់ក្រុមស៊ើប អង្កេតដែលដឹកនាំដោយ លោក ម៉ៃ ឌិកសិន និង លោក ស្វាយ សំណាង ដែលរយៈពេលថតសំឡេងមានតែ១៨នាទី ប៉ុន្តែ សាក្សីបញ្ជាក់ថា បានទទួលការសម្ភាសន៍រហូតពេញមួយថ្ងៃ ។ ឆ្លើយតបទៅលោកមេធាវី សាក្សី រចឹម តុន ហៅ ជាម បានបញ្ជាក់ថា លោកមិនចាំលម្អិតទេ ហើយការផ្តល់សក្ខីកម្មនៅមុននេះ គឺលោកមានស្មារតីមិនសូវល្អ ច្របូកច្របល់ដោយសារសម្រាកមិនបានគ្រប់គ្រាន់ ។ លោកមិនចាំថាការថតសំឡេងក្នុងរយៈពេល ១៨នាទីនោះនិយាយពីអ្វីខ្លះនោះទេ ។ លោកមេធាវីបានសួរបញ្ជាក់សាក្សីអំពីតួនាទីនិង ទំនាក់ទំនងជាមួយ សូ ហុង ព្រមទាំងបានអានអត្ថបទសម្រង់ដែល សូ ហុង ធ្លាប់បានមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះទៀតផង ។ សាក្សីបានបញ្ជាក់ថា នៅពេលខ្លួន និង សូ ហុង រស់នៅខេត្តរតនគិរីអ្នកទាំងពីរគឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់ ប៉ាំង ។ សាក្សីបន្តទៀតថា អំឡុងពេលដែលលោកធ្វើការនៅមន្ទីរស-៧១ លោកធ្វើការជាអ្នកយាមជាមួយ សូ ហុង ដែលពេលនោះ សូ ហុង យាមនៅផ្នែកខាងក្នុង ចំណែកលោកយាមនៅខាងក្រៅ ។ រហូតមកដល់មន្ទីរ ប-៥ និងមន្ទីរស្តុកគោល លោកនៅតែធ្វើការជាមួយ សូ ហុង ដដែល ។ សាក្សីបានជម្រាបជូនអង្គជំនុំជម្រះថា ខ្លួនធ្លាប់បានទទួលការបណ្តុះបណ្តាលអំពីរបៀបទទួលភ្ញៀវ ការជ្រើសរើសនូវប្រភេទកម្រាល និងការរៀបចំតុទទួលភ្ញៀវមកពីប្រទេសចិន និងបានទៅទស្សនកិច្ចសិក្សានៅក្វាងស៊ី(ប្រទេសចិន) ។ សាក្សីបានរៀបរាប់ថា អ្នកដែលទទួលខុសត្រូវផ្នែកសន្តិសុខមាន អៀង សារី សូ ហុង និង ជាម (សាក្សី) ។ អ្នកទាំងបីទទួលខុសត្រូវដូចៗគ្នាខាងផ្នែកសន្តិសុខនៅក្នុងក្រសួងការបរទេសទាំងមូល ។ លោកមេធាវីបានធ្វើការដកស្រង់នូវអត្ថន័យពីសៀវភៅ "ប្រវត្តិនៃសុបិន្តអាក្រក់" របស់លោក ហ្វីលីព ហ្សត ដែលសាក្សីបាននិយាយថា សាក្សី គឺជាប្រធានសន្តិសុខ ។ ឆ្លើយតបនឹងសំណួរនេះ សាក្សីបានជម្រាបថា ខ្លួនមានតួនាទីជាប្រធានប-១ ដូច្នេះរាល់ការងារទាំងអស់គឺស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួនរួមទាំងផ្នែកសន្តិសុខទៀតផង ។ នៅមុនពេលបញ្ចប់ការសាកសួររបស់ខ្លួន លោក កាណាវ៉ាស បានលើកឡើងនូវសេចក្តីសន្និដ្ឋានមួយពាក់ព័ន្ធនឹងខ្សែអាត់ថតសម្លេងរយៈពេល១៨នាទី ដោយលោកអះអាងថា នៅក្នុងបទសម្ភាសន៍នេះ គឺមានវត្តមានរបស់សាក្សី ប៉ុន្តែសាក្សីបញ្ជាក់ថា ខ្លួនមិនចាំច្បាស់អំពីបទសម្ភាសន៍នេះ ហើយទាមទារឲ្យមានការស្តាប់ឡើងវិញ ដែលបង្ហាញឲ្យឃើញពីភាពមិនអាចទុកចិត្តបានលើសាក្សីរូបនេះ ។ លោកមេធាវី បានស្នើឲ្យអង្គជំនុំជម្រះមានការយកចិត្តទុកដាក់ពិចារណាលើបញ្ហានេះ ដោយសារវាមានសារសំខាន់ពាក់ព័ន្ធនឹងសុច្ចរិតភាពនៃដំណើរការនីតិវិធីរបស់តុលាការ ។ ឆ្លើយតបនឹងសំណើនេះ លោកប្រធានអង្គជំនុំជម្រះបានបង្គាប់ឲ្យក្រុមមេធាវីការពារក្តី អៀង សារី ធ្វើសំណើជាលាយលក្ខណ៍អក្សរជូនមកអង្គជំនុំជម្រះ ដោយហេតុថា សំណើផ្ទាល់មាត់របស់លោកនាពេលនេះ គឺមិនទាន់គ្រប់គ្រាន់នៅឡើយទេ ។

## ៤.៣) ក្រុមមេធាវីការពារក្តី ខៀវ សំផន

លោក គង់ សំអុន មេធាវីជាតិការពារក្តីជនជាប់ចោទ ខៀវ សំផន បានធ្វើការតាំងសំណួរដំបូងទាក់ទងនឹងពាក្យថា "រណសិរ្ស" ។ សាក្សីបានបញ្ជាក់ថា លោកក៏មិនសូវយល់ច្បាស់ពីរណសិរ្សនេះទេ គឺលោកបានដឹងខ្លះៗតាមរយៈការស្តាប់វិទ្យុ និងការអានឯកសារ (ទង់បដិវត្ត និងទង់យុវជន) ដែលនិយាយពីរណសិរ្សរួបរួមជាតិកម្ពុជាប៉ុណ្ណោះ ។ បន្ទាប់មក លោកមេធាវីបានសួរទាក់ទងនឹងសាលាបច្ចេកទេសសូវៀត ហើយសាក្សីបានអះអាងថា ខ្លួនធ្លាប់បានទៅសាលានេះបានម្តងប៉ុណ្ណោះនៅរបបខ្មែរក្រហម ដែលក្នុងរយៈពេលរៀនប្រហែលពីរទៅបីថ្ងៃនិងមានអ្នកចូលរួមប្រហែល៤០នាក់ នោះ គឺមាន ខៀវ សំផន ជាអ្នកធ្វើបទខុទ្ទេសនាម ។ ដូចសព្វដងគឺ ខៀវ សំផន បានធ្វើបទខុទ្ទេសនាមអំពីទស្សនៈសភាពការណ៍ក្នុង និង

ក្រៅប្រទេស ការធ្វើបដិវត្តសង្គមនិយម ការឆ្លងជីវទស្សនៈបដិវត្ត និងចុងក្រោយ គឺការបិទវគ្គសិក្សា ។ ទាក់ទងនឹង ខៀវ សំផន សាក្សីបានបញ្ជាក់ថា ក្រោយរដ្ឋប្រហារឆ្នាំ១៩៧០ ខ្លួនបានចូលរួមរៀបចំ



មេធាវីការពារក្តី គង់ សំអុន

រណសិរ្សរួបរួមជាតិកម្ពុជា ដោយរស់នៅក្នុងព្រៃជាមួយ ខៀវ សំផន ដែលនៅពេលនោះ ខៀវ សំផន ជាអ្នកកាន់ការងាររណសិរ្ស និងជាមេបញ្ជាការទ័ព ។

លោក អាកទូ វែកគែន មេធាវីអន្តរជាតិបានបន្តសំណួរពីដៃគូរបស់ខ្លួនដោយចោទសំណួរទាក់ទងនឹងការងារជាអង្គរក្ស ឬកងការពាររបស់ ប៉ុល ពត នៅក្នុងព្រៃ ។ សាក្សីបានរៀបរាប់ថា នៅពេលលោកមកធ្វើជាកងការពារនៅមន្ទីរស-៧១នោះ គឺលោកបានធ្វើការជាមួយបុគ្គលិកចំនួន៨០នាក់ផ្សេងទៀត ដែលមានឋានៈដូចៗគ្នា ។ លោកចាប់ផ្តើមការពារ នួន ជា ពីឆ្នាំ១៩៧២ និងធ្វើជានីរសារដែលមានម៉ូតូមួយសម្រាប់រត់សំបុត្រ ។ ចំពោះមុខងារដែលជាកងការពារ លោកបានចាប់ផ្តើមតាំងពីខែឧសភាឆ្នាំ ១៩៧០ មកម្ល៉េះ ប៉ុន្តែលោកក៏បានទទួលស្គាល់ថា ជាការពិតដែលខ្លួនមិនបានទទួលការតែងតាំងជាពិសេស ដើម្បីការពារថ្នាក់ដឹកនាំណាមួយជាក់លាក់នៅមន្ទីរស-៧១នោះទេ ។ នៅក្នុងការយាមនៅពេលថ្ងៃមានការ គឺបែងចែកគ្នា កម្លាំងមួយចំនួននៅយាម ហើយមួយចំនួនធ្វើពលកម្មដូចជាកាប់ឈើធ្វើជាដើម ។ ចំណែក នៅពេលយប់គឺមានការបែងចែកជាក្រុម ក្នុងមួយក្រុមមានសមាជិកប្រហែល ១០នាក់នៅយាមតាមចំណុចនីមួយៗវៀងខ្លួន ។ លោកបានបន្តថា លោកធ្លាប់ត្រូវបានគេបញ្ជូនទៅមន្ទីរប-៥ ដែលបង្កើតនៅឆ្នាំ១៩៧៣ ក្នុងនាមជាសមាជិកអចិន្ត្រៃយ៍ និងបន្តការងារជានីរសារពីសមរភូមិសមរភូមិក្រោយ និងនាំសារពីភូមិភាគនិរតី ។លោកបានបន្តទៀតថា ការបង្កើតមន្ទីរប-៥ គឺសម្រាប់បញ្ជាសមរភូមិវាយសម្រុកចូលរំដោះទីក្រុងភ្នំពេញ ។ លោកមេធាវីបានសួរសាក្សីអំពីទីតាំងសមរភូមិក្រោយ ហើយសាក្សីបានបញ្ជាក់ថា ចាប់ពីឆ្នាំ១៩៧៣ មានមន្ទីរចល័តមួយនៅខាងក្រោយ គឺមន្ទីរ២៤ មានទីតាំងនៅជិតមន្ទីរស-៧១ ។ ចំពោះមន្ទីរស្តុកគោលវិញ គឺស្ថិតក្រោមការគ្រប់គ្រងរបស់ ប៉ុល ពត និងបានបញ្ជាឲ្យវាយទីក្រុងភ្នំពេញ ។ នៅក្នុងការការពារមេដឹកនាំខ្មែរក្រហមពេលប្រជុំម្តងៗ កងការពារនៅយាមមិនឆ្ងាយប៉ុន្មានឡើយ ។ សាក្សីបានបញ្ជាក់ថា ការយាមកាមនេះក្នុងបំណងការពារខ្មាំងក្រែងមានជងឺ ដូចជា ខ្យល់គ រក្សា នូវសន្តិសុខទូទៅ និងស្តាប់ការខទ្មេសនាមពីមេដឹកនាំទាំងនោះ ។

គួរបញ្ជាក់ថា នៅខណៈដែលលោកមេធាវី អាកទូ វែកគែន កំពុងសួរដេញដោលសាក្សី រចឹម គុន នៅព្រឹក ថ្ងៃទី២ ខែសីហា ឆ្នាំ ២០១២ គឺមានបញ្ហាប្រឈមខ្លះ ដោយសារភាគីមិនអាចស្តាប់គ្នាយល់ដោយសារមូលហេតុនៃការបកប្រែភាសាខ្មែរ និងភាសាបារាំងមានភាពខ្វះចន្លោះទើបនាំឲ្យមានចម្ងល់មួយចំនួនតម្រូវឲ្យមេធាវីសួរបញ្ជាក់សាក្សីឡើងវិញ ប៉ុន្តែសំណួរដែលសួរឡើងវិញទាំងនោះត្រូវបានជំទាស់ដោយលោកប្រធានអង្គជំនុំជម្រះថាជាសំណួរច្រំដែល ។ ភ្លាមៗនោះ លោកមេធាវីបានឆ្លើយតបថា ដោយសារនៅក្នុងតុលាការមានការប្រើប្រាស់បីភាសា ហើយបើខ្លួនមិនអាចស្តាប់ភាសាបារាំងបាននោះទេ លោកមិនអាចបន្តការងារជាមេធាវីបានទៀតទេ ប៉ុន្តែបញ្ហានេះលោកប្រធានបានបញ្ជាក់ថា លោកបានសម្រេចរួចហើយ និងបង្គាប់ឲ្យមេធាវីតាំងសំណួរសារថ្មីម្យ៉ាងទៀតលោកប្រធានបានកត់សម្គាល់ឃើញថា លោកមេធាវីតាំងសំណួរច្រំដែលច្រើន ។ បន្ទាប់មក លោកមេធាវីបានសួរបញ្ជាក់

ពីមន្ទីរស្តុកគោល ដែលលោកមានកំណត់ត្រារបស់ខ្លួនថា មន្ទីរនេះ ជាបញ្ជាការវាយយកទីក្រុងភ្នំពេញ គឺមិនមែននៅមន្ទីរប-៥ទេ ។ បន្ទាប់មកលោកមេធាវីបានសួរសាក្សី រចឹម គុន អំពីការផ្តល់បទ


មេធាវីការពារក្តី អាកទួរ វ៉ែកកែន

សម្ភាសន៍របស់សាក្សីជាមួយលោក ហ្វីលីព ស្សុត ពិភាក្សាអំពីការប្រជុំនៅមន្ទីរប-៥ សម្រេចពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ។ សាក្សីបានទទួលស្គាល់ថា ខ្លួនបានផ្តល់សម្ភាសន៍ជូនជនជាតិបារាំងម្នាក់មែន និងផ្តល់យោបល់ឲ្យមេធាវីយោងទៅលើបទសម្ភាសន៍ និងអត្ថន័យដែលមាននៅក្នុងសៀវភៅរបស់លោក ហ្វីលីព ស្សុត ព្រមទាំងស្នើឲ្យមេធាវីធ្វើការស្វែងយល់ដោយខ្លួននូវសំណួរដែលចោទសួរមកខ្លួន ។ នៅក្នុងស្ថានភាពនេះលោកមេធាវីបានស្នើឲ្យអង្គជំនុំជម្រះជួយធ្វើអន្តរាគមន៍ ។ ភ្លាមៗនោះលោកប្រធានអង្គជំនុំជម្រះបានណែនាំសាក្សីអំពីកាតព្វកិច្ចរបស់សាក្សីក្នុងការឆ្លើយសំណួរដែលចោទសួរមកលើខ្លួនដោយភាគី នៅចំពោះមុខអង្គជំនុំជម្រះសួរគ្រប់សំណួរទាំងអស់តាមលទ្ធភាព និងសមត្ថភាពដែលសាក្សីយល់ដឹង បានឮ បានឃើញ ចងចាំ និងមានបទពិសោធន៍នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

បន្ទាប់មក សាក្សីបានជម្រាបថា លោកមានទំនាក់ទំនងជាមួយ ខៀវ សំផន ដែលបានបន្តដំណែងពី ឌឿន ក្នុងករណីចាំបាច់ម្តងម្កាលរវាងមន្ទីរ៨៧០ និងមន្ទីរប-១ តែប៉ុណ្ណោះទាក់ទងនឹងការទទួលភ្ញៀវបរទេស និងការនាំភ្ញៀវទៅតាមបណ្តាខេត្តជាដើម ។ សាក្សីបានអះអាងថា ខ្លួនមិនបានដឹងពីការថ្លែងសុន្ទរកថារបស់ ខៀវ សំផន ទាក់ទងនឹងមហាក្បត់ទាំង៧នាក់ និងសេចក្តីប្រកាសរបស់សម្តេច សីហនុ នៅថ្ងៃទី២៧ ខែមិនា ដែលនិយាយពីការប្រហារជីវិត ឡុង បូរ៉េត នោះទេ ។

**កំណត់សម្គាល់**

មុននឹងឈានដល់ការសួរដេញដោលសាក្សី រចឹម គុន លោកមេធាវី កាណាវ៉ាស បានលើកយកបញ្ហាទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយចំនួនពីរលើករបស់សាក្សីរូបនេះ ដែលបានផ្តល់ជូនសហចៅក្រមស៊ើបអង្កេតមកពិភាក្សានៅចំពោះអង្គជំនុំជម្រះ ។ លោកមេធាវីមានការសង្ស័យចំពោះការថតសម្លេងលើកទីពីរ ដែលលោកគិតថា មិនមានភាពប្រក្រតី ដោយសារលោកដឹងថា បទសម្ភាសន៍ធ្វើក្នុងរយៈពេលពីរម៉ោង ប៉ុន្តែមានថតសម្លេងតែរយៈពេល១៥នាទីនៅក្នុងអត្ថបទជាអក្សរវិញ គឺឃើញមានតែបួនទំព័រប៉ុណ្ណោះជាភាសាខ្មែរ និងអង់គ្លេស ។ លោកតំណាងសហព្រះរាជអាជ្ញា ឌេលលី សាក់ បានឆ្លើយតបថា ប្រសិនបើយល់ថា ការកត់ត្រាជាខ្សែអាត់នោះមានបញ្ហា ឬមានបញ្ហាអ្វីគឺយើងអាចឃើញ និងសួរបញ្ជាក់ពេលសួរដេញដោលសាក្សីក្នុងសវនាការនេះ ។ អង្គជំនុំជម្រះក៏បានកោះហៅសាក្សី រចឹម គុន ចូលក្នុងបន្ទប់សវនាការ និងបានសួរសំណួរមួយចំនួនទាក់ទងនឹងបទសម្ភាសន៍របស់សាក្សីជាមួយចៅក្រមស៊ើបអង្កេត ។ សាក្សី រចឹម គុន ធ្លាប់បានធ្វើការសម្ភាសន៍ពីរដង គឺលើកទីមួយ នៅឃុំម៉ាឡៃ ស្រុកម៉ាឡៃ នៅឆ្នាំ២០០៧ និងលើកទីពីរ នៅផ្ទះរបស់លោកក្នុងឆ្នាំ២០០៨ ។ សាក្សីបានជម្រាបជូនអង្គជំនុំជម្រះថា មុនពេលមកផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ លោកបានអានសារចុះឡើងអំពីបទសម្ភាសន៍ដែលខ្លួនធ្លាប់ធ្វើ ប៉ុន្តែលោកមិនចាំនោះឡើយ ។ លោកឃើញការសម្ភាសន៍នោះមានលក្ខណៈដូចគ្នាទាំងពីរលើក ដែលនៅក្នុងសម្ភាសន៍នីមួយៗលោកបានរៀបរាប់អំពីអ្វីដែលលោកបានជួបប្រទះតាំងពីឆ្នាំ១៩៦៧កន្លងមកតាមអ្វីខ្លួនបានដឹង ។

# សវនាការស្តីពីការផ្តល់សក្ខីកម្មរបស់សាក្សី សួង ស៊ីគឿន

បន្ទាប់ពីបានបញ្ចប់ការផ្តល់សក្ខីកម្មរបស់សាក្សី រចឹម គុន ហៅ ភី ភួន ហៅ ជាម នៅថ្ងៃទី២ ខែសីហា ឆ្នាំ២០១២ ភ្លាម អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបន្តបើកសវនាការស្តាប់សក្ខីកម្មរបស់សាក្សីមួយរូបទៀត គឺលោក សួង ស៊ីគឿន អតីតកម្មាភិបាលខ្មែរក្រហម ម្នាក់ដែលបម្រើការនៅក្នុងក្រសួងការបរទេសក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ សវនាការនេះ បានចាប់ផ្តើមពីល្ងាចថ្ងៃទី២ដល់ថ្ងៃទី២០ ខែសីហា ឆ្នាំ២០១២ ពោលគឺមានរយៈពេលជាងពីរសប្តាហ៍ ។ មូលហេតុដែលនាំឲ្យចំណាយពេលយ៉ាងយូរដូច្នេះ គឺដោយសារៈ ទី១) សាក្សីរូបនេះមានបញ្ហាសុខភាពមិនគ្រប់គ្រាន់ ដែលនាំឲ្យអង្គជំនុំជម្រះសម្រេចផ្អាកសវនាការមួយរយៈពេលខ្លី ។ ទី២) បញ្ហាសុខភាពរបស់ជនជាប់ចោទ អៀង សារី ដែលមិនអាចតាមដានកិច្ចដំណើរការនីតិវិធីរបស់តុលាការបាន ហើយមិនព្រមលះបង់សិទ្ធិចូលរួមសវនាការដោយជនជាប់ចោទបានស្នើសុំឲ្យផ្អាកសវនាការជាបណ្តោះអាសន្ន ។ ដូច្នេះអង្គជំនុំជម្រះបានសម្រេចផ្អាកសវនាការជាបន្តបន្ទាប់ ។ គួរបញ្ជាក់ថា ដោយសារសាក្សីមានបញ្ហាសុខភាពមិនអាចផ្តល់សក្ខីកម្មបានពេញមួយថ្ងៃ ដូច្នេះអង្គជំនុំជម្រះបានសម្រេចស្តាប់សក្ខីកម្មរបស់សាក្សីពីរនាក់ឆ្លាស់គ្នា ដោយ សួង ស៊ីគឿន ធ្វើនៅពេលព្រឹក និង អុង ថុងហឿង ធ្វើនៅពេលល្ងាច ។


សាក្សី សួង ស៊ីគឿន

ក្នុងអំឡុងពេលសវនាការជាងពីរសប្តាហ៍នេះ មានប្រជាជនកម្ពុជាមិនតិចជាង ៣៥០០ នាក់ឡើយ ដែលបានចូលរួមតាមដានសវនាការដោយផ្ទាល់តាមរយៈការអញ្ជើញពីមន្ត្រីផ្នែកកិច្ចការសាធារណៈរបស់តុលាការ ។ ដូចគ្នានឹងសាក្សីផ្សេងៗទៀតដែរ សួង ស៊ីគឿន ត្រូវបានអង្គជំនុំជម្រះអនុញ្ញាតឲ្យភាគីទាំងអស់ចោទសំណួរទាក់ទងនឹងអង្គហេតុស្តីពី រចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាល ប្រព័ន្ធទំនាក់ទំនងការងារ និងតួនាទីរបស់ជនជាប់ចោទម្នាក់ៗ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ក្នុងការសួរដេញដោលនេះ ភាគីបានសួរពាក់ព័ន្ធនឹងរណសិរ្សរួបរួមជាតិកម្ពុជា(ហៅកាត់ថា FUNK អានថា “ហ្វុង”) រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា(ហៅកាត់ថា GRUNK អានថា“គ្រុង”) , តួនាទីរបស់ អៀង សារី ក្នុងការអំពាវនាវដល់បញ្ញាជនដែលរស់នៅបរទេសឲ្យវិលចូលស្រុកវិញ, ការចាប់ខ្លួនកម្មាភិបាលខ្មែរក្រហមមួយចំនួននៅក្រសួងការបរទេស ។ល ។ ក្រៅពីនេះ មានសំណួរមួយចំនួនទៀតទាក់ទងនឹងប្រវត្តិសាវតារនិងគោលបំណងរបស់សាក្សីក្នុងការចូលរួមចលនាតស៊ូបដិវត្ត និងតួនាទីរបស់សាក្សីនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ការសួរនេះប្រព្រឹត្តទៅតាមលំដាប់លំដោយដោយចាប់ផ្តើមពីតំណាងសហព្រះរាជអាជ្ញា ក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី អង្គជំនុំជម្រះ និងមេធាវីការពារក្តីជនជាប់ចោទទាំងបីក្រុម ។

គួរបញ្ជាក់ថា មុននឹងផ្តល់វេទិកាជូនភាគីក្នុងការចោទសួរសាក្សី ប្រធានអង្គជំនុំជម្រះបានបញ្ជាក់ជូនសាក្សីអំពីសិទ្ធិមិនផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯងដែលនាំឲ្យមានពិរុទ្ធភាព និងករណីកិច្ចរបស់សាក្សីក្នុងការឆ្លើយតបសំណួររបស់ភាគីផ្សេងៗនូវអ្វីដែលខ្លួនបានដឹងបានឮ បានឃើញនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ លើកលែងតែការឆ្លើយសំណួរនោះអាចបណ្តាលឲ្យដាក់ពិរុទ្ធភាពមកលើខ្លួនឯង ។ តាមរយៈសិទ្ធិនេះ អង្គជំនុំជម្រះបានផ្តល់មេធាវីប្រឹក្សាសម្រាប់សាក្សីធ្វើការប្រឹក្សាមុននឹងផ្តល់សក្ខីកម្មជូនអង្គជំនុំ

ជម្រះ ។ ក្នុងអំឡុងពេលនោះដែរ លោក ពេជ អង្គ សហមេធាវីជាតិ នាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំអង្គជំនុំជម្រះទទួលស្គាល់លោក ហ៊្វេឌីណង់ ចាមិនហ្វេប៉ា ជនជាតិបារាំង ដែលជាសមាជិករបស់ក្រុមមេធាវីគ្មានព្រំដែនឲ្យមានសិទ្ធិការពារផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿង ០០២ ស្របតាមវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះ ។ លោក ហ៊្វេឌីណង់ បានធ្វើសម្បថនៅចំពោះមុខសាលាឧទ្ធរណ៍នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឆ្នាំ២០០៨ ។ តាមរយៈសំណើនេះប្រធានអង្គជំនុំជម្រះយល់ព្រមទទួលស្គាល់មេធាវីរូបនេះឲ្យមានសិទ្ធិ និងបុព្វសិទ្ធិដូចមេធាវីតំណាងដើមណ្តឹងរដ្ឋប្បវេណីផ្សេងៗទៀត ដើម្បីការពារផលប្រយោជន៍កូនក្តីរបស់ខ្លួន ។

## ១) ប្រវត្តិសាវតាររបស់សាក្សី ស្វួង ស៊ីគឿន

ស្វួង ស៊ីគឿន ហៅ គង់ ឬ ធន់ កើតនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ ១៩៣៦ ។ បច្ចុប្បន្នរស់នៅភូមិក្បាលស្ពាន ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។ ឪពុកឈ្មោះ ស្វួង កាក់, ម្តាយឈ្មោះ នួ រីម និងប្រពន្ធឈ្មោះ តាំង ហ៊ុយអៀង ហើយមានកូនចំនួន៥នាក់ ។ លោកបានប្រើឈ្មោះ ធន់ គឺក្នុងអំឡុងពេលតស៊ូធ្វើបដិវត្តន៍នៅខេត្តកោះកុង ហើយឈ្មោះ គង់ ក៏ប្រើនៅពេលធ្វើបដិវត្តន៍ដែរ តែត្រូវបានគេស្គាល់ជាទូទៅនៅម៉ាឡៃ ។ នៅដើមឆ្នាំ១៩៥៧ ស្វួង ស៊ីគឿន ត្រូវបាន អៀង សារី អនុញ្ញាតឲ្យចូលជាសមាជិករបស់អង្គការតស៊ូសម្ងាត់ ដែលជាចលនាដំបូងរបស់បក្សកុម្មុយនីស្តកម្ពុជា ។ ក្នុងឆ្នាំដដែលនេះ លោកទទួលបានអាហារូបករណ៍ទៅសិក្សានៅប្រទេសបារាំងផ្នែកអាកាសចរណ៍ស៊ីវិល ។ បន្ទាប់មកបន្តសិក្សាថ្នាក់បញ្ញាបត្រ និងអនុបណ្ឌិតផ្នែកអក្សរសាស្ត្រ នៅប្រទេសបារាំង ។ នៅខែតុលា ឆ្នាំ១៩៥៧ លោកត្រូវបាន ខៀវ សំផន បញ្ចូលជាសមាជិករបស់ «វង្សម៉ាក-ឡេនីន» ដែលបានបង្កើតដោយ អៀង សារី, ទូ សាមុត និង កេង វ៉ាន់សាក់ នៅប្រទេសបារាំង ។ ក្រៅពីតួនាទីជាសមាជិករបស់«វង្សម៉ាក-ឡេនីន» លោកមានឋានៈជាប្រធានសហភាពនិស្សិតខ្មែរប្រចាំនៅប្រទេសបារាំង ។បន្ទាប់ពីមានការប្រកាសបង្កើត«ហ៊្វុង» នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧០ ស្វួង ស៊ីគឿន បានធ្វើដំណើរមកទីក្រុងប៉េកាំង ដើម្បីពាំនាំនូវការគាំទ្ររបស់សហភាពនិស្សិតខ្មែរ ដល់«ហ៊្វុង» ដែលមានសម្តេចព្រះបាទនរោត្តម សីហនុ ជាព្រះប្រធាន ។ នៅឆ្នាំ១៩៧១ លោកក្លាយជាសមាជិកពេញសិទ្ធិរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលមាន អៀង សារី ជាអ្នកទទួលស្គាល់ និងមានការធានាដោយ គាត ឈន់ និង ដួន ប្រសិទ្ធ ។ បន្ទាប់មកលោកត្រូវបានចាត់តាំងជាអ្នកតំណាងទីភ្នាក់ងារសារព័ត៌មាន អា.កា.អ៊ី ប្រចាំនៅទីក្រុងប៉េកាំង ។ ចំណែកនៅក្នុង «ហ៊្វុង» លោកត្រូវបានជ្រើសតាំងឲ្យធ្វើជាលេខានៃគណៈកម្មការកណ្តាល និងជាប្រធានការិយាល័យផ្នែកព័ត៌មាន ។ លើសពីនេះលោក មានតួនាទីកាន់ការងារពាក់ព័ន្ធផ្នែកយោធា ដោយទទួលបន្ទុកខាងសន្តិសុខរបស់«ហ៊្វុង» ក្រោមការចាត់តាំងរបស់ ដួង សំអុល ។ នៅដើមខែឧសភា ឆ្នាំ១៩៧៤ លោកត្រូវបានបក្សបញ្ជូនមកធ្វើការនៅវិទ្យុ «សម្លេងរណសិរ្សរួបរួមជាតិកម្ពុជា» នៅទីក្រុងហាណូយ ប្រទេសវៀតណាមដែលមាន អៀង ធីរិទ្ធ ជាអ្នកទទួលខុសត្រូវរួម ។ វិទ្យុនេះទទួលបន្ទុកផ្សព្វផ្សាយព័ត៌មានដែលផ្ញើមកពីប្រទេសកម្ពុជា(ដោយកម្មាភិបាលខ្មែរក្រហម) អំពីស្ថានភាពតស៊ូនៅក្នុង និងក្រៅប្រទេស ។ ស្វួង ស៊ីគឿន ជាអ្នកទទួលបន្ទុកផ្សព្វផ្សាយព័ត៌មានអន្តរជាតិដែលមាន អៀង ធីរិទ្ធ ជាអ្នកត្រួតពិនិត្យមុននឹងអនុញ្ញាតឲ្យផ្សាយចេញ ។ កម្មវិធីសំខាន់របស់វិទ្យុនេះ គឺផ្សាយអំពីបទវិចារណកថា របស់មេដឹកនាំខ្មែរក្រហម និងតំបន់សមរភូមិដែលបក្សកំពុងរំដោះ ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ស្វួង ស៊ីគឿន បម្រើការងារនៅក្រសួងការបរទេស ដែលដឹកនាំដោយ អៀង សារី ក្នុងឋានៈជាឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេស ។ លោកត្រូវបាន អៀង សារី ចាត់តាំងឲ្យទទួលខុសត្រូវផ្នែកកិច្ចការអាស៊ីអាគ្នេយ៍ និងអឺរ៉ុប បន្ទាប់មកជាអនុប្រធាន ផ្នែកពិធីការ និងជាសមាជិកផ្នែកនយោបាយក្នុងក្រសួងការបរទេស និងចុងក្រោយឲ្យធ្វើជាប្រធានផ្នែកព័ត៌មាននិងឃោសនាការ និងជាអ្នកនាំពាក្យរបស់ក្រសួងការបរទេស ។ ក្នុងក្របខណ្ឌបំពេញការងារទាំងនេះ លោករាយការណ៍ដោយផ្ទាល់ទៅ អៀង សារី ។ ក្រៅពីនេះ លោកមានតួនាទីជាអ្នកបកប្រែជូនប្រមុខរដ្ឋ ខៀវ សំផន នៅពេលទទួលសារតាំង ។ បន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យដួលរលំនៅឆ្នាំ១៩៧៩ ស្វួង ស៊ីគឿននៅតែបន្តមានទំនាក់ទំនងការងារជាមួយ អៀង សារី និង ខៀវ សំផន ។ ជាងនេះទៅទៀត ក្រោយឆ្នាំ១៩៧៩ លោកបានភៀសខ្លួនទៅប្រទេសថៃ ហើយ

ទទួលមើលការខុសត្រូវលើជនភៀសខ្លួនចំនួន៨០០នាក់ ។ ក្នុងឆ្នាំ ១៩៨១ សួង ស៊ីគឿន ទទួលតួនាទីជាអ្នកតំណាងឲ្យរបបកម្ពុជាប្រជាធិបតេយ្យចរចាជាមួយសម្តេចព្រះនរោត្តម សីហនុ និង សឺន សាន ដើម្បីបង្កើតរដ្ឋាភិបាលត្រីភាគី ។ រហូតមកដល់ថ្ងៃទី០៤ ខែតុលា ឆ្នាំ១៩៨១ ការចរចារនេះទទួលបានជោគជ័យ នៅប្រទេសសិង្ហបុរី ដោយបង្កើតបានជាសម្ព័ន្ធភាពត្រីភាគី ដែលមានកម្លាំងរបស់កម្ពុជាប្រជាធិបតេយ្យកម្លាំងរបស់សម្តេចព្រះនរោត្តម សីហនុ និងកម្លាំងរបស់លោក សឺន សាន ។

## ២) ការសួរសាក្សីដោយសហព្រះរាជអាជ្ញា

### ២.១) សហព្រះរាជអាជ្ញារងជាតិ

ក្នុងការសួរដេញដោលសាក្សី សហព្រះរាជអាជ្ញារងជាតិ គឺលោក ចាន់ តារាស្មី បានផ្តោតសំខាន់លើគោលបំណងក្នុងការចូលរួម«វង្សម៉ាក-ឡេនីន», តួនាទីរបស់សាក្សីនៅក្នុងទីភ្នាក់ងារសារព័ត៌មានខ្មែរ(ហៅកាត់ថា«អា.កា.អ៊ី») និងនៅក្នុង«ហ៊ុង», ការអមដំណើរគណៈប្រតិភូទៅធ្វើទស្សនៈកិច្ចនៅក្រៅប្រទេស, ការកំណត់សត្រូវរបស់បក្សកុម្មុយនីស្តកម្ពុជា និងចុងក្រោយលោកបានសួរពាក់ព័ន្ធនឹងឈ្មោះបុគ្គលមួយចំនួនដែលជាសមាជិករបស់«គ្រុង» ។ ចំណែកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ គឺលោក វីនសិន ដឺវ៉ាល់ ចោទសំណួរភាគច្រើនទាក់ទងនឹងមូលហេតុនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ, តួនាទីរបស់សាក្សីនៅក្នុងក្រសួងការបរទេស, អំពីកិច្ចប្រជុំ និងការបាត់ខ្លួនបុគ្គលមួយចំនួននៅក្រសួងការបរទេស ។ ឆ្លើយតបសំណួររបស់លោក តារាស្មី ពាក់ព័ន្ធនឹងគោលបំណងក្នុងការចូលរួម«វង្សម៉ាក-ឡេនីន» សួង ស៊ីគឿន បានបញ្ជាក់ថា មូលហេតុចំបងដែលនាំឲ្យលោកចូលរួមក្នុងចលនារបស់«វង្សម៉ាក្ស-ឡេនីន»គឺដោយសារការឈឺចាប់ចំពោះភាពអយុត្តិធម៌ និងជីវភាពក្រីក្ររបស់លោក និងរបស់កសិករក្រីក្រផ្សេងទៀតដែលរស់នៅក្រោមរបបមួយដែលសម្រេចផលប្រយោជន៍ឲ្យអាណានិគមនិយមបារាំង ។ ដូច្នេះ លោកសម្រេចជ្រើសរើសយក«លទ្ធិកុម្មុយនីស្ត» ឬជា«លទ្ធិម៉ាក្ស-ឡេនីន» ដើម្បីរំដោះប្រទេសជាតិចេញពីរបបជិះជាន់នៅពេលនោះ ។ សាក្សីបន្ថែមថា«វង្សម៉ាក្ស-ឡេនីន»ត្រូវបានបង្កើតដោយ អៀង សារី, ទូ សាមុត និង កេង វ៉ាន់សាក់ ។ ទោះបីជាយ៉ាងណាក៏ដោយ លោកមិនបានដឹងច្បាស់អំពីគោលបំណងនៃការបង្កើត«វង្សម៉ាក្ស-ឡេនីន» នេះឡើយ គឺគ្រាន់តែដឹងថា ការងារបឋមនៅក្នុងវង្សនេះគឺត្រូវរៀនសូត្រទ្រឹស្តីម៉ាក្ស-ឡេនីន ដើម្បីត្រៀមខ្លួនឲ្យក្លាយជាជនកុម្មុយនីស្ត ។

បន្ទាប់មកលោក តារាស្មី បន្តសំណួរទាក់ទងនឹងរណសិរ្សរួបរួមជាតិកម្ពុជាដែលត្រូវបានបង្កើតឡើងនៅទីក្រុងប៉េកាំងប្រទេសចិន ។ ឆ្លើយតបនឹងសំណួរនេះ សួង ស៊ីគឿន បញ្ជាក់ថា រណសិរ្សរួប



តំណាងសហព្រះរាជអាជ្ញាជាតិ ចាន់ តារាស្មី

រួមជាតិកម្ពុជាត្រូវបានបង្កើតឡើងដើម្បីរំដោះប្រទេសចេញពីរបបសាធារណរដ្ឋខ្មែររបស់សេនាប្រមុខ លន់ នល់ ដែលជារបបមួយគាំទ្រដោយចក្រពត្តិអាមេរិក ។ រណសិរ្សនេះត្រូវបានគ្រប់គ្រងដោយសម្តេច នរោត្តម សីហនុ ក្នុងឋានៈជាប្រធាន ហើយត្រូវបានបែងចែកជាពីរផ្នែក គឺផ្នែកការិយាល័យនយោបាយ (មាន ជួន មុំ និង ជួន ប្រសិទ្ធ ជាសមាជិក) និងផ្នែកការិយាល័យព័ត៌មានដែលមានរូបលោក(សួង ស៊ីគឿន) ជាប្រធាន ។ ការិយាល័យព័ត៌មានមានតួនាទីរៀបចំបោះផ្សាយព្រឹត្តិបត្រព័ត៌មានបន្ទាប់ពីមានការត្រួតពិនិត្យរបស់ការិយាល័យនយោបាយ និងផ្សព្វផ្សាយទៅអន្តរជាតិអំពីការតស៊ូនៅក្នុងប្រទេស និងសកម្មភាពការទូតព្រឹត្តិបត្រទាំងនេះត្រូវបានបោះផ្សាយរៀងរាល់សប្តាហ៍ ហើយបញ្ជូនទៅគ្រប់ការិយាល័យតំណាងរបស់ "ហ៊ុង" ដែលមានមូលដ្ឋាននៅប្រទេសផ្សេងៗទៀត ដូចជាប្រទេសបារាំងជាដើម ។ ភ្ជាប់គ្នានេះដែរលោក តារាស្មី បានសួរបញ្ជាក់អំពីតួនាទីរបស់ទីភ្នាក់ងារសារព័ត៌មាន

កម្ពុជា(អា.កា.អ៊ី) ដែលមានទីតាំងនៅទីក្រុងប៉េកាំង ។ សាក្សីបញ្ជាក់ថា ទីភ្នាក់ងារនេះមានតួនាទីប្រហាក់ប្រហែលនឹងព្រឹត្តិបត្រព័ត៌មានរបស់"ហ្វុង"ដែរ គឺផ្សព្វផ្សាយការតស៊ូរបស់ប្រជាជនកម្ពុជា និងកងទ័ពរំដោះជាតិកម្ពុជានៅសមរភូមិក្នុងប្រទេស ព្រមទាំងសកម្មភាពការទូតក្នុងការប្រមូលការគាំទ្រពីសកលលោក ដើម្បីតស៊ូប្រឆាំងនឹងរបប លន់ នល់ និងចក្រពត្តិអាមេរិក ។ បន្ទាប់មកតំណាងសហព្រះរាជអាជ្ញាជាតិសួរអំពីសមាសភាពរបស់រណសិរ្សរួបរួមជាតិកម្ពុជានិងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ។ ជាការឆ្លើយតបសាក្សីរៀបរាប់ឈ្មោះ និងតួនាទីរបស់បុគ្គលមួយចំនួនដូចខាងក្រោម៖


អៀង សារី (ទី៦ រាប់ពីស្ដាំទៅឆ្វេង) ធ្វើទស្សនកិច្ចនៅកំពង់ផែ (រូបភាពមជ្ឈមណ្ឌលឯកសារកម្ពុជា)

១) សារិន ឆាក ជាសមាជិកការិយាល័យនយោបាយនៃរណសិរ្សរួបរួមជាតិកម្ពុជា និងជារដ្ឋមន្ត្រីក្រសួងការបរទេសនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ។

២) ហ៊ួត សម្បត្តិ ជាសមាជិកការិយាល័យនយោបាយនៃរណសិរ្សរួបរួមជាតិកម្ពុជា និងជារដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ។

៣) ចាន់ យូរ៉ាន់ ជាសមាជិកការិយាល័យនយោបាយនៃរណសិរ្សរួបរួមជាតិកម្ពុជា និងជារដ្ឋមន្ត្រីក្រសួងអប់រំនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ។

៤) ជា សាន ជាសមាជិកការិយាល័យនយោបាយនៃរណសិរ្សរួបរួមជាតិកម្ពុជា និងជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌នៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ។

៥) គាត ឈន់ ជាសមាជិកបម្រុងរបស់ការិយាល័យនយោបាយនៃរណសិរ្សរួបរួមជាតិកម្ពុជា និងជារដ្ឋមន្ត្រីអមទីស្ដីការនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ។

៦) ជួន ប្រសិទ្ធ ជាសមាជិកបម្រុងរបស់ការិយាល័យនយោបាយនៃរណសិរ្សរួបរួមជាតិកម្ពុជា និងជារដ្ឋមន្ត្រីសម្របសម្រួលការងារតស៊ូនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ។

៧) វ៉ាន់ ពីនី ជាអនុរដ្ឋមន្ត្រីក្រសួងការបរទេសនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ។

៨) កែវ មាស គឺជាអតីតមេដឹកនាំនៃបក្សកុម្មុយនីស្តកម្ពុជា ។

៩) អ៊ីស៊ុប គន្ធី គឺជាភារធារីស្ដីទីរបស់ស្ថានទូតកម្ពុជាប្រចាំប្រទេសអាល់បានី ។

១០) ចៅ សេង ជាសមាជិកការិយាល័យនយោបាយ

នៃរណសិរ្សរួបរួមជាតិកម្ពុជា និងជារដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេសនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ។

១១) ដួង សំអុល ជាសមាជិកការិយាល័យនយោបាយនៃរណសិរ្សរួបរួមជាតិកម្ពុជា និងជារដ្ឋមន្ត្រីសព្វាវុធនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ។

១២) ដួន មុំ ជាសមាជិកការិយាល័យនយោបាយនៃរណសិរ្សរួបរួមជាតិកម្ពុជា និងជារដ្ឋមន្ត្រីហិរញ្ញវត្ថុនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ។

១៣) អ៊ិន សុកាន ជាអ្នកតំណាងនៃរណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិ កម្ពុជាប្រចាំប្រទេសបារាំង ។ សាក្សី សួង ស៊ីគឿន បញ្ជាក់បន្ថែមថា ក្នុងចំណោមបុគ្គលទាំង១៣រូបខាងលើ គឺមានតែ គាត ឈន់ និង ដួន ប្រសិទ្ធ ប៉ុណ្ណោះ ដែលបានធ្វើការ នៅក្រសួងការបរទេស នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

បន្ទាប់ពីបញ្ចប់សំណួរពាក់ព័ន្ធនឹងរណសិរ្សរួបរួមជាតិកម្ពុជា តំណាងសហព្រះរាជអាជ្ញាជាតិបន្តសួរអំពីការកំណត់សត្រូវរបស់បក្សកុម្មុយនីស្តកម្ពុជា ។ លោកបានចោទសួរថា “ *តើគោលមាគ៌ា ឬលក្ខន្តិកៈរបស់បក្សបានកំណត់បុគ្គលប្រភេទណាខ្លះដែលជាសត្រូវរបស់បក្សកុម្មុយនីស្តកម្ពុជា?* ” ។ ឆ្លើយតបសំណួរនេះ សួង ស៊ីគឿន បញ្ជាក់ថា “ *សត្រូវរបស់បក្សកុម្មុយនីស្តកម្ពុជា នៅពេលនោះ គឺចក្រពត្តិអាមេរិក និងបរិវារផ្ទៃក្នុងរបស់វា ។ អាហ្នឹងសត្រូវទីមួយ ។ បន្ទាប់មកគឺថា ពួកម្ចាស់ដីកុំប្រាឌ័រដែលនិយមគាំទ្រសហរដ្ឋអាមេរិក* ” ។ លោកបានបង្ហាញឯកសារកំណត់ហេតុរបស់សាក្សីដោយបានដកស្រង់ខ្លឹមសារ “ *...បក្សតំណាងឲ្យអំណាចដ៏ខ្លាំងក្លា ។ ដូច្នេះ បក្សគឺជាអាទិទេពថ្មីមួយ* ” ។ បន្ទាប់ពីបង្ហាញឯកសារ លោកបានចោទសួរថា “ *តើដោយសារតែបក្សជាអាទិទេពមែនទេដែលថា បក្សមិនអនុគ្រោះចំពោះវត្តមាននៃសាសនាផ្សេងៗ ទៀតនោះ? តើអាចរិះគន់ទៅលើគោលនយោបាយរបស់បក្សបានឬទេ?* ” ។ ឆ្លើយតបចំពោះសំណួរទាំងនេះ សួង ស៊ីគឿន បានបញ្ជាក់ថា តាមទស្សនៈរបស់ជនកុម្មុយនីស្ត សាសនា គឺជាអាភៀនរបស់ប្រជាជន ។ ដូច្នេះ សាសនា ត្រូវបានចាត់ទុកថាជាអាភៀនរបស់ប្រជាជន និងប្រឆាំងបដិវត្តន៍ ។ ចំពោះការរិះគន់គោលនយោបាយរបស់បក្សវិញ សាក្សីបានបញ្ជាក់ថា មិនមាននរណាអាចរិះគន់បានឡើយ ពេលគឺបក្សសម្រេចបែបណា គឺត្រូវធ្វើតាម ។ ម្យ៉ាងវិញទៀតសម្រាប់រូបលោកផ្ទាល់ គឺមិនដែលមានបំណងរិះគន់គោលនយោបាយរបស់បក្សឡើយ ព្រោះខ្លួនចាត់ទុកបក្ស គឺជាអាទិទេពថ្មីមួយ ។ ដូច្នេះបក្សសម្រេចអ្វី គឺត្រូវយល់ស្របទាំងអស់ ។

ជាចុងក្រោយ តំណាងសហព្រះរាជអាជ្ញាជាតិសួរសាក្សីពាក់ព័ន្ធនឹងការអមដំណើរគណៈប្រតិភូ ដែលដឹកនាំដោយ ខៀវ សំផន និង អៀង សារី ទៅធ្វើទស្សនកិច្ចនៅក្រៅប្រទេស ។ សួង ស៊ីគឿន បានបញ្ជាក់ថា នៅឆ្នាំ១៩៧៤ លោកបានអមដំណើរ ខៀវ សំផន និង អៀង សារី ទៅធ្វើទស្សនកិច្ចនៅប្រទេសមួយចំនួនដូចជា ប្រទេសយូហ្គោស្លាវី, រ៉ូម៉ានី, អាល់បានី, អាល់ហ្សេរី, ម៉ូរីតានី និង អេហ្ស៊ីប ។ ដំណើរទស្សនកិច្ចនេះធ្វើឡើងក្នុងគោលបំណងជូនដំណឹងអំពីការតស៊ូរបស់ប្រជាជនកម្ពុជាប្រឆាំងនឹងរបប លន់ នល់ និងដើម្បីប្រមូលការគាំទ្រពីប្រទេសទាំងនោះចំពោះរណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ។ បន្ទាប់មកលោកបានអមដំណើរគណៈប្រតិភូដដែលនេះទៅធ្វើទស្សនកិច្ចនៅតំបន់រំដោះនៅប្រទេសវៀតណាម និងឡាវ ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ លោកបានអមដំណើរ ខៀវ សំផន ជាមួយ អៀង សារី ទៅចូលរួមកិច្ចប្រជុំកំពូលរបស់ប្រទេសមិនចូលបក្សសម្ព័ន្ធនៅប្រទេស ស្រីលង្កា ។

### ២.២) សហព្រះរាជ អាជ្ញាអន្តរជាតិ

ចំពោះសំណួររបស់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិពាក់ព័ន្ធនឹងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ សាក្សីបានបញ្ជាក់ថា មូលហេតុដែលនាំឲ្យមានការជម្លៀសនេះគឺ ទី១) ដើម្បីឲ្យប្រជាជនគេចពីការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិក ទី២) ទីក្រុងនៅពេលនោះកំពុងកើតគ្រោះទុរ្ភិក្ស និងទី៣) ដើម្បីបំបែកបណ្ដាញរបស់ខ្មាំងដែលមាននៅក្នុងទីក្រុងភ្នំពេញ ។ ប៉ុន្តែលោកមិនដឹងថា ផែនការជម្លៀសនេះចេញមកពីមេដឹកនាំខ្មែរក្រហមរូបណាឡើយ ។

គួរកត់សម្គាល់ថា នៅពេលតំណាងសហព្រះរាជអាជ្ញា សួរថា តើសាក្សីដឹងពីគោលបំណងនៃការជម្លៀសនេះដោយរបៀបណា? សាក្សីឆ្លើយទាំងទឹកមុខមិនពេញចិត្តថា “ *ខ្ញុំមិនមែនជាទីងមោងឡើយដែលមិនអាចសន្និដ្ឋានអំពីមូលហេតុទាំងនេះ* ” ។

ភ្លាមនោះ ប្រធានអង្គជំនុំជម្រះបញ្ជាក់សាក្សីថាត្រូវឆ្លើយ សំណួរទាំងឡាយណាដែលភាគីបានសួរ លើកលែងតែចម្លើយ ដែលធ្វើឲ្យដាក់បន្ទុកលើខ្លួនឯងតែប៉ុណ្ណោះ ។ ម្យ៉ាងវិញទៀត



តំណាងសហព្រះរាជអាជ្ញា វ៉ាំងសង់ ដឺវ៉ាល់ ដេស្មាឯល

សាក្សីត្រូវគ្រប់គ្រងអារម្មណ៍ឲ្យបាននៅពេលឆ្លើយសំណួរ ព្រោះ សាក្សីនឹងត្រូវប្រឈមមុខជាមួយសំណួរជាច្រើនរយទៀត ដែល នឹងចោទសួរដោយភាគី ។ បន្ទាប់ពីមានការណែនាំនេះសាក្សីបាន សម្តែងនៅទឹកមុខជាប្រក្រតីឡើងវិញ ហើយបានបញ្ជាក់ថា“ខ្ញុំទើបនឹង បានដឹងថា មានសំណួរចំនួនរាប់រយ ។ ដូច្នេះខ្ញុំសូមអរគុណ ព្រោះ បើខ្ញុំឆ្លើយរបៀប ដែលខ្ញុំបានធ្វើហ្នឹង ខ្ញុំប្រហែលនៅមិនដល់ម៉ោង ពីរផង” ។ ក្រោយមកសាក្សីបញ្ជាក់ថា លោកបានដឹងពីគោល បំណងនៃការជម្លៀសនេះគឺតាមរយៈការផ្សាយតាមវិទ្យុ ។ ពាក់ព័ន្ធ នឹងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនេះដែរ តំណាង សហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំអង្គជំនុំជម្រះដាក់បង្ហាញឯក សារ ដោយលោកបានបញ្ជាក់ថាឯកសារនេះគឺជាប្រវត្តិរូបរបស់ ជួន ប្រសិទ្ធ ដែលសរសេរដោយបុគ្គលនេះផ្ទាល់ ។ សំណើសុំនេះ ក្នុងគោលបំណងឲ្យសាក្សីបញ្ជាក់ថា តើអក្សរនៅក្នុងប្រវត្តិរូបនោះ ពិតជារបស់ ជួន ប្រសិទ្ធ ដែរឬទេ? សំណើសុំនេះត្រូវបានលោក មេធាវី ហ្សាស្តើប៉ៅ ជំទាស់ ដោយផ្តល់សំអាងហេតុថា តំណាង សហព្រះរាជអាជ្ញាបានសួរសំណួរនាំមុខ ពីព្រោះតំណាងសហ ព្រះរាជអាជ្ញាបានបញ្ជាក់រួចមកហើយថា ប្រវត្តិរូបនេះត្រូវបាន សរសេរដោយ ជួន ប្រសិទ្ធ មុនពេលសួរឲ្យសាក្សីបញ្ជាក់ ។ ម្យ៉ាង វិញទៀត តំណាងសហព្រះរាជអាជ្ញាមិនអាចសួរឲ្យសាក្សី បញ្ជាក់ ពីយថាភាពនៃឯកសារឡើយ ។ សេចក្តីជំទាស់នេះត្រូវបានអង្គ ជំនុំជម្រះទទួលយក ពោលគឺ មិនអនុញ្ញាតឲ្យដាក់បង្ហាញប្រវត្តិរូប របស់ ជួន ប្រសិទ្ធ ឲ្យសាក្សីពិនិត្យ ។ ប៉ុន្តែអង្គជំនុំជម្រះអនុញ្ញាតឲ្យ តំណាងសហព្រះរាជអាជ្ញាបន្តសួរសំណួរទូទៅពាក់ព័ន្ធនឹងប្រវត្តិរូប នេះ ។ សំណួរបន្ទាប់របស់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ គឺពាក់ព័ន្ធនឹងតួនាទីរបស់ សួង ស៊ីគឿន នៅក្រសួងការបរទេស ចន្លោះឆ្នាំ១៩៧៥-១៩៧៩ ។ សួង ស៊ីគឿន បានរៀបរាប់ថា ពេលមកដល់ប្រទេសកម្ពុជាភ្លាម អៀង សារី បានចាត់តាំង គាត ឈន់, រស់ សារិន និងលោកផ្ទាល់ (សួង ស៊ីគឿន) ឲ្យជួយរៀបចំ និងធ្វើការនៅក្រសួងការបរទេស ។ សួង ស៊ីគឿន ត្រូវបានចាត់ តាំងឲ្យទទួលខុសត្រូវផ្នែកកិច្ចការអាស៊ីអាគ្នេយ៍និងអឺរ៉ុប បន្ទាប់មក ជាអនុប្រធានផ្នែកពិធីការ និងជាសមាជិកផ្នែកនយោបាយនៅ ក្នុងក្រសួងការបរទេស និងចុងក្រោយឲ្យធ្វើជាប្រធានផ្នែកព័ត៌មាន និងឃោសនាការ និងជាអ្នកនាំពាក្យរបស់ក្រសួងការបរទេស ។ ក្នុងក្របខណ្ឌការងារ សួង ស៊ីគឿន មានតួនាទីតាមដានព័ត៌មាន អន្តរជាតិ ដែលផ្សាយជាភាសាចិន បារាំង អង់គ្លេស និងវៀត ណាម ហើយត្រូវរាយការណ៍ជាប្រចាំទៅឲ្យ អៀង សារី ។ សាក្សី បានបញ្ជាក់ថា ក្នុងអំឡុងពេលនោះ លោកបានស្តាប់ការផ្សាយ របស់វិទ្យុ ប៊ី, ប៊ី, ស៊ី (B.B.C) ស៊ីវិទ្យុបារាំងអន្តរជាតិ និងវិទ្យុ សម្លេងសហរដ្ឋអាមេរិកដែលបានផ្សាយពីអំពើខ្រិដ្ឋរបស់របប កម្ពុជាប្រជាធិបតេយ្យ ។ ទាក់ទងនឹងភារកិច្ចនៅក្រសួងការបរទេស លោក សួង ស៊ីគឿន បញ្ជាក់ថា មានកិច្ចប្រជុំជាច្រើនប្រភេទ ដែលត្រូវបានធ្វើនៅក្រសួងនេះរួមមានការប្រជុំតាមផ្នែកនីមួយៗ កិច្ចប្រជុំធ្វើជីវៈទស្សន៍ កិច្ចប្រជុំដើម្បីរៀនសូត្រ ការធ្វើសន្និបាត ក្រសួង...។ បន្ថែមពីលើនេះ មានកិច្ចប្រជុំរៀនសូត្រនយោបាយ រយៈពេលវែង ដែលតម្រូវឲ្យបុគ្គលិកធ្វើការក្នុងក្រសួងការ បរទេសទាំងអស់ចូលរួមក្រោមអធិបតីរបស់ អៀង សារី ។ អៀង

សារី បានធ្វើខទ្ទេសនាមអំពីស្ថានភាពនយោបាយក្នុង និងក្រៅប្រទេសអំពីខ្មាំងរបស់បក្ស ហើយបានចែកឯកសារនយោបាយឲ្យអ្នកចូលរួម ។ សួង ស៊ីគឿន បញ្ជាក់ថា “ខ្មាំងមានច្រើនប្រភេទ គឺខ្មាំងក្នុងប្រទេស ខ្មាំងក្រៅប្រទេស និងខ្មាំងកុំប្រាឌ័រផ្ទៃក្នុងរបស់យើងម្នាក់ៗ ។ ខ្មាំងក្រៅប្រទេស អាហ្នឹងយើងដឹងហើយក្នុងពេលនោះមានអ្នកណាខ្លះ? គឺមានចក្រពត្តិអាមេរិក ចាប់ពីឆ្នាំ១៩៧០ មក ។ ចុងឆ្នាំ១៩៧៧ និង១៩៧៨ គឺថាមានប្រទេសវៀតណាមអាហ្នឹងជាខ្មាំងរួមហើយ មានភ្នាក់ងារចារកម្មផ្សេងៗរបស់បស្ចិមប្រទេសរបស់ គួង មីងតាំង ។ ចំណែកខ្មាំងក្នុងប្រទេស គឺមានភ្នាក់ងាររបស់មហាអំណាចទាំងនោះ ជាពិសេសគឺថា ខ្មាំងដែលបង្កប់ស៊ីរូងក្នុងជួរបក្ស ក្នុងជួរកងទ័ព និងក្នុងចំណោមប្រជាជន ។ ក៏ប៉ុន្តែឯកសារពេលនោះសង្កត់ធ្ងន់ទៅលើខ្មាំងកុំប្រាឌ័រផ្ទៃក្នុងរបស់យើងដែលជាទិសដៅសំខាន់បំផុតនៃបដិវត្តន៍សង្គមនិយម ។ ខ្មាំងកុំប្រាឌ័រផ្ទៃក្នុង គឺជាកេរ្តិ៍ដំណែលសង្គមចាស់ កេរ្តិ៍ដំណែលវណ្ណៈជិះជាន់ដែលមានជាប់នៅក្នុងខ្លួនយើងដូចជា ការលោភលន់បុណ្យស័ក្តិ ការរស់នៅដោយប្លែកពីប្រជាជន ការរស់នៅចាយវាយហួសហេតុលើសពីសេចក្តីត្រូវការ” ។ សាក្សីបានបន្ថែមថា អ្នកចូលរួមប្រជុំនៅពេលនោះ គឺត្រូវរាយការណ៍អំពីការងាររបស់ខ្លួនជូនអង្គប្រជុំ ហើយទទួលផែនការសម្រាប់ធ្វើបន្ត ។

ចុងក្រោយ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិបានចោទសំណួរទាក់ទងនឹងការចាប់ខ្លួនកម្មាភិបាលក្នុងក្រសួងការបរទេស ។ សាក្សីបញ្ជាក់ថា នៅពេលដែលកម្មាភិបាល ឬបុគ្គលិកណាម្នាក់ត្រូវបានឆ្លើយដាក់៣ដង (៣ឯកសារ) ថាជាសមាសភាពមិនល្អ បុគ្គលនោះនឹងត្រូវបានចាប់ខ្លួន ។ ក្រោយមក ចំនួនឯកសារត្រូវបានតម្លើងដល់៥ឯកសារ ពោលគឺទាល់តែមានការឆ្លើយដាក់ ៥ឯកសារ បុគ្គលនោះនឹងត្រូវចាប់ខ្លួន ។

### ៣) ការសួរសាក្សីដោយមេធាវីដើមបណ្តឹងរដ្ឋប្បវេណី

បន្ទាប់ពីតំណាងសហព្រះរាជអាជ្ញាបានបញ្ចប់សំណួររបស់ខ្លួន អង្គជំនុំជម្រះបានប្រគល់វេទិកាជូន ក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីដើម្បីសាកសួរបន្ត ។ មុនពេលសួរសាក្សី មេធាវី ម៉ុច សុវណ្ណារី ជាមេធាវីជាតិតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី បានសម្តែងនូវការគួរសមចំពោះសាក្សី ដោយបានថ្លែងថា “ក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំសូមអរគុណចំពោះការខិតខំប្រឹងប្រែងរបស់លោកដែលបានចំណាយពេលវេលាទាំងកម្លាំងកាយ និងកម្លាំងចិត្តរបស់លោកក្នុងការផ្តល់សក្ខីកម្មដល់តុលាការ ដើម្បីជាប្រយោជន៍នៃការស្វែងរកយុត្តិធម៌ នាំមកនូវការផ្សះផ្សាជាតិនៅក្នុងចំណោមប្រជាជនខ្មែរ រកយុត្តិធម៌ដែលជាប្រយោជន៍ដល់អ្នកជំនាន់ក្រោយ” ។ ក្នុងការសួរសាក្សីលោកស្រីមេធាវីបានចោទសំណួរមួយចំនួនទាក់ទងនឹងកិច្ចពិភាក្សាក្នុងការផ្ទេរទីក្រុង


មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ម៉ុច សុវណ្ណារី

ភ្នំពេញឲ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងការទេស និងការប៉ុនប៉ងចាប់បុគ្គលមួយចំនួននៅក្នុងក្រសួងការបរទេស ។ ក្នុងការចោទសួរលើបញ្ហាទាំងនេះ លោកស្រីមេធាវីផ្តោតសំខាន់លើសិទ្ធិអំណាចរបស់ អៀង សារី ក្នុងការជំទាស់នៅពេលកិច្ចពិភាក្សាទាំងនេះ ។ មុនពេលចោទសួរ លោកស្រីមេធាវីបានដាក់បង្ហាញឯកសារកំណត់ហេតុស្តាប់ចម្លើយដែលសាក្សីបានផ្តល់ជូនសហចៅក្រមស៊ើបអង្កេត ។ លោកស្រីបានដកស្រង់ឃ្លាមួយចំនួនដែលមានខ្លឹមសារថា “...មានការពិភាក្សាផងដែរក្នុងការផ្ទេរការគ្រប់គ្រងទីក្រុងភ្នំពេញទៅឲ្យក្រសួងការបរទេស ប៉ុន្តែ លោក អៀង សារី បានជំទាស់នឹងគំនិតនេះ” ។ បន្ទាប់មកលោកស្រីមេធាវីបានលើក

ជាសំណួរថា តើការជំទាស់របស់ អៀង សារី មានប្រសិទ្ធភាពដែរឬទេ? ឆ្លើយតបនឹងសំណួរនេះ សាក្សីបញ្ជាក់ថា សេចក្ដីជំទាស់របស់ អៀង សារី មានប្រសិទ្ធភាព ព្រោះក្រោយមកទីក្រុងភ្នំពេញមិនត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងការបរទេសឡើយ ។ លោកបានបន្ថែមថា សេចក្ដីជំទាស់របស់ អៀង សារី ចំពោះការប៉ុនប៉ងចាប់ខ្លួន ដួន ប្រសិទ្ធ និង គាត ឈន់ ក៏មានប្រសិទ្ធភាពដែរ ព្រោះថា បន្ទាប់ពីមានការជំទាស់របស់ អៀង សារី អ្នកទាំងពីររូប



មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ហ្វែឌីណង់ ហ្សារាមិនហ្សេប៉ា

នេះមិនត្រូវបានចាប់ខ្លួនឡើយ ។ លោក សួង ស៊ីគឿន បានបន្ថែមថា ស្ថានទូតនៅក្រៅប្រទេស និងអាកាសចរណ៍ស៊ីវិលត្រូវបានគ្រប់គ្រងដោយក្រសួងការបរទេស ។ គួរបញ្ជាក់ថា តាមការដកស្រង់របស់លោកស្រីមេធាវី សាក្សីធ្លាប់បានផ្ដល់សក្ខីកម្មជូនសហចៅក្រមស៊ើបអង្កេតថា បញ្ញាជន និង មន្ត្រីទូតដែលធ្វើមាតុភូមិនិវត្តនៅក្នុងឆ្នាំ ១៩៧៥ ត្រូវធ្វើដំណើរដោយត្រូវឆ្លងកាត់ស្ថានទូតខ្មែរប្រចាំនៅទីក្រុងប៉េកាំង មុនចូលមកដល់ប្រទេសកម្ពុជា ។ ចុងក្រោយលោកស្រីមេធាវីបានដាក់ដកស្រង់ឯកសារដែលសាក្សីបានផ្ដល់សក្ខីកម្មជូនសហចៅក្រមស៊ើបអង្កេតថា “ខ្ញុំជាខ្មែរក្រហមរហូតដល់ឆ្នាំ១៩៧៥ ដោយសារតែខ្ញុំដឹងថា ខ្មែរក្រហមនាពេលនោះ មិនខុសប៉ុន្តែពួកគេបានក្បត់នឹងឧត្ដមគតិនេះចាប់ពីឆ្នាំ១៩៧៥មក” ។ ឆ្លើយតបនឹងឯកសារនេះ សាក្សីមិនបានបញ្ជាក់ថា អំពើអ្វីខ្លះដែលបានកើតឡើងក្រោយឆ្នាំ១៩៧៥ ផ្ទុយនឹងឧត្ដមគតិរបស់ខ្មែរក្រហមដែលប្រកាន់យកកាលពីមុននោះទេ ដោយលោកគ្រាន់តែបញ្ជាក់ថា ឯកសារនេះ គឺជាទស្សនៈរបស់លោកដែលយល់ឃើញក្រោយពីរបបខ្មែរក្រហមបានដួលរលំ ។

ដោយឡែក សំណួររបស់លោក ហ្វែឌីណង់ ហ្សារាមិនហ្សេប៉ា ជាមេធាវីអន្តរជាតិតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណីបានផ្ដោតសំខាន់អំពីតួនាទីរបស់ជនជាប់ចោទ អៀង សារី ក្នុងការអំពាវនាវឲ្យបញ្ញាជន ដែលរស់នៅបរទេសវិលចូលស្រុកវិញ ។ លោកមេធាវីបានសួរថា “តើអ្នកណាជាអ្នកទទួលបន្ទុកក្នុងការកោះហៅបញ្ញាជននៅបរទេសឲ្យត្រលប់មកប្រទេសកម្ពុជាវិញ? តើ អៀង សារី ជាអ្នកដែលទៅបរទេស ដើម្បីបញ្ចុះបញ្ចូលបញ្ញាជននិស្សិត នៅបរទេសឲ្យពួកគេទាំងអស់នោះត្រលប់ចូលក្នុងប្រទេសកម្ពុជាវិញដែរឬទេ?” ។ ឆ្លើយតបនឹងសំណួរទាំងនេះ សួង ស៊ីគឿនបានបញ្ជាក់ថាក្នុងការប្រមូលបញ្ញាជន និស្សិតនៅបរទេសឲ្យត្រលប់មកប្រទេសកម្ពុជាវិញ គឺត្រូវបានធ្វើឡើងដោយអង្គការតំណាងរបស់រណសិរ្សរួបរួមជាតិប្រចាំនៅប្រទេសនីមួយៗ ដែលបញ្ញាជនទាំងនោះរស់នៅ ។ សាក្សីបានផ្ដល់ឧទាហរណ៍ថា បញ្ញាជនដែលរស់នៅប្រទេសបារាំង គឺអង្គការតំណាងរណសិរ្សរួបរួមជាតិកម្ពុជាប្រចាំនៅប្រទេសបារាំង ជាអ្នកអំពាវនាវ និងប្រមូលឲ្យត្រលប់មកស្រុកខ្មែរ ។ អៀង សារី គឺជាប្រធានទី១ នៃសហភាពនិស្សិតខ្មែរ និងជាអ្នកស្ថាបនាដើមដំបូងនៃបក្ស “វង្សម៉ាក-ឡេនីន” ប្រចាំប្រទេសបារាំង ។ អៀង សារី មានតួនាទីអំពាវនាវឲ្យបញ្ញាជនដែលរស់នៅបរទេសឲ្យត្រលប់មកស្រុកខ្មែរវិញ ។ សាក្សី បញ្ជាក់បន្ថែមថា ស្របពេលជាមួយគ្នានោះបញ្ញាជន និងនិស្សិតដែលរស់នៅបរទេសក៏មានបំណងចូលមកស្រុកខ្មែរវិញ ដើម្បីចូលរួមជួយកសាងជាតិ ព្រោះពេលនោះរណសិរ្សរួបរួមជាតិកម្ពុជា គឺដឹកនាំដោយព្រះបាទសម្ដេចព្រះនរោត្ដម សីហនុ ។ ម្យ៉ាងវិញទៀត នៅក្នុងប្រទេសគឺមាន ខៀវ សំផន, ហ៊ូ យន់ និង ហ៊ូ នឹម ជាអ្នកតស៊ូ ។ គួរបញ្ជាក់ថា ជាញឹកញាប់ សួង ស៊ីគឿន បានសម្ដែងនូវការគោរពចំពោះបុគ្គលទាំងបីរូបនេះ ដោយលោកបានបញ្ជាក់ថា “...ព្រះពុទ្ធ គឺ ខៀវ សំផន ។ ព្រះធម៌ គឺសំដៅទៅលើ ហ៊ូ យន់ និង

ព្រះសង្ឃ គឺសំដៅទៅលើ ហ៊ូ នឹម ដែលជាបញ្ញាជនស្នេហាជាតិស្អាតស្អំ ។ បន្ទាប់មកលោក ហ្វែឌីណង់ បានចូលដល់ប្រធានបទថ្មីពាក់ព័ន្ធនឹងសេចក្តីថ្លែងការណ៍របស់សាក្សីចំពោះ សុន សេន និង នី កន(ប្អូនប្រុសរបស់ សុន សេន) ។ លោកមេធាវីបានបង្ហាញឯកសារ ដែលក្នុងនោះ សួង ស៊ីគឿន បានចោទប្រកាន់ថា សុន សេន និង នី កន គឺជាឃាតករដ៏សាហាវឃោរឃៅ ដែលបានសម្លាប់ប្រជាជនខ្មែរ ។ ខ្លឹមសារនេះត្រូវបាន សួង ស៊ីគឿន បដិសេធចោលភ្លាមៗ ដោយលោកបញ្ជាក់ថា ជារឿងមិនពិតដែលថាលោកបានចោទប្រកាន់អ្នកទាំងពីររូបនេះ ព្រោះ នី កន គឺជាមិត្តភក្តិបានធ្វើការនៅក្រសួងការបរទេសជាមួយគ្នា ហើយលោកផ្ទាល់(សួង ស៊ីគឿន) ក៏ធ្លាប់ត្រូវបានចោទថា ជាខ្សែបក្សពួករបស់ សុន សេន ដែរ ។ ជាពិសេស លោកនឹងមិនអាចចោទប្រកាន់ នី កន ថាជាឃាតករឡើយ ។ ចុងក្រោយសាក្សីស្នើសុំមើលឯកសារដែលសរសេរដោយលោកផ្ទាល់ពាក់ព័ន្ធនឹងបញ្ហានេះ ។ បន្ទាប់ពីបានពិនិត្យឯកសារ សាក្សីបញ្ជាក់ថា ឯកសារនោះមិនមែនជារបស់លោកទេ ព្រោះជាអក្សរពុម្ពមិនមែនជាអក្សរដៃរបស់លោកឡើយ ។ ចំណុចនេះត្រូវបានលោក ហ្វែឌីណង់ និង តំណាងសហព្រះរាជអាជ្ញាបំភ្លឺថា ឯកសារនេះ គឺជាអត្ថបទការសែតដែលចុះផ្សាយដោយការសែតភ្នំពេញប៉ុស្តិ៍នៅថ្ងៃទី១៥ - ២៨ ខែវិច្ឆិកា ឆ្នាំ១៩៩៦ ហើយត្រូវបានអង្គជំនុំជម្រះទទួលស្គាល់ជាឯកសារផ្លូវការក្នុងសំណុំរឿងរួចហើយ ។ តំណាងសហព្រះរាជអាជ្ញាផ្តល់យោបល់បន្ថែមថា ប្រសិនបើមានបំណងស្វែងរកឯកសារគប្បីសួរទៅកាសែតភ្នំពេញប៉ុស្តិ៍ ។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះបានសម្រេចឲ្យមេធាវីប្តូរសំណួរថ្មី ពោលគឺសាក្សីមិនចាំបាច់ឆ្លើយតបនឹងសំណួរនេះទេ ។

សំណួរមួយចំនួនទៀតរបស់លោកមេធាវី ហ្វែឌីណង់ គឺពាក់ព័ន្ធនឹងការបង្ហាត់បង្រៀនកូនកម្មាភិបាលនៅក្រសួងការបរទេស ។ លោកបានចោទសួរថា តើសាក្សីដែលក្នុងឋានៈជាឪពុកម្តាយម្នាក់អាចទទួលយកបានដែរឬទេនៅពេលដែលកូនត្រូវបានបំបែកចេញពីការគ្រប់គ្រងរបស់ខ្លួន? តើការបង្រៀនកូនកម្មាភិបាលនៅក្រសួងការបរទេស គឺក្នុងគោលបំណងបញ្ចូលមនោគមវិជ្ជាឲ្យដើរតាមមាគ៌ារបស់បក្សកុម្មុយនីស្តកម្ពុជា? ឆ្លើយតបនឹងសំណួរទាំងនេះសាក្សីបានបញ្ជាក់ថា ចំពោះការបំបែកកុមារឲ្យទៅរស់នៅអង្គភាពផ្សេងពីឪពុកម្តាយ គឺមិនមែនធ្វើនៅតែក្រសួងការបរទេសប៉ុណ្ណោះទេ គឺធ្វើឡើងទូទាំងប្រទេស ។ ដូច្នេះលោកមិនមានការជំទាស់ឡើយ ។ ចំពោះការបង្ហាត់បង្រៀនដល់កូនកម្មាភិបាលទាំងនោះលោកមិនដឹងពីគោលបំណងរបស់បក្សឡើយ ។ ប៉ុន្តែទោះបីបក្សបង្រៀនឲ្យប្រកាន់យកមាគ៌ារបស់បក្ស ក៏លោកមិនមានការជំទាស់ដែរ ព្រោះលោកក៏បានសម្រេចប្រកាន់យកមាគ៌ាទាំងនោះដែរ ។ ជាចុងក្រោយលោក ហ្វែឌីណង់ មានបំណងសួរសាក្សីអំពីអង្គហេតុទាក់ទងនឹងការបញ្ចោកផ្ទៃខ្មែរក្រហមក្នុងខែមិថុនា ឆ្នាំ ១៩៩៨ ។ ប៉ុន្តែត្រូវបានមេធាវីអន្តរជាតិការពារក្តីជនជាប់ចោទខៀវ សំផន ជំទាស់ដោយផ្តល់សំអាងហេតុថា អង្គហេតុដែលកើតក្នុងរយៈពេលនេះគឺមិនស្ថិតក្នុងវិសាលភាពដែលត្រូវជំនុំជម្រះឡើយ ។ លោក ហ្វែឌីណង់ បានឆ្លើយតបដោយសង្ខេបថា លោកនៅសល់ពេល ៣០ នាទី ហើយសំណួរដែលនៅសល់ គឺពាក់ព័ន្ធនឹងអង្គហេតុទាំងនេះ ។ ដូច្នេះលោកចង់ប្រើពេលនេះដើម្បីសួរសំណួរដែលនៅសល់ ហើយប្រសិនបើអង្គជំនុំជម្រះមិនអនុញ្ញាតនោះលោកនឹងបញ្ចប់ការសួរដេញដោលសាក្សី សួង ស៊ីគឿន ។ បន្ទាប់ពីមានការបញ្ជាក់ដូច្នេះ ប្រធានអង្គជំនុំជម្រះបានសម្រេចបញ្ឈប់ និងផ្ទេរវេទិកាជូនចៅក្រមជំនុំជម្រះ ផ្សេងៗទៀតដើម្បីសួរសាក្សី ។

## ៤) ការសួរសាក្សីដោយចៅក្រម ហ្សង់ម៉ាក ឡាវើញ

បន្ទាប់ពីទទួលបានការអនុញ្ញាតពីប្រធានអង្គជំនុំជម្រះ លោកចៅក្រម ហ្សង់ម៉ាក ឡាវើញ បានចោទសំណួរមួយចំនួនទាក់ទងនឹងមាគ៌ានយោបាយរបស់រណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ដែលត្រូវបានបង្កើតឡើងបន្ទាប់ពីមានរដ្ឋប្រហារឆ្នាំ១៩៧០ ។ ឆ្លើយតបនឹងសំណួរទាំងនេះ សួង ស៊ីគឿន បានបញ្ជាក់ថា រណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាដែលមានសម្តេចព្រះនរោត្តម សីហនុ ជាព្រះប្រធាន គឺមានមានគោលនយោបាយច្បាស់លាស់ គឺរំដោះប្រទេសចេញពីរបបសាធារណៈរដ្ឋ លន់ នល់ និងការអន្តរាគមរបស់ចក្រពត្តិអាមេរិក ហើយត្រូវប្រកាន់យករបបសង្គមនិយម ។ សាក្សីបានបន្ថែមថា ក្នុងឆ្នាំ១៩៧៣ អៀង សារី ក្នុងឋានៈជាអ្នកតំណាងឲ្យរណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាបានប្រកាសមិនសម្របសម្រួលជាមួយរបប លន់ នល់ ដាច់ខាត ទោះបីពេលនោះមានការជំរុញឲ្យមាន

ការបរចាពីប្រទេសវៀតណាម និង សហរដ្ឋអាមេរិកក៏ដោយ ។

បន្ទាប់មកលោកចៅក្រមសួរបន្ថែមអំពីតួនាទីរបស់ សួង ស៊ីគឿន នៅក្នុងរណសិរ្សរួបរួមជាតិកម្ពុជាប្រចាំទីក្រុងប៉េកាំង ។ សាក្សីបញ្ជាក់ថា នៅពេលធ្វើការក្នុងការិយាល័យព័ត៌មាន និង ឃោសនាការរបស់រណសិរ្សរួបរួមជាតិកម្ពុជា លោកបានទទួលព័ត៌មានពីប្រភពសំខាន់បី គឺទីភ្នាក់ងារសារព័ត៌មានបារាំង អា.អេហ្វ.ប៉េ (AFP) , ទីភ្នាក់ងារសារព័ត៌មានចិនស៊ីនហួរ និងទីភ្នាក់ងារសារព័ត៌មានវៀត ណាម ។ ចំពោះព័ត៌មានទាក់ទងនឹងការតស៊ូ និងសមរភូមិនៅក្នុងប្រទេស គឺទទួលបានតាមរយៈវិទ្យុសម្លេងរណសិរ្សរួបរួមជាតិកម្ពុជាប្រចាំទីក្រុងហាណូយប្រទេសវៀតណាម ។ ប៉ុន្តែសារព័ត៌មានទាំងនេះ មិនដែលផ្សាយពីការជម្លៀសប្រជាជនចេញពីតំបន់ដែលបក្សកុម្មុយនីស្តកម្ពុជារំដោះបានឡើយ ។

ចុងក្រោយលោក ហ្សង់ម៉ាក ដាក់បង្ហាញឯកសារស្តីពី “ការអនុវត្តន៍នយោបាយបង្រួបបង្រួមបក្ស” និងបានដកស្រង់ខ្លឹមសារជាច្រើនដើម្បីសួរដេញដោលសាក្សី ។ សម្រង់ទី១គឺជាសំណួរចម្លើយដែលមានខ្លឹមសារ ៖

> “ពាក់ព័ន្ធទៅខាងក្រៅតើមានអ្វីផ្លាស់ប្តូរ? ចម្លើយ : នៅខាងក្រៅប្រទេសមានការផ្លាស់ប្តូរជាច្រើនដែលមានចរិតលក្ខណៈដូចតទៅ៖ ទី១) រណសិរ្សខាងក្រៅត្រូវចូលមកក្នុងប្រទេសគ្មាននៅក្រៅទៀតទេ ។ ពោលគឺយើងបានបញ្ចប់អង្គការដឹកនាំក្រៅប្រទេសនេះបានដោយស្រួល និងដោយគ្មានឥទ្ធិពលអាក្រក់ទៅលើសកលលោកទេ ។ ផ្ទុយទៅវិញឥទ្ធិពលនៅក្នុងពិភពលោកនេះ គឺមានភាពខ្លាំងក្លា ។ ឥទ្ធិពលយើង គឺថាត្រូវបានបង្កើនថែមទៀត ។ សកលលោកមិននឹកស្មានថាយ៉ាងនេះទេ ។ ទី២) យកមកក្នុងប្រទេស ហើយយើងក្តាប់នៅក្នុងដៃបានទាំងអស់ទៀតតាំងពីប៉ែន នុត រហូតដល់ថ្នាក់ក្រោម ។ កម្លាំងរណសិរ្សក្រៅប្រទេសនេះមិនទាន់អស់ទេ គឺចេះតែមក ។ សីហនុក៏យើងក្តាប់បានដោយគាត់គ្មានអ្វីទាំងអស់ ទាំងសេដ្ឋកិច្ចទាំងអំណាច ។ ដូច្នេះត្រូវរណបយើងទាំងស្រុង ទាំងសម្ភារៈ ទាំងនយោបាយ ។ យើងហ៊ានថា បើចេញពីយើងគាត់ត្រូវស្លាប់ ។ បើប្រៀបធៀបគាត់ នៅមានឥទ្ធិពលជាងអ្នកដទៃទៀត ។ ដល់ឥឡូវ យើងក្តាប់គាត់បានច្រើនជាងមុន ដោយយើងឈ្នះខ្លាំង ។ យើងមានអ្វីៗទាំងអស់ អ្វីៗនៅលើយើងរហូតដល់វាំងក៏ជារបស់យើង ។ ប៉ុន្តែយើងដំណើរការជាមួយគាត់បានស្រួល ។ បច្ចុប្បន្នគាត់ឃើញថា គាត់នៅជាមួយយើងបាន បើបានប៉ុណ្ណឹងគាត់ពេញចិត្តហើយ ។ ឲ្យតែគាត់បាននៅក្នុងប្រទេសខ្លះទៅក្រៅប្រទេសខ្លះ ។ នេះជាសភាពការណ៍ដែលពន្យារពេលឲ្យយើងពង្រឹង និងពង្រីកកម្លាំងយើងបាន ។ បើថ្ងៃក្រោយគាត់ប្រែប្រួលយើងប្រដូចគាត់បានទៅក្រម” គឺជ្រុះឯង គ្មាននរណាធ្វើអីទេដោយគ្មានការឈឺចាប់ មិនមែនរបួស ឬដំបៅទេយើងគ្មានការព្រួយបារម្ភទេ មានតែចំណេញឲ្យយើងជាអតិបរិមា ។ ដូច្នេះធ្វើរណសិរ្សជាមួយពួកនេះគ្មានអ្វីជាការលំបាកទេចាប់ពី ប៉ែន នុត មក ។ ឯជាមួយ សីហនុ ត្រូវមាននយោបាយបន្តិចប៉ុន្តែមិនលំបាកទេ» ។

បន្ទាប់ពីបញ្ចប់ការដកស្រង់ លោកចៅក្រមបានសួរបញ្ជាក់សាក្សីអំពីឯកសារមុនពេលចូលសំណួរផ្សេងៗ ។ សួង ស៊ីគឿន បញ្ជាក់ថា លោកមិនដែលស្គាល់ឯកសារនេះមុនទេ ។ ប៉ុន្តែខ្លឹមសារដែលត្រូវបានដកស្រង់មកនេះ គឺស្របគ្នានឹងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ លោកចៅក្រមបានអានសម្រង់ទី២ចេញពីឯកសារនេះ ដែលមានខ្លឹមសារថា “...យើងត្រូវប្រមូលបញ្ញាជនដើម្បីកុំឲ្យពួកគេនៅបរទេស គឺធ្វើឲ្យយើងបាត់បង់ខាងនយោបាយប្រសិនបើយើងមិនប្រមូលទេ ព្រោះពួកអាមេរិកអាចនឹងប្រមូលយកដែលអាចធ្វើឲ្យខាតនយោបាយ ។ កម្លាំងនេះគឺជាកម្លាំងបន្ទាប់បន្សំទេ ក៏ប៉ុន្តែយើងត្រូវហ៊ឹកហ៊ឺនពួកនេះដើម្បីកសាងពួកគេនៅក្នុងសង្គមថ្មីនៅក្នុងចលនាថ្មី» ។ បន្ទាប់ពីបញ្ចប់ការដកស្រង់ លោកចៅក្រមបានចោទសំណួរថា តើបក្សចាត់វិធានការដូចម្តេចចំពោះបញ្ញាជនដែលមកពីក្រៅប្រទេស? ឆ្លើយតបនឹងសំណួរនេះ សាក្សីបញ្ជាក់ថា បញ្ញាជនទាំងនោះត្រូវឆ្លងកាត់ការដាក់ឲ្យធ្វើពលកម្មដើម្បីជាការលត់ដំ ។ បន្ថែមលើនេះត្រូវបានទទួល

ការអប់រំបំពាក់បំប៉នខាងផ្នែកនយោបាយ និងសតិអារម្មណ៍ ។

បន្ទាប់ពីបញ្ចប់ការសួរដេញដោលលើឯកសារស្តីពី "ការអនុវត្តនយោបាយបន្ស្រួបបន្ស្រួមបក្ស" លោក ហ្សង់ម៉ាក់ បានសួរសាក្សីពាក់ព័ន្ធនឹងការធ្វើអត្តឃាតរបស់កម្មាភិបាលខ្មែរក្រហមម្នាក់ដែលធ្វើ ការនៅក្រសួងការបរទេស ។ សាក្សីបញ្ជាក់ថា កម្មាភិបាលដែលបានធ្វើអត្តឃាតនោះ គឺជាជនជាតិដើមភាគតិច(ជនជាតិចារ៉ាយ) ។ កម្មាភិបាលម្នាក់នេះបានធ្វើអត្តឃាតខ្លួនឯង បន្ទាប់ពីខ្លួនបានទទួលរងការ ទិតៀនយ៉ាងខ្លាំងនៅក្នុងកិច្ចប្រជុំមួយដែលមានការចូលរួមដោយ អៀង សារី, សូ ហុង, ភី ភួន(ចៀម) , សូ សែ និងរូបលោកផ្ទាល់(សាក្សី) ។ កម្មាភិបាលខ្មែរក្រហមនោះត្រូវបានទិទៀន ដោយសារពីមុន ធ្លាប់មានភាពជិតស្និតជាមួយ កុយ ធួន ដែលបក្សចោទថាជាជនក្បត់ និងត្រូវបានសម្លាប់ចោល ។ សំណួរចុងក្រោយរបស់លោកចៅក្រម ហ្សង់ម៉ាក ឡាវ៉ែញ គឺពាក់ព័ន្ធនឹងសំណើសុំផ្តល់ជំនួយជាហិរញ្ញវត្ថុ និងស្បៀងអាហារពីបណ្តាប្រទេសអង្គការ និងសហគមន៍អន្តរជាតិដល់ប្រទេសកម្ពុជានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ពាក់ព័ន្ធនឹងបញ្ហានេះ សាក្សីបញ្ជាក់ថា នៅឆ្នាំ១៩៧៥ អង្គការផលិតប្រេងកាត "អូប៉ិច" បានស្នើសុំផ្តល់ជំនួយដល់ប្រទេសកម្ពុជាចំនួនប្រាំលានដុល្លារដោយគ្មានសំណង ប៉ុន្តែជំនួយនេះត្រូវបាន ប៉ុល ពត បដិសេធមិនទទួលយក ។

## ៥) ការសួរសាក្សីដោយមេធាវីការពារក្តីទាំងបីក្រុម

បន្ទាប់ពីបញ្ចប់ការសួរដេញដោលរបស់លោកចៅក្រម ហ្សង់ម៉ាក ឡាវ៉ែញ អង្គជំនុំជម្រះបានប្រគល់វេទិកាជូនមេធាវីការពារក្តីជនជាប់ចោទទាំងបីក្រុម ដោយចាប់ផ្តើមពីមេធាវីជនជាប់ចោទ ខៀវ សំផន បន្ទាប់មកមេធាវីជនជាប់ចោទ នួន ជា និងចុងក្រោយមេធាវីជនជាប់ចោទ អៀង សារី ។

### ៥.១) ក្រុមមេធាវីការពារក្តី ខៀវ សំផន

ក្នុងការសួរដេញដោលសាក្សីដោយក្រុមមេធាវីការពារក្តីជនជាប់ចោទ ខៀវ សំផន បានចោទសំណួរជាច្រើនទាក់ទងនឹងរណសិរ្សរួបរួមជាតិកម្ពុជា, ការប្រមូលកម្លាំងបញ្ញាជនដើម្បីចូលរួមធ្វើបដិវត្ត, តួនាទី និងអំណាចរបស់ជនជាប់ចោទ ខៀវ សំផន នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ, គោលការណ៍នៃការរក្សាការសម្ងាត់របស់បក្សកុម្មុយនីស្តកម្ពុជា ។

ចាប់ផ្តើមដំបូង លោកមេធាវី គង់ សំអុន ស្នើឲ្យសាក្សីពន្យល់ត្រួសៗអំពីសមាសភាព និងរចនាសម្ព័ន្ធរបស់រណសិរ្សរួបរួមជាតិកម្ពុជា ។ ឆ្លើយតបនឹងសំណើនេះ លោក សួង ស៊ីគឿន បានបញ្ជាក់ថា រណសិរ្សរួបរួមជាតិកម្ពុជា គឺជាអង្គការនយោបាយមួយដែលមានគណៈកម្មាធិការកណ្តាលប្រចាំទីក្រុងប៉េកាំងប្រទេសចិន ។ គណៈកម្មាធិការនេះស្ថិតនៅក្រោមការគ្រប់គ្រងរបស់ការិយាល័យនយោបាយ ដែលដឹកនាំដោយសម្តេច ប៉ែន នុត ជាប្រធាន ។ នៅក្នុងប្រទេសផ្សេងៗទៀត រណសិរ្សរួបរួមជាតិកម្ពុជាបានរៀបចំឲ្យមានគណៈកម្មាធិការមួយដើម្បីប្រចាំការ ។ សាក្សីបន្ថែមថា សមាសភាពរបស់រណសិរ្សរួបរួមជាតិ គឺមាននិន្នាការនយោបាយផ្សេងៗ ពោលគឺមានក្រុម"សីហនុនិយម" ,ក្រុម"ឆ្វេងនិយម" និងក្រុម"អ្នកតស៊ូចាស់"រួមមាន ជា សុត, កែវ មាស...ដែលរត់ទៅវៀតណាមខាងជើងក្រោយមានកិច្ចព្រមព្រៀងហ្សឺណែវឆ្នាំ១៩៥៤ ។ ក្រុមចុងក្រោយគឺ"ក្រុមខ្មែរក្រហម" ដែលរួមមាន អៀង សារី, ខៀវ សំផន, ហ៊ូ យន់, ហ៊ូ នឹម, ដួន មុំ និង គាត ឈន់ ជាដើម ។ សាក្សីបានបែងចែកក្រុមខ្មែរក្រហម ដែលនៅប្រទេសបារាំងជាពីរ គឺក្រុមដែលបង្កើតដោយសមាគមនិស្សិតខ្មែរ(ក្រុមនេះត្រូវបានចាត់ទុកថាជាក្រុមឆ្វេងនិយម) និងក្រុមវង្សម៉ាកឡេនីន ។ ទាក់ទងនឹងការតស៊ូប្រឆាំងរបប លន់ នល់ សាក្សីបានបញ្ជាក់ថា នៅក្នុងប្រទេសគឺមានការតស៊ូដោយអាវុធដែលដឹកនាំដោយបក្សកុម្មុយនីស្តកម្ពុជា និងមានការចូលរួមពីកងទ័ពវៀតកុងរបស់វៀតណាម ។ កងកម្លាំងទាំងពីរនេះបានលើកទង់របស់សម្តេចព្រះ នរោត្តម សីហនុ ដើម្បីដឹកនាំ និងប្រមូលកម្លាំងប្រជាជនកម្ពុជាប្រឆាំងនឹងរបប លន់ នល់ ។ ចំណែកសម្តេចព្រះ នរោត្តម សីហនុ ដឹកនាំរណៈសិរ្សរួបរួមជាតិកម្ពុជាដើម្បីប្រមូលកម្លាំងតស៊ូនៅក្រៅប្រទេស ។

បន្ទាប់មកលោក គង់ សំអុន បានចោទសំណួរមួយចំនួនពាក់ព័ន្ធនឹងតួនាទី និងអំណាចរបស់ជនជាប់ចោទ ខៀវ សំផន ។ ឆ្លើយតបនឹងសំណួរទាំងនេះ សួង ស៊ីគឿន បានបញ្ជាក់ថា នៅក្នុងរណសិរ្សរួបរួមជាតិកម្ពុជា ខៀវ សំផន មានតួនាទីជាឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីការពារជាតិ និងជាអគ្គមេបញ្ជាការកងទ័ពរំដោះជាតិ ។ ប៉ុន្តែលោកបានសន្និដ្ឋានថា ខៀវ សំផន មិនមានអំណាចនេះពិតប្រាកដឡើយ គឺមានតែឈ្មោះប៉ុណ្ណោះ ។ នៅក្នុងរបបកម្ពុជាប្រជា

ធិបតេយ្យ ខៀវ សំផន មានតួនាទីជាប្រធានគណៈប្រធានរដ្ឋ ។ គណៈប្រធានរដ្ឋមានគ្នាបីនាក់ គឺប្រធានមួយរូប និងអនុប្រធានពីររូប ។ សាក្សីបានបន្ថែមថា តាមរយៈការសង្កេតរបស់ខ្លួន គឺ ខៀវ សំផន មិនមានអំណាចដូចប្រមុខរដ្ឋប្រទេសផ្សេងៗឡើយ ព្រោះការងារនៅក្នុងពេលនោះ គឺមិនមានភាពច្បាស់លាស់នោះទេ ។ ម្យ៉ាងវិញទៀតការណ៍ដែល ខៀវ សំផន ត្រូវបានចាត់តាំងឲ្យធ្វើជាប្រមុខរដ្ឋពេលនោះគឺដោយសារ ខៀវ សំផនជាមនុស្សចាស់ទុំនឹងនរតែប៉ុណ្ណោះ ។ បន្ទាប់ពីសាក្សីបញ្ជាក់ដូច្នេះ តំណាងសហព្រះរាជអាជ្ញា វ៉ាំងសង់ ឡើងជិទាស់ ដោយស្នើឲ្យអង្គជំនុំជម្រះរំឭកដល់សាក្សីគឺមិនត្រូវឆ្លើយព្រាវៗដោយគ្មានភស្តុតាងឡើយ ព្រោះចម្លើយជាច្រើន គឺសាក្សីទាញសេចក្ដីសន្និដ្ឋានផ្ទាល់ខ្លួន ។ ឆ្លើយតបនឹងការលើកឡើងនេះ លោកមេធាវី គង់ សំអុន លើកឡើងថា ការវាយតម្លៃរបស់សាក្សីក្នុងបញ្ហានេះ គឺមានសារៈសំខាន់ ព្រោះសាក្សីបានចូលរួមព្រឹត្តិការណ៍ជាច្រើនទាំងនៅមុន និងក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ ។ បន្ទាប់ពីការលើកឡើងនេះ លោកមេធាវីបានសួរសំណួររបស់ខ្លួនបន្តទៀត ដោយមិនមានសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះអំពីបញ្ហានេះឡើយ ។ មេធាវីបានសួរសំណួរចុងក្រោយរបស់ខ្លួនថា« តើមានគោលការណ៍អ្វីរបស់បក្សកុម្មុយនីស្តកម្ពុជាដែលកម្រិតការគិតការពិចារណា ឬការប្រើខួរក្បាលរបស់បញ្ញាជនដែលជាសមាជិករបស់បក្សនោះ? » ។ ឆ្លើយតបនឹងសំណួរនេះ សួង ស៊ីគៀន បញ្ជាក់ថា តាមបទពិសោធន៍របស់លោកបានបង្ហាញថា ការណ៍ដែលលោកទទួលបានការអប់រំរៀនសូត្រពីប្រទេសដែលមានរបបនាយទុន និងធ្លាប់ជាប្រទេសធ្វើអាណានិគមមកលើកម្ពុជា (បារាំង) គឺជាឧបសគ្គមួយសម្រាប់លោកក្នុងការចូលបម្រើការងារ ឬក្លាយជាសមាជិករបស់បក្សកុម្មុយនីស្តកម្ពុជា ។ ដូច្នេះអ្វីដែលលោកទទួលបានពីការសិក្សានៅបរទេស គឺសុទ្ធតែជាឧបសគ្គជាបន្ទុក និងជាសម្ពាយដែលត្រូវបោះបង់ចោល ។ ជំនួសមកវិញ គឺលោកត្រូវចាប់ផ្ដើមកសាងខ្លួនកសាងទស្សនៈតាមរបៀបថ្មី គឺអនុវត្តន៍តាមមាគ៌ា តាមគោលការណ៍របស់បក្សកុម្មុយនីស្តកម្ពុជា ។ ដូច្នេះអ្វីដែលបក្សសម្រេចជាមាគ៌ាយុទ្ធសាស្ត្រក្ដីជាមាគ៌ាយុទ្ធវិធីក្ដី គឺត្រូវតែគោរព ។ លោកបានបន្ថែម ថាក្នុងករណីលោកគិតផ្សេងពីមាគ៌ាដែលបក្សបានកំណត់ គឺមានន័យថាខុះជំនឿលើបក្ស ។


ព្រះអង្គម្ចាស់ប្រទេសឡាវ សុផានុវង្ស, សួង ស៊ីគៀន និង ខៀវ សំផន (រូបភាពមជ្ឈមណ្ឌលឯកសារកម្ពុជា)

បន្ទាប់ពីចប់សំណួររបស់ខ្លួន លោកមេធាវី គង់ សំអុន បានផ្ទេរវេទិកាជូនសហមេធាវីអន្តរជាតិរបស់ខ្លួន គឺលោកស្រីមេធាវី អង់តា ហ្គីសេ ។ លោកស្រីមេធាវីបានចាប់ផ្តើមសំណួររបស់ខ្លួន ដោយផ្តោតសំខាន់អំពីគោលការណ៍នៃការរក្សាការសម្ងាត់របស់បក្សកុម្មុយនីស្តកម្ពុជា ។ ពាក់ព័ន្ធបញ្ហានេះ សួង ស៊ីគៀន បានបញ្ជាក់ថា គោលការណ៍នៃការរក្សាការសម្ងាត់ គឺចេញមកពីបក្សកុម្មុយនីស្តកម្ពុជា ។ ជារឿយៗបក្សបានបញ្ជាក់ថា «បើអាចរក្សាការសម្ងាត់បាននោះចាត់ទុកថាបានទទួលទទួលជោគជ័យ ៥០ភាគរយ» ។ បន្ទាប់ពីមានការបញ្ជាក់ដូច្នេះ លោកស្រីមេធាវីបានចោទសំណួរថា «តើលោកយកគោលការណ៍នេះទៅអនុវត្តដែរឬទេនៅក្នុងក្របខ័ណ្ឌការងាររបស់លោកនៅក្នុងក្រសួងការបរទេស? មានព័ត៌មានមួយចំនួនដែលលោករក្សាទុកតែខ្លួនឯង ហើយលោកមិនប្រាប់អ្នកដ៏ទៃដូចជាសហការីរបស់លោក ឬក៏មិនប្រាប់ទៅអ្នកនៅក្រោមបង្គាប់របស់លោកទេ តើអ៊ីចឹងមែនទេ?» ។ ឆ្លើយតបនឹងសំណួរនេះ សាក្សី បញ្ជាក់យ៉ាងច្បាស់ថា «...តាមគោលការណ៍របស់បក្សក្នុងឋានៈជាបក្ខជន យើងមិនត្រូវលាក់ព័ត៌មានដែលយើងដឹងចំពោះអ្នកដែលជាអ្នកដឹកនាំ ឬអ្នកទទួលខុសត្រូវរបស់យើងផ្ទាល់ទេ ។ យើងត្រូវតែប្រាប់លាតត្រដាងព័ត៌មាននោះដល់អ្នកទទួលខុសត្រូវរបស់យើង...» ។ ចុងក្រោយលោកស្រីមេធាវីដាក់បង្ហាញឯកសារបទសម្ភាសន៍ដែល សួង ស៊ីគៀនបានផ្តល់ជូនសហចៅក្រមស៊ើបអង្កេត ដោយដកស្រង់ឃ្លាមួយចំនួនដែលមានខ្លឹមសារថា «...ខ្ញុំស្គាល់ ខៀវ សំផន នៅប៉ារីសគាត់ត្រូវបានគេស្គាល់ល្បីឈ្មោះ ដោយសារតែមានគុណភាពជាមនុស្សរបស់គាត់ ។ គាត់គួរសម និងសាមញ្ញជាជាងការប្រឡូកក្នុងនយោបាយរបស់គាត់ ។ គាត់ត្រូវបានខ្មែរក្រហមចាត់ទុកថា ជាកម្លាំងយុទ្ធវិធីច្រើនជាងកម្លាំងយុទ្ធសាស្ត្រ» ។ បន្ទាប់មកលោកស្រីមេធាវីស្នើឲ្យសាក្សីបញ្ជាក់អំពីពាក្យ«កម្លាំងយុទ្ធវិធី» និង«កម្លាំងយុទ្ធសាស្ត្រ»ឲ្យបានច្បាស់ ។ សួង ស៊ីគៀន បានបញ្ជាក់ថា កម្លាំងយុទ្ធវិធី គឺសំដៅទៅបញ្ញាជនដែលសិក្សានៅប្រទេសបារាំងជាពិសេសបញ្ញាជនដែលចូលរួមក្នុងវង្សម៉ាក្ស-ឡេនីន ។ បក្សកុម្មុយនីស្តកម្ពុជាបានចាត់ទុកកម្លាំងនេះ គឺអាចប្រមូលបញ្ញាជន និស្សិតខ្មែរដែលសិក្សានៅបរទេសបានច្រើន ។ ចំណែកកម្លាំងយុទ្ធសាស្ត្រ គឺជាកម្លាំងដែលបានចូលប្រឡូកតស៊ូធ្វើបដិវត្តន៍ដោយផ្ទាល់នៅក្នុងប្រទេសជាមួយបក្សកុម្មុយនីស្តកម្ពុជា ។ កម្លាំងនេះភាគច្រើនគឺជាវណ្ណៈអធន ដែលរួមមានកសិករ និងកម្មករ ។

### ៥.២) ក្រុមមេធាវីការពារក្តី នួន ជា

មុនពេលចូលដល់សំណួរពាក់ព័ន្ធនឹងអង្គហេតុដែលចោទប្រកាន់លើកូនក្តីរបស់ខ្លួនលោកមេធាវី ហ្សាស្តេ ប៉ៅ បានចោទសំណួរមួយចំនួនទាក់ទងនឹងប្រភពចំណេះដឹងរបស់សាក្សី ។ គោលបំណងនៃសំណួរទាំងនេះ គឺដើម្បីបង្ហាញថា តើព័ត៌មានដែលសាក្សីបានផ្តល់សក្ខីកម្មជូនអង្គជំនុំជម្រះ គឺពិតជាអ្វីដែលសាក្សីបានដឹងបានឃើញ ឬបានអនុវត្តនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឬគ្រាន់តែជាចំណេះដឹងដែលបានមកតាមរយៈការអានសៀវភៅ ឬឯកសារផ្សេងៗ ដែលត្រូវបានសរសេរឡើងក្រោយរបបកម្ពុជាប្រជាធិបតេយ្យ ។ មេធាវីបានសួរថា ចាប់ពីឆ្នាំ១៩៧៩មកតើសាក្សីបានអានសៀវភៅ ឯកសារ និងព័ត៌មានអ្វីខ្លះដែលនិយាយពីរបបខ្មែរក្រហម? ឆ្លើយតបនឹងសំណួរទាំងនេះ សួង ស៊ីគៀន បញ្ជាក់ថា លោកធ្លាប់អានសៀវភៅរបស់លោក ដេវីដ ឆេនដ្លើរ, លោក ប៊ែន ឃៀរនិន, ហ្វីលីព ស្សូត និងរបស់អ្នកនិពន្ធមួយចំនួនទៀត ។ ចំពោះវិទ្យុ លោកស្តាប់វិទ្យុអូស្ត្រាលី, វិទ្យុបារាំងអន្តរជាតិ, វិទ្យុសម្លេងសហរដ្ឋអាមេរិក និងវិទ្យុអាស៊ីសេរី ។ តាមរយៈការផ្សាយរបស់វិទ្យុទាំងនេះ សួង ស៊ីគៀន បានដឹងខ្លះអំពីកិច្ចដំណើរការសវនាការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ សំណួរចុងក្រោយពាក់ព័ន្ធនឹងបញ្ហានេះ គឺលោកមេធាវីសួរថា មុនពេលមកផ្តល់សក្ខីកម្ម តើ សួង ស៊ីគៀន មានបានជួបសាក្សីណាម្នាក់ ដែលបានមកផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះរួចហើយឬទេ? ឆ្លើយតបនឹងសំណួរនេះ សាក្សីបានបញ្ជាក់ថា លោកបានណាត់ជួប ភី ភួន ហៅ ចឹម តុន ហៅ ជាម ។ ការណាត់ជួបនេះ គឺដើម្បីចង់ដឹងថា តើតុលាការនឹងសួរអំពីបញ្ហាអ្វីខ្លះ ។ ប៉ុន្តែការណាត់ជួបនេះ គឺមិនបាននិយាយអ្វីច្រើនទេព្រោះ ភី ភួន ត្រូវបានអមដំណើរដោយអង្គភាពគាំពារសាក្សី ដូច្នេះមិនមានពេលច្រើនដើម្បីនិយាយគ្នាឡើយ ។ សំណួរបន្ទាប់របស់លោកមេធាវី ហ្សាស្តេ ប៉ៅ គឺពាក់ព័ន្ធនឹងតួនាទីរបស់លោក គាត ឈន់ នៅក្នុងរណសិរ្សរួបរួមជាតិកម្ពុជា និងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ លោកបានដាក់បង្ហាញឯកសារសារទូរលេខចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៧១ ផ្ញើពីស្ថានទូតសហរដ្ឋអាមេរិក

ប្រចាំនៅទីក្រុងភ្នំពេញទៅទីក្រុងវ៉ាស៊ីនតោន សហរដ្ឋអាមេរិក ។ សាទូរលេខនេះបញ្ជាក់ថា ស្វង ស៊ីគឿន គឺជាសមាជិកគណៈមជ្ឈិមនៃរណសិរ្សរួបរួមជាតិកម្ពុជា ។ រីឯ គាត ឈន់ គឺជាលេខាធិការនៃការិយាល័យនយោបាយរបស់រណសិរ្សរួបរួមជាតិកម្ពុជា និងជារដ្ឋមន្ត្រីប្រតិភូរបស់នាយករដ្ឋមន្ត្រី ។ បន្ទាប់មកលោកមេធាវី



មេធាវីការពារក្ដី ហ្សាស្ដើ ជ៉ោ

បានដាក់បង្ហាញឯកសារកំណត់ហេតុដែល ស្វង ស៊ីគឿន បានផ្ដល់សក្ខីកម្មជូនសហចៅក្រមស៊ើបអង្កេតថា “..អៀង សារី បានជំទាស់ដោយពន្យល់ប្រាប់ ប៉ុល ពត ថា ប្រសិនបើចាប់ខ្លួន គាត ឈន់ និង ដួន ប្រសិទ្ធ ក្រសួងការបរទេសត្រូវតែលុបចោលតែម្ដង” ។ បន្ទាប់ពីការដកស្រង់ លោកមេធាវីសួរថា តើ គាត ឈន់ និង ដួន ប្រសិទ្ធ គឺជាមនុស្សសំខាន់ជាខួរក្បាលរបស់ក្រសួងបរទេសដែរឬទេ? ប៉ុន្ដែសំណួរនេះមិនត្រូវបានអង្គជំនុំជម្រះអនុញ្ញាតឲ្យសាក្សីឆ្លើយតបឡើយ ។

គួរកត់សម្គាល់ថា ជាទូទៅ លោកមេធាវី ហ្សាស្ដើ ជ៉ោ បានចោទសំណួរជាច្រើនពាក់ព័ន្ធនឹងតួនាទី និងភារកិច្ចរបស់លោក គាត ឈន់ នៅក្នុងក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ប៉ុន្ដែសំណួរទាំងនេះភាគច្រើនមិនត្រូវបានអង្គជំនុំជម្រះអនុញ្ញាតឲ្យសាក្សីឆ្លើយតបឡើយ ដោយផ្ដល់សំអាងហេតុថា សំណួរទាំងនោះមិនជាប់ពាក់ព័ន្ធនឹងអង្គហេតុដែលចោទប្រកាន់ជនជាប់ចោទ នួន ជា ពោលគឺជាសំណួរក្រៅអង្គហេតុ ។ ទោះបីជាយ៉ាងណាក៏ដោយ លោកមេធាវី នៅតែព្យាយាមលើកយកឯកសារផ្សេងៗទៀតដែលមានបញ្ជាក់ពីតួនាទីរបស់លោក គាត ឈន់ និង ដួន ប្រសិទ្ធនៅក្នុងរណសិរ្សរួបរួមជាតិកម្ពុជា, រាជរដ្ឋាភិបាលរួបរួមជាតិ និងនៅក្នុងក្រសួងការបរទេស ។ ចុងក្រោយលោកមេធាវីបានធ្វើការកត់សម្គាល់ថា “ខ្ញុំសូមកត់សម្គាល់ថា យើងបានព្យាយាមបង្ហាញភស្ដុតាងអំពីប្រវត្តិសាស្ដ្រនៃរណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិ ។ នេះហើយជាគោលបំណងដែល ខ្ញុំបានធ្វើ ហើយមេធាវីការពារលោក ខៀវ សំផន ព្យាយាម ហើយតុលាការទំនងជាមិនអនុញ្ញាតឲ្យយើងសួរពីផ្នែកនេះឡើយ...” ។

បន្ទាប់ពីមេធាវី ហ្សាស្ដើ ជ៉ោ បានព្យាយាមបង្ហាញអំពីតួនាទីរបស់ គាត ឈន់ និង ដួន ប្រសិទ្ធ នៅក្នុងរណសិរ្សរួបរួមជាតិកម្ពុជា និងរបបកម្ពុជាប្រជាធិបតេយ្យតាមរយៈការដាក់ឯកសារនៅចំពោះមុខសាក្សី អង្គជំនុំជម្រះបានរំឭកដល់មេធាវីថា “លោកមេធាវីគប្បីសួរសាក្សីថា តើឯកសារនេះសាក្សីធ្លាប់បានឃើញ បានអានពីមុនដែរឬទេ? លោកត្រូវបង្ហាញអំពីការដែលធ្លាប់បានឃើញបានអានជាមុនសិននោះ ទើបអាចជូនទៅសាក្សីពិនិត្យមើលឯកសារហើយដេញដោលបាន ។ បើសាក្សីមិនធ្លាប់ឃើញ មិនធ្លាប់ស្គាល់ឯកសារនេះទេ គឺត្រូវដកមកវិញ ហើយនឹងដកចេញពីអេក្រង់កុំព្យូទ័រ” ។ អង្គជំនុំជម្រះបានចេញសេចក្ដីសម្រេចភ្លាមៗនោះថា “មេធាវីអាចតាំងសំណួរទៅលើខ្លឹមសារ ដោយមិនអនុញ្ញាតដកស្រង់ខ្លឹមសារទាំងស្រុងនៃឯកសារនេះមកសួរដេញដោលសាក្សីទេ” ។

បន្ទាប់ពីបញ្ចប់សំណួរពាក់ព័ន្ធនឹងលោក គាត ឈន់ លោកមេធាវី ហ្សាស្ដើ ជ៉ោ បានបន្ដសាក្សី ដោយផ្ដោតសំខាន់អំពីតួនាទី និងភារកិច្ចរបស់លោក ហោ ណាំហុង នៅមន្ទីរបឹងត្របែកនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ សំណួរដំបូងគឺពាក់ព័ន្ធនឹងតួនាទីរបស់លោក ហោ ណាំហុង នៅមុនរបបកម្ពុជាប្រជាជាធិបតេយ្យ ។ ឆ្លើយតបនឹងសំណួរនេះ សាក្សីបញ្ជាក់ថា មុនរដ្ឋប្រហារឆ្នាំ១៩៧០

*លោក ហោ ណាំហុង ធ្វើជាលេខាអមស្ថានទូតកម្ពុជានៅទីក្រុងប៉ារីសប្រទេសបារាំង ។ ក្នុងក្របខណ្ឌរណសិរ្សរួបរួមជាតិកម្ពុជា លោក ហោ ណាំហុង ធ្វើជារដ្ឋរាជទូតប្រចាំប្រទេសគុយបា ជំនួស តូច ខាំឌឿន ។ ប៉ុន្តែនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ សាក្សីមិនដឹងថា លោក ហោ ណាំហុង ធ្វើអ្វីនោះទេ ។ បន្ទាប់មក លោកមេធាវីបានដកស្រង់សម្តីរបស់ ដួង ប្រសិទ្ធ ដែលបានសន្ទនាតាមទូរស័ព្ទជាមួយលោក ស៊ីវ ហេងឌ័រ ថាលោក ហោ ណាំហុង គឺជាអ្នកទទួលបន្ទុកការងារនៅមន្ទីរបឹងត្របែក ហើយចោទសំណួរថា« លោកសាក្សី តើលោកសាក្សីធ្លាប់បានដឹងអំពីមុខដំណែង និងតួនាទីរបស់លោក ហោ ណាំហុង នៅបឹងត្របែកដែរឬទេនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ?» ។ សួង ស៊ីគឿន បញ្ជាក់ថា លោកមិនបានដឹងអំពីតួនាទីរបស់លោក ហោ ណាំហុង នៅបឹងត្របែកឡើយ ។ គួរបញ្ជាក់ថា មានសំណួរជាច្រើនដែលលោកមេធាវី ហ្សាស្តេ ប៉ោ បានសួរពាក់ព័ន្ធនឹងតួនាទីរបស់លោក ហោ ណាំហុង នៅមន្ទីរបឹងត្របែក ។ ប៉ុន្តែសំណួរទាំងនេះត្រូវបានតំណាងសហព្រះរាជអាជ្ញា គឺលោក ចាន់ តារាវស្មី ឡើងជំទាស់ជាញឹកញាប់ដោយផ្តល់សំអាងហេតុថា សំណួរទាំងនេះ គឺមិនជាប់ពាក់ព័ន្ធនឹងអង្គហេតុដែលកំពុងជំនុំជម្រះនៅក្នុងដំណាក់កាលទី១(សំណុំរឿង០០២/០១) ។ ប៉ុន្តែលោក ហ្សាស្តេ ប៉ោ នៅតែអះអាងថា សំណួរទាំងនេះ គឺជាប់ទាក់ទងនឹងអង្គហេតុដែលបានចោទប្រកាន់កូនក្តីរបស់ខ្លួនព្រោះនៅក្នុងដីកាដំណោះស្រាយ នួន ជា ត្រូវបានចោទប្រកាន់ថាមានការទាក់ទងដោយផ្ទាល់ជាមួយបឹងត្របែក ។*

*ចុងក្រោយលោក ហ្សាស្តេ ប៉ោបានសួរថា « លោកសាក្សី លោកគិតថាលោក គាត ឈន់ គប្បីតែមកផ្តល់សក្ខីកម្មដើម្បីស្វែងរកការពិតជូនតុលាការដែរឬទេ?» ។ មេធាវីបញ្ជាក់ថា លោកព្យាយាមកំណត់អត្តសញ្ញាណបុគ្គលមួយចំនួន ដែលអាចមានព័ត៌មានច្បាស់លាស់ពាក់ព័ន្ធនឹងរបបកម្ពុជាប្រជាធិបតេយ្យ និងកូនក្តីរបស់ខ្លួន ។ ប៉ុន្តែសំណួរនេះមិនត្រូវបានអង្គជំនុំជម្រះអនុញ្ញាតឲ្យសាក្សីឆ្លើយតបឡើយ ព្រោះជាសំណួរក្រៅអង្គហេតុ ។ គួរកត់សម្គាល់ថា ជាទូទៅក្រុមមេធាវីការពារក្តីជនជាប់ចោទ នួន ជា តែងតែសួរសាក្សីដែលធ្លាប់ធ្វើការនៅក្រសួងការបរទេសអំពីតួនាទី និងភារកិច្ចរបស់លោក គាត ឈន់ និងលោក ហោ ណាំហុង និងមានបំណងឲ្យ*



**ហួត សម្បត្តិ, ហាក់ សៀងឡាយនី ទស្សនកិច្ចប្រទេសអាល់បាលនី** *(រូបភាពមជ្ឈមណ្ឌលឯកសារកម្ពុជា)*

លោកទាំងរូបនេះមកផ្តល់សក្ខីកម្មចំពោះមុខតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។

**កំណត់សម្គាល់** ៖ ដោយក្រុមមេធាវីការពារក្តីជនជាប់ចោទ នួន ជា បានផ្តោតសំខាន់អំពីតួនាទី និងភារកិច្ចរបស់លោក គាត ឈន់ និងលោក ហោ ណាំហុង នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ សួង ស៊ីគឿន បានឆ្លៀតឱកាសធ្វើសេចក្តីថ្លែងការណ៍មួយចំនួននៅចំពេលដែលខ្លួនកំពុងទទួលសំណួរពីមេធាវីការពារក្តីជនជាប់ចោទ អៀង សារី ។ លោកបានបញ្ជាក់ថា“...ពេលនោះ បញ្ញាជនដែលមកពីក្រៅប្រទេស គឺមានតែខ្ញុំទេគេអាចតែងតាំងជាប្រធានផ្នែក ។ ដូច្នេះ លោកទាំងពីរហ្នឹង លោក គាត ឈន់ ឬលោកហោ ណាំហុង មានអំណាចតិចជាងខ្ញុំទេ ។ ខ្ញុំសូមអង្វរ កុំទៅរករឿងអីគាត់នោះ គឺថា បើនិយាយជារួម គឺគាត់មានឋានៈជាបញ្ញាជនដូចខ្ញុំអីចឹង ។ នេះខ្ញុំសូមចប់សក្ខីកម្មរបស់ខ្ញុំ ។ ខ្ញុំចង់និយាយតែប៉ុណ្ណឹងទេ ព្រោះវាស្រគៀត្រចៀកណាស់ តិចៗ គាត ឈន់ តិចៗ ហោ ណាំហុង ។ តិចៗ គាត ឈន់តិចៗ ហោ ណាំហុង វាស្រគាត្រចៀកណាស់” ។

### ៩.៣) ក្រុមមេធាវីការពារក្តី អៀង សារី

ក្នុងការសួរដេញដោលសាក្សីមេធាវីការពារក្តីជនជាប់ចោទ អៀង សារី បានផ្តោតសំខាន់អំពីការបង្កើតរណសិរ្សរួបរួមជាតិកម្ពុជា, ការធ្វើទស្សនកិច្ចរបស់សម្តេច សីហនុ អៀង សារី និង ខៀវ សំផន ទៅប្រទេសផ្សេងៗ , សមាសភាពនិងរចនាសម្ព័ន្ធគ្រប់គ្រងក្រសួងការបរទេសជាដើម ។

សំណួរមួយចំនួនរបស់លោកមេធាវីអន្តរជាតិ ម៉ៃឃើល កាណាវាស គឺពាក់ព័ន្ធនឹងទំនាក់ទំនងរវាង សួង ស៊ីគឿន ជាមួយបុគ្គលមួយចំនួនរួមមាន ភី ភួន ហៅ រចឹម តុន និង សា ឡុតបាន ហៅ សូ ហុង ដែលទើបតែផ្តល់សក្ខីកម្មជូនអង្គជំនុំជម្រះថ្មីៗ ។ មេធាវីសួរថាតើ សួង ស៊ីគឿន បានព្យាយាមជួបបុគ្គលទាំងពីររូបនេះដែរឬទេ មុនមកផ្តល់សក្ខីកម្មជូនអង្គជំនុំជម្រះ? សាក្សីបញ្ជាក់ ថា លោកបានណាត់ជួប ភី ភួន មុននឹងលោក(សួង ស៊ីគឿន) មកផ្តល់សក្ខីកម្មជូនអង្គជំនុំជម្រះ ។ ការណាត់ជួបនេះ គឺដើម្បីចង់ដឹងថាតុលាការនឹងសួរអំពីបញ្ហាអ្វីខ្លះ ។ លោកបានជួប ភី ភួន ប្រហែលជាកន្លះម៉ោងតែប៉ុណ្ណោះ ហើយមិនបានសួរនាំច្រើនឡើយ ព្រោះពេលនោះ ភី ភួន នៅជាមួយមន្ត្រីនៃអង្គភាពគាំពារសាក្សី ។ សាក្សីបានបញ្ជាក់ថា លោកបានដឹងខ្លះៗអំពីការផ្តល់សក្ខីកម្មរបស់ ភី ភួន តាមរយៈការផ្សាយរបស់វិទ្យុផ្សេងៗ ។ ប៉ុន្តែសម្រាប់ សូ ហុង វិញ លោកមិនដែលណាត់ជួបឡើយ ហើយក៏មិនដឹងថា សូ ហុងបានផ្តល់សក្ខីកម្មនៅអង្គជំនុំជម្រះដែរ ។ បន្ទាប់មកលោកមេធាវីបានសួរបញ្ជាក់មួយចំនួនទាក់ទងរណសិរ្សរួបរួមជាតិកម្ពុជា ដែលសាក្សីបានផ្តល់សក្ខីកម្មជូនសហព្រះរាជអាជ្ញា មេធាវីដើមបណ្តឹងរដ្ឋប្បវេណី និងអង្គជំនុំជម្រះ ។ ជាថ្មីម្តងទៀត សួង ស៊ីគឿនបញ្ជាក់ថា រណសិរ្សនេះត្រូវបានបង្កើតឡើងក្រោយពីមានសេចក្តីប្រកាសរបស់ព្រះបាទនរោត្តម សីហនុ នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧០ បន្ទាប់ពីមានរដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ។ សម្តេច សីហនុ បានអំពាវនាវឲ្យប្រជាជនរត់ចូលព្រៃម៉ាគី ដើម្បីរួមកម្លាំងជាមួយកងទ័ពរបស់បក្សកុម្មុយនីស្តកម្ពុជា និងកងទ័ពវៀតណាមដែលនៅក្នុងព្រៃស្រាប់ ដើម្បីតស៊ូប្រដាប់អាវុធប្រឆាំងនឹងរបប លន់ នល់ ។ នៅក្នុងរណសិរ្សរួបរួមជាតិកម្ពុជាមានកម្លាំងសំខាន់ៗពីរ គឺកម្លាំងរបស់បក្សកុម្មុយនីស្តកម្ពុជា កម្លាំងរាជានិយម និងកម្លាំងអ្នកស្នេហាជាតិ (កម្លាំងកណ្តាល) ។ សាក្សីបញ្ជាក់បន្ថែមថា ពេលនោះសម្តេចសីហនុ បានធ្វើសេចក្តីថ្លែងការណ៍ជាច្រើន ដែលសេចក្តីថ្លែងការណ៍ទាំងនោះមានអំណោយផល និងលើកទឹកចិត្តដល់ការតស៊ូ នៅក្នុងប្រទេស ។ ទាក់ទងនឹងការអមដំណើរគណៈប្រតិភូ ទៅធ្វើទស្សនកិច្ចនៅក្រៅប្រទេស សួង ស៊ីគឿន បានបញ្ជាក់ថា នៅខែឧសភា ឆ្នាំ១៩៧០ លោកបានអមដំណើរសម្តេច សីហនុ ទៅធ្វើទស្សនកិច្ចនៅប្រទេសវៀតណាមជាលើកទីមួយ ព្រោះពេលនោះមានតែវៀតណាម និង ចិនតែប៉ុណ្ណោះដែលទទួលស្គាល់រណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ។ ដំណើរទស្សនកិច្ចនេះត្រូវបានទទួលយ៉ាងកក់ក្តៅពីសំណាក់ប្រទេសវៀតណាម ។ នៅឆ្នាំ១៩៧៣ លោកបានអមដំណើរគណៈប្រតិភូដែលដឹកនាំដោយសម្តេច សីហនុ,អៀង សារី និង អិន សុភាព ទៅធ្វើទស្សនកិច្ចនៅប្រទេសរ៉ូម៉ានី ។ ក្នុងឆ្នាំ១៩៧៤ លោកបានអមដំណើរគណប្រតិភូដែលដឹកនាំដោយ ខៀវ សំផន និង អៀង សារី ទៅធ្វើទស្សនកិច្ចនៅបូការេស ប្រទេសរ៉ូម៉ានី ម្តងទៀត ។ ការធ្វើដំណើរទស្សនកិច្ចទាំងនេះគឺដើម្បីប្រាប់អំពីការតស៊ូរបស់ប្រជាជនកម្ពុជា និងដើម្បីទទួលបានការគាំទ្រពីប្រទេសទាំងនោះមកលើរណសិរ្សរួបរួមជាតិកម្ពុជា

និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ។

សំណួរបន្តបន្ទាប់មកទៀតរបស់លោក កាណាវ៉ាស គឺពាក់ព័ន្ធនឹងសិទ្ធិអំណាចក្នុងការសម្រេចរបស់ ប៉ុល ពត និងអៀង សារី ។ លោកមេធាវីបានដកស្រង់សក្ខីកម្មរបស់ សួង ស៊ីគៀន ដែលផ្ដល់ជូនសហព្រះរាជអាជ្ញាថា« ក្រោយឆ្នាំ១៩៧៩ តាមពិតទៅដែលខ្ញុំចង់បញ្ជាក់គឺ អៀង សារី ជាអ្នកផ្ដល់ការណែនាំដល់ខ្ញុំប៉ុន្តែគាត់មិនមានសិទ្ធិអំណាចក្នុងការសម្រេចនោះទេ ។ សេចក្ដីសម្រេចគឺធ្វើឡើងនៅក្នុងកម្រិតថ្នាក់អចិន្ត្រៃយ៍ ជាពិសេសដោយ ប៉ុល ពត តែម្ដង ។ ដូច្នេះការចាត់តាំងរបស់ខ្ញុំនោះ គឺមិនមែនធ្វើដោយ អៀង សារី នោះទេ គឺដោយ ប៉ុល ពត ។ ដូច្នេះ ប៉ុល ពត គាត់ធ្វើសេចក្ដីសម្រេចដែលថារដ្ឋមន្ត្រីទទួលបន្ទុកហ្នឹងត្រូវតែចេញបញ្ជា ឬក៏គ្រាន់តែបញ្ជូនបញ្ជា ឬបញ្ជូនការណែនាំហ្នឹងទៅថ្នាក់ក្រោម» ។ បន្ទាប់មកលោក កាណាវ៉ាស សួរថា តើស្ថានភាពនៅចន្លោះឆ្នាំ១៩៧៥ ដល់១៩៧៩ ដូចគ្នានឹងស្ថានភាពក្រោយឆ្នាំ១៩៧៩ដែរឬទេ? ឆ្លើយតបនឹងសំណួរនេះ សួង ស៊ីគៀន បញ្ជាក់ថា« ស្ថានភាពនេះគឺថាវាត្រូវប្រើនៅចន្លោះឆ្នាំ១៩៧៥ ដល់១៩៧៩ ហើយបន្តក្រោយពី១៩៧៩នេះ ទៀតរហូតដល់ការផ្ដាច់ខ្លួនរបស់លោក អៀង សារី ពីចលនាខ្មែរក្រហមនៅឆ្នាំ១៩៩៦ » ។ លោកបានផ្ដល់ឧទាហរណ៍បន្ថែមថា សម្រាប់រូបលោកផ្ទាល់ទោះបីលោកធ្វើការនៅក្នុងក្រសួងការបរទេសដែលគ្រប់គ្រងដោយ អៀង សារី ប៉ុន្តែអ្នកដែលសម្រេចអំពីជោគវាសនារបស់លោក គឺមជ្ឈិមដែលពាក្យនេះ គឺសំដៅ ប៉ុល ពត ។ ទោះបីមានការបញ្ជាក់ដូច្នេះក្ដី នៅពេលដែលលោក កាណាវ៉ាស សួរថា ហេតុអ្វី សួង ស៊ីគៀន មានសិទ្ធិអំណាចបដិសេធសេចក្ដីសម្រេចរបស់ ប៉ុល ពត ដែលចាត់តាំងឲ្យធ្វើការនៅទីភ្នាក់ងារសារព័ត៌មានកម្ពុជា? សាក្សីបញ្ជាក់ថា មូលហេតុ ដែលលោកហ៊ានបដិសេធនឹងសេចក្ដីសម្រេចនេះ គឺដោយសារ អៀង សារី បានប្រាប់មិនឲ្យលោកទទួលកិច្ចការនេះ ព្រោះខ្លាចប៉ះពាល់ការងារនៅក្រសួងការបរទេស ។ ម្យ៉ាងវិញទៀតលោកក៏មានរូបលោកផ្ទាល់ (សាក្សី) ក៏មានទំនាក់ទំនងល្អជាមួយ ប៉ុល ពត ដែរ ។ ជារឿយៗ សួង ស៊ីគៀន បានបង្ហាញពីការយល់ឃើញផ្ទាល់ខ្លួនថា បញ្ញាជនដែលត្រូវបានប្រមូលឲ្យចូលក្នុងប្រទេសវិញ គឺជាការសម្រេចរបស់ ប៉ុល ពត ។ ទោះបី អៀង សារី ជាអ្នកអំពាវនាវក៏ដោយ ប៉ុន្តែ អៀង សារី ប្រហែលជាមិនបានដឹងពីគោលបំណងនៃការប្រមូលនេះឡើយ ។ សួង ស៊ីគៀន បញ្ជាក់បន្ថែមថា ប៉ុល ពត អនុវត្តអំណាចនិងគ្រប់គ្រងការងារស្ទើរគ្មានចន្លោះ ។

គួរកត់សម្គាល់ថា ក្នុងការសួរដេញដោលសាក្សី សួង ស៊ីគៀន លោកមេធាវី ម៉ៃឃើល កាណាវ៉ាស តែងតែដកស្រង់សក្ខីកម្មដែល សួង ស៊ីគៀន បានផ្ដល់ជូនតំណាងសហព្រះរាជអាជ្ញាម្ដងរួចហើយ ដើម្បីឲ្យសាក្សីពន្យល់បន្ថែម ។ មានពេលខ្លះលោកមេធាវីបានរំឭកដល់សាក្សីថា សក្ខីកម្មដែលសាក្សីបានផ្ដល់(ឧទាហរណ៍សាក្សីបានផ្ដល់សក្ខីកម្មថា « ពេលខ្លះ ប៉ុល ពត គឺជាអ្នកចេញសេចក្ដីសម្រេចដោយខ្លួនឯងតែម្ដង» ) គឺបានធ្វើសម្បថរួចហើយ ។ ប្រតិកម្មតបនឹងការរំឭកនេះ សួង ស៊ីគៀន កត់សម្គាល់ថាការដែលមេធាវីរំឭកអំពីការធ្វើសម្បថម្ដងជាពីរដង គឺហាក់ដូចជាចង់ខោកក្បាលរបស់លោកអ៊ីចឹងដែរ ។ អង្គជំនុំជម្រះបានរំឭកដល់មេធាវីបន្ថែមថា« លោកមេធាវីសូមលោករៀបចំនូវការតាំងសំណួររបស់លោកឲ្យបានសមស្របធ្វើយ៉ាងណាឲ្យចៀសវាងការធ្វើឲ្យប៉ះពាល់សតិអារម្មណ៍របស់សាក្សី ធ្វើឲ្យសាក្សីបាត់បង់ជំនឿចិត្តក្នុងការផ្ដល់សក្ខីកម្ម ។ បញ្ហាសម្បថនេះយើងដឹងទាំងអស់គ្នា ហើយអង្គជំនុំជម្រះបានតាំងសំណួរតាំងពីដំបូង ហើយក្នុងកំណត់ហេតុសួរចម្លើយរបស់គាត់ទាំងប៉ុន្មានលើកសុទ្ធតែមានខ្លឹមសានៃសម្បថដែលបានធ្វើ» ។ ទាក់ទងនឹងរចនាសម្ព័ន្ធគ្រប់គ្រង សួង ស៊ីគៀន បញ្ជាក់ថា ក្រសួងការបរទេសចែកជាពីរផ្នែកគឺផ្នែកមន្ទីរ និងផ្នែកការិយាល័យ ។ ផ្នែកមន្ទីរទទួលខុសត្រូវខាងសន្តិសុខ និងការបង្កបង្កើនផល ។ ចំណែកផ្នែកការិយាល័យទទួលខុសត្រូវការងារការទូត ។ អៀង សារី ជាឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីនៃក្រសួងការបរទេស សូ ហុង មានតួនាទីជាអគ្គលេខាធិការ, លោកស្រី សួរ សែ គឺជាលេខាសាខាបក្ស ចំណែក ភី ភួន ហៅ ជាម ទទួលបន្ទុកការពារសន្តិសុខជូនស្ថានទូត ។ សួរ សែ ជាអ្នកទទួលបន្ទុករៀបចំការងារនៅក្នុងអគ្គលេខាធិការដ្ឋាននៃក្រសួងការបរទេស និងរៀបចំកិច្ចប្រជុំរួមនៅក្នុងក្រសួង ។ សួង ស៊ីគៀន បញ្ជាក់បន្ថែមថា« សួរ សែ ជាលេខាសាខាបក្ស ប៉ុន្តែគ្មានអំណាចអ្វីទេ ព្រោះនៅពីលើគាត់មានលោក សូ ហុង និងលោក អៀង សារី ។ ដូច្នេះគាត់មិនមានអំណាចអ្វីទេ គឺគ្រាន់តែដឹកនាំប្រជុំប៉ុណ្ណឹងទេបាទ ហើយរាយការណ៍លទ្ធផលនៃការប្រជុំហ្នឹងជូនទៅលោក អៀង សារី

ឬលោក សូ ហុង...» ។ ពាក់ព័ន្ធនឹងវចនាសម្ព័ន្ធគ្រប់គ្រងនេះ លោក កាណាវ៉ាស បានសួរដោយផ្ដោតសំខាន់អំពីទំនាក់ទំនងរវាងបុគ្គលមួយចំនួនដែលទទួលបន្ទុកកិច្ចការសន្តិសុខក្នុងក្រសួង ដូចជា ជាម, សូ ហុង និង ប៉ង់ ជាមួយ ប៉ុល ពត ។ ប៉ុន្តែសាក្សីបញ្ជាក់ថា លោកមិនសូវដឹងច្បាស់អំពីទំនាក់ទំនងទៅវិញទៅមករបស់បុគ្គលទាំងនេះទេ ព្រោះលោកស្ថិតនៅក្នុងក្រុមបញ្ញាជន ។ ជាពិសេសលោកមិនដឹងទាល់តែសោះថា ប៉ង់ មានទំនាក់ទំនងជាមួយ សូ ហុង និង ភី ភួន ។

### បញ្ហាផ្សេងៗ

សវនាការស្ដាប់សក្ខីកម្មរបស់ សួង ស៊ីគឿន ត្រូវបានលើកពេលជាញឹកញាប់ ។ មានមូលហេតុសំខាន់ពីរដែលនាំឲ្យមានបញ្ហានេះគឺ ទី១) សួង ស៊ីគឿន មានបញ្ហាសុខភាពជាញឹកញាប់មិនអាចផ្ដល់សក្ខីកម្មបាន ព្រោះលោកធ្លាប់វះបេះដូង ។ ទី២) ជនជាប់ចោទ អៀង សារី ក៏មានបញ្ហាសុខភាពជាញឹកញាប់ដែរ ក្នុងអំឡុងពេលនោះ ដែលមិនអាចតាមដានកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះ ហើយជនជាប់ចោទមិនព្រមលះបង់សិទ្ធិចូលរួមសវនាការស្ដាប់សក្ខីកម្មរបស់ សួង ស៊ីគឿន ព្រោះអង្គហេតុដែលសាក្សីផ្ដល់សក្ខីកម្មគឺភាគច្រើនពាក់ព័ន្ធនឹងក្រសួងការបរទេស ។ ដូច្នេះតម្រូវឲ្យអង្គជំនុំជម្រះផ្អាកសវនាការជាច្រើនថ្ងៃក្នុងការស្ដាប់សក្ខីកម្មរបស់ សួង ស៊ីគឿន ។ ប៉ុន្តែដើម្បីដោះស្រាយបញ្ហានេះអង្គជំនុំជម្រះបានសម្រេចស្ដាប់សក្ខីកម្មសាក្សីឆ្លាស់គ្នារវាង សួង ស៊ីគឿន និង អុង ថុងហឿង ។

គួររំឭកបន្តិចអំពីបញ្ហាសុខភាពរបស់ជនជាប់ចោទ អៀង សារី ក្នុងការចូលរួមសវនាការ ។ នៅពេលចាប់ផ្ដើមនៃសវនាការថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១២ ក្រុមមេធាវីការពារក្ដីជនជាប់ចោទ អៀង សារី បានស្នើសុំអង្គជំនុំជម្រះអនុញ្ញាតឲ្យកូនក្ដីរបស់ខ្លួនចូលរួមសវនាការពីចម្ងាយតាមរយៈប្រព័ន្ធសោតទស្សន៍ដូចសព្វដង ។ ប៉ុន្តែមួយរយៈពេលខ្លីក្រោយមក លោកស្រីចៅក្រម ស៊ីវៀល ខាតព្រ៉ាយត៍ បានជូនដំណឹងដល់ក្រុមមេធាវីថា ពេទ្យប្រចាំការនៅអង្គជំនុំជម្រះទើបតែចេញរបាយការណ៍ថា អៀង សារី មានការវិលមុខមិនអាចផ្ចង់អារម្មណ៍ដើម្បីតាមដាននីតិវិធីបានឡើយ ។ បន្ទាប់ពីមានការបញ្ជាក់ដូច្នេះ លោកមេធាវី ម៉ៃឃើល កាណាវ៉ាស បានស្នើសុំឲ្យពិនិត្យសុខភាពជនជាប់ចោទ អៀង សារី សារជាថ្មី ។ លោកបញ្ជាក់ថា អៀង សារី មិនមានបំណងលះបង់សិទ្ធិចូលរួមសវនាការស្ដាប់សក្ខីកម្មរបស់ សួង ស៊ីគឿន ឡើយ ។ ដោយក្រុមមេធាវីបង្ហាញជំហរដូច្នេះ អង្គជំនុំជម្រះសម្រេចផ្អាកសវនាការមួយអន្លើ ហើយបង្គាប់ឲ្យពេទ្យប្រចាំការនៅតុលាការពិនិត្យ និងផ្ដល់របាយការណ៍សារជាថ្មីអំពីបញ្ហាសុខភាព អៀង សារី ។

បន្ទាប់ពីបានពិនិត្យសុខភាពរបស់ អៀង សារី លោកវេជ្ជបណ្ឌិត គីម សមសាន្ត បានបញ្ជាក់ជូនអង្គជំនុំជម្រះថា អៀង សារី បានចូលបន្ទប់ទឹកញឹកញាប់ខុសពីធម្មតា ។ ការចូលញឹកញាប់នេះ អៀង សារី បានត្អូញត្អែរថា បានធ្វើឲ្យអស់កម្លាំង វិលមុខ ហើយបានបណ្ដាលឲ្យមានការលំបាកផ្ចង់អារម្មណ៍ដើម្បីតាមដានកិច្ចដំណើរការនីតិវិធីរបស់តុលាការ ។ អង្គជំនុំជម្រះបានចោទសំណួរទៅលោកសមសាន្តថាតាមការពិនិត្យវេជ្ជសាស្ត្រ តើបានរកឃើញដូចអ្វីដែល អៀង សារី បានលើកឡើងដែរឬទេ? ឆ្លើយបតនឹងសំណួរនេះ លោកវេជ្ជបណ្ឌិតបានបញ្ជាក់ថា «ចំពោះខ្ញុំ លទ្ធភាពវាយតម្លៃស្ថានភាពគាត់នៅពេលដំបូងហ្នឹងបង្ហាញថា គាត់ពិតជាវិលមុខមែន ។ អ្វីដែលយើងអះអាងថាគាត់វិលមុខហ្នឹង គឺនៅពេលដែលគាត់ក្រោកឈរទៅនោមម្ដងៗ គឺដំណើរគាត់គេសគះ ហើយនៅពេលគាត់នោមគាត់ត្រូវទប់គ្រែហ្នឹង បើមិនទប់ទេគាត់ត្រូវដួល ។ បាទ ហើយក្រោយពីគាត់នោមហើយគាត់ត្រូវចូលទៅសម្រាកវិញ ។ នៅពេលដែលគាត់សម្រាកហ្នឹងដង្ហើមគាត់ក៏ញាប់ខុសពីធម្មតា ហើយគាត់ហត់និយាយដាច់ៗ ។ នេះគឺជាសញ្ញាបញ្ជាក់ថា ភាពវិលមុខហ្នឹងពិតជាមាន ។ ចំណែកការភ្លេចភ្លាំងដែលគាត់និយាយ ហ្នឹងខ្ញុំមិនអាចសន្និដ្ឋានបានឡើយ» ។ បន្ទាប់ពីបានស្ដាប់ការលើកឡើងរបស់គ្រូពេទ្យ ប្រធានអង្គជំនុំជម្រះបានផ្ដល់ឱកាសឲ្យភាគីផ្សេងៗផ្ដល់យោបល់អំពីការផ្អាកសវនាការ ។ ភ្លាមនោះ លោក សុន អរុណ បាន លើកឡើងថា «តាមយោបល់ខ្ញុំជាក្រុមមេធាវីការពារលោក នួន ជា ខ្ញុំយល់ថា ការស្ដាប់មិនបាន ហើយមិនយល់នៅក្នុងសវនាការនេះ ទោះបីឲ្យគាត់នៅក្នុងបន្ទប់ក្រោមក៏ដោយគឺចាត់ទុកជាអត់បានការ ។ ដូច្នេះ គួរតែសម្រាកនៅព្រឹកនេះ» ។ បន្ទាប់ពីបានស្ដាប់ការផ្ដល់សក្ខីកម្មរបស់លោកវេជ្ជបណ្ឌិត គីម សមសាន្ត និងការស្នើសុំរបស់ភាគី អង្គជំនុំជម្រះបានសម្រេចផ្អាកសវនាការស្ដាប់សក្ខីកម្មរបស់ សួង ស៊ីគឿន នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១២ តែម្ដង ។

# សវនាការស្ដីពីការផ្ដល់សក្ខីកម្មរបស់សាក្សី អុង ចុងហឿង

ចាប់ពីថ្ងៃទី៧ដល់ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១២ អង្គជំនុំជម្រះបានបន្តសាកសួរដេញដោលសាក្សី អុង ចុងហឿង ដែលជាអតីតបញ្ញាជនដែលត្រូវបានជាប់ឃុំនៅមន្ទីរបឹងត្របែក និងមន្ទីរផ្សេងៗទៀតនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ។ ការសួរដេញដោលសាក្សី អុង ចុងហឿង គឺធ្វើឡើងឆ្លាស់គ្នាជាមួយនឹងលោកសាក្សី សួង ស៊ីគឿន ដោយសារមូលហេតុសុខភាព និងវ័យចាស់ជរារបស់សាក្សី ស៊ីគឿន ។ សវនាការសួរដេញដោលសាក្សី អុង ចុងហឿង ភាគច្រើនគឺធ្វើឡើងត្រឹមតែរយៈពេលកន្លះថ្ងៃតែប៉ុណ្ណោះ ។ ការផ្ដល់សក្ខីកម្មនេះគឺផ្ដោតសំខាន់លើការអំពាវនាវរបស់មេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យឲ្យបញ្ញាជន និងអ្នកការទូតត្រលប់ចូលក្នុងប្រទេសវិញ ដើម្បីចូលរួមកសាងប្រទេស ប៉ុន្ដែក្រោយត្រលប់ចូលក្នុងប្រទេសភាគច្រើននៃអ្នកទាំងអស់នោះត្រូវបានចាប់ដាក់ក្នុងមន្ទីរឃុំឃាំង និងត្រូវបានសម្លាប់តែម្ដង ។



សាក្សី អុង ចុងហឿង

ការសួរដេញដោលសាក្សី អុង ចុងហឿង បានចាប់ផ្ដើមដោយចៅក្រមអង្គជំនុំជម្រះដោយចោទសួរទាក់ទងនឹងប្រវត្តិសាវតាររបស់លោកសាក្សី បន្ទាប់មកវេទិកាសួរដេញដោលត្រូវបានប្រគល់ជូនសហព្រះរាជអាជ្ញា មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី និងមេធាវីការពារក្ដីទាំងបីក្រុម ។

## ១) ប្រវត្តិសាវតាររបស់សាក្សី

ប្រធានអង្គជំនុំជម្រះ លោកចៅក្រម និល ណុន បានសាកសួរដេញដោល អុង ចុងហឿង ទាក់ទងនឹងប្រវត្តិសាវតាររបស់សាក្សីមុនពេលប្រគល់វេទិកាសួរដេញដោលជូនតំណាងសហព្រះរាជអាជ្ញា ។ ឆ្លើយតបនឹងសំណួររបស់អង្គជំនុំជម្រះ សាក្សី អុង ចុងហឿង បានជម្រាបជូនលោកប្រធានអង្គជំនុំជម្រះថា លោកកើតនៅថ្ងៃទី៧ ខែសីហា ឆ្នាំ១៩៤៥ ហើយបច្ចុប្បន្នលោកកំពុងរស់នៅប្រទេស ប៊ែលហ្ស៊ិក ទីក្រុងប្រ៊ុចសែល ។ លោកបានបញ្ជាក់ថា ឪពុករបស់លោកឈ្មោះ អុង លី ហៅ ដោក និងម្ដាយឈ្មោះ នាង ទ្រីយឿ រីឯប្រពន្ធរបស់លោកមានឈ្មោះថា ជួ ប៊ុននី និងមានកូនស្រីពីរនាក់ ។ បន្ទាប់មក លោកប្រធានអង្គជំនុំជម្រះបានបញ្ជាក់ជូនសាក្សីអំពីសិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង និងកាតព្វកិច្ចដែលសាក្សីត្រូវអនុវត្តនៅចំពោះមុខអង្គជំនុំជម្រះ ។

ដុយពីសាក្សីមុនៗសាក្សី អុង ចុងហឿង បានបញ្ជាក់ថា លោកមិនត្រូវការមេធាវីប្រឹក្សាដើម្បីជួយដល់លោកឡើយ ។ បន្ទាប់ពីបញ្ចប់ការសួរដេញដោល លោកប្រធានអង្គជំនុំជម្រះបានប្រគល់វេទិកាជូនសហព្រះរាជអាជ្ញាដើម្បីបន្តការសួរដេញដោលសាក្សី ។

## ២) ការសួរសាក្សីដោយសហព្រះរាជអាជ្ញា

នៅអំឡុងពេលនៃការសួរដេញដោលសាក្សី អុង ចុងហឿង សហព្រះរាជអាជ្ញាបានចំណាយពេលមួយរសៀលថ្ងៃទី៧ និងទី៨ ខែសីហា ឆ្នាំ២០១២ ដើម្បីសាកសួរសាក្សីដោយផ្ដោតសំខាន់លើការជំរុញរបស់ អៀង សារី ចំពោះបញ្ញវន្ត និងខ្មែររស់នៅឯបរទេសឲ្យវិលត្រលប់ចូលក្នុងប្រទេស និងការបាត់ខ្លួនរបស់អ្នកទាំងនោះជាបន្តបន្ទាប់ ។

សូមបញ្ជាក់ថា ការសាកសួរដោយសហព្រះរាជអាជ្ញាលើរូបសាក្សី អុង ចុងហឿង បានចាប់ផ្ដើមដោយលោកសហព្រះរាជអាជ្ញារងជាតិ ចាន់ តារារស្មី និងបន្ទាប់មក គឺលោកតំណាងសហព្រះ រាជអាជ្ញាអន្តរជាតិ វ៉ាំងសង់ វ៉ាយដ៍ ដេស្វាងល ។

### ក) សហព្រះរាជអាជ្ញារងជាតិ

### ក.១) ប្រវត្តិសិក្សា និងការចូលរួមក្នុងចលនានយោបាយនៅប្រទេសបារាំង

សហព្រះរាជអាជ្ញារងជាតិលោក ចាន់ តារាវស្ម៊ី បានចាប់ផ្ដើមដោយចោទសួរសំណួរទាក់ទងនឹងប្រវត្តិនៃការសិក្សារៀនសូត្ររបស់សាក្សី អ៊ុង ចុងហឿង ។ ឆ្លើយតបនឹងសំណួរដំបូងរបស់លោកសហព្រះរាជអាជ្ញារងជាតិ សាក្សីបានរៀបរាប់ថា លោកធ្លាប់បានរៀនសូត្រកម្រិតបឋមសិក្សានៅស្រុកកោះធំ ហើយបានបន្តរៀននៅកម្រិតមធ្យមសិក្សានៅទីក្រុងភ្នំពេញ ។ បន្ទាប់មកនៅក្នុងឆ្នាំ១៩៦៥ លោកបានជាប់ទៅរៀននៅប្រទេសបារាំងជំនាញសេដ្ឋកិច្ចនយោបាយ ។ សាក្សីបានបន្ថែមថា មូលហេតុដែលនាំឲ្យលោកមានបំណងចង់ទៅសិក្សានៅប្រទេសបារាំង គឺដោយសារប្រទេសបារាំង គឺជាប្រទេសនិមិត្តរូបនៃការសិក្សា ។ ឆ្លើយតបនឹងសំណួរបន្ទាប់ដែលសួរថា តើលោកធ្លាប់បានរស់នៅប្រទេសបារាំងរយៈពេលប៉ុន្មានឆ្នាំ? សាក្សី ចុងហឿង បានឆ្លើយថា លោកធ្លាប់បានរស់នៅប្រទេសបារាំងចាប់តាំងពីឆ្នាំ១៩៦៥ រហូតដល់ឆ្នាំ១៩៧៦ ។ នៅអំឡុងពេលនោះ លោកធ្លាប់បានចូលរួមជាមួយសហភាពនិស្សិតខ្មែរដែលហៅថា “អ៊ុយ.អឺ.កា” បន្ទាប់ពីមានសេចក្ដីថ្លែងការណ៍ប្រាំចំណុចរបស់សម្ដេច សីហនុ នៅក្រោយរដ្ឋប្រហារទម្លាក់ព្រះអង្គចេញពីអំណាចនៅក្នុងឆ្នាំ១៩៧០ ។ លោកបន្តទៀតថា ការណ៍ដែលលោកចូលរួមនៅក្នុងសភាពនិស្សិតខ្មែរនេះ គឺដោយសារថា នៅពេលដែលលោកនៅប្រទេសកម្ពុជា លោកតែមានការគោរពស្រឡាញ់ខ្លាំងលើអ្នកស្អាតស្អំបីរូប គឺ ខៀវ សំផន, ហ៊ូ យន់ និង ហ៊ូ នឹម ។ នៅពេលដែលលោកទៅដល់ស្រុកបារាំង លោកបានដឹងថា អ្នកទាំងបីរូបនេះធ្លាប់ជាសមាជិកនៃសហភាពនិស្សិតខ្មែរ ដូច្នេះហើយលោកក៏ចង់យកតម្រាប់តាមគំរូអ្នកទាំងបី ។ បន្ទាប់មក លោកសហព្រះរាជអាជ្ញារង តារាវស្ម៊ី បានបន្តសួរទៀតថា តើអ្វីទៅជាគោលបំណងសំខាន់នៃការបង្កើតសហភាពនិស្សិតខ្មែរនាពេលនោះ? សាក្សីបានឆ្លើយតបនឹងសំណួរនេះថា ក្រោយសង្គ្រាមលោកលើកទីពីរ បានបញ្ចប់និស្សិតខ្មែរដែលបានទៅរៀននៅប្រទេសបារាំងមានចំនួនមិនច្រើនទេ ។ ពីដំបូងនិស្សិតខ្មែរទាំងនោះមានព្រះអង្គម្ចាស់ យុត្តិវង្ស ចូលរួមបង្កើតសមាគមមួយដែលបារាំងហៅថា “អាសូស៊ីអាស្យុង អា.អឺ.កា” ដែលមានសមាជិកប្រហែល២០នាក់តែប៉ុណ្ណោះ ។ នៅពេលនោះទាំងនិស្សិតដែលនិយមនិន្នាការឆ្វេង និងនិយមនិន្នាការស្ដាំសុទ្ធតែតស៊ូដើម្បីទាមទារឯករាជ្យជូនប្រទេសជាតិ ។ ប៉ុន្តែក្រោយមក ការតស៊ូនេះក៏បានបែកចេញជាពីរ ។ ទី១ គឺអ្នកដែលមាននិន្នាការនិយមឆ្វេង និងទី២ គឺអ្នកដែលមាននិន្នាការនិយមស្ដាំ ។ សាក្សីបញ្ជាក់ថា សហភាពនិស្សិតខ្មែរដែលបានចូលរួមជាមួយនោះគឺមាននិន្នាការនិយមទៅខាងឆ្វេង ។ ឆ្លើយតបនឹងសំណួររបស់លោកសហព្រះរាជអាជ្ញារងដែលសួរថា តើនរណាជាប្រធានសហភាពនិស្សិតខ្មែរនាពេលនោះ? សាក្សី ចុងហឿង បានអះអាងថា នៅពេលដែលលោកទៅដល់ប្រទេសបារាំងបានបន្តិច គឺលោក តូច ខាំឌឿន ធ្វើជាប្រធាន ប៉ុន្តែក្រោយមក លោក សួង ស៊ីគឿន បានចូលធ្វើជាប្រធាន និងបានបង្កើតជាគណបក្សសហភាពនិស្សិតខ្មែរនៅពេលបន្ទាប់ ។ សាក្សីបន្តថា អ្នកផ្ដួចផ្ដើមគំនិតក្នុងការបង្កើតសហភាពនិស្សិតខ្មែររួមមាន អៀង សារី, ខៀវ សំផន, និង ជួន មុំ រួមជាមួយបុគ្គលមួយចំនួនទៀតដែលលោកមិនអាចចាំឈ្មោះអស់ ។ លោកមិនច្បាស់ថា សហភាពនិស្សិតខ្មែរនេះត្រូវបានបង្កើតឡើងនៅឆ្នាំណាពិតប្រាកដទេ ប៉ុន្តែបើតាមការចងចាំរបស់លោក គឺប្រហែលជាត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៥៦ ហើយលោកបានចូលរួមជាមួយនឹងសហភាពនេះនៅក្រោយពេលដែល លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្ដេច សីហនុ ចេញពីអំណាច ។

បន្ទាប់មក លោកសហព្រះរាជអាជ្ញារង បានបន្តសួរទៀត ថា តើសាក្សីធ្លាប់បានឮអំពីពាក្យថា ខ្មែរក្រហម ដែរឬទេ នៅពេលដែលលោកកំពុងសិក្សានៅប្រទេសបារាំង? សាក្សីបានបញ្ជាក់ថា លោកធ្លាប់បានឮពាក្យ ខ្មែរក្រហម តាំងពីពេលដែលលោកនៅប្រទេសកម្ពុជានៅឡើយ ហើយពាក្យនេះសម្រាប់លោកគឺជាពាក្យដែលតំណាងឲ្យភាពស្អាតស្អំដោយសារមាន ខៀវ សំផន, ហ៊ូ យន់, ហ៊ូ នឹម ជានិមិត្តរូប ។

### ក.២) ការបង្កើតរណសិរ្សរួបរួមជាតិកម្ពុជា

ឆ្លើយតបនឹងសំណួររបស់លោកសហព្រះរាជអាជ្ញារងជាតិទាក់ទងនឹងគោលបំណងនៃការបង្កើតរណសិរ្សរួបរួមជាតិកម្ពុជា សាក្សី ចុងហឿង បានពន្យល់ថា រណសិរ្សរួបរួមជាតិកម្ពុជា

បង្កើតឡើងនៅទីក្រុងប៉េកាំងបន្ទាប់ពី សម្តេច សីហនុ បានចេញសេចក្តីថ្លែងការណ៍ប្រាំចំណុច ។ រណសិរ្សនេះ មានគោលបំណងរួបរួមខ្មែរទាំងអស់ដើម្បីកសាងសង្គមមួយដែលមានយុត្តិធម៌ និងស្មើភាពគ្នា ។ ក្រុមដែលបានចូលរួមនៅក្នុងរណសិរ្សនោះមានទាំងក្រុមកុម្មុយនីស្ត សក្តិភូមិ បញ្ញវន្តចម្រើនដែលកម្មវិធីនៅពេលនោះគឺជាកម្មវិធីបើកទូលាយ ។ សាក្សីបន្តថា រណសិរ្សរួបរួមជាតិកម្ពុជានៅពេលនោះ គឺមានសម្តេច នរោត្តម សីហនុ ជាប្រធាន ។ លោកបន្ថែមថា បើតាមលោកដឹងរណសិរ្សរួបរួមជាតិកម្ពុជាដំណើរការបានគឺផ្អែកលើហិរញ្ញវត្ថុដែលឧបត្ថម្ភដោយរដ្ឋាភិបាលប្រទេសចិន ។ បន្ទាប់មក លោកសហព្រះរាជអាជ្ញារង តារាវស្នី បានចោទសួរទៀតថា តើសាក្សីមានធ្លាប់ដឹងថា ខៀវ សំផន, នួន ជា និង អៀង សារី បានចូលរួមសកម្មភាពជាមួយនឹងរណសិរ្សរួបរួមជាតិកម្ពុជាដែរឬទេ? សាក្សីបានបញ្ជាក់ថា នៅពេលនោះធ្លាប់ឮឈ្មោះរបស់ ខៀវ សំផន ប៉ុន្តែលោកពុំដែលបានជួបជាមួយ ខៀវ សំផន ទេ ប៉ុន្តែលោកគ្រាន់តែបានដឹងថា ខៀវ សំផន ពិតជាមានឈ្មោះនៅក្នុងរណសិរ្ស ។ នួន ជា លោកមិនធ្លាប់ឮឈ្មោះទេ នៅពេលនោះ ។ ចំពោះ អៀង សារី លោកសាក្សីបានអះអាងថា ក្រោយពេលរដ្ឋប្រហារទម្លាក់សម្តេច សីហនុ ប្រហែលជា២ឆ្នាំ អៀង សារី បានធ្វើដំណើរទៅទីក្រុងប៉េកាំងដើម្បីតំណាងឲ្យភាគីក្នុងស្រុក ។ សាក្សីបានសង្កត់ធ្ងន់ថា នៅពេលនោះ អៀង សារី មានឥទ្ធិពលខ្លាំងលើនិស្សិតខ្មែរដែលរៀននៅបរទេស ។

លោកសហព្រះរាជអាជ្ញារង តារាវស្នី បានបន្តសួរទាក់ទងនឹងការធ្វើសកម្មភាពរបស់រណសិរ្សរួបរួមជាតិកម្ពុជានៅក្នុងប្រទេសកម្ពុជាថា តើរណសិរ្សនេះផ្តោតសំខាន់លើតំបន់ណាខ្លះ? ឆ្លើយតបនឹងសំណួរនេះ សាក្សីបានបញ្ជាក់ថា សកម្មភាពរបស់រណសិរ្សភាគច្រើន គឺធ្វើនៅតាមតំបន់ជនបទ ។ ទាក់ទងនឹងមធ្យោបាយផ្សព្វផ្សាយរបស់រណសិរ្សនេះ សាក្សី ថុងហឿង បានអះអាងថា អៀង សារី បានផ្សព្វផ្សាយព័ត៌មានតាមរយៈព្រឹត្តិប័ត្ររបស់រណសិរ្ស និងធ្វើការតស៊ូដោយចំហតាមរយៈការទាក់ទងជាមួយនិស្សិតនៅឯបរទេសដោយមានការបង្ហាត់បង្រៀនពីគោលចំហនៃការតស៊ូនៅក្នុងប្រទេសដែលមានខ្លួនជាអ្នកតំណាង ។

នៅអំឡុងពេលនៃការសួរដេញដោលទាក់ទងនឹងរណសិរ្សរួបរួមជាតិកម្ពុជា លោកសហព្រះរាជអាជ្ញារងជាតិបានងាកទៅសួរទាក់ទងនឹងពាក្យថា "សីហនុ និយម" តើពាក្យ "សីហនុ និយម" បង្កើតឡើងដោយនរណានិងក្នុងគោលបំណងអ្វី? លោកសាក្សីបានឆ្លើយថា ពាក្យ"សីហនុ និយម" គឺបង្កើតឡើងដោយសម្តេច សីហនុ ។ ពាក្យនេះសំដៅលើអ្នកដែលមាននិន្នាការស្និទ្ធនឹងព្រះបរមរាជវាំង និងអ្នកដែលរស់នៅជុំវិញសម្តេច សីហនុ ។ អ្នកទាំងនោះមានដូចជា សម្តេច ប៉ែន នុត និងលោក សារិន ឆាក ហើយអ្នកនៅជុំវិញលោក សារិន ឆាក មានលោក វ៉ាន់ ពីនី, លោក ចាន់ យូរ៉ាន់ និងប្រហែលជាមានលោក ហោ ណាំហុង ដែរ ។

បន្ទាប់ពីលោកសហព្រះរាជអាជ្ញារងបានត្រលប់មកសួរទាក់ទងនឹងការិយាល័យទទួលបន្ទុកបេសកកម្មរបស់រណសិរ្សរួបរួមជាតិកម្ពុជានៅទីក្រុងប៉ារីសថា តើការិយាល័យនោះមានបេសកកម្មចម្បងអ្វីខ្លះនៅពេលនោះ? សាក្សីបានឆ្លើយថា ការិយាល័យនោះដឹកនាំដោយលោក ឱក សុគន្ធ ដោយមានគោលដៅធំបី ។ ទី១ គឺឃោសនាជាមួយនិស្សិតខ្មែរនៅប្រទេសបារាំង និងនៅប្រទេសអឺរ៉ុបផ្សេងទៀត ។ ទី២ គឺផ្សាយព័ត៌មានបន្តទៅព័ត៌មានអន្តរជាតិនានាដែលប្រចាំនៅទីក្រុងប៉ារីស ។ ទី៣ គឺទាក់ទងនឹងគណបក្សនយោបាយផ្សេងៗទៀតនៅប្រទេសបារាំង និងឥស្សរជនបារាំងផ្សេងៗទៀត ។ ទាក់ទងនឹងការធ្វើទស្សនកិច្ចរបស់គណៈប្រតិភូនៃរណសិរ្សរួបរួមជាតិកម្ពុជាទៅបរទេស សាក្សី ថុងហឿង បានរៀបរាប់ថា លោកធ្លាប់ដឹងថាក្នុងចំណោមគណៈប្រតិភូដែលចេញទៅបរទេស មាន អៀង សារី ក្នុងនោះក៏មានលោក សួង ស៊ីគឿន ហើយពេលខ្លះមានលោក ចាន់ យូរ៉ាន់ និងអ្នកដទៃផ្សេងទៀតដែលលោកមិនអាចចាំអស់ ។សាក្សីបន្តថា អៀង សារី ធ្លាប់បានចូលរួមប្រជុំនិងដឹកនាំគណៈប្រតិភូពីប្រទេសកម្ពុជាទៅបរទេសច្រើនដាងគេ ពេលខ្លះទៅអាមេរិកខាងត្បូងទៅអាហ្វ្រិក និងពេលខ្លះទៅប៉ារីសដើម្បីជួបជាមួយខ្មែរដែលរស់នៅបរទេស ។ បន្ថែមពីលើនេះ អៀង សារី ក៏ធ្លាប់បានចូលរួមប្រជុំនៅអង្គការសហប្រជាជាតិដោយលើកឡើងអំពីចលនាតស៊ូនៅកម្ពុជាគឺធ្វើឡើងដោយឯករាជ្យ ម្ចាស់ការ ពឹងលើកម្លាំងខ្លួនឯង និងថាប្រទេសកម្ពុជាជាប្រទេសឯករាជ្យមិនចូលបក្សសម្ព័ន្ធ ។

### ក.៣) ដំណឹងអំពីការជម្លៀសប្រជាជនពីទីក្រុងភ្នំពេញ

លោកសហព្រះរាជអាជ្ញារងជាតិ គារ៉ាវស្មី បានបន្តសួរទៀតថា នៅអំឡុងពេលរស់នៅប្រទេសបារាំង មុនពេលត្រលប់មកប្រទេសកម្ពុជាវិញ តើលោកសាក្សីធ្លាប់បានឮអំពីការធ្វើទារុណកម្ម ឬការកាប់សម្លាប់ប្រជាជនកម្ពុជានៅផ្ទៃក្នុងប្រទេសដែរឬទេ? ឆ្លើយតបនឹងសំណួរនេះ សាក្សីបានរៀបរាប់ថា ក្រោយពេលមានការជម្លៀសប្រជាជនពីទីក្រុងភ្នំពេញលោកបានឮថា មានការធ្វើបាបប្រជាជននៅតាមជនបទមិនមានអាហារហូបចុកគ្រប់គ្រាន់ ប៉ុន្តែលោកមិនជឿថា ប្រទេសកម្ពុជាអត់បាយនោះ



(រូបភាពមជ្ឈមណ្ឌលឯកសារកម្ពុជា)

ទេ ។ សូម្បីតែបងរបស់លោកឃាត់ក៏លោកនៅតែមិនជឿតាមដែរ ហើយនៅពេលនោះ លោកក៏មិនជឿថា មានខ្មែរសម្លាប់ខ្មែរនោះទេ ។ បន្ទាប់ពីបានឮសាក្សីនិយាយអំពីការជម្លៀសប្រជាជន លោកសហព្រះរាជអាជ្ញារងបានបន្តសួរទាក់ទងនឹងការជម្លៀសប្រជាជនពីទីក្រុងភ្នំពេញថាតើ លោកសាក្សីបានដឹងអំពីដំណឹងនោះដោយរបៀបណា? សាក្សី ចុងហឿង បានឆ្លើយតបចំពោះសំណួរនេះថា សារព័ត៌មានអន្តរជាតិ ជាពិសេសសារព័ត៌មានបារាំងនៅពេលនោះបាននិយាយច្រើនពីប្រទេសកម្ពុជាដោយលើកឡើងថា មានបរទេសជាច្រើនបានចូលជ្រកកោននៅក្នុងស្ថានទូតបារាំង ហើយមានការហាមឃាត់មិនឲ្យខ្មែររត់ចូលក្នុងស្ថានទូតនោះឡើយ ។ ប៉ុន្តែលោកនៅតែមិនជឿថា ខ្មែរធ្វើដូច្នេះទេ ។ ឆ្លើយតបនឹងសំណួររបស់លោកសហព្រះរាជអាជ្ញារងដែលសួរថា តើសាក្សីបានទទួលព័ត៌មានអ្វីខ្លះពី អៀង សារី ឬមេដឹកនាំផ្សេងទៀតអំពីបញ្ហាជម្លៀសប្រជាជននៅអំឡុងពេលដែលលោករស់នៅទីក្រុងប៉ារីសដែរឬទេ? សាក្សីបានបញ្ជាក់ថា លោកនៅចាំថា នៅអំឡុងដែល អៀង សារី ធ្វើដំណើរទៅអង្គការសហប្រជាជាតិ លោកធ្លាប់បានឮ អៀង សារី និយាយប្រាប់អ្នកកាសែតថា ប្រជាជនខ្មែរដែលត្រូវបានជម្លៀសនោះបានចាប់ផ្ដើមត្រលប់ចូលទីក្រុងវិញបណ្ដើរៗហើយ ។ លោកបន្ថែមថា ដោយសារតែលោកមានសន្ដានចិត្តជាមួយនឹងក្រុមខ្មែរក្រហមស្រាប់ និងដោយឃើញបងៗ(ដែលលោកសំដៅលើ ខៀវ សំផន អៀង សារី និងអ្នកផ្សេងៗទៀតដែលធ្លាប់បានរៀនសូត្រនៅប្រទេសបារាំង) បានលះបង់តស៊ូគ្រប់បែបយ៉ាងដើម្បីឈ្នះ និងជាអ្នកដែលមាន

ចំណេះដឹងខ្ពង់ខ្ពស់ ជាហេតុធ្វើឲ្យលោកគិតថាអ្នកទាំងនោះមិនអាចសម្លាប់ខ្មែរគ្នាឯងទេ ។ ដូច្នេះនៅពេលដែល អៀង សារី និយាយស្រុះស្រួលជាមួយលោកបន្តិច លោកក៏បានជឿជាក់១០០ភាគរយលើសម្តីទាំងនោះតែម្តង ។

### ក.៤) ដំណើរវិលត្រលប់ចូលក្នុងប្រទេសដោយស្ម័គ្រចិត្ត

ទាក់ទងនឹងដំណើរវិលត្រលប់ចូលក្នុងប្រទេសកម្ពុជារបស់សាក្សី លោកសហព្រះរាជអាជ្ញារង គារាវស្មី បានចោទសួរថា តើលោកសាក្សីវិលត្រលប់ពីប្រទេសបារាំងចូលមកក្នុងប្រទេសកម្ពុជាវិញ ដោយស្ម័គ្រចិត្តឬដោយមានកត្តាជំរុញណាមួយ? ឆ្លើយតបនឹងសំណួរនេះ សាក្សី ថុងហឿង បានបញ្ជាក់ថា ការវិលត្រលប់របស់លោកគឺជាការវិលត្រលប់ដោយស្ម័គ្រចិត្ត មិនមានការបង្ខិតបង្ខំអ្វីឡើយ ។ ម្យ៉ាងវិញទៀត ដោយសារតែភរិយារបស់លោកបានត្រលប់ចូលក្នុងប្រទេសកម្ពុជាតាំងពីខែមករា ឆ្នាំ១៩៧៦ គឺត្រលប់ចូលក្នុងប្រទេសមុនលោក៦ខែ ។ ដូច្នេះការត្រលប់ចូលក្នុងប្រទេសវិញគឺដោយសារមូលហេតុច្រើនយ៉ាង ។ សាក្សីបន្តថា នៅពេលដែលលោកបានត្រលប់ចូលក្នុងប្រទេសវិញ លោកបានធ្វើដំណើររួមជាមួយប្រជាជនខ្មែរមួយចំនួនផ្សេងទៀតមានដូចជា អតីតទាហានមកពីអាមេរិកប្រហែល ១០នាក់មានការធារីរដ្ឋាភិបាលរួបរួមជាតិកម្ពុជានៅប្រទេសគុយបា គឺលោក ហៃ គឹមសៀង និងភរិយាដែលជាអតីតតារាភាពយន្តខ្មែរ លោកស្រី ម៉ាន់នីណា គីរីរ៉ាត់ រួមជាមួយកូនស្រីម្នាក់ និង បន្ទាប់មកមានសមាជិកក្រុមគ្រួសារជនជាប់ចោទ អៀង ធីរិទ្ធ មួយចំនួនទៀតក៏បានរួមដំណើរជាមួយគ្នានៅពេលនោះដែរ ។ ក្រុមគ្រួសារ អៀង ធីរិទ្ធ ដែលបានត្រលប់ចូលប្រទេសនៅពេលនោះរួមមាន ម្តាយ,ប្អូនស្រីពីរនាក់ និងក្មួយប្រុសស្រីចំនួនបីនាក់ ។ នៅពេលធ្វើដំណើរនោះសាក្សីបានកត់សម្គាល់ឃើញ ថាសមាជិកគ្រួសារទាំងអស់របស់ អៀង ធីរិទ្ធ គឺជាអ្នកដែលមានអត្តចរិកចេះគួរសម ហើយម្តាយរបស់ អៀង ធីរិទ្ធ ជាមនុស្សគួរសមមិនចេះនិយាយស្តីច្រើនដែលធ្វើឲ្យលោកចាត់ទុកម្តាយរបស់ អៀង ធីរិទ្ធ ដូចជាម្តាយរបស់លោកដែរ ។ ប៉ុន្តែលោកមិនបានដឹងអំពីមូលហេតុពិតប្រាកដនៃការវិលត្រលប់ចូលក្នុងប្រទេសរបស់ក្រុមគ្រួសាររបស់ អៀង ធីរិទ្ធ នេះទេ ។ សាក្សីបានបន្តទៀតថា មនុស្សភាគច្រើនដែលត្រលប់ចូលក្នុងប្រទេសជាមួយលោកនៅពេលនោះបានបញ្ជាក់ថា ខ្លួនចង់ចូលរួមការពារទឹកដីប្រទេសកម្ពុជា ។

លោក គារាវស្មី បានបន្តចោទសួរលោកសាក្សីទាក់ទងនឹងការទទួលបានដំណឹងពីស្ថានភាពនៅក្នុងប្រទេសកម្ពុជានៅមុនពេលត្រលប់ពីប្រទេសបារាំង ថាតើលោកសាក្សីទទួលបានព័ត៌មានអ្វីខ្លះមុនពេលលោកចូលមកកម្ពុជានៅពេលនោះ? លោកសាក្សី ថុងហឿង បានឆ្លើយតបចំពោះសំណួរនេះថា ដំណឹងដែលលោកចង់បានខ្លាំងជាងគេ គឺព័ត៌មានទាក់ទងនឹងភរិយារបស់លោកដែលបានវិលត្រលប់ចូលក្នុងប្រទេសកម្ពុជាមុនលោក ព្រោះលោកមិន



អៀង សារី ដឹកនាំគណៈប្រតិភូត្រឡប់មកពីប រទេស

ដែលបានទទួលដំណឹងអ្វីទាំងអស់ពីភរិយាលោក ។ ប៉ុន្តែនៅពេលបន្ទាប់ លោកក៏ឃើញមានមិត្តភក្តិរបស់លោកបានចេញទៅក្រៅប្រទេសជាមួយគណៈប្រតិភូមានដូចជា សួង ស៊ីគឿន និង អ៊ិន សុភាព ហើយលោកក៏បានសាកសួរអ្នកទាំងនេះអំពីស្ថានភាពរបស់ភរិយាលោកដែលកំពុងរស់នៅក្នុងប្រទេសកម្ពុជា ។

អ្នកទាំងនេះបានឆ្លើយតបថា“ អ្នកទាំងអស់គ្នាសុខសប្បាយ ទេ គាត់នៅវិទ្យាស្ថានគរុកោសល្យ” ក្រោយពីបានឮមិត្តរបស់លោកនិយាយដូច្នេះ លោក ក៏ជឿមិត្តរបស់លោកតែម្តង ប៉ុន្តែក្រោយមក ទើបលោកដឹងថា មិត្តភក្តិរបស់លោកចេះតែនិយាយឲ្យរួចពីមាត់ តែប៉ុណ្ណោះ ។

ចំពោះដំណឹងផ្សេងៗ ទៀតដែលលោកទទួលបាន គឺមានព័ត៌មានពីជនភៀសខ្លួនតែរត់ចេញពីកម្ពុជា ហើយនិយាយថា ខ្មែរពិបាកណាស់ឥឡូវមិនមានបាយទឹកហូបចុកគ្រប់គ្រាន់នៅតាមទីជនបទទេ ប៉ុន្តែលោកនៅតែមិនទាន់ជឿដោយសារលោក




...កពីប រទេស (រូបភាពមជ្ឈមណ្ឌលឯកសារកម្ពុជា)

ធ្លាប់រស់នៅស្រុកខ្មែរ លោកនឹកឃើញពាក្យថា “ទីណាមានទឹក ទីនោះមានត្រី” ដូច្នេះប្រជាជនមិនអាចអត់បាយហូបនោះទេ ។

លោកសហព្រះរាជអាជ្ញារង តារាស្មី បានបន្តសួរទាក់ទងនឹងស្ថានភាពនៅពេលដែលសាក្សី អ៊ុង ចុងហឿង បានឈប់សំចតនៅទីក្រុងប៉េកាំងប្រទេសចិនមុនពេលមកដល់ប្រទេសកម្ពុជា ។

សាក្សីបានរៀបរាប់ថា បន្ទាប់ពីចាកចេញពីប្រទេសបារាំង យន្តហោះដែលលោកធ្វើដំណើរមកបានឈប់សំចតនៅទីក្រុងប៉េកាំងរយៈពេល២ថ្ងៃ ។ នៅពេលទៅដល់ទីនោះ លោកបញ្ជាក់ថាមានក្រុមយុវជន៤ ឬ៥នាក់ ដែលមើលទៅហាក់បីដូចជាមិនមែនជាអ្នកការទូតបានរង់ចាំទទួលលោក និងអ្នកផ្សេងទៀតនៅអាកាសយានដ្ឋាននៅទីក្រុងប៉េកាំង ។ សាក្សីបន្តថា សមាជិកក្រុមគ្រួសាររបស់ អៀង ធីរិទ្ធ និង អៀង សារី មានអ្នកការទូតចិនមកទទួលយកទៅ ប៉ុន្តែលោកមិនបានដឹងថាអ្នកទាំងនោះស្នាក់នៅទីណាទេ ។ រីឯ លោក ហៃ គឹមសៀង ដែលជាអ្នកការទូតនៅប្រទេសគុយបា និងជាអតីតនិស្សិតដែលធ្លាប់បានសិក្សានៅទីក្រុងម៉ូស្គូ បានទៅស្នាក់នៅក្នុងស្ថានទូតប្រទេសកម្ពុជាប្រចាំទីក្រុងប៉េកាំង ។ សម្រាប់សាក្សី ចុងហឿង និងអ្នកផ្សេងៗ ទៀតបានទៅស្នាក់នៅសណ្ឋាគារ ។ នៅទីនោះសាក្សីបានបញ្ជាក់ថា លោកបានជួបជាមួយនឹងលោក ពេជ ឈាង ដែលជាអ្នកការទូតតំណាងឲ្យកម្ពុជាប្រជាធិបតេយ្យប្រចាំនៅទីក្រុងប៉េកាំង និងបានជជែកគ្នាអំពីបញ្ហាប្រទេសកម្ពុជា ។ លោក ពេជ ឈាង បានសួរនាំសាក្សីអំពីការយល់ឃើញរបស់បញ្ញាជនដែលរស់នៅបរទេសចំពោះរបបកម្ពុជាប្រជាធិបតេយ្យ ។ ពេលនោះសាក្សីបានប្រាប់ ពេជ ឈាង ថា អ្នករស់នៅបរទេសបានគាំទ្រ និងរង់ចាំឲ្យមានការបើកទ្វារប្រទេសដើម្បីឲ្យអ្នកទាំងនោះបានទៅធ្វើទស្សនកិច្ចដោយផ្ទាល់ភ្នែក ព្រោះថា បញ្ញាជនមួយចំនួនមានការសង្ស័យដោយសារតែមានការផ្សព្វផ្សាយអំពីរឿងមិនល្អអំពីរបបនេះ(របបខ្មែរក្រហម) ។ បន្ទាប់មក លោក ពេជ ឈាង បាននិយាយថា“ពួកហ្នឹងជាពួកសេរីនិយមអស់ហើយ បដិវត្តន៍កម្ពុជាលែងត្រូវការពួកហ្នឹងហើយ” ។ បន្ទាប់ពីបានឮការលើកឡើងរបស់លោក ពេជ ឈាង ដូច្នេះ សាក្សីគិតថា គឺប្រហែលដោយសារតែលោក ពេជ ឈាង មិនទាន់យល់អំពីសភាពការណ៍អន្តរជាតិ និងបញ្ហាទំនាក់ទំនងអន្តរជាតិ និងប្រហែលជាលោកកំពុងតែសប្បាយភ្លើតភ្លើននឹងជ័យជម្នះទើបបានជានិយាយដូច្នេះ ។ សាក្សីបានអះអាងបន្ថែមថា បន្ទាប់ពីបានឮសម្តីរបស់អ្នកការទូតមួយរូបនិយាយដូច្នេះលោកក៏មានការខកចិត្ត និងមានការសង្ស័យនៅក្នុងអារម្មណ៍ ប៉ុន្តែក្រោយពីបានពិចារណាចុះឡើង លោកគិតថា ប្រហែលជាមិនមានបញ្ហាអ្វីឡើយ ព្រោះជ្រុលដំណើរហើយ ។

### ក.៥) ទិដ្ឋភាពទីក្រុងភ្នំពេញក្រោយការមកដល់កម្ពុជា

លោកសហព្រះរាជអាជ្ញារង តាវារស្មី បានប្តូរប្រធានបទដោយងាកទៅសួរទាក់ទងនឹងទិដ្ឋភាពនៃទីក្រុងភ្នំពេញ និងហេតុការណ៍ដែលបានកើតឡើងចំពោះលោកសាក្សីនៅពេលដែលលោកធ្វើដំណើរមកដល់ទីក្រុងភ្នំពេញ ។ សាក្សី អុង ថុងហឿង បានរៀបរាប់អំពីព្រឹត្តិការណ៍ និងទិដ្ឋភាពនៅដែលលោកបានមកដល់ទីក្រុងភ្នំពេញថា ចំពោះលោកព្រឹត្តិការណ៍នៅពេលនោះហាក់បីដូចជាទើបតែកើតឡើងពីម្សិលមិញ ។ នៅពេលចុះពីលើយន្តហោះលោកមិនបានឃើញអ្វីដូចដែលលោករំពឹងទុកឡើយ គឺឃើញមានតែអ្នកបច្ចេកទេសជនជាតិចិនប៉ុន្មាននាក់ដែលស្លៀកសំលៀកបំពាក់ដូចៗគ្នាតែប៉ុណ្ណោះ ។ សាក្សីបានគិតនៅក្នុងចិត្តថា ប្រសិនបើគេអនុញ្ញាតឲ្យលោកឡើងយន្តហោះទៅវិញ លោកនឹងរត់ឡើងទៅវិញ ដោយសារលោកមិនដឹងថាលោកកំពុងតែស្ថិតនៅក្នុងប្រទេសកម្ពុជា ឬប្រទេសផ្សេង ព្រោះទិដ្ឋភាពប្រទេសកម្ពុជាដែលលោកធ្លាប់រស់នៅមុនពេលចាកចេញទៅស្រុកបារាំង និងទិដ្ឋភាពប្រទេសកម្ពុជា ដែលលោកបានឃើញនៅពេលត្រលប់មកវិញមានសភាពផ្ទុយគ្នាស្រឡះ ។ លោកបន្ថែមថា លោកមិនបានឃើញក្រុមគ្រួសារ និងភរិយារបស់លោកមករង់ចាំទទួលលោកឡើយ ប៉ុន្តែលោកបាន ឃើញវត្តមានរបស់ សូ ហុង (សូ ហុង ឬសាឡុត បាន ដែលត្រូវជាក្មួយប្រុសរបស់ ប៉ុល ពត) ដែលលោកធ្លាប់បានជួបនៅប្រទេសបារាំងរង់ចាំទទួលអ្នកដែលវិលត្រលប់ពីបរទេស និងបានស្នើឲ្យអ្នកទាំងនោះប្រគល់លិខិតឆ្លងដែនទុកនៅអ្នកដែលរង់ចាំទទួលទាំងនោះ ។ សាក្សីបានបញ្ជាក់ថា នៅពេលជួបគ្នានៅប្រទេសបារាំង សាក្សី និង សូ ហុង ធ្លាប់បានជជែកគ្នាលេង ប៉ុន្តែនៅពេលជួបគ្នានៅឯព្រលានយន្តហោះនៅពេលនោះ សូ ហុង បានបង្ហាញអាកប្បកិរិយាធ្វើដូចជាមិនស្គាល់គ្នា ។ បន្ទាប់ពីចាកចេញពីព្រលានយន្តហោះ សាក្សី ត្រូវបានអ្នករង់ចាំទទួលទាំងនោះនាំទៅវិទ្យាស្ថានបច្ចេកទេសមិត្តភាពខ្មែរ-សូវៀត ។ ឆ្លើយតបនឹងសំណួររបស់សហព្រះរាជអាជ្ញាទាក់ទងនឹងឈ្មោះ សូ ហុង សាក្សីបានបញ្ជាក់ថា លោកធ្លាប់បានជួប សូ ហុង នៅទីក្រុងប៉ារីស និងបានដឹងថា សូ ហុង ជាដៃស្តាំរបស់ អៀង សារី ។ លោកបានបញ្ជាក់បន្ថែមថា លោកមិនបានដឹងថា មូលហេតុអ្វីទើបជាអ្នកទាំងនោះដកយកលិខិតឆ្លងដែនរបស់លោកទេ ព្រោះលោកមិនហ៊ានសួរ ហើយសូម្បីតែជម្រាបសួរ ឬសើចដាក់អ្នកទាំងនោះ ក៏លោកមិនហ៊ានដែរ ដោយសារទឹកមុខនារីៗ ដែលទទួលយកលិខិតឆ្លងដែនរបស់លោកនោះមានសភាពម៉ឺងម៉ាត់ដែលធ្វើឲ្យលោកមិនហ៊াননិយាយស្តីអ្វីទាំងអស់ ។ សាក្សីបន្តថា នៅតាមផ្លូវធ្វើដំណើរចេញពីព្រលានយន្តហោះលោកមិនឃើញប្រជាជនរស់នៅតាមផ្ទះឡើយ គឺឃើញតែក្រុមយោធាក្មេងៗរបស់របបកម្ពុជាប្រជាធិបតេយ្យ ។ ឆ្លើយតបនឹងសំណួររបស់លោកសហព្រះរាជអាជ្ញារងដែលសួរថា តើមានការរៀបចំពិធីបដិសណ្ឋារកិច្ចដើម្បីទទួលបញ្ញវន្តដែលត្រលប់ពីបរទេសពីសំណាក់មេដឹកនាំ របបកម្ពុជាប្រជាធិបតេយ្យ ដូចជា អៀង សារី, ខៀវ សំផន ឬ នួន ជា ដែរឬទេ? លោកសាក្សីបានឆ្លើយថា មិនមានការរៀបចំពិធីណាមួយឡើយ ហើយលោកក៏មិនដែលធ្លាប់បានឃើញមុខមេដឹកនាំទាំងអស់នោះដែរលើកលែងតែ អៀង សារី លោកធ្លាប់បានជួបនៅមន្ទីរបឹងត្របែក២ ឬ៣សប្តាហ៍មុនពេលរបបកម្ពុជាប្រជាធិបតេយ្យដួលរលំ ។

### ក.៦) ភារកិច្ចសម្រាប់បញ្ញវន្ត

លោកសហព្រះរាជអាជ្ញារង តាវារស្មី បានបន្តសួរទាក់ទងនឹងការងារដែលរបបកម្ពុជាប្រជាធិបតេយ្យបានផ្តល់ជូនសាក្សីបន្ទាប់ពីពេលដែលសាក្សីបានចូលមកដល់ប្រទេសកម្ពុជា ។ សាក្សីបានឆ្លើយតបចំពោះសំណួរនេះថា ក្រោយពេលមកដល់ភ្លាមលោកត្រូវបានអនុញ្ញាតឲ្យសម្រាក និងមានការទទួលរៀបចំបាយសម្រាប់លោក ប៉ុន្តែលោកបញ្ជាក់ថា បាយនោះគឺជាបាយរឹង ។ បន្ទាប់មក សាក្សីត្រូវបានផ្តល់ភារកិច្ចឲ្យធ្វើស្រែ និងរើផ្ទះនៅខាងក្រោយវិទ្យាស្ថានមិត្តភាពខ្មែរ-សូវៀត ។ ធ្វើការនៅទីនោះ សាក្សីបានជួបមិត្តភិក្តចាស់ៗ និងអ្នកដែលលោកធ្លាប់ស្គាល់មួយចំនួនដែលមានរូបរាងស្គមស្គាំងដូចជាទិដ្ឋភាពនៃជនជាតិជ្វីសដែលលោកធ្លាប់បានមើលក្នុងខ្សែភាពយន្តស្តីពីសង្គ្រាមលោកលើកទី២ដូច្នេះដែរ ។ បុគ្គលដែលលោកធ្លាប់បានឃើញនៅទីនោះមានអ្នកដែលធ្លាប់ធ្វើជាសាស្ត្រាចារ្យល្បីល្បាញដូចជា លោក ឈុក មឹងម៉ៅ និង លោក ភឹង គុន ដែលត្រូវបានបញ្ជាឲ្យរែកទឹកក្នុងរូបរាងស្គមស្គាំង និងបានឃើញលោកទាំងនោះរើធុងសំរាមដើម្បីយកសំបកចេកដែលជាហេតុធ្វើឲ្យលោកមានការហួសចិត្តជាខ្លាំងបន្ទាប់ពីបានឃើញ

ទិដ្ឋភាពដូច្នេះ ។ សាក្សីបន្តថា នៅទីនោះ លោកបានឃើញភរិយារបស់លោកពីចម្ងាយដែលកំពុងធ្វើការ នៅក្នុងសាលាបច្ចេកទេសដូចគ្នាជាមួយលោក ប៉ុន្តែភ្លាមៗនោះ ភរិយារបស់លោកមិនបានដើរមកជិតលោកទេ គឺរហូតដល់ពេលល្ងាចក្រោយចប់កិច្ចការ ទើបលោក និងភរិយាបានជួបគ្នាមួយភ្លែត ដោយភរិយារបស់លោកបានផ្ដែផ្ដាំដល់លោកថា បើគេប្រាប់ឲ្យធ្វើអ្វី គឺធ្វើតាមគេទៅ ហើយកុំយកដៃច្រត់ចង្កេះ និងកុំឆ្ងល់អ្វីទាំងអស់ ។ បន្ថែមពីលើនេះ បើសិនជាមានស្ករ ឬថ្នាំសង្កូវផ្សេងៗកុំអាលចែកឲ្យអ្នកដទៃ ពីព្រោះប្រសិនបើមានអ្នកដឹង នឹងមានបញ្ហាដល់ខ្លួនឯង ហើយភរិយារបស់លោកក៏ចាកចេញពីនោះ ។ ក្រោយពីលោកជួបគ្នា១សប្ដាហ៍ ឬ១០ថ្ងៃទើបលោកត្រូវបានអនុញ្ញាតឲ្យរស់នៅជាមួយភរិយា ។

### ក.៧) មន្ទីរក-១៥ទីកន្លែងកសាងបញ្ញវន្តមកពីបរទេស

លោកសហព្រះរាជអាជ្ញារង គារារស្មី បានប្ដូរប្រធានបទសាកសួរពីភារកិច្ចរបស់សាក្សីនៅសាលាបច្ចេកទេសមកប្រធានបទទាក់ទងនឹងមន្ទីរក-១៥ ដោយលោកបានចោទសួរសាក្សី អ៊ុង ចុងហឿង ថា តើសាក្សីធ្លាប់ស្គាល់មន្ទីរក-១៥ដែរឬទេ? និងថា តើមន្ទីរនេះមានទីតាំងស្ថិតនៅកន្លែងណា ហើយគ្រប់គ្រងដោយនរណា? ឆ្លើយតបនឹងសំណួរនេះ សាក្សីបានបញ្ជាក់ថា មន្ទីរក-១៥ គឺមានទីតាំងនៅសាលាបច្ចេកទេសមិត្តភាពខ្មែរ-សូវៀត ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ឈ្មោះ ភុំ ហើយគោលបំណងសំខាន់នៃមន្ទីរនេះ គឺដើម្បីធ្វើការកសាងខ្លួន ឬអប់រំកែប្រែ ។ សាក្សីបន្ថែមថា អ្នកដែលត្រូវបញ្ជូនទៅអប់រំនៅទីនោះ គឺជាក្រុមខ្មែរដែលមកពីបរទេស ហើយជាទូទៅអ្នកដែលមកពីបរទេសទាំងអស់ត្រូវតែឆ្លងកាត់មន្ទីរក-១៥ ប៉ុន្តែក្រោយមកសាក្សីបានដឹងថា មានអ្នកមកពីបរទេសមួយចំនួនមិនបានចូលក្នុងមន្ទីរក-១៥ទេ គឺអ្នកទាំងនោះត្រូវបានបញ្ជូនទៅមន្ទីរស-២១ ឬគុកទួលស្លែងតែម្ដង ។ អ្នកដែលមកពីបរទេសភាគច្រើនគឺមកពីប្រទេសបារាំង និងមានបុគ្គលមួយចំនួនទៀតមកពីសហរដ្ឋអាមេរិក សហភាពសូវៀត ឬប្រទេសនៅអឺរ៉ុបខាងកើតជាដើម ។ ក្រោយមក អ្នកទាំងនោះបានបាត់ខ្លួនជាបន្តបន្ទាប់ ។

លោកសហព្រះរាជអាជ្ញារងបានបន្តសួរថា តើសាក្សីធ្លាប់បានឃើញជនជាប់ចោទ នួន ជា, អៀង សារី ឬ ខៀវ សំផន ចូលរួមប្រជុំឬទស្សនកិច្ចនៅមន្ទីរក-១៥ដែរឬទេ? សាក្សីបានបំភ្លឺថាចាប់តាំងពីពេលដែលលោកចូលដល់មន្ទីរក-១៥ និងរហូតដល់ពេលដែលលោកចាកចេញពីមន្ទីរនោះ លោកមិនដែលបានឃើញជនជាប់ចោទទាំងបីរូបទៅទីនោះទេ ប៉ុន្តែភរិយារបស់លោកដែលបានមកដល់ប្រទេសកម្ពុជាមុនលោករយៈពេល៦ខែ ហើយធ្វើការនៅទីនោះមុនលោកបានប្រាប់លោកថា ខៀវ សំផន ធ្លាប់បានទៅបើកវគ្គរៀនសូត្រមួយនៅមន្ទីរក-១៥ ប៉ុន្តែមិនចាំច្បាស់អំពីកាលបរិច្ឆេទនៃវគ្គសិក្សារៀនសូត្រនាពេលនោះឡើយ ។

បន្ទាប់មកសាក្សី អ៊ុង ចុងហឿង បានធ្វើការបញ្ជាក់ទាក់ទងនឹងពាក្យថា *"ការកសាងខ្លួន"* ដោយអះអាងថា *ការកសាងខ្លួន* មានដូចជា ការវាយថ្មដើម្បីយកដីធ្វើស្រែ ដាំត្រកួន ព្រោះថាការធ្វើពលកម្មគឺជាមធ្យោបាយដ៏ស័ក្តិសិទ្ធដើម្បីកសាងខ្លួន ហើយការកសាងខ្លួន គឺដើម្បីបំភ្លេចនូវវណ្ណភាពដើមរបស់ខ្លួន ។ ជារៀងរាល់ថ្ងៃត្រូវមានការប្រជុំទិតៀន ហើយយូរៗម្ដងមានវគ្គសិក្សារៀនសូត្រ ។ សាក្សីបន្តថា ការប្រជុំទិតៀន គឺទិតៀនបានតែអ្នកដែលមកពីបរទេសដូចគ្នាតែប៉ុណ្ណោះ មិនអាចទិតៀនប្រធាននៅទីនោះបានឡើយ ។ សាក្សីបញ្ជាក់បន្ថែមថា អំឡុងពេលដែលនៅធ្វើការនៅមន្ទីរ-១៥នោះ លោកមិនដែលបានឃើញមានការធ្វើទារុណកម្ម ឬវាយដំចំពោះអ្នកនៅទីនោះទេ ប៉ុន្តែលោកមានការចាប់អារម្មណ៍ថា មានការដឹកមនុស្សចេញពីទីកន្លែងនោះ ដោយមានអ្នកនិយាយថា អង្គការត្រូវការអ្នកទាំងអស់នោះហើយ ដោយមិនដែលដឹងថាអង្គការយកអ្នកទាំងនោះទៅទីណាទេ ។

### ក.៨) ការបាត់ខ្លួនបញ្ញវន្តមកពីបរទេស

បន្ទាប់ពីសាក្សីលើកឡើងអំពីការបាត់ខ្លួន លោកសហព្រះរាជអាជ្ញារង ចាន់ គារារស្មី បានចោទសួរបន្តថា តើសាក្សីធ្លាប់បានឮអំពីការបាត់ខ្លួនដែរឬទេ? សាក្សី អ៊ុង ចុងហឿង បានអះអាងថា លោកបានដឹងអំពីការបាត់ខ្លួនច្បាស់គឺ នៅក្រោយពេលរបបខ្មែរក្រហមបានដួលរលំ ។ ៥ឬ៦ខែក្រោយការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ សាក្សីបានធ្វើការនៅសារមន្ទីរទួលស្លែង ដែលជាអតីតមន្ទីរស-២១បានមួយរយៈ ។ នៅពេលនោះ ហើយដែលសាក្សីបានដឹងថាមិត្តភក្តិរបស់លោកដែលបាត់

ខ្លួននៅពេលនោះ មានឈ្មោះនៅក្នុងបញ្ជីអ្នកដែលត្រូវបានចាប់ខ្លួនបញ្ជូនមកគុកទួលស្លែងឬមន្ទីរស-២១ ។ រីឯមិត្តភក្តិរបស់លោកមួយចំនួនទៀតដែលបានបាត់ខ្លួនពីជំរំដីក្រហម ដែលមានទីតាំងនៅស្រុកស្ទឹងត្រង់មិនមានឈ្មោះនៅក្នុងបញ្ជីនៃមន្ទីរស-២១ទេ ប៉ុន្តែមានអ្នកប្រាប់លោកថា អ្នកដែលបាត់ខ្លួនពីជំរំដីក្រហម គឺត្រូវបានយកទៅសម្លាប់នៅចម្ងាយប្រហែលពាក់កណ្ដាលគីឡូម៉ែត្រពីមន្ទីរប-២០ នៅម្តុំព្រៃកុង ។

### ក.៩) ការលត់ដំខ្លួននៅមន្ទីរជ-២

ឆ្លើយតបនឹងសំណួររបស់លោកសហព្រះរាជអាជ្ញារង ដែលសួរទាក់ទងនឹងមន្ទីរជ-២ សាក្សី ជុងហឿង បានពន្យល់ថា បន្ទាប់ពីធ្វើការនៅមន្ទីរក-១៥បានរយៈពេល៣ខែ លោក និងអ្នកមកពីបរទេសជាមួយលោកមួយចំនួនទៀតត្រូវបានផ្លាស់ឲ្យទៅធ្វើការនៅមន្ទីរជ-២ ដែលមានទីតាំងស្ថិតនៅជិតគីឡូម៉ែត្រលេខ៦ តាមផ្លូវពីភ្នំពេញទៅព្រែកព្នៅ ។ សាក្សីបន្តថា មន្ទីរជ-២ គឺជារោងចក្រស្លដែកសម្រាប់ផលិតម៉ាស៊ីនកិនស្រូវ ដើម្បីប្រើប្រាស់នៅតាមសហករណ៍ ។ ប្រធានមន្ទីរជ-២ ឈ្មោះ សុខ បានប្រគល់ភារកិច្ចឲ្យលោកធ្វើជាប្រធានក្រុមនៃអ្នកដែលមកពីបរទេសធ្វើការខាងផ្នែកក្រុមជាងឈើ ដោយសារលោកមានអាយុច្រើនជាងគេក្នុងចំណោមអ្នកដែលទៅជាមួយលោក ។ នៅទីនោះ លោកធ្លាប់បានឃើញ វន វ៉េត ធ្វើទស្សនកិច្ចនៅមន្ទីរជ-២ម្តង ប៉ុន្តែលោកពុំដែលឃើញ នួន ជា, អៀង សារី ឬ ខៀវ សំផន ធ្វើទស្សនកិច្ចនៅទីនោះឡើយ ។

### ខ) សហព្រះរាជអាជ្ញាអន្តរជាតិ

នៅរសៀលថ្ងៃទី៨ ខែសីហា ឆ្នាំ២០១២ ដែលត្រូវជាថ្ងៃទី២នៃសវនាការសួរដេញដោលលើសាក្សី អុង ជុងហឿង អង្គជំនុំជម្រះបានប្រគល់វេទិកាជូនតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ គឺលោក វ៉ាំងសង់ ដឺវ៉ាល់ ដេស្មាឯល បន្តសាកសួរទាក់ទងនឹងបទពិសោធន៍ និងរឿងរ៉ាវរបស់សាក្សីនៅពេលដែលធ្វើការនៅមន្ទីរប-២ និងការស្រាវជ្រាវអំពីចម្លើយសារភាពក្រោយពេលរបបខ្មែរក្រហមបានដួលរលំនៅឆ្នាំ១៩៧៩ ។

### ខ.១) ការជួបប្រជុំរវាង អៀង សារី និងសហភាពនិស្សិតខ្មែរនៅទីក្រុងប៉ារីស

មុនពេលចាប់ផ្តើមសួរសំណួរសាក្សី លោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ វ៉ាំងសង់ បានបង្ហាញឯកសារមួយមានចំណងជើងថា *«ដំណឹងកម្ពុជា»* ដែលផ្សព្វផ្សាយដោយមន្ទីរព័ត៌មាននៃរណសិរ្សរួបរួមជាតិកម្ពុជាដែលមានច្បាប់ដើមជាភាសាបារាំងជូនសាក្សីដើម្បីធ្វើការពិនិត្យ និងបញ្ជាក់ ។ សាក្សី ជុងហឿង បានឆ្លើយតបយ៉ាងខ្លីថា លោកពិតជាធ្លាប់បានឃើញឯកសារនោះ ។ បន្ទាប់មក លោកតំណាងសហព្រះរាជអាជ្ញាបានបង្ហាញឯកសារមួយទៀតទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីដែលធ្លាប់បានផ្តល់ចម្លើយជូនសហចៅក្រមស៊ើបអង្កេតអំពីកិច្ចប្រជុំដែលសាក្សីបានចូលរួមជាមួយនឹង អៀង សារី និងសហភាពនិស្សិតខ្មែរ នៅពេលដែល អៀង សារី ធ្វើដំណើរទៅប្រទេសបារាំង ។ ឆ្លើយតបនឹងសំណួរនេះ សាក្សីបានបញ្ជាក់ថា លោកបានចូលរួមប្រជុំជាមួយសហភាពនិស្សិតខ្មែរ និង អៀង សារី នៅទីក្រុងប៉ារីសលើសពី២ដង ទាំងមុនពេល និងក្រោយពេល ខ្មែរក្រហមទទួលបានជ័យជម្នះ ប៉ុន្តែលោកមិនបានជួបនិយាយគ្នាដោយផ្ទាល់ជាមួយនឹង អៀង សារី នោះទេ ។ សាក្សីបន្តថា បញ្ញវន្តទាំងអស់នោះបានទទួល អៀង សារី ក្នុងឋានៈជាមគ្គុទេសក៍ឆ្នើមដោយមានទាំងបញ្ញវន្តចាស់ៗ និងបញ្ញវន្តដែលទើបនឹងទៅដល់ប្រទេសបារាំង ។ លោកបានបន្ថែមថា ក្នុងចំណោមអ្នកអមដំណើរជាមួយ អៀង សារី នៅពេលនោះ លោកនៅចងចាំ សូ ហុង ច្បាស់ជាងគេបង្អស់ដោយសារលោកធ្លាប់បានជួបពិភាក្សា និងសំណេះសំណាលជាមួយគ្នា ។ នៅអំឡុងពេលនៃដំណើរទស្សនកិច្ចនោះ អៀង សារី បាននិយាយជាមួយបញ្ញវន្តនៅទីនោះដោយប្រើពាក្យជាច្រើន ដូចជា *«ព្រលឹងជាតិ ស្នេហាជាតិ ឯករាជ្យម្ចាស់ការ ខ្លួនទីពឹងខ្លួន»* ហើយប្រទេសកម្ពុជាមិនរណបវៀតណាមទេ ។ លោកសង្កត់ត្រង់ចំណុចនេះថា ពាក្យដែល អៀង សារី និយាយថា ប្រទេសកម្ពុជាមិនរណបវៀតណាម គឺខ្មែរនៅគ្រប់ប្រទេស និងគ្រប់មជ្ឈដ្ឋានចូលចិត្តស្តាប់ពាក្យនេះណាស់ ។ អៀង សារី មិនបាននិយាយអំពីភាពលំបាកនៅក្នុងប្រទេសកម្ពុជានាពេលនោះទេ ប៉ុន្តែលើកឡើងច្រើនអំពីការចូលរួមរបស់ សួង ស៊ីគឿន និង អ៊ិន សុភាព ជាមួយចលនាតស៊ូនៅក្នុងប្រទេសដែលជាហេតុធ្វើសាក្សីមានអារម្មណ៍រិតតែចង់វិលត្រលប់ចូលក្នុងប្រទេសឲ្យបានកាន់តែឆាប់ ។

បន្ទាប់មក លោកតំណាងសហព្រះរាជអាជ្ញាបានបន្តសួរ

ទាក់ទងនឹងកសាងខ្លួនថា តើ អៀង សារី ឬអ្នកដែលស្និទ្ធនឹង អៀង សារី មាននិយាយថា ត្រូវតែឆ្លងកាត់ការកសាងខ្លួននៅពេលត្រឡប់ចូលក្នុងប្រទេសវិញដែរឬទេ? សាក្សីបានឆ្លើយតបនឹងសំណួរនេះថា លោកធ្លាប់បានឮ អៀង សារី និយាយអំពីការលត់ដំកសាងខ្លួន ប៉ុន្ដែលោកមិនដែលដឹងថាការលត់ដំនោះ គឺជាការធ្វើពលកម្មមិនមានអាហារដូចដែលលោកបានជួបប្រទះដោយផ្ទាល់នាពេលនោះទេ ។ សាក្សីគិតថា ការកសាងខ្លួន គឺគ្រាន់តែជាការធ្វើខ្លួនឲ្យដូចជាការរស់នៅរបស់ប្រជាជនទូទៅ ។ លោកបានបន្ដថាការអំពាវនាវរបស់ អៀង សារី មានឥទ្ធិពលខ្លាំងណាស់ក្នុងចំណោមអ្នកដែលរស់នៅបរទេស អ្នកខ្លះបានលះបង់ទ្រព្យសម្បត្តិ និងភរិយាដើម្បីចូលរួមក្នុងការជួយកសាងប្រទេសជាតិ ។ ក្នុងចំណោមនោះមានលោក ទីវ ឈុនឡេង គឺជាវិស្វករដែលរស់នៅក្នុងប្រទេសបារាំង និងមានការទទួលស្គាល់យ៉ាងច្រើននៅក្នុងប្រទេសបារាំង បន្ទាប់មកគឺ លោក លី ណៃស៊ីម ដែលមានជំនាញជាគ្រូពេទ្យ និងលោក ប៉ែន ទ្រីវ៉ាន់ គឺជាវិស្វករ ។ ប៉ុន្ដែអ្នកទាំងអស់នេះបានស្លាប់បាត់បង់ជីវិតអស់ទៅហើយ ។

**១.២) ចំនួននៃបញ្ញវន្ដ និងប្រជាជនដែលវិលត្រលប់ពីបរទេស**

លោកតំណាងសហព្រះរាជអាជ្ញាបានចោទសួរលោកសាក្សីទាក់ទងនឹងចំនួនតួលេខនៃអ្នកដែលបានវិលត្រលប់ពីបរទេសចូលមកប្រទេសកម្ពុជាដើម្បីចូលរួមកសាងជាតិនៅអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ សាក្សី អ៊ុង ចុងហឿង បានសង្កត់ធ្ងន់ថា តាមការស្រាវជ្រាវរបស់លោកខ្មែរដែលបានវិលត្រលប់ចូលក្នុងប្រទេសកម្ពុជានៅពេលនោះមានចំនួន១.៧០០នាក់ ហើយនៅក្នុងចំណោមអ្នកទាំងអស់នោះមាន១.៥០០នាក់បានស្លាប់បាត់បង់ជីវិត ។ អ្នកដែលនៅរស់រានមានជីវិតពីរបបនោះគឺនៅសល់ត្រឹមតែ២០០នាក់ប៉ុណ្ណោះ ។ នៅមុនពេលវិលត្រលប់ចូលក្នុងប្រទេសកម្ពុជា សាក្សីបានគិតនៅក្នុងចិត្តថា អ្នកតស៊ូក្នុងប្រទេសគឺសុទ្ធតែជាអ្នកចេះដឹង ដូច្នេះលោកមិនជឿថា អ្នកទាំងនោះព្រៃផ្សៃរហូតដល់សម្លាប់ជាតិឯងនោះទេ ។ បន្ទាប់មក លោកក៏បានសម្រេចចិត្តវិលត្រលប់ចូលក្នុងប្រទេសកម្ពុជាវិញ ។ ប៉ុន្ដែលោកត្រូវបានផ្ដល់ដំបូន្មានថាឲ្យយករបស់របរតែមួយបង្អួចបានហើយកុំយកអ្វីទាំងអស់មកជាមួយ ព្រោះបើយកមកច្រើនពេកនាំឲ្យធ្ងន់ ហើយម្យ៉ាងវិញទៀតការត្រលប់ចូលក្នុងប្រទេសនេះគឺដើម្បីកសាងខ្លួនជាមួយប្រជាជន ។

**១.៣) ការបញ្ចូល និងការដកចេញនូវអ្នកធ្វើការនៃមន្ទីរ ក-១៥**

លោកតំណាងសហព្រះរាជអាជ្ញាអន្ដរជាតិបានងាកមកសួរទាក់ទងនឹងមន្ទីរក-១៥សារជាថ្មីម្ដងទៀតបន្ថែមលើសំណួរដែលសហការីជាតិរបស់ខ្លួនបានសាកសួរកាលពីថ្ងៃទី៧ ខែសីហា ឆ្នាំ២០១២ ។ ឆ្លើយតបនឹងសំណួររបស់លោកតំណាងសហព្រះរាជអាជ្ញាទាក់ទងនឹងរយៈពេលនៃការស្នាក់នៅនៃក្រុមខ្មែរវិលត្រលប់មកពីបរទេសនៅមន្ទីរក-១៥ សាក្សី ចុងហឿង បានរៀបរាប់ថា លោកបានវិលត្រលប់ចូលក្នុងប្រទេសក្រោយភរិយារបស់លោករយៈពេល៦ខែ ។ នៅពេលដែលលោកចូលមកដល់ក្នុងប្រទេសវិញលោកបានសង្កេតឃើញមានបញ្ញវន្ដ និងខ្មែរដែលវិលត្រលប់មកពីបរទេសមុនលោក មួយចំនួនត្រូវបានបញ្ជូនទៅកន្លែងផ្សេងមួយទៀតគឺនៅ ជំរំតាឡី ។ ក្រោយមក ទើបលោកបានដឹងថាអ្នកដែលត្រូវបានបញ្ជូនទៅ ជំរំតាឡី នោះមានឈ្មោះនៅក្នុងបញ្ជីអ្នកទោសនៅគុកទួលស្លែង ។

លោកតំណាងសហព្រះរាជអាជ្ញា វ៉ាំងសង់ បានបន្ដសួរទៀតថា បន្ទាប់ពីការចូលមកដល់មន្ទីរក-១៥របស់សាក្សី តើមានបញ្ញវន្ដ និងអ្នកដែលវិលត្រលប់ពីបរទេសផ្សេងទៀតត្រូវនាំចូលទីនោះតាមក្រោយទៀតដែរឬទេ? សាក្សីបានអះអាងថា បន្ទាប់ពីលោកបានទៅដល់មន្ទីរក-១៥ លោកបានឃើញមានអ្នកផ្សេងទៀតត្រូវបាននាំចូលទីនោះ ក្នុងនោះក៏មានបងថ្លៃរបស់លោកដែរគឺលោក រស់ សារិន និងគ្រួសាររួមជាមួយនឹងប្រជាជនខ្មែរផ្សេងទៀត ។ លោកបន្ដទៀតថា ខ្មែរដែលវិលត្រលប់ពីបរទេសត្រូវបានចាត់តាំងឲ្យត្រួតពិនិត្យមើលលើក្រុមខ្មែរមកពីបរទេសផ្សេងទៀតដែលធ្វើការនៅទីនោះដូចជាពួកណាហ្សី ដែលបានបញ្ជាឲ្យជនជាតិជ្វីសត្រួតពិនិត្យមើលគ្នាឯង ហើយរាយការណ៍ជូនថ្នាក់លើនៅក្នុងសម័យសង្គ្រាមលោកលើកទី២ដូច្នេះដែរ ។ សាក្សីបានពន្យល់ថា ការធ្វើបែបនេះបានធ្វើឲ្យអ្នកទាំងអស់ដែលរស់នៅទីនោះចាប់ផ្ដើមមានការគិតអំពីផលប្រយោជន៍ផ្ទាល់ខ្លួន និងកាន់តែ

មានការទាស់គ្នា និងមិនទុកចិត្តគ្នាតាមរយៈស៊ុយទិតៀនគ្នាទៅវិញទៅមកដែលធ្វើឲ្យស្ថានភាពនៅទីនោះមានសភាពច្របូកច្របល់កាន់តែខ្លាំង ។

### ១.៤) សភាពការណ៍នៅមន្ទីរតាខ្មៅ

ឆ្លើយតបនឹងសំណួររបស់លោកតំណាងសហព្រះរាជអាជ្ញាដែលសួរថា ក្រៅពីមន្ទីរក-១៥ និងមន្ទីរដ-២ តើលោកសាក្សីមានត្រូវបានបញ្ជូនទៅទីណាទៀតដែរឬទេ? សាក្សី ថុង ដោយសាក្សីបានលើកយកករណីរបស់ឈ្មោះ ចៅ សេងណុង ដែលបានលួចរត់ចេញពីមន្ទីរតាខ្មៅ ក្រោយមកត្រូវបានចាប់ខ្លួន ។ ប៉ុន្តែលោកមិនបានឃើញឈ្មោះនោះត្រលប់មកវិញទេ ក្រោយមកទើបលោកឃើញឈ្មោះ ចៅ សេងណុង នោះនៅមន្ទីរស-២១ ។ បន្ទាប់មកសាក្សី អ៊ុង ថុងហឿង បានសង្កត់ធ្ងន់ថាការវិលត្រលប់ចូលក្នុងប្រទេសរបស់លោក គឺដោយសារការអំពាវនាវ របស់អៀងសារី ។



គុកទួលស្លែងក្រោយពេលការដួលរលំនៃរបបខ្មែរក្រហម (រូបភាពមជ្ឈមណ្ឌលឯកសារកម្ពុជា)

ហឿង បានបញ្ជាក់ថា បន្ទាប់ពីមន្ទីរក-១៥ លោកត្រូវបានបញ្ជូនទៅមន្ទីរដ-២ ក្រោយមកអង្គការបានបញ្ជូនលោកទៅតាខ្មៅ ។ លោកបន្តថា អ្នកគ្រប់គ្រងមន្ទីរនៅតាខ្មៅមានឈ្មោះ យុត ។ លោកសាក្សី ថុងហឿង បានរំឭកអំពីស្ថានភាពនៅពេលលោករស់នៅមន្ទីរនៅតាខ្មៅនោះថា សម្រាប់លោកដែលជាអ្នកត្រលប់ពីបរទេសសភាពការណ៍នៅទីនោះកាន់តែធ្លាក់ដុនដាប ហើយគ្មាននរណាមានសិទ្ធិឈឺបានទេ ព្រោះបើឈឺអាហាររបស់អ្នកនោះនឹងត្រូវកាត់បន្ថយ ។ ពេលនោះមានបញ្ញវន្តមួយចំនួនបានលួចរត់ចេញពីមន្ទីរនោះ

### ១.៥) បញ្ញវន្ត និងមន្ទីរបឹងត្របែក

លោកតំណាងសហព្រះរាជអាជ្ញាបានបន្តសួរទៀតថា បន្ទាប់ពីមន្ទីរតាខ្មៅ តើលោកសាក្សីមានត្រូវបានបញ្ជូនទៅទីណាទៀតដែរឬទេ? សាក្សី អ៊ុង ថុងហឿង បានរៀបរាប់ថា នៅក្នុងឆ្នាំ ១៩៧៦ ប្រហែលជាខែវិច្ឆកា លោកត្រូវបានបញ្ជូនទៅមន្ទីរបឹងត្របែក ហើយនៅទីនោះលោកបានដឹងថា មន្ទីរក-១៥ ដែលលោកធ្លាប់ធ្វើការនៅទីនោះដំបូងត្រូវបានបិទ ហើយបញ្ញវន្ត និងខ្មែរដែលវិលត្រលប់ពីបរទេសទាំងអស់ត្រូវបានបញ្ជូនទៅមន្ទីរបឹងត្របែក ។

សាក្សីបានកត់សម្គាល់ថា នៅមន្ទីរបឹងត្របែក លោកឃើញមានមនុស្សច្រើនជាងមន្ទីរនៅតាខ្មៅ ប៉ុន្តែនៅតែតិច បើប្រៀបធៀបនឹងចំនួនបញ្ញវន្តដែលត្រលប់មកពីបរទេសទាំងអស់ ។ លោកបន្តថា នៅទីនោះមិនមែនមានតែបញ្ញាជននោះទេ ប៉ុន្តែក៏មានដែរកម្មាភិបាលខ្មែរក្រហមពីរ ឬបីរូបផ្សេងទៀត ប៉ុន្តែលោកមិនបានចាំឈ្មោះអ្នកទាំងនោះទេ ។ បញ្ញាជនដែលត្រូវបានបញ្ជូនទៅមន្ទីរបឹងត្របែកភាគច្រើន គឺជាអ្នកដែលមកពីប្រទេសបារាំង ហើយអ្នកដែលវិលត្រលប់មកពីសហភាពសូវៀតមានចំនួនតិចតួចប៉ុណ្ណោះ ដោយសារនៅពេលនោះអ្នកផ្សេងទៀតបានបាត់ខ្លួន ។

ឆ្លើយតបនឹងសំណួររបស់សហព្រះរាជអាជ្ញាដែលសួរថា តើលោកសាក្សីបានជួបជាមួយនឹងអ្នកដែលធ្លាប់ជិះយន្តហោះត្រលប់មកពីបរទេសជាមួយគ្នានៅមន្ទីរបឹងត្របែកដែរឬទេ? លោកបានបញ្ជាក់ថា នៅមន្ទីរបឹងត្របែក លោកមិនបានឃើញអ្នកដែលធ្លាប់ជិះនៅក្នុងយន្តហោះជាមួយលោកពេលត្រលប់មកប្រទេសកម្ពុជា ឬអ្នកធ្លាប់ធ្វើការក្នុងរបបសាធារណរដ្ឋទេ ហើយក៏មិនឃើញអតីតអ្នកការទូតមកពីបរទេសដែរ ។ សាក្សីបានបន្ថែមថា ភារកិច្ចរបស់លោកនៅទីនោះសំខាន់បំផុត គឺត្រូវតស៊ូប្រឆាំងនឹងសតិអារម្មណ៍ជាធំដោយត្រូវស្វែងរកសត្រូវផ្ទៃក្នុងនៅក្នុងខ្លួនបុគ្គលម្នាក់ៗ ។ លោកបានលើកឧទាហរណ៍ទាក់ទងនឹងការតស៊ូសតិអារម្មណ៍នេះថា នៅបឹងត្របែកមានផ្លែដូងចាស់ដែលជ្រុះមកដី និងមានខ្ទឹងខ្មៅជាដើម ប៉ុន្តែអ្នកទាំងអស់ត្រូវបានហាមឃាត់មិនឲ្យរើសយករបស់ទាំងនោះមកបរិភោគជាដាច់ខាត ប្រសិនបើមាននរណាម្នាក់ហ៊ានរើសយករបស់ទាំងអស់នោះមកបរិភោគអ្នកនោះនឹងត្រូវហៅមកប្រជុំដើម្បីទទួលការស្ដីបន្ទោស ។ ការប្រជុំនេះគឺដើម្បីប្រឆាំងនឹង អ្នកក្បត់វណ្ណៈ ។

បន្ទាប់មក លោកតំណាងសហព្រះរាជអាជ្ញាបានបន្តសាកសួរសាក្សីទៀតថា តើនៅមន្ទីរបឹងត្របែកមានការរៀបចំរចនាសម្ព័ន្ធ និងឋានានុក្រមដែរឬទេ? សាក្សីបានបំភ្លឺថាបើតាមលោកដឹង គឺមានរបៀបចាត់តាំងជាប្រធានក្រុម ហើយយកអ្នកមកពីបរទេសដូចគ្នាធ្វើជាប្រធានក្រុម ដើម្បីរាយការណ៍ជូនតំណាងអង្គការនិងមានការគោរសង្កត់មិត្តភក្តិខ្លួនឯង ដើម្បីផ្គាប់ចិត្តថ្នាក់លើ ហើយស្ថានការណ៍នៅទីនោះមានសភាពតឹងតែងជាងនៅតាខ្មៅ ។ ឆ្លើយតបនឹងសំណួររបស់តំណាងសហព្រះរាជអាជ្ញា លោក វ៉ាំងសង់ ទាក់ទងនឹងអ្នកគ្រប់គ្រងនៅមន្ទីរបឹងត្របែក សាក្សីបានរៀបរាប់ថា កម្មាភិបាលដែលគ្រប់គ្រងនៅទីនោះមានឈ្មោះ សារ៉ែន ។ នៅមន្ទីរបឹងត្របែកលោកបានសង្កេតឃើញថា មានការនាំបញ្ញវន្តជាច្រើនរូបចេញពីទីនោះ នៅមុនពេលលោកត្រូវបានបញ្ជូនទៅជំរំដីក្រហម ។ លោកបន្តថា បញ្ញាជនដែលត្រូវបាននាំចេញពីមន្ទីរបឹងត្របែករួមមានបងថ្លៃរបស់លោកសាក្សីគឺលោករស់ សារិន, លោកសាស្ត្រាចារ្យ ភីង គុន លោកសាស្ត្រាចារ្យ ឈូក មីងម៉ៅ និងអ្នកផ្សេងទៀតដែលលោកមិនចាំឈ្មោះអស់ ។ លោកមិនបានដឹងថា អ្នកទាំងអស់នោះត្រូវបាននាំយកទៅទីណានោះទេ ។

## ១.៦) ការបញ្ជូនបញ្ញវន្តពីបឹងត្របែកទៅជំរំដីក្រហម

បន្ទាប់ពីសាក្សី អ៊ុង ចុងហឿង បានលើកឡើងទាក់ទងនឹងជំរំដីក្រហម លោកតំណាងសហព្រះរាជអាជ្ញាបានស្នើឲ្យសាក្សីរៀបរាប់អំពីរយៈពេល និងស្ថានភាពនៅអំឡុងពេលដែល លោករស់នៅទីនោះ ។ ឆ្លើយតបនឹងសំណើនេះ សាក្សីបានបញ្ជាក់ថា លោកត្រូវបាននាំចេញពីមន្ទីរបឹងត្របែកទៅ ជំរំដីក្រហម នៅចុងឆ្នាំ១៩៧៦ ហើយរស់នៅទីនោះរហូតដល់ចុងឆ្នាំ១៩៧៨ គឺ២ ឬ៣ខែ មុនពេលដែលរបបកម្ពុជាប្រជាធិបតេយ្យដួលរលំ ប៉ុន្តែលោកមិនបានចាំអំពីពេលវេលាច្បាស់លាស់នោះទេ ។ សាក្សីបន្តថា ពេលដែលលោកមកដល់មន្ទីរបឹងត្របែកដំបូង លោកត្រូវបានប្រាប់ឲ្យចុះឈ្មោះក្នុងបញ្ជីស្ថិតិដើម្បីទៅធ្វើការនៅជំរំដីក្រហម ដោយសារនៅទីនោះមានដំឡូង និងមានរបស់អាហារហូបគ្រប់គ្រាន់ ។ ក្រោយមក លោកក៏បានចុះឈ្មោះនៅក្នុងបញ្ជីនោះ ។ ជំរំដីក្រហមមានទីតាំងនៅស្រុកស្ទឹងត្រង់ ។ ពេលទៅដល់កម្មាភិបាលនៅទីនោះបានបញ្ជូនលោកទៅមន្ទីរ១៧ ហើយមានការទទួលយ៉ាងរាក់ទាក់ចំពោះលោក ។ សាក្សីបានបញ្ជាក់ថា នៅជំរំដីក្រហម លោកត្រូវបានបញ្ជាឲ្យកាប់ឆ្ការព្រៃដើម្បីដាំដំឡូងឈើ ។ ប៉ុន្តែក្រោយមក លោកបានសង្កេតឃើញថា មានការយកមនុស្សចេញពីទីនោះ ដូចជា ក្មួយរបស់ អៀង សារី និងអៀង ធីរិទ្ធ ពីរនាក់ និងឈ្មោះ ហម សុគង់ ដែលជាវិស្វករធ្លាប់រៀននៅប្រទេសបារាំងត្រូវបាននាំចេញនៅក្នុងមួយសប្តាហ៍ដំបូង ។ នៅអំឡុងពេលនោះ

មានការនាំមនុស្សចេញប្រហែល១០០នាក់ ហើយអ្នកដែលត្រូវបាននាំចេញពីទីនោះមិនដឹងថាទៅទីណាទេ ។ ប៉ុន្តែលោកបានកត់សម្គាល់ថា ក្មួយ អៀង ធីរិទ្ធ ទាំងពីររូបនៅមានជីវិតរស់នៅរហូតដល់ពេលបច្ចុប្បន្ន ។ រីឯអ្នកដែលត្រូវបាននាំចេញពីដីរដីក្រហមដទៃផ្សេងទៀត ត្រូវបាននាំយកទៅសម្លាប់នៅព្រៃកុងដែលមានចម្ងាយប្រហែលជា៣០នាទីពីមន្ទីរដែលលោកស្នាក់នៅ ។

***១.៧) ការនាំយកបញ្ញវន្តពីដីរដីក្រហមត្រលប់មកបឹងត្របែកវិញ***

បន្ទាប់មកលោកតំណាងសហព្រះរាជអាជ្ញាបានបន្តសួរទៀតថា នៅពេលដែលលោកសាក្សីបញ្ចប់ការងារនៅដីក្រហម តើកម្មាភិបាលខ្មែរក្រហមបានចាត់ទុកថា ការអប់រំបញ្ចប់ហើយ ឬនៅមិនទាន់បញ្ចប់ដែលត្រូវបញ្ជូនទៅដីរផ្សេងទៀតដើម្បីកសាងបន្ត? លោកសាក្សីបានបញ្ជាក់ថា លោកមិនបានដឹងថា តើសិក្សាកសាងខ្លួននោះចប់ ឬមិនចប់យ៉ាងណានោះទេ ប៉ុន្តែលោកគ្រាន់តែដឹងថា កម្មាភិបាលខ្មែរក្រហមបានប្រាប់លោកថា "សព្វថ្ងៃហ្នឹង អង្គការត្រូវការពួកបង១ ហើយដូច្នេះពួកបង១ត្រូវទៅភ្នំពេញវិញ" ។

ក្រោយមក លោក និងអ្នកដែលនៅសេសសល់ទាំងប៉ុន្មានត្រូវបាននាំមកទីក្រុងភ្នំពេញដោយស្នាក់នៅជិតវត្តភ្នំចំនួនមួយយប់ ។ លោកបានបន្តថា នៅយប់នោះ អៀង សារី បានមកជួបអ្នកដែលនាំមកពីដីក្រហមដោយសួរសំណេះសំណាល ប៉ុន្តែលោកសាក្សីមិនបានជួបជាមួយ អៀង សារី ដោយផ្ទាល់នោះទេ ដោយសារលោកគេងលក់ បន្ទាប់មកទើបមិត្តភក្តិរបស់លោកប្រាប់លោកអំពីការសំណេះសំណាលនេះនៅពេលព្រឹក ។ នៅព្រឹកបន្ទាប់លោកត្រូវបានបញ្ជូនទៅមន្ទីរបឹងត្របែកម្តងទៀតដោយកម្មាភិបាលខ្មែរក្រហមឲ្យលោកស្នាក់នៅមន្ទីរប-៣០ ។ លោកសាក្សីបានបន្តថា លោកបានដឹងថា នៅបឹងត្របែកនៅពេលនោះមានការបែងចែកជាមន្ទីរប-៣០ មន្ទីរប-៣១ និងប-៣២ ស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់ អៀង សារី ។ នៅមន្ទីរប-៣០បានមួយរយៈលោកត្រូវបានផ្លាស់ទៅមន្ទីរប-៣១ ដោយត្រូវស្នាក់នៅជាមួយនឹងអតីតក្រុមអ្នកការទូត ។ លោកបន្ថែមថា អ្នកដែលផ្លាស់ចេញពីមន្ទីរប-៣១នឹងត្រូវបញ្ជូនឲ្យធ្វើការនៅមន្ទីរប-១ដែលជាក្រសួងការបរទេសស្ថិតក្រោមការគ្រប់គ្រងរបស់ អៀង សារី ។ ស្ថានការណ៍នៅពេលនោះចាប់ផ្តើមមានសភាពធូរស្រាលដោយមិនតម្រូវឲ្យធ្វើការលំបាកនិងមានអាហារហូបគ្រប់គ្រាន់ជាងមុន ។ ក្រោយមកលោកបានដឹងថា សារិន ដែលជាអតីតអ្នកគ្រប់គ្រង នៅមន្ទីរបឹងត្របែកត្រូវបានចាប់ខ្លួន ។

ឆ្លើយតបនឹងសំណួររបស់សហព្រះរាជអាជ្ញាដែលសួរថា នៅមន្ទីរបឹងត្របែក តើលោកសាក្សីធ្លាប់បានប្រជុំជាមួយ អៀង សារី ដែរឬទេ? ឆ្លើយតបនឹងសំណួរនេះ លោកសាក្សី អុង ថុងហឿង បានអះអាងថា លោកធ្លាប់បានប្រជុំជាមួយ អៀង សារី ចំនួនពីរដង ដោយលើកទីមួយ គឺមានការចូលរួមពីសំណាក់អ្នកធ្វើការនៅក្នុងមន្ទីរប-១,មន្ទីរប-៣០,មន្ទីរប-៣១ និងមន្ទីរប-៣២ ។ នៅអំឡុងពេលនោះហើយដែលលោកមានឱកាសបានជួបជាមួយនឹងអ្នកការទូតចាស់ៗ ដូចជាលោក សារិន ឆាត, លោក ថែម ស្នួន និងលោក ហោ ណាំហុង ។ ក្នុងកិច្ចប្រជុំនោះ អៀង សារី បានលើកឡើងអំពីបញ្ហាសន្តិសុខនិងប្រាប់ថាកុំមានការបារម្ភចំពោះរឿងជម្លោះជាមួយវៀតណាម ហើយក៏មាននិយាយអំពីខ្មាំងដែរ ។ លោកបានបញ្ជាក់ថា អៀង សារី បានប្រាប់អ្នកចូលទាំងអស់នៅក្នុងកិច្ចប្រជុំនោះថា ខ្លួនបានព្យាយាមការពារអ្នកដែលមកពីបរទេសទាំងអស់តាមលទ្ធភាពដែលអាចធ្វើបាន ព្រោះ អៀង សារី មិនជឿថា ខ្មែរមកពីបរទេសទាំងអស់សុទ្ធតែក្បត់នោះទេ ។ បន្ទាប់មក អៀង សារី ក៏បាននិយាយអំពីរឿងរបស់ វ៉ាន់ ពីនី ដែលត្រូវបានចោទប្រកាន់ថាក្បត់នៅក្នុងឯកសារចំនួនពីរ ប៉ុន្តែចាប់ពីពេលនេះតទៅត្រូវមានឯកសារឆ្លើយដាក់ចំនួនបីទើបត្រូវចាប់ខ្លួន ។ អៀង សារី បានបញ្ជាក់នៅក្នុងកិច្ចប្រជុំនោះថា ដោយសារតែ សារិន ត្រូវបានរកឃើញថាក្បត់ ទើបត្រូវអង្គការចាប់ខ្លួន ។ លោកសាក្សីពន្យល់ថា នៅពេលនោះលោកមិនបានដឹងថាអ្នកដែលត្រូវចោទថាក្បត់ត្រូវបានយកទៅសម្លាប់នោះទេ ។ លោកគ្រាន់តែគិតថាអ្នកទាំងនោះអាចត្រូវបានយកទៅអប់រំឬកែប្រែតែប៉ុណ្ណោះ ។ បន្ថែមពីលើនេះនៅក្នុងកិច្ចប្រជុំនោះក៏មានការលើកឡើងអំពីបញ្ហារបស់ឈ្មោះ លាន សេរីវុធ ដែលត្រូវបានចោទថា សេ.អ៊ី.អា ហើយលោកសាក្សីស្គាល់ឈ្មោះនេះច្បាស់ដោយសារ លាន សេរីវុធ គឺជាប្អូនជីដូនមួយរបស់លោក សួង ស៊ីគឿន ហើយក៏ជាមិត្តភក្តិរបស់លោកដែរ ហើយការណ៍

ដែលចោទប្រកាន់ លាន សេរីវុធ ថាជា សេ.អ៊ី.អា គឺជារឿងដែលធ្វើឲ្យលោកហួសចិត្ត ។

ទាក់ទងនឹងបញ្ហាជម្លោះជាមួយវៀតណាម អៀង សារី បានបញ្ជាក់ប្រាប់អ្នកចូលរួមនៅក្នុងកិច្ចប្រជុំនោះថា កម្ពុជាកំពុងតែប្រយុទ្ធក្តៅជាចុងក្រោយបំផុតជាមួយវៀតណាម ។ លោកសាក្សីបានបន្តថា មុនពេលដែលវៀតណាមចូលដល់ទីក្រុងភ្នំពេញ នៅថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ សូ ហុង បានមកហៅ លោក និងអ្នកផ្សេងទៀតឲ្យចាកចេញពីបឹងត្របែកដោយប្រាប់ថានឹងនាំយកប្រុសៗចាកចេញទៅមុន ប៉ុន្តែនៅល្ងាចថ្ងៃទី៦ ខែមករា មិនមានរទេះភ្លើងចេញពីភ្នំពេញ ហើយលោកត្រូវរង់ចាំរហូតដល់ថ្ងៃទី៧ ទើបបានចាកចេញជាមួយនឹងក្រុមគ្រួសារតែម្តង ។ លោកបានបញ្ជាក់បន្ថែមថា នៅពេលរត់ចេញពីទីក្រុងភ្នំពេញមិនមានមេដឹកនាំខ្មែរក្រហមណាម្នាក់ធ្វើដំណើរជាមួយទេ គឺមានតែក្រុមបញ្ញវន្តដែលមកពីបរទេសជាមួយគ្នាប៉ុណ្ណោះ ។

**គួរកត់សម្គាល់ថា**

ការសួរដេញដោលសាក្សី អ៊ុង ចុងហឿង ដោយសហព្រះរាជអាជ្ញាបានបញ្ចប់នៅរសៀលថ្ងៃទី៨ ខែសីហា ឆ្នាំ២០១២ ។

### ៣) ការសួរសាក្សីដោយមេធាវីដើមបណ្តឹងរដ្ឋប្បវេណី

នៅព្រឹកថ្ងៃទី៩ ខែមករា ឆ្នាំ២០១២ អង្គជំនុំជម្រះបានប្រគល់វេទិកាសួរដេញដោលសាក្សី អ៊ុង ចុងហឿង ជូនសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ។ ប៉ុន្តែសហមេធាវីជាតិនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី គឺលោក ពេជ អង្គ បានឡើងជម្រាបជូនអង្គជំនុំជម្រះថា លោកនឹងផ្ទេរវេទិកាសួរដេញដោលសាក្សី អ៊ុង ចុងហឿង ជូនមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី គឺលោក ឡោ ជុនធី និងលោកស្រីមេធាវី ម៉ារី ហ្គីរ៉ូដ ។ អំឡុងពេលនៃការសួរដេញដោល មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងពីររូបបានសួរផ្តោតសំខាន់លើការចូលរួមនៅក្នុងសហភាពនិស្សិតខ្មែរនៅប្រទេសបារាំង និងការវិលត្រលប់របស់បញ្ញវន្តខ្មែរពីបរទេសដើម្បីចូលរួមជាមួយរបបកម្ពុជាប្រជាធិបតេយ្យ ។ មេធាវីទាំងពីររូបក៏បានលើកយកផ្នែកខ្លះនៃសៀវភៅដែលមានចំណងជើងថា "ខ្ញុំជឿខ្មែរក្រហម" ដែលនិពន្ធដោយលោកសាក្សី ដើម្បីស្នើឲ្យលោកធ្វើការបញ្ជាក់ ។

### ក) មេធាវីជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី

មេធាវីជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី គឺលោក ឡោ ជុនធី បានចាប់ផ្តើមសំណួរដំបូងទាក់ទងនឹងបញ្ញវន្តរៀននៅប្រទេស



មេធាវី ឡោ ជុនធី

បារាំងដែលបានចូលរួមនៅក្នុងចលនាកុម្មុយនីស្ត គឺវង់មាក្ស-ឡេនីន ថាតើនិស្សិតខ្មែរទាំងអស់ដែលរៀននៅទីនោះសុទ្ធតែចូលរួមក្នុងចលនានោះដោយសម្ងាត់ឬយ៉ាងណា? ឆ្លើយតបនឹងសំណួររបស់លោកមេធាវី សាក្សី អ៊ុង ចុងហឿង បានរៀបរាប់យ៉ាងវែងអំពីការវិវឌ្ឍនៃសភាពការណ៍នយោបាយអន្តរជាតិនៅអំឡុងពេលនិស្សិតខ្មែរកំពុងរៀននៅប្រទេសបារាំងដោយលោកបានលើកឡើងអំពីប្រវត្តិនិស្សិតកម្ពុជានៅប្រទេសបារាំង និងខ្មែរដែលរៀននៅបរទេស គឺសុទ្ធតែចង់យកចំណេះវិជ្ជារបស់ខ្លួនចូលរួមកសាងប្រទេស ហើយអ្នករៀននៅទីនោះឯកភាពគ្នាដោយមិនប្រកាន់និន្នាការនយោបាយឆ្វេង ឬស្តាំ មានទិសដៅតែមួយ គឺចង់បានឯករាជ្យពីប្រទេសបារាំង ។ ក្រោយពេលគស៊ូបានបន្តិច មាននិន្នាការពីរបានលេចចេញឡើងថា តើគួរតស៊ូដើម្បីបណ្តេញបារាំងចេញ ឬតស៊ូដើម្បីរៀបចំរចនាសម្ព័ន្ធប្រទេសឡើងវិញ ។ ពេលនោះនិន្នាការនយោបាយពិភពលោកក៏ចាប់មានការប្រែប្រួលដោយបែងចែកជាលោកសេរី និងលោកកុម្មុយនីស្ត ។ ចំណែក

និស្សិតបញ្ញវន្តខ្មែររៀននៅបារាំងគឺសុទ្ធតែទទួលរងឥទ្ធិពលពីបក្សកុម្មុយនីស្តបារាំង ដោយសារនៅក្នុងតំបន់អាស៊ី ជាពិសេសនៅក្នុងតំបន់ឥណ្ឌូចិនកំពុងមានចលនាបះបោរទាមទារឯករាជ្យពីបារាំង ដែលដឹកនាំដោយ ហូជីមិញ ហើយនៅប្រទេសចិនមាន ម៉ៅសេទុង ដែលបានដឹកនាំបដិវត្តន៍ចិនឲ្យទទួលបានជ័យជម្នះ ។ ដោយមើលឃើញពីគំរូបដិវត្តន៍នៅប្រទេសចិននេះហើយ ធ្វើឲ្យឥទ្ធិពលកុម្មុយនីស្តនៅអាស៊ីមានការកើនឡើង ហើយនៅបារាំងក៏ដូចគ្នាដែរ ។ ហេតុដូច្នេះហើយ ទើបនិស្សិតខ្មែរមួយចំនួនបានចូលរួមនៅក្នុងចលនាម៉ាក្ស-ឡេនីន ដោយមានការគាំទ្រពីបក្សកុម្មុយនីស្តបារាំង ។

បន្ទាប់មក លោកមេធាវីបានបន្តសួរទៀតថា តើនិស្សិតខ្មែរដែលរៀននៅប្រទេសបារាំងមានទំនាក់ទំនងអ្វីជាមួយបក្សកុម្មុយនីស្តបារាំង? ឆ្លើយតបនឹងសំណួរនេះ សាក្សីបានបញ្ជាក់ថា សំណួរនេះ គឺមានការជាប់ទាក់ទំនងជាមួយបរិបទប្រវត្តិសាស្រ្ត ហើយជាគន្លឹះនៃប្រវត្តិសាស្រ្ត ។ លោកបន្តថា និស្សិតបង១ ទាំងអស់សុទ្ធតែចង់ឲ្យប្រទេសជាតិមានការរីកចម្រើន និងដើម្បីការពារទឹកដីធ្វើយ៉ាងណា ដើម្បីកុំឲ្យជាតិរលាយមុននឹងអ្នកទាំងនោះក្លាយជាខក្រិដ្ឋជន ។ ប៉ុន្តែមកដល់ចំណុចនេះ លោកប្រធានអង្គជំនុំជម្រះបានកាត់លោកសាក្សី ដោយសារការលើកឡើងរបស់សាក្សីមិនមានជាប់ពាក់ព័ន្ធនឹងអង្គហេតុ និងស្នើឲ្យលោកមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសាកសួរសំណួរដោយប្រុងប្រយ័ត្នដើម្បីជៀសវាងការចំណាយពេលវេលាដោយឥតប្រយោជន៍ ។

លោកមេធាវី ដុនធី បានបន្តសួរទាក់ទងនឹងមូលហេតុដែលនាំឲ្យបញ្ញវន្តខ្មែរវិលត្រលប់ចូលក្នុងប្រទេសថាតើមានព័ត៌មានអ្វីខ្លះដែលបញ្ញវន្តទាំងនោះទទួលបានមុនពេលវិលត្រលប់មកប្រទេសកម្ពុជា? លោកសាក្សីបានអះអាងថា ប្រសិនបើនរណាម្នាក់មានជំនឿលើអ្វីមួយហើយ គ្មានអ្វីដែលអាចកែប្រែជំនឿនោះបានឡើយ ដូចជាបញ្ញវន្តនៅបរទេសដែលមានជំនឿលើ ខៀវ សំផន, ហ៊ូ យន់, ហ៊ូ នឹម, ដែលត្រូវបានចាត់ទុកដូចជា ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ទោះបីជាកាសែតបរទេសសរសេរអ្វីក៏ដោយ ក៏មិនអាចកែប្រែការជឿទុកចិត្តរបស់បញ្ញវន្តខ្មែរបានដែរ ។ លោកបន្តថា ព័ត៌មានទាំងអស់ដែលបញ្ញវន្តខ្មែរទទួលបាននៅពេលនោះ គឺតាមរយៈ អៀង សារី ។

បន្ទាប់មក លោកមេធាវី ដុនធី បានសួរទាក់ទងនឹងការវិលត្រលប់មកប្រទេសកម្ពុជា ថាតើការធ្វើដំណើរនាពេលនោះមានឈប់សំចតនៅប្រទេសណាខ្លះមុនមកដល់ប្រទេសកម្ពុជា? លោកសាក្សីបានបញ្ជាក់ថា រាល់ការហោះហើរមកប្រទេសកម្ពុជាត្រូវតែឆ្លងកាត់តាមប្រទេសចិនដោយសារឆ្នាំដែលលោកវិលត្រលប់នោះ កម្ពុជាក្លាយជាប្រទេសឯកោ ហើយមានតែប្រេកប៉េកាំងមួយប៉ុណ្ណោះដែលអាចធ្វើដំណើរបាន ។ លោកបន្តថា នៅពេលនោះលោកត្រូវចេញថ្លៃសំបុត្រយន្តហោះដោយខ្លួនឯង ហើយលុយដែលសេះសល់ទាំងប៉ុន្មានលោកបានប្រគល់ជូនអង្គការដើម្បីទិញត្រាក់ទ័រ និងដើម្បីកសាងប្រទេស ។ ប៉ុន្តែនៅពេលមកដល់ទីក្រុងភ្នំពេញអង្គការបានបញ្ជូនអ្នកទាំងអស់ទៅមន្ទីរក-១៥ ដោយដកហូតវិទ្យុម៉ាស៊ីនថត រីឯមិត្តភក្តិរបស់លោក និងអ្នកការទូតមួយចំនួនទៀតមិនត្រូវបានបញ្ជូនចូលមន្ទីរក-១៥ទេ ដូចជាលោក អ៊ុក កេត ជាដើម ។ ក្រោយមកឈ្មោះ អ៊ុក កេត នេះ លោកបានឃើញ នៅក្នុងបញ្ជីឈ្មោះនៅទួលស្លែង ។

ឆ្លើយតបនឹងសំណួររបស់លោកមេធាវីដែលសួរទាក់ទងនឹងប្រភេទទណ្ឌកម្មដែលកម្មាភិបាលខ្មែរក្រហមបានប្រើលើលោកនៅអំឡុងពេលធ្វើការនៅមន្ទីរបឹងត្របែក លោកសាក្សីបានរៀបរាប់ថា អ្វីដែលធ្វើឲ្យលោកមានការឈឺចាប់ជាងគេ គឺមិនមែនទណ្ឌកម្មជាការវាយដំទេ ប៉ុន្តែគឺជាទណ្ឌកម្មផ្លូវចិត្ត ដោយសារអ្នកទាំងអស់នៅទីនោះត្រូវបានមើលងាយ ដោយនិយាយថាមិនបានការធ្វើយ៉ាងណាក៏នៅតែមិនអាចកសាងខ្លួនបានដែរ ព្រោះនៅជាប់កម្រែលចក្រព័ត្តិ ។ លោកសាក្សីបានបញ្ជាក់បន្ថែមថា លោកបានរស់នៅមន្ទីរបឹងត្របែកចំនួនពីរដង លើកទីមួយគឺមុនពេលលោកត្រូវបានផ្លាស់ទៅរស់នៅជំរំដីក្រហម គឺប្រហែលនៅខែធ្នូ ឆ្នាំ១៩៧៦ ហើយលើកទីពីរ គឺលោកបានមករស់នៅមន្ទីរបឹងត្របែកនេះរយៈពេល២ខែនៅមុនពេលនៃការដួលរលំរបបកម្ពុជាប្រជាធិបតេយ្យ ។ នៅពេលនោះមន្ទីរបឹងត្របែកស្ថិតក្រោមការគ្រប់គ្រងរបស់ អៀង សារី ។

បន្ទាប់មក លោកមេធាវីបានបន្តសួរទៀតថា មុនពេលដែលលោកសាក្សីចាកចេញពីទីក្រុងប៉ារីស តើលោកសាក្សីបាន

ឃើញសេចក្ដីប្រកាសអ៊ីទេ? លោកសាក្សី ថុងហឿង ឆ្លើយតបនឹងសំណួរនេះថា គឺពិតជាមានសេចក្ដីប្រកាសមួយដែលធ្វើឡើងដោយអ្នកស្និទ្ធជាមួយនឹង អៀង សារី ប៉ុន្តែលោកមិនបានដឹងថានរណាជាអ្នករៀបចំសេចក្ដីប្រកាសនោះទេ ។ លោកបានបន្តថា



មេធាវី ម៉ារី ហ្គីរ៉ូដ

សេចក្ដីប្រកាសនោះត្រូវបានផ្សព្វផ្សាយដើម្បីទាក់ទាញបញ្ញវន្តដោយវាយប្រហារលើសារព័ត៌មានចក្រពិត្ត និងអាណានិគម និងបានអះអាងថា ប្រសិនបើអង្គការបដិវត្តន៍ព្រៃវែង្សធ្វើបាបប្រជារាស្ត្រខ្លួនឯង ដូចអ្វីដែលសារព័ត៌មានចក្រព័ត្តចុះផ្សាយមែននោះប្រជាពលរដ្ឋនឹងមិនគាំទ្រ ហើយបដិវត្តន៍ក៏មិនអាចទទួលបានជ័យជម្នះដែរ ។ ម្យ៉ាងវិញទៀត នៅក្នុងសេចក្ដីប្រកាសនោះក៏បានបង្ហាញអំពីការតស៊ូនៅក្នុងប្រទេស គឺកំពុងមានភាពផុសផុល ។

ឆ្លើយតបនឹងសំណួរទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍ លោកសាក្សីបានបញ្ជាក់ថា អ្នកដែលមកពីបរទេសត្រូវបានដាក់ឲ្យនៅដាច់ដោយឡែកពីប្រជាជនមូលដ្ឋាន ហើយអ្នកដែលមកពីបរទេស មិនត្រូវបានអនុញ្ញាតឲ្យរៀបការជាមួយនឹងអ្នកមូលដ្ឋានឡើយ ។ លោកមេធាវីបានបន្តសួរទៀតថា នៅអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ជាពិសេសនៅពេលដែលលោកសាក្សីរស់នៅមន្ទីរបឹងត្របែក តើលោកសាក្សីធ្លាប់បានដឹងអំពីការបោសសម្អាតខ្មាំងដែរឬទេ? លោកសាក្សីបានរៀបរាប់ថា លោកមិនដែលគិតថា មានការយកមនុស្សទៅសម្លាប់នោះទេ ហើយលោកក៏មិនធ្លាប់ដឹងថា មានមន្ទីរស-២១ នៅជិតមន្ទីរបឹងត្របែកនោះដែរ ។ ប៉ុន្តែ ក្រោយមកលោកក៏ចាប់អារម្មណ៍អំពីការបាត់ខ្លួនមិត្តភក្តិ និងអ្នកធ្វើការជាមួយលោក ប៉ុន្តែលោកមិនគិតថាអ្នកទាំងនោះត្រូវបាននាំយកទៅសម្លាប់នោះទេ ព្រោះលោកបានជួបមិត្តរបស់លោកមួយចំនួននៅកន្លែងផ្សេងដែរ ។

## ១) មេធាវីអន្តរជាតិតំណាងដើមបណ្ដឹងរដ្ឋប្បវេណី

មេធាវីអន្តរជាតិតំណាងដើមបណ្ដឹងរដ្ឋប្បវេណី គឺលោក ស្រី ម៉ារី ហ្គីរ៉ូដ ត្រូវបានអង្គជំនុំជម្រះផ្ដល់វេទិកាសួរដេញដោលលោកសាក្សី អុង ថុងហឿង បន្ដពីសហភាគាជាតិរបស់ខ្លួន ។ នៅពេលចាប់ផ្ដើម លោកស្រីមេធាវី ម៉ារី បានស្នើឲ្យលោកសាក្សីធ្វើការពន្យល់អំពីសម្ដីដែលលោកបានឆ្លើយប្រាប់សហចៅក្រមស៊ើបអង្កេតថា «អៀង សារី គឺជាអ្នកទទួលខុសត្រូវលើក្រុមខ្មែរដែលវិលត្រលប់មកពីបរទេស» ។ លោកសាក្សីបានអះអាងថា អៀង សារី ជាអ្នកទទួលខុសត្រូវចំពោះខ្មែរដែលវិលត្រលប់ចូលក្នុងប្រទេស ព្រោះ អៀង សារី គឺជាបុគ្គលម្នាក់ដែលបានរៀបចំឲ្យមានការវិលត្រលប់របស់ខ្មែរពីបរទេស ។ លោកសាក្សីបានបន្ថែមថា នៅពេលលោកវិលត្រលប់ពីជំរំដីក្រហម លោកបានជួបជាមួយ អៀង សារី ហើយនៅពេលនោះ អៀង សារី សួរថា «តើនរណាជាអ្នកបញ្ជូនអ្នកទាំងអស់គ្នាទៅជំរំដីក្រហម?» ។ លោកមានចម្ងល់នៅក្នុងចិត្តថា ហេតុអ្វីបានជា អៀង សារី មិនបានដឹងអំពីបញ្ហានេះឬមួយ អៀង សារី ធ្វើមិនដឹងដើម្បីលាងសម្អាតខ្លួន? ប៉ុន្តែបើ អៀង សារី មិនដឹងហេតុអ្វីបានជាក្មួយពីរនាក់របស់ អៀង សារី ត្រូវបានយកចេញពីដីក្រហម ហើយអ្នកទាំងនោះនៅរស់រានមានជីវិតរហូតដល់សព្វថ្ងៃរីឯអ្នកផ្សេងទៀតបាត់ខ្លួនទៅវិញ ។

បន្ទាប់មក លោកស្រីមេធាវីបានបន្តសួរទាក់ទងនឹងលោក រស់ សារិន ដែលត្រូវបានហៅចេញពីអង្គប្រជុំនៅមន្ទីរបឹងត្របែក ក្រោយមក ឈ្មោះរបស់លោកត្រូវបានរកឃើញនៅក្នុងបញ្ជីឈ្មោះនៃអ្នកជាប់ឃុំនៅមន្ទីរស-២១ ។ គួរកត់សម្គាល់ថា ដោយសារភរិយារបស់លោក រស់ សារិន គឺជាដើមបណ្ដឹងរដ្ឋប្បវេណីមួយ

រូបនៅក្នុងសំណុំរឿង០០២ ដូច្នេះលោកស្រីមេធាវីបានផ្តោតសំណួរមួយចំនួនទាក់ទងនឹងការចាប់ខ្លួននិងការស្លាប់របស់លោក វស់ សារិន ។ ឆ្លើយតបនឹងសំណួររបស់លោកស្រីមេធាវីដែលសួរថា តើលោកសាក្សីមានវត្តមាននៅពេលដែលអង្គការហៅលោក វស់ សារិន ចេញពីអង្គប្រជុំដែរឬទេ? សាក្សីបានអះអាងថា នៅអំឡុងពេលនៃកិច្ចប្រជុំនៅមន្ទីរបឹងត្របែក លោកបានឃើញលោក វស់ សារិន ដែលជាបងថ្លៃរបស់ខ្លួន លោកសាស្ត្រាចារ្យ ឈូក មឹងម៉ៅ និងលោកសាស្ត្រាចារ្យ ភឹង គុន រួមនឹងខ្មែរដែលវិលត្រលប់មកពីបរទេសមួយចំនួនទៀតត្រូវបានកម្មាភិបាលខ្មែរក្រហមនាំចេញពីសាលប្រជុំ ហើយលោកក៏នៅទីនោះជាមួយគ្នាដែរ ប៉ុន្តែលោកមិនអាចនិយាយលាគ្នាបានទេ ។ សាក្សីមិនបានដឹងថា ហេតុអ្វីកម្មាភិបាលខ្មែរក្រហមនាំយកអ្នកទាំងនោះចេញពីកិច្ចប្រជុំនោះទេ លោកគ្រាន់តែគិតថាប្រហែលជាអង្គការត្រូវការអ្នកទាំងនោះធ្វើការវិញតែប៉ុណ្ណោះ ។

គួរកត់សម្គាល់ថា នៅពេលលោកស្រីមេធាវី ម៉ារី ហ្គីរ៉ូដ បានលើកយកឃ្លាមួយនៃសៀវភៅ «ខ្ញុំជឿខ្មែរក្រហម» របស់លោកសាក្សីមកអានជូនលោកសាក្សីធ្វើការបញ្ជាក់ ស្រាប់តែលោកសាក្សី អុង ថុងហឿង មានអារម្មណ៍ក្តុកក្តួល និងបានសម្រក់ទឹកភ្នែក បន្ទាប់ពីលោកបានរៀបរាប់បានបន្តិច ។ ឃ្លាដែលលោកស្រីមេធាវីបានលើកឡើងនោះបានសរសេរថាៈ

*«ខ្ញុំគ្មានបំណងសរសេរសៀវភៅប្រវត្តិសាស្ត្រទេ តែទិសដៅនៃសៀវភៅនេះ គឺរៀបរាប់អំពីការ លាងខួរ ការកម្ទេចបុគ្គល ការខ្លាច ទុក្ខវេទនា ការស្រេកឃ្លាន ការឈ្លោះប្រកែកគ្នានៅពេលដែលគេយកមនុស្សទៅដាក់ក្នុងមន្ទីរឃុំឃាំង ហើយធ្វើទារុណកម្ម ។ ខ្ញុំឆ្លៀតបង្ហាញថា នៅពេលវេទនា យើងអាចប្រព្រឹត្តអំពើដែលនៅពេលធម្មតាយើងខ្មើមរអើម ។ ខ្ញុំបង្ហាញឲ្យឃើញថា អ្នកខ្លះដោយឱកាសនិយម ឬក៏ដោយការលាងខួរ នោះក្បត់គ្នាឯង ។ ខ្ញុំលើកឧទាហរណ៍ពីនេះបន្តិចពីនោះបន្តិចដើម្បីបង្ហាញឲ្យឃើញថា ក្នុងបុគ្គលយើងម្នាក់ៗមានការប្រទាញប្រទង់គ្នា ហើយមនុស្សម្នាក់ៗមានអត្តសញ្ញាណខុសៗគ្នា ។ នៅក្នុងសៀវភៅនេះ ខ្ញុំបានលើកតម្កើងវីរភាពរបស់គ្នាយើងមួយចំនួន ដែលក្លាហានហ៊ានប្រឆាំងនឹងខ្មែរក្រហម ។ អ្នកខ្លះគេលួចរត់អ្នកខ្លះទៀតធ្វើឃាតខ្លួនឯង ។ ជីវិតពួកអ្នកបាត់បង់ទៅនឹងនៅជាអមតៈនៅក្នុងព្រលឹងរបស់ខ្ញុំ ។»*

បន្ទាប់មក លោកស្រីមេធាវីបានបន្តសួរទាក់ទងនឹងកិច្ចប្រជុំជ្រើសតាំងខ្មែរដែលវិលត្រលប់មកពីបរទេសដើម្បីគ្រប់គ្រងមន្ទីរប-៣០, ប-៣១ និងប-៣២ នៅមន្ទីរបឹងត្របែក ។ ឆ្លើយតបនឹងសំណួរនេះ លោកសាក្សីបានបញ្ជាក់ថា នៅអំឡុងពេលដែលលោកត្រលប់មកមន្ទីរបឹងត្របែកជាលើកទីពីរ គឺចាប់ផ្តើមមានការផ្លាស់ប្តូរដោយមានការជ្រើសតាំងខ្មែរដែលត្រលប់មកពីបរទេសឲ្យគ្រប់គ្រងខ្មែរផ្សេងទៀតនៅទីតាំង ។ ការជ្រើសតាំងនេះ គឺធ្វើ ឡើងក្រោមវត្តមានរបស់ អៀង សារី ។ ពេលនោះលោក ហំ ហ៊ុយ ត្រូវបានជ្រើសតាំងឲ្យធ្វើជាប្រធានមន្ទីរប-៣០ ហើយលោក ហោ ណាំហុង ត្រូវបានជ្រើសតាំងធ្វើជាប្រធានមន្ទីរប-៣២ ។

ឆ្លើយតបនឹងសំណួររបស់លោកស្រីមេធាវីដែលសួរទាក់ទងនឹងវិធីសាស្ត្រក្នុងការចងក្រងសៀវភៅ «ខ្ញុំជឿខ្មែរក្រហម» សាក្សី អុង ថុងហឿង បានបញ្ជាក់ថា ផ្នែកទីមួយនៃសៀវភៅរបស់លោកគឺលោកផ្អែកលើសៀវភៅកំណត់ហេតុរបស់ភរិយាលោកដែលបានកត់ត្រាទុកអំពីអ្វីដែលកើតឡើងនៅមុនពេលលោកវិលត្រលប់ចូលប្រទេសកម្ពុជានៅពាក់កណ្តាលឆ្នាំ១៩៧៦ ។ សាក្សីបានបន្តថា កំណត់ហេតុនោះភរិយារបស់លោកបានសរសេររហូតដល់ពេលលោកត្រូវផ្លាស់ទៅរស់នៅនៅឯជំរំដីក្រហម ។ បន្ទាប់ពីចាកចេញពីជំរំដីក្រហម គឺលោកបានកត់ត្រាបន្តនៅក្នុងកំណត់ហេតុផ្ទាល់ខ្លួន ។ សៀវភៅរបស់លោកត្រូវបានបោះពុម្ពនៅឆ្នាំ២០០៣នៅក្នុងរោងពុម្ពមួយនៅក្នុងប្រទេសបារាំង ដោយសារមានការជំរុញពីលោក ហង់រី ឡូកា, លោកសាស្ត្រាចារ្យ ដេវីដ ឆេនដល័រ និងលោក ស្ទីវិន ហេដឌ័រ ។ ប៉ុន្តែ លោកអះអាងថា លោកមិនដែលមានបំណងបោះពុម្ពកំណត់ហេតុរបស់លោកជាសៀវភៅទេ លោកគ្រាន់តែសរសេរឡើងក្នុងគោលបំណងទុកឲ្យកូនៗរបស់លោកមើលតែប៉ុណ្ណោះ ។ លោកបានពន្យល់ទៀតថា សៀវភៅរបស់លោកមិនមែនសរសេរឡើងក្នុងគោលបំណងសងសឹកឬក៏ចង់លើកឡើងអំពីការធ្វើបាបរបស់ខ្មែរក្រហមចំពោះលោកនោះទេ លោកគ្រាន់តែចង់បង្ហាញថា ពេលដែលបុគ្គលណា

ម្នាក់ត្រូវបានចាប់ដាក់ឲ្យនៅកន្លែងមួយដែលខ្វះសេរីភាព តើអ្នកទាំងនោះនឹងមានប្រតិកម្មរបៀបណា ។

មុនពេលបញ្ចប់ការសាកសួរ លោកស្រីមេធាវី ម៉ារី បានស្នើសុំការពន្យល់ពីសាក្សី អ៊ុង ចុងហឿង អំពីមូលហេតុដែលនាំឲ្យលោកដាក់ចំណងជើងសៀវភៅរបស់លោកថា "ខ្ញុំជឿខ្មែរក្រហម" ។ ឆ្លើយតបនឹងសំណើនេះ សាក្សី ចុងហឿង បានពន្យល់ថា លោកបានគាំទ្រចលនាតស៊ូ លោកគាំទ្រ ខៀវ សំផន, ហ៊ូ នឹម និង ហ៊ូ យន់ ចាប់តាំងពីលោកមានអាយុ២៥ឆ្នាំមកម៉្លេះ ។ រីឯចំណងជើងនៃសៀវភៅរបស់លោក លោកបញ្ជាក់ថា ចំណងជើងនេះមិនមែនលោកជាអ្នកជ្រើសរើសនោះទេ គឺរោងពុម្ពដែលបោះផ្សាយសៀវភៅរបស់លោកនោះជាអ្នកស្នើឲ្យលោកដាក់ចំណងជើងដូច្នេះ ។

**សូមបញ្ជាក់ថា** បន្ទាប់ពី ក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបញ្ចប់ការសាកសួរដេញដោលរបស់ខ្លួន អង្គជំនុំជម្រះបានប្រគល់វេទិកាបន្តជូនលោកចៅក្រម ហ្សង់ម៉ាក ឡាវើញ (Jean-Marc Lavergne) សាកសួរសាក្សី អ៊ុង ចុងហឿង មុននឹងប្រគល់វេទិកាជូនមេធាវីការពារក្តីទាំងបីក្រុម ។

### ៤) ការសួរសាក្សីដោយចៅក្រម ហ្សង់ម៉ាក ឡាវើញ

លោកចៅក្រមសញ្ជាតិបារាំង ហ្សង់ម៉ាក ឡាវើញ បានចាប់ផ្តើមសំណួរដំបូងរបស់លោកទាក់ទងនឹងកិច្ចប្រជុំរវាងបញ្ញវន្តដែលរស់នៅមន្ទីរបឹងត្របែកជាមួយនឹង អៀង សារី ដែលពេលនោះ អៀង សារី បានលើកឡើងអំពីការចោទប្រកាន់ចំពោះ វ៉ាន់ ពីនី ថាជាប់ពាក់ព័ន្ធនឹងសេ.អ៊ី.អា និងអេស.ដេ.អឺ.សេ.អឺ និងថាទាល់តែមានការឆ្លើយដាក់ចំនួនបីទើបអាចចាប់ខ្លួននរណាម្នាក់បាន ។ លោកចៅក្រមបានសួរបញ្ជាក់ថា តើសម្តីនោះពិតជាសម្តីរបស់ អៀង សារី ឬយ៉ាងណា? លោកសាក្សីបានអះអាងថា ឃ្លាដែល លោកចៅក្រមបានលើកឡើងនោះ គឺពិតជាសម្តីរបស់ អៀង សារី ដោយសារ វ៉ាន់ ពីនី គឺជាមិត្តភក្តិបងប្រុសរបស់លោក ដូច្នេះ នៅពេល អៀង សារី លើកឡើងអំពី វ៉ាន់ ពីនី ធ្វើឲ្យលោកមានការចាប់អារម្មណ៍យ៉ាងខ្លាំង ។

ឆ្លើយតបនឹងសំណួររបស់លោកចៅក្រម ឡាវើញ ដែលសួរថា តើអ្នកដែលលោកសាក្សីធ្លាប់ជួបនៅក្នុងសម័យខ្មែរក្រហមមានសិទ្ធិក្នុងការទាមទារអាហារ ដើម្បីហូបឲ្យបានគ្រប់គ្រាន់ដែលឬទេ? លោកសាក្សីបានបញ្ជាក់ថា អ្នករស់នៅក្នុងសម័យនោះមិនមាននរណាម្នាក់មានសិទ្ធិក្នុងទាមទារអាហារគ្រប់គ្រាន់ទេ ។ លោកបន្តថា លោកពិតជាមានការសោកស្តាយចំពោះការត្រលប់មកវិញ ប៉ុន្តែលោកមិនដែលហ៊ានតវ៉ា ឬប្រឆាំងនឹង អៀង សារី ឡើយ ។ ចំពោះសិទ្ធិក្នុងការចាកចេញ លោកសាក្សីបញ្ជាក់ថាមិនមាននរណាម្នាក់ស្រមៃថាចង់ត្រលប់ទៅជួបជាមួយមិត្តភក្តិរបស់ខ្លួននៅទីក្រុងប៉ារីសវិញទេ ។

បន្ទាប់មក លោកចៅក្រមបានស្នើលោកសាក្សីឲ្យធ្វើការបញ្ជាក់អំពីពាក្យសម្តីដែលលោកសាក្សីបានអះអាងថា លោកធ្លាប់បានចូលរួមនៅក្នុងការដ្ឋានវាយកម្ទេចព្រះវិហារមួយនៅទីក្រុងភ្នំពេញ និងមូលហេតុដែលនាំឲ្យមានការវាយកម្ទេចវិហារនោះ ។ ឆ្លើយតបនឹងសំណើរបស់លោកចៅក្រម លោកសាក្សីបានអះអាងថា នៅពេលដែលលោកវិលត្រលប់ចូលប្រទេសកម្ពុជាបានបន្តិច គឺនៅពេលដែលលោករស់នៅមន្ទីរក-១៥ កម្មាភិបាលខ្មែរក្រហមបានដឹកលោក និងអ្នកផ្សេងទៀតប្រហែលដប់នាក់ទៅធ្វើការនៅកន្លែងមួយ ប៉ុន្តែលោកមិនដឹងថានៅទីណានោះទេ ។ នៅពេលទៅដល់ទីនោះ លោក និងអ្នកដទៃទៀតត្រូវបានបញ្ជាឲ្យវាយថ្ម វាយសសរធំៗដើម្បីយកដែក ក្រោយមកលោកបានឮអ្នកផ្សេងនិយាយថាទីកន្លែងវាយថ្មនោះជាវិហារដែលមានទីតាំងនៅមុខស្ថានីយរថភ្លើង ។ ចំពោះមូលហេតុដែលនាំឲ្យមានការវាយវិហារនោះ លោកសាក្សីបានបញ្ជាក់ថា លោកមិនបានដឹងច្បាស់នោះទេ ប៉ុន្តែលោកគ្រាន់តែសង្ស័យថា ដែកទាំងនោះត្រូវបានយកមកធ្វើជាឧបករណ៍ដើម្បីធ្វើទារុណកម្មនៅមន្ទីរស-២១ ឬគុកទួលស្លែង ។

មុនពេលបញ្ចប់ការសាកសួរ លោកចៅក្រម ហ្សង់ម៉ាក ឡាវើញ បានផ្តល់ឱកាសជូនលោក សាក្សី អ៊ុង ចុងហឿង ឲ្យបង្ហាញពីអារម្មណ៍របស់លោកចំពោះការបាត់បង់សាច់ញាតិ បងប្អូន និងមិត្តភក្តិជិតស្និទដោយសាររបបកម្ពុជាប្រជាធិបតេយ្យ ។ លោកសាក្សី បានពិពណ៌នាអំពីអារម្មណ៍របស់លោកចំពោះខ្មែរក្រហមថា ក្រុមគ្រួសាររបស់លោកត្រូវរលត់រលាយឪពុករបស់លោកបងប្អូន៤នាក់ និងក្រុមគ្រួសាររបស់អ្នកទាំងនោះត្រូវបានសម្លាប់ ។ សុភមង្គលជាមនុស្សរបស់លោកបានរលាយអស់នៅក្នុងរយៈកាល៤ឆ្នាំនោះ ហើយការចូលរួមរបស់លោកក្នុងតុលាការ

នាពេលនេះ មិនមែនក្នុងគោលបំណងដើម្បីសងសឹកទេ ប៉ុន្តែលោកគ្រាន់តែចង់ចូលរួមចំណែកក្នុងការទប់ស្កាត់កុំឲ្យមានការសម្លាប់មនុស្សបន្តទៀតនាពេលអនាគត។ លោកបានបន្ថែមថា សមាជិកគ្រួសាររបស់លោកដែលនៅរស់រានមានជីវិត គឺមានម្តាយ ប្អូនស្រី និងក្មួយស្រីរបស់លោកដែលកំពុងរស់នៅប្រទេសបារាំង។ រីឯផ្ទះសម្បែងរបស់លោកនៅសម័យនោះត្រូវបានកម្ទេច។ លោកបញ្ជាក់ថា នេះគឺជារឿងរ៉ាវដែលលោកមិនអាចបំភ្លេចបាននៅក្នុងជីវិតរបស់លោក។

**គួរកត់សម្គាល់ថា** បន្ទាប់ពីចៅក្រម ហ្សង់ម៉ាក ឡាវែញ បញ្ចប់ការសួរដេញដោលរបស់ខ្លួន មេធាវីជាតិការពារក្តីជនជាប់ចោទ អៀង សារី គឺលោក អាង ឧត្តម បានឡើងធ្វើការកត់សម្គាល់ចំពោះការអនុញ្ញាតរបស់លោកចៅក្រម ឡាវែញ ឲ្យសាក្សីបង្ហាញពីទុក្ខសោករបស់ខ្លួន។ លោកមេធាវីបានកត់សម្គាល់ថា ការណ៍ដែលលោកចៅក្រមអនុញ្ញាតឲ្យសាក្សីបង្ហាញអំពីទុក្ខសោករបស់ខ្លួនគឺអាចនឹងធ្វើឲ្យប៉ះពាល់ដល់ពេលវេលា និងឋានៈជាសាក្សី ដោយហេតុថា ការអនុវត្តមុនៗគឺមានតែដើមបណ្តឹងរដ្ឋប្បវេណីតែប៉ុណ្ណោះដែលត្រូវបានអនុញ្ញាតឲ្យបង្ហាញអំពីទុក្ខសោក ប៉ុន្តែសាក្សីមិនត្រូវបានអនុញ្ញាតឲ្យធ្វើដូច្នេះឡើយ។ លោកមេធាវីបានអះអាងទៀតថា ការសម្តែងអំពីទុក្ខសោករបស់លោកសាក្សី អ៊ុង ចុងហឿង ហាក់បីដូចជាបង្ហាញឲ្យឃើញថា លោកគឺជាដើមបណ្តឹងរដ្ឋប្បវេណីទៅវិញ។ ការលើកឡើងរបស់លោកមេធាវី អាង ឧត្តម ត្រូវបានជំទាស់ដោយតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ គឺលោក វាំងសង់ និងលោកស្រីមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ស៊ីម៉ុណូហ្វុត។ បន្ទាប់ពីបានពិភាក្សាក្នុងចំណោមចៅក្រមអង្គជំនុំជម្រះរួចមក ប្រធានអង្គជំនុំជម្រះ គឺលោកចៅក្រម និល ណុន បានដោះស្រាយបញ្ហានេះដោយសម្រេចថា ការលើកឡើងរបស់លោក មេធាវី អាង ឧត្តម មិនមានចែងក្នុងវិធានផ្ទៃក្នុង ឬក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាទេ។ បន្ថែមពីលើនេះ លោកចៅក្រមក៏បានព្រមានដល់លោកមេធាវីមុននឹងធ្វើអត្ថាធិប្បាយអំពីអ្វីដែលខ្លួនមានបំណងចង់លើកឡើង លោកមេធាវីចាំបាច់ត្រូវកំណត់អំពីប្រធានបទដែលខ្លួនចង់លើកឡើង ដើម្បីឲ្យអង្គជំនុំជម្រះអាចពិចារណាថា តើគួរអនុញ្ញាត ឬមិនអនុញ្ញាតឲ្យលើកឡើងដើម្បីចៀសវាងបញ្ហាដែលអាចនាំឲ្យមានការបំភិតបំភ័យដល់សាក្សី និងធ្វើឲ្យសាក្សីបាត់បង់នូវជំនឿចិត្តរបស់ខ្លួននៅក្នុងការផ្តល់សក្ខីកម្ម។

**៥) ការសួរសាក្សីដោយមេធាវីការពារក្តីទាំង បីក្រុម**

អង្គជំនុំជម្រះបានបន្តប្រគល់វេទិកាជូនក្រុមមេធាវីការពារក្តីទាំងបីក្រុមដើម្បីសាកសួរសាក្សីដោយចាប់ផ្តើមពីក្រុមមេធាវីការពារក្តី នួន ជា និងបន្តទៅក្រុមមេធាវី អៀង សារី និង ខៀវ សំផន។ ដោយសារការផ្តល់សក្ខីកម្មរបស់សាក្សី អ៊ុង ចុងហឿង បានដាក់បន្ទុកភាគច្រើនលើជនជាប់ចោទ អៀង សារី ធ្វើឲ្យក្រុមមេធាវីការពារក្តី អៀង សារី ចំណាយពេលវេលាច្រើនជាងក្រុមមេធាវីការពារក្តីជនជាប់ចោទផ្សេងទៀត។

**ក) ក្រុមមេធាវីការពារក្តី នួន ជា**

ការសួរដេញដោលសាក្សីដោយក្រុមមេធាវីការពារក្តី នួន ជា បានចាប់ផ្តើមដោយមេធាវីអន្តរជាតិគឺលោក អេនឌ្រូ អ៊ីនូហ្វ៊ី និងបន្ទាប់មក គឺមេធាវីជាតិលោក សុន អរុណ។ មេធាវីទាំងពីររូបបានចំណាយពេលវេលាប្រហែល១ម៉ោងកន្លះតែប៉ុណ្ណោះក្នុងការសាកសួរលើលោកសាក្សី អ៊ុង ចុងហឿង។ ការសួរដេញដោលរបស់ក្រុមមេធាវីការពារក្តី នួន ជា បានផ្តោតជាសំខាន់លើប្រវត្តិនៃការងារ និងការស្រាវជ្រាវរបស់សាក្សីនៅសារមន្ទីរទួលស្លែងក្រោយពីការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ និងការទាក់ទងរវាងលោកសាក្សី និងអ្នកស្រាវជ្រាវល្បីៗអំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហម។

**ក.១) ការរៀបចំឯកសារដើម្បីចោទប្រកាន់មេដឹកនាំខ្មែរក្រហម**

មេធាវី អ៊ីនូហ្វ៊ី បានចាប់ផ្តើមសំណួរដំបូងដោយលើកយកកំណត់ហេតុស្តាប់ចម្លើយដែលធ្វើឡើងដោយការិយាល័យសហចៅក្រមស៊ើបអង្កេតជាមួយសាក្សី អ៊ុង ចុងហឿង ដើម្បីសាកសួរ។ លោកមេធាវីបានអានផ្នែកមួយនៃកំណត់ហេតុស្តាប់ចម្លើយនោះទាក់ទងនឹងការធ្វើការងាររបស់សាក្សីនៅសារមន្ទីរទួលស្លែងនៅក្រោយថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ទាក់ទងនឹងការធ្វើការនៅទួលស្លែង។ លោកសាក្សីបានទទួលស្គាល់ថា លោកធ្លាប់បានធ្វើការនៅទីនោះរយៈពេល២ទៅ៣ខែមានតួនាទីជាអ្នក

រៀបចំឯកសារសំណុំរឿង ជាពិសេសឯកសារចម្លើយសារភាពរបស់បុគ្គលដែលត្រូវបានសម្លាប់នៅមន្ទីរស-២១ ដើម្បីឲ្យមានសណ្តាប់ធ្នាប់ និងមានរបៀបរៀបរយ ។

បន្ទាប់មក លោកមេធាវីបានបន្តសួរទាក់ទងនឹងលោក អ៊ីង ប៊ិច និងឈ្មោះ ម៉ៃ ឡាំ ដែលជាជនជាតិវៀតណាមធ្វើការនៅសារមន្ទីរទួលស្លែង ថាតើលោកសាក្សីធ្លាប់ស្គាល់អ្នកទាំងពីរនេះដែរឬទេ? លោកសាក្សីបានអះអាងថា លោកធ្លាប់ស្គាល់អ្នកទាំងពីររូបនេះ ប៉ុន្តែនៅពេលមេធាវីការពារក្តីសួរថា តើអ្នកទាំងពីរនាក់នោះជាមនុស្សគួរឲ្យទុកចិត្តដែរឬយ៉ាងណា? លោកបានឆ្លើយថា លោកមិនអាចអះអាងថា លោកទុកចិត្តអ្នកទាំងនោះ១០០ភាគរយទេ ។ ឆ្លើយតបនឹងសំណួរទាក់ទងនឹងឯកសារដែលមាននៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង លោកបានបញ្ជាក់ថា លោកមិនបានដឹងឯកសារនោះបាត់ ឬយ៉ាងណានោះទេ ប៉ុន្តែលោកបានព្យាយាមស្វែងរកឯកសារមួយចំនួនដូចជាចម្លើយសារភាពរបស់លោក នួន ឃឿន និងឯកសារមួយចំនួនទៀត ប៉ុន្តែលោកមិនបានរកឃើញទេ ។ លោកបានបន្តទៀតថា មានឯកសារមួយចំនួនត្រូវបានយកទៅខ្ចប់ចេកចៀន ហើយឯកសារខ្លះ ឃើញមាននៅតាមផ្សារជាដើម ។

ឆ្លើយតបនឹងសំណួររបស់មេធាវីដែលសួរថា តើការងាររៀបចំឯកសាររបស់លោកសាក្សីនៅពេលនោះគឺដើម្បីកាត់មេដឹកនាំខ្មែរក្រហមឬយ៉ាងណា? សាក្សី អ៊ុង ចុងហឿង បានអះអាងថា លោកពិតជាធ្លាប់បានជួយរៀបចំឯកសារដើម្បីកាត់ទោស ប៉ុល ពត មែន ប៉ុន្តែលោកមិនចាំច្បាស់អំពីទីតាំងជំនុំជម្រះទោសថានៅទូតចិន ឬនៅសាលចតុមុខទេ ។

បន្ទាប់មក លោកមេធាវីបានបន្តសួរទៀតថា តើជាការត្រឹមត្រូវដែរឬទេ ដែលថាវៀតណាមមានបំណងចង់ដាក់បញ្ចូលនូវខ្លឹមសារដែលខ្លួនចង់បានទៅក្នុងការសរសេរឯកសារប្រវត្តិសាស្ត្រកម្ពុជានៅពេលនោះ បើផ្អែកលើបទពិសោធន៍របស់លោកសាក្សីនៅទួលស្លែងនៅពេលនោះ? សាក្សីឆ្លើយតបនឹងសំណួរនេះដោយបានពន្យល់ថា នៅពេលនោះលោក ម៉ៃឡាំ ដែលជាជនជាតិវៀតណាមគឺជាអ្នកដឹកនាំនិងជាប្រធាននៅសារមន្ទីរទួលស្លែង ។ លោកក៏បានទទួលស្គាល់ដែរថា ជាការពិត វៀតណាម ពិតជាចង់ឲ្យលោក, លោក វ៉ាន់ឌី កាអុន និងលោក សាំងកង់ សេណាវ៉ាត និងមិត្តភក្តិរបស់លោកមួយចំនួនទៀតសរសេរសៀវភៅប្រវត្តិសាស្ត្រឡើងវិញ ប៉ុន្តែដោយសារមិនចុះសម្រុងគ្នា លោកក៏បានរត់ចេញពីប្រទេសកម្ពុជានៅពេលនោះ ។

### ក.(២) មន្ទីរបឹងត្របែក និងតួនាទីរបស់លោក ហោ ណាំហុង

ដូចជាការចោទសួរលើសាក្សីផ្សេងមុនៗដែរ លោកមេធាវីការពារក្តីឲ្យជនជាប់ចោទ នួន ជា បានចោទសួរលោកសាក្សី អ៊ុង ចុងហឿង អំពីតួនាទីរបស់លោក ហោ ណាំហុង នៅមន្ទីរបឹងត្របែកក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ឆ្លើយតបនឹងសំណួរនេះ លោកសាក្សីបានបញ្ជាក់ថា លោក ហោ ណាំហុង ពិតជាធ្លាប់បានគ្រប់គ្រងនៅមន្ទីរប-៣២ នៅបឹងត្របែក ។ លោកបន្តថាលោក ហោ ណាំហុង បានទទួលតំណែងជាប្រធានមន្ទីរប-៣២ នេះបន្ទាប់ពី សាវ៉ែន និង វ៉ាន់ពីនី ត្រូវបានបាត់ខ្លួន ។ លោក អ៊ុង ចុងហឿង បានសង្កត់ធ្ងន់ថា បើតាមការយល់ឃើញរបស់លោក លោកមិនជឿថា លោក ហោ ណាំហុង គឺជាកម្មាភិបាលរបស់ខ្មែរក្រហមទេ ព្រោះគ្មានឯកសារណាដែលបញ្ជាក់ថា គាត់ជាបក្ខជននៃបក្សកុម្មុយនីស្តកម្ពុជា ហើយលោកជឿជាក់ថា លោក ហោ ណាំហុង ក៏មិនបានដឹងថា មានមន្ទីរស-២១ នៅពេលនោះដែរ ។ សាក្សី អ៊ុង ចុងហឿង បញ្ជាក់បន្ថែមថា ការលើកឡើងរបស់លោកដូច្នេះ មិនមែនដើម្បីការពារលោក ហោ ណាំហុង ទេ ប៉ុន្តែលោកគ្រាន់តែចង់ការពារយុត្តិធម៌តែប៉ុណ្ណោះ ។ លើសពីនេះទៀត នៅពេលដែលលោកមកដល់មន្ទីរបឹងត្របែក លែងមានការបាត់ខ្លួនមនុស្សទៀតហើយ ។ លោកបានបញ្ជាក់ថា បច្ចុប្បន្នលោក ហោ ណាំហុង ពិតជាមានតួនាទីជារដ្ឋមន្ត្រីក្រសួងការបរទេសនៃប្រទេសកម្ពុជា ។

បន្ទាប់មក លោកមេធាវីបានសួរទៀតថា បើតាមបទពិសោធន៍របស់លោកសាក្សីនៅបឹងត្របែក តើលោក ហោ ណាំហុង អាចចូលមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះអំពីរចនាសម្ព័ន្ធនៃមន្ទីរបឹងត្របែកបានដែរឬទេ? ភ្លាមៗនោះ លោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ វ៉ាំងសង់ បានជំទាស់នឹងសំណួររបស់មេធាវី នួន ជា ដោយអះអាងថា សំណួរដែលចោទសួរលើសាក្សី គឺជាសំណួរដែលធ្វើឲ្យសាក្សីឆ្លើយស្មានៗ ។ អង្គជំនុំជម្រះ

បានយល់ស្របចំពោះការជំទាស់របស់សហព្រះរាជអាជ្ញា និង បង្គាប់មិនឲ្យសាក្សីឆ្លើយតបនឹងសំណួរនេះឡើយ ។ បន្ទាប់មក លោកមេធាវី អ៊ីនូហ៊្វី បានបញ្ចប់ការសួរដេញដោលរបស់ខ្លួន និង ប្រគល់វេទិកាបន្តទៅសហភាតារបស់ខ្លួនគឺលោកមេធាវី សុន អរុណ ដើម្បីសាកសួរលោកសាក្សី អ៊ុង ចុងហៀង ។

### *ក.៣) ទំនាក់ទំនងរវាងរណសិរ្សរួបរួមជាតិកម្ពុជា និងបក្សកុម្មុយនីស្តកម្ពុជា*

លោកមេធាវី សុន អរុណ បានចាប់ផ្តើមសំណួរដំបូងរបស់ខ្លួនទាក់ទងនឹងទំនាក់ទំនងរវាងបក្សកុម្មុយនីស្តកម្ពុជា និងរណសិរ្សរួបរួមជាតិកម្ពុជា ។ ឆ្លើយតបនឹងសំណួរនេះ លោកសាក្សីបាន ពន្យល់ថា បក្សកុម្មុយនីស្តកម្ពុជាដែលមាន សាឡុត ស ជាលេខាបក្ស គឺជាអង្គការសម្ងាត់មួយ ហើយក្រោយរដ្ឋប្រហារឆ្នាំ១៩៧០ ប្រជាជនទាំងក្នុង និងក្រៅប្រទេសមិនបានដឹងថា ខៀវ សំផន, ហ៊ូ យន់, ហ៊ូ នឹម គឺជាសមាជិកនៃបក្សកុម្មុនីស្តកម្ពុជានោះទេ ។ នៅពេលនោះគ្មាននរណាម្នាក់ស្គាល់ ប៉ុល ពត ជានរណាទេ ។ ដូច្នេះ លោកមិនអាចនិយាយថា រណសិរ្សរួបរួមជាតិកម្ពុជាសហការជាមួយនឹងបក្សកុម្មុយនីស្តកម្ពុជាបានឡើយ ព្រោះរណសិរ្សរួបរួមជាតិកម្ពុជា សហការជាមួយឥស្សរជនដែលប្រជាជនធ្លាប់ទទួលស្គាល់ថា ជាអ្នកស្អាតស្អំ ដូចជា ខៀវ សំផន, ហ៊ូ យន់ និង ហ៊ូ នឹម រួមជាមួយនឹងបញ្ញវន្តមួយចំនួនទៀត មិនមែនសហការជាមួយនឹងបក្សកុម្មុយនីស្តកម្ពុជាទេ ។ បន្ទាប់មកលោកមេធាវីបានសួរលោកសាក្សីថាតើលោកសាក្សីបានចូលរួមជាមួយរណសិរ្សរួបរួមជាតិកម្ពុជានៅពេលណា? លោកសាក្សីបានឆ្លើយថា លោកបានចូលរួមរណសិរ្សបន្ទាប់ពីមានសេចក្តីថ្លែងការណ៍៥ចំណុចរបស់សម្តេចសីហនុ នៅខែមិនា ឆ្នាំ១៩៧០ គឺក្រោយពេលលោក លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេចរួចហើយ ។ លោកបានបន្តថា អាវុធដែលរណសិរ្សរួបរួមជាតិកម្ពុជាប្រើប្រាស់ដើម្បីការធ្វើការតស៊ូភាគច្រើនគឺបានមកពីប្រទេសចិន ។

### *ក.៤) មូលហេតុនៃការចូលបម្រើការនៅសារមន្ទីរទួលស្លែង*

ឆ្លើយតបនឹងសំណួររបស់លោកមេធាវី អរុណ ទាក់ទងនឹងរយៈពេលដែលលោកបានបម្រើការនៅសារមន្ទីរទួលស្លែង លោកសាក្សី អ៊ុង ចុងហៀង បានអះអាងថា លោកធ្លាប់បានធ្វើការនៅសារមន្ទីរទួលស្លែងប្រហែល៣ខែគឺចាប់ពីខែតុលាដល់ខែធ្នូ ឆ្នាំ១៩៧៩ ប៉ុន្តែលោកមិនចាំច្បាស់ទេ ។ លោកបន្ថែមថា កន្លែងលោកធ្វើការងារនៅពេលនោះត្រូវបានហៅថា សាលាទួលស្លែង ដែលគ្រប់គ្រងដោយ ឈ្មោះ ម៉ៃឡាំ ។ មូលហេតុដែល ម៉ៃឡាំ គ្រប់គ្រងទីនោះ គឺដោយសារវៀតណាមចូលប្រទេសកម្ពុជានិងមានជនជាតិវៀតណាមនៅគ្រប់ទីកន្លែងនៅពេលនោះ ។

លោក អ៊ុង ចុងហៀង បានបញ្ជាក់ថា គោលដៅចម្បងរបស់លោកដែលនាំឲ្យលោកចូលធ្វើការនៅសារមន្ទីរទួលស្លែង គឺដោយសារលោកចង់ស្វែងរកមិត្តភក្តិរបស់លោកដែលវិលត្រលប់មកពីបរទេសជាមួយគ្នាត្រូវបានចាប់បញ្ចូលក្នុងគុកទួលស្លែងនៅអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ហើយលោកគ្រាន់តែព្យាយាមអានឯកសារទាំងនោះដើម្បីដឹងព័ត៌មានរបស់អ្នកដែលលោកស្គាល់ ។ បន្ទាប់មក ទើបលោកបានដឹងថា ឌុច គឺជាប្រធាននៅទីនោះ ។ ទាក់ទងនឹងជនជាប់ចោទ នួន ជា លោកសាក្សីបានបញ្ជាក់ថា លោកបានដឹងថា នួន ជា មានតួនាទីសំខាន់នៅក្នុងបក្សកុម្មុយនីស្តកម្ពុជានៅពេលដែលលោកអានដួបចំណាររបស់ នួន ជា នៅលើចម្លើយសារភាពរបស់អ្នកដែលមកពីបរទេស ។ លោកបន្តថា លោកស្គាល់ហត្ថលេខារបស់ នួន ជា ដោយសារលោក អ៊ីង ពេជ និងលោក កង ស៊ិនវ៉ាត ជាអ្នកបានប្រាប់លោក ។ បន្ទាប់ពីការបញ្ចប់ការសួរដេញដោលក្រុមមេធាវីការពារក្តី នួន ជា អង្គជំនុំជម្រះបានប្រគល់វេទិកាជូនក្រុមមេធាវីការពារក្តី អៀង សារី ដើម្បីសាកសួរលោកសាក្សី អ៊ុង ចុងហៀង ។

### *១) ក្រុមមេធាវីការពារក្តី អៀង សារី*

នៅអំឡុងពេលនៃការសួរដេញដោលសាក្សី មេធាវីការពារក្តី អៀង សារី បានចោទសួរលោក សាក្សី អ៊ុង ចុងហៀង ជាច្រើនសំណួរដើម្បីបង្ហាញថា ការវិលត្រលប់របស់បញ្ញវន្តពីបរទេសចូលមកប្រទេសកម្ពុជាមិនមែនកើតឡើងដោយសារការអំពាវនាវរបស់ អៀង សារី ទេ ។ ម្យ៉ាងវិញទៀត មេធាវីការពារក្តី អៀង សារី ក៏បានព្យាយាមចោទសួរដើម្បីរំលេចឲ្យឃើញថា ការបាត់ខ្លួនបញ្ញវន្តនិងអ្នកវិលត្រលប់ពីបរទេសនៅមន្ទីរបឹងត្របែកក៏មិនមែនដោយសារ អៀង សារី ដែរ គឺដោយសារអ្នកគ្រប់គ្រងផ្ទាល់នៅមន្ទីរបឹងត្របែកនោះតែម្តង ។ សូមបញ្ជាក់ថា មន្ទីរបឹងត្របែក

គឺជាមន្ទីរមួយដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងការបរទេសដែលត្រូវបានស្គាល់ថាជាមន្ទីរប-១ ។

**គួរកត់សម្គាល់ថា** ការសួរដេញដោលសួរសាក្សី អ៊ុង ចុងហឿង ដោយក្រុមមេធាវីការពារក្ដី អៀង សារី គឺធ្វើឡើងដោយមេធាវីអន្ដរជាតិ គឺលោក ម៉ៃឃើល កាណាវ៉ាស តែម្នាក់ប៉ុណ្ណោះ ។

### ១.១) ទំនាក់ទំនងរវាងបញ្ញវន្ដនៅបរទេសជាមួយ អៀង សារី

មេធាវី កាណាវ៉ាស ចាប់ផ្ដើមដំបូងដោយសាកសួរទាក់ទងនឹងប្រវត្តិសាវតាររបស់សាក្សីដែលភាគច្រើននៃចម្លើយទាំងអស់នោះ លោកសាក្សីធ្លាប់បានឆ្លើយជូនអង្គជំនុំជម្រះនិងសហព្រះរាជអាជ្ញាម្ដងរួចទៅហើយ ។

លោកមេធាវីបានបន្តសួរទាក់ទងនឹងសហភាពនិស្សិតខ្មែរនៅប្រទេសបារាំងថាតើសហភាពនោះ មានសមាជិក មានប្រធាន និងមានលក្ខន្តិកៈផ្ទៃក្នុងរបស់ខ្លួនដែរឬទេ? លោកសាក្សីបានបញ្ជាក់ថា សហភាពនិស្សិតខ្មែរនៅពេលនោះមានសមាជិកលើសពី៥០រូប ដោយមានលោក សួង ស៊ីគឿន ជាប្រធាន និងមានលក្ខន្តិកៈផ្ទៃក្នុងរបស់ខ្លួន ។ លោកបន្តថា សមាជិកនៃសហភាពនេះអ្នកខ្លះមាននិន្នាការទៅរកបក្សកុម្មុយនីស្ដបារាំង អ្នកខ្លះមាននិន្នាការទៅរកប្រទេសចិន ។

បន្ទាប់មក មេធាវីបានលើកយកសម្ដីដែលលោកសាក្សីធ្លាប់បានឆ្លើយតបនឹងសំណួររបស់សហចៅក្រមស៊ើបអង្កេតថា "អៀង សារី បានសម្រេចដើម្បីរំលាយសហភាពនេះចោល" បន្ទាប់មកមេធាវី កាណាវ៉ាស បានសួរលោកសាក្សីថា បើតាមលក្ខន្តិកៈរបស់សហភាពនិស្សិតខ្មែរនៅពេលនោះ តើបុគ្គលម្នាក់ ដែលមិនមែនជាសមាជិកនៃសហភាពនោះដូចជា អៀង សារី អាចប្រកាសរំលាយសហភាពនោះយ៉ាងដូចម្ដេចទៅ? ឆ្លើយតបនឹងសំណួរនេះ លោកសាក្សី អ៊ុង ចុងហឿង បានបញ្ជាក់ថា នៅអំឡុងពេលនោះមានសមាគមនិស្សិតជាច្រើននៅក្នុងប្រទេសបារាំង ដែលគាំទ្រសេចក្ដីថ្លែងការណ៍៥ចំណុចរបស់ សម្ដេច សីហនុ និងមាននិស្សិតក្រុមខ្លះគាំទ្រចលនារបស់ ខៀវ សំផន, ហ៊ូ នឹម, និង ហ៊ូ យន់ ។ លោកបន្តថា និស្សិតទាំងអស់គាំទ្ររណសិរ្សរួបរួមជាតិកម្ពុជានៅពេលនោះ អៀង សារី ក៏បានណែនាំឲ្យគណបក្សទាំងអស់រំលាយខ្លួនចូលរណសិរ្សតែមួយ បន្ទាប់មក អ្នកទាំងអស់គ្នាក៏បានយល់ស្របរួមបញ្ចូលគ្នាតាមសំណើរបស់ អៀង សារី ។ ដោយលោកបានសង្កត់ធ្ងន់ថា នៅពេលនោះអ្នកទាំងអស់គ្នាបានចាត់ទុកសម្ដីរបស់ អៀង សារី ថាជា



មេដឹកនាំខ្មែរក្រហមសំណេះសំណាលជាមួយគណៈប្រតិភូបរទេស (រូបភាពមជ្ឈមណ្ឌលឯកសារកម្ពុជា)

សម្តីទិព្វ ដូច្នេះនៅពេលដែល អៀង សារី ស្នើយ៉ាងណាអ្នកទាំងអស់ក៏សុខចិត្តធ្វើតាម ។

លោកមេធាវី កាណាវ៉ាស បានចោទសួរទៀតថា តើមូលហេតុអ្វី បានជាលោកសាក្សីធ្វើដំណើរចាកចេញពីប្រទេសបារាំងទៅទីក្រុងប៊ុយការ៉េសនៃប្រទេសរ៉ូម៉ានីនៅក្នុងឆ្នាំ១៩៧៤? លោកសាក្សីបានទទួលស្គាល់ថា នៅក្នុងឆ្នាំ១៩៧៤ លោកពិតជាបានទៅទីក្រុងប៊ុយការ៉េស គឺក្នុងគោលបំណងដើម្បីជួបជាមួយ អៀង សារី និង សម្តេច សីហនុ ។ លោកបញ្ជាក់ថា ខ្លឹមសារសំខាន់នៃកិច្ចប្រជុំនៅពេលនោះគឺ សម្តេច សីហនុ គ្រាន់តែលើកឡើងអំពីជំនួបរវាងព្រះអង្គនឹងប្រមុខដឹកនាំប្រទេសផ្សេងៗតែប៉ុណ្ណោះ ។ ឆ្លើយតបនឹងសំណួររបស់លោកមេធាវីទាក់ទងនឹងការវិលត្រលប់ចូលក្នុងប្រទេសកម្ពុជាវិញ លោកសាក្សីបានទទួលស្គាល់ថា លោកពិតជាបានដាក់ពាក្យស្នើសុំដើម្បីចូលក្នុងប្រទេសកម្ពុជាវិញប្រាកដមែន ។ លោកបន្តថា រយៈពេលមួយឆ្នាំក្រោយពេលស្នើសុំទើបលោកត្រូវបានហៅឲ្យវិលត្រលប់ចូលក្នុងប្រទេស ។

### ១.២) ការប្រាស្រ័យទាក់ទងជាមួយនឹងអ្នកស្រាវជ្រាវអំពីខ្មែរក្រហម

បន្ទាប់មក មេធាវី កាណាវ៉ាស បានចោទសួរលោកសាក្សីអំពីការប្រាស្រ័យទាក់ទងរវាងលោកសាក្សី និងអ្នកស្រាវជ្រាវល្បីៗទាក់ទងនឹងប្រវត្តិសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យ ដោយលោកមេធាវីបានលើកយកផ្នែកជាច្រើននៃសៀវភៅរបស់លោកសាស្ត្រាចារ្យដេវីដ ឆេនដល័រ ដើម្បីស្នើលោកសាក្សីធ្វើការបញ្ជាក់ ។ ប៉ុន្តែលោកសាក្សីបានព្យាយាមជាច្រើនលើកច្រើនសារបដិសេធមិនឆ្លើយតបចំពោះការស្នើរបស់លោកមេធាវីដោយលោកសាក្សីបានស្នើឲ្យលោកមេធាវី កាណាវ៉ាស សួរលោកសាស្ត្រាចារ្យ ឆេនដល័រ ដោយផ្ទាល់ ព្រោះលោកមិនអាចឆ្លើយតបចំពោះអ្វីដែលលោកមិនបានសរសេរទេ ។

មេធាវីបានចោទសួរថា តើលោកសាក្សីធ្លាប់បានជួបជាមួយនឹងលោកសាស្ត្រាចារ្យ ដេវីដ ឆេនដល័រ ដែរឬទេ? ឆ្លើយតបនឹងសំណួរនេះលោកបញ្ជាក់ថា លោកពិតជាធ្លាប់ជួបជាមួយនឹងសាស្ត្រាចារ្យ ដេវីដ ឆេនដល័រ ប្រាកដមែន ។ នៅពេលសួរថាតើលោកសាក្សីទទួលស្គាល់ការសរសេររបស់សាស្ត្រាចារ្យ ឆេនដល័រអំពីរូបលោកដែរឬទេ? ភ្លាមៗនោះ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិបានជំទាស់នឹងការសួរសំណួរដូច្នេះ ហើយអង្គជំនុំជម្រះក៏បានយល់ស្របជាមួយនឹងការជំទាស់របស់សហព្រះរាជអាជ្ញា ដោយបង្គាប់ឲ្យលោកសាក្សីមិនចាំបាច់ឆ្លើយតបចំពោះសំណួរនេះទេ ។

មេធាវីបានបន្តសួរទៀតថា តើសាក្សីធ្លាប់បានអានសៀវភៅដែលសរសេរដោយលោកសាស្ត្រាចារ្យ ឆេនដល័រ ដែរឬទេ? សាក្សីបានបញ្ជាក់ថា លោកមិនធ្លាប់បានអានសៀវភៅរបស់លោកសាស្ត្រាចារ្យដើម្បីយកមកធ្វើការស្រាវជ្រាវទេ ។

### ១.៣) ការអំពាវនាវឲ្យបញ្ញវន្តចូលក្នុងប្រទេស

បន្ទាប់មក មេធាវីលើកយកឃ្លាមួយទាក់ទងនឹងចម្លើយរបស់សាក្សីដែលបានឆ្លើយតបចំពោះសំណួររបស់សហព្រះរាជអាជ្ញាពាក់ព័ន្ធនឹងការប្រជុំរវាងបញ្ញវន្តនៅប្រទេសបារាំង និង អៀង សារី ដើម្បីស្នើឲ្យសាក្សីធ្វើការបញ្ជាក់ ។ សាក្សី អុង ថុងហឿង បានបញ្ជាក់ជូនមេធាវីដោយសម្តីច្បាស់ៗថា គឺ អៀង សារី នេះហើយ ជាអ្នកដែលណែនាំលោក និងបញ្ញាជន ១.៧០០ នាក់ផ្សេងទៀតត្រលប់ពីបរទេសចូលក្នុងប្រទេសកម្ពុជាវិញ ។

ឆ្លើយតបនឹងសំណួរទាក់ទងនឹងការជួបជាមួយ អៀង សារី ដោយផ្ទាល់ សាក្សីបានអះអាងថា លោកមិនធ្លាប់បានជួបនិយាយជាមួយនឹង អៀង សារី ដោយផ្ទាល់ទេ ។ ប៉ុន្តែលោកពិតជាបានជួបជាមួយ សម្តេច សីហនុ នៅទីក្រុងប៊ុយការ៉េសក្នុងឋានៈព្រះអង្គជាប្រមុខរដ្ឋស្របច្បាប់ក្នុងរាជរដ្ឋាភិបាលរួបរួមជាតិនៃប្រទេសកម្ពុជាប្រាកដមែន ។ លោកបន្តថា នៅក្នុងកិច្ចប្រជុំនោះព្រះអង្គបានលើកឡើងពីដំណើរទស្សនកិច្ចរបស់ព្រះអង្គដែលបានជួបជាមួយនឹងប្រមុខរដ្ឋដទៃទៀតនៅអំឡុងពេលនៃដំណើរទស្សនកិច្ចរបស់ព្រះអង្គនៅពេលនោះ ។

មេធាវីបានបន្តសួរទៀតថា តើសម្តេច សីហនុ មានអំពាវនាវឲ្យនិស្សិតចូលរួមប្រឆាំងនឹងរដ្ឋាភិបាលដែលទម្លាក់ព្រះអង្គដែរឬទេ? លោកសាក្សីបានបញ្ជាក់ថា ពិតជាមានការអំពាវនាវដូច្នេះមែន ព្រោះនៅក្នុងឯកសារក៏បានសរសេរថា សម្តេចបានសរសេរលិខិតអំពាវនាវឲ្យអ្នកនៅបរទេសចូលរួមជាមួយព្រះអង្គដែរ ប៉ុន្តែ អៀង សារី ក៏បានចូលរួមអំពាវនាវជាមួយព្រះអង្គដែរ ។

មេធាវី កាណាវ៉ាស បានចោទសួរទៀតថា តើលោក

សាក្សីដែលមានវត្តមាននៅក្នុងកិច្ចប្រជុំ នៅពេលដែលសម្តេច សីហនុ និង អៀង សារី ប្រជុំពីបញ្ហាអ្វីមួយដែរឬទេ? លោកបានឆ្លើយថា លោកមិនដែលមានវត្តមាននៅក្នុងកិច្ចប្រជុំបែបនេះទេ ។ បន្ទាប់មក មេធាវី បានបន្តសួរថា តើនៅក្នុងអំឡុងពេលនៃកិច្ចប្រជុំនៅទីក្រុងប៉ិយការ៉េស លោកសាក្សីបានឮ អៀង សារី និយាយអ្វីដែរឬទេ? សាក្សីបានបញ្ជាក់ថា នៅក្នុងកិច្ចប្រជុំនោះគឺមានតែសម្តេច សីហនុ មួយព្រះអង្គឯងប៉ុណ្ណោះដែលបានធ្វើខទ្ទេសនាម ហើយ អៀង សារី មិនបាននិយាយអ្វីទេ ។

### ១.៤) អ្នកគ្រប់គ្រងផ្ទាល់លើបញ្ញវន្ត និងខ្មែរមកពីបរទេស

បន្ទាប់មក មេធាវី កាណាវ៉ាស បានបន្តសួរទាក់ទងនឹងអ្នកគ្រប់គ្រងនៅមន្ទីរប-១៥ និងមន្ទីរបឹងត្របែក ។ សាក្សីបានបញ្ជាក់ថា អ្នកគ្រប់គ្រងនៅមន្ទីរប-១៥មានឈ្មោះ ភុំ ប៉ុន្តែលោកមិនដឹងថានរណាជាថ្នាក់លើរបស់ ភុំ ទេ គឺគ្រាន់តែដឹងថាជាតំណាងរបស់អង្គការ ។ ក្រោយមក លោកដឹងថា ភុំ គឺជាតំណាងគណៈមជ្ឈិមរបស់បក្សកុម្មុយនីស្តកម្ពុជានៅពេលដែលលោកចាប់ផ្តើមស្រាវជ្រាវ ។ ទាក់ទងនឹងមន្ទីរបឹងត្របែកលោកបានបញ្ជាក់ថា មានកម្មាភិបាលខ្មែរក្រហមម្នាក់ឈ្មោះ ជាម បានមកទទួលក្រុមបញ្ញវន្តពីទូកនៅពេលដែលលោកចាកចេញមកពីដំរំដីក្រហមមកបឹងត្របែក ។ នៅពេលនោះ ជាម គឺជាអ្នកដែលធ្វើការនៅក្រសួងការបរទេស និងជាដៃស្តាំរបស់ សូ ហុង ។

### ១.៥) ការចូលបម្រើការនៅទួលស្លែងដោយសារចម្លើយសារភាព

មេធាវី កាណាវ៉ាស បានបង្ហាញឯកសារមួយទៀតជូនលោកសាក្សី និងបានសួរថា តើលោកសាក្សីនៅចងចាំអ្នកណាដែលត្រូវបានកាត់ទោសដែរឬទេ? លោកសាក្សីបានឆ្លើយថា គឺ អៀង សារី និង ប៉ុល ពត ប៉ុន្តែលោកមិនបានចូលរួមនៅក្នុងការជំនុំជម្រះនាពេលនោះទេ ។ លោកបន្តថា លោកបានជួយរៀបចំសំណុំរឿង និងជួយបកប្រែចម្លើយសារភាពជាភាសាបារាំង ហើយលោក កែវ ចិន្តា គឺជា អ្នកទទួលខុសត្រូវរឿងកាត់ក្តីនោះ ។

បន្ទាប់មក មេធាវីបានសាកសួរលោកសាក្សីអំពីមូលហេតុដែលនាំឲ្យលោកសាក្សីចូលទៅបម្រើការនៅសារមន្ទីរទួលស្លែង ថាតើដោយសារលោកសាក្សីឃើញឯកសារចម្លើយសារភាពត្រូវបានយកទៅខ្ចប់ចេកចៀន ទើបនាំឲ្យលោកចង់ធ្វើការនៅទីនោះឬយ៉ាងណា? ឆ្លើយតបនឹងសំណួរនេះលោកសាក្សីបានពន្យល់ថា មានពេលមួយនោះលោកបានទិញចេកចៀននៅផ្សារទួលទំពូង បន្ទាប់មកលោកបានឃើញឈ្មោះមិត្តភក្តិរបស់លោកម្នាក់ គឺលោក កុល ដូរាធី នៅលើក្រដាសដែលអ្នកលក់យកមកខ្ចប់ចេកចៀន ហើយលោកបានសាកសួរអ្នកលក់ថាតើក្រដាសនោះបានមកពីទីណា ពេលនោះអ្នកលក់បានប្រាប់ថាជាក្រដាសដែលយកមកពីទួលស្លែង ។ មេធាវីបានបន្តសួរទៀតថា តើអ្វីដែលលោកសាក្សីអះអាងនៅពេលមុនថា លោកចូលធ្វើការនៅសារមន្ទីរទួលស្លែងតាមរយៈជនជាតិវៀតណាម គឺជារឿងត្រឹមត្រូវឬមួយការឆ្លើយថាដោយសារក្រដាសដែលលោកឃើញយកមកខ្ចប់ចេកចៀនជារឿងត្រឹមត្រូវ? លោកសាក្សីអះអាងថា ដោយសារលោកបានឃើញក្រដាសចម្លើយសារភាពត្រូវបានយកមកខ្ចប់ចេកចៀន បន្ទាប់មកទើបលោកទៅសារមន្ទីរទួលស្លែងដើម្បីស្វែងរកឯកសារនោះ ។ នៅពេលនោះលោកបានជួបជាមួយនឹងអ្នកធ្វើការនៅទីនោះ ហើយលោកត្រូវបានប្រាប់ថា សារមន្ទីរត្រូវការអ្នកជួយរៀបចំឯកសារដើម្បីបង្កើតតុលាការកាត់ទោស ប៉ុល ពត និង អៀង សារី ហើយលោកក៏បានសម្រេចចិត្តធ្វើការនៅទីនោះ ។

### ១.៦) ប្រធានមន្ទីរប-៣២

ឆ្លើយតបសំណួររបស់មេធាវី កាណាវ៉ាស ទាក់ទងនឹងលោក ហោ ណាំហុង លោកសាក្សីបានឆ្លើយថា អៀង សារី បានចាត់តាំងលោក ហោ ណាំហុង ឲ្យធ្វើជាប្រធានក្រុមនៅមន្ទីរប-៣២ ។ លោក បានបន្តថា ការចាត់តាំងលោក ហោ ណាំហុង លើកទីមួយ លោកមិនមានវត្តមាននៅក្នុងបឹងត្របែកទេ ដោយសារលោកត្រូវបានបញ្ជូនទៅដីក្រហម ប៉ុន្តែលោកមានវត្តមាននៅក្នុងការចាត់តាំងលើកទី២ ដែលមាន អៀង សារី ជាអធិបតី ។

ចំពោះសំណួរចុងក្រោយរបស់ខ្លួនមេធាវី កាណាវ៉ាស ដែលបានសួរទាក់ទងនឹងវត្តមានរបស់ អៀង សារី នៅពេលតែងតាំងលោក ហោ ណាំហុង ឲ្យធ្វើជាប្រធានក្រុមបញ្ញវន្តនៅមន្ទីរប-៣២ ។ ឆ្លើយតបនឹងសំណួរនេះ លោកសាក្សីបានបញ្ជាក់ថា លោក ហោ ណាំហុង ពិតជាត្រូវបានចាត់តាំងដោយ អៀង សារី ប្រាកដមែន ប៉ុន្តែនៅពេលនោះមិនមែនមានតែការចាត់តាំងលោក

ហោ ណាំហុង ម្នាក់ឯងទេ ព្រោះជាការចាត់តាំងទូទៅសូម្បីតែមន្ទីរផ្សេងៗទៀត ដូចជាមន្ទីរប-៣០ និងមន្ទីរប-៣១ ក៏មានការចាត់តាំងខ្មែរដែលមកពីបរទេសឲ្យធ្វើជាប្រធានក្រុមដូចគ្នានេះដែរ ។

**ក) ក្រុមមេធាវីការពារក្ដី ខៀវ សំផន**

អង្គជំនុំជម្រះបានប្រគល់វេទិកាសួរដេញដោលសាក្សី អ៊ុង ចុងហឿង ជូនក្រុមមេធាវីការពារក្ដី ខៀវ សំផន បន្ទាប់ពីក្រុមមេធាវីការពារក្ដី អៀង សារី ។ ដូចបានជម្រាបពីខាងដើម ដោយសារការផ្ដល់សក្ខីកម្មរបស់សាក្សី អ៊ុង ចុងហឿង ផ្ដោតសំខាន់តែលើជនជាប់ចោទ អៀង សារី ដូច្នេះ ក្រុមមេធាវីការពារក្ដី ខៀវ សំផន បានចំណាយពេលត្រឹមតែ១ម៉ោងប៉ុណ្ណោះក្នុងការសាកសួររបស់ខ្លួន ។ នៅអំឡុងពេលនៃការសួរដេញដោល គឺមានតែមេធាវីអន្តរជាតិសញ្ជាតិបារាំងម្នាក់ប៉ុណ្ណោះដែលបានចោទសួរសាក្សី ។

**គួរកត់សម្គាល់ថា** ភាគច្រើននៃចម្លើយរបស់លោក សាក្សី អ៊ុង ចុងហឿង ឆ្លើយតបនឹងសំណួររបស់មេធាវីការពារក្ដី គឺលោកបានគាំទ្រចំពោះជនជាប់ចោទ ខៀវ សំផន និងបានបញ្ជាក់ថា ខៀវ សំផន គឺជាបុគ្គលដែលគ្មានអំណាចក្នុងបក្សកុម្មុយនីស្ដកម្ពុជា និងគ្រាន់តែជាឧបករណ៍របស់ ប៉ុល ពត តែប៉ុណ្ណោះ ។

មេធាវីអន្តរជាតិការពារក្ដី ខៀវ សំផន គឺមេធាវី អង់តា ហ្គិសសេ បានចាប់ផ្ដើមសំណួររបស់ខ្លួនដោយលើកឡើងពីសៀវភៅដែលនិពន្ធដោយលោកសាក្សីដែលមានចំណងជើងថា "ខ្ញុំជឿខ្មែរក្រហម" ដើម្បីស្នើលោកសាក្សីឲ្យបញ្ជាក់ ។ មេធាវី ហ្គិសសេ បានសាកសួរលោកសាក្សីថា តើលោកធ្លាប់ជួបដោយផ្ទាល់ជាមួយ ខៀវ សំផន ដែរឬទេ? ឆ្លើយតបសំណួរនេះ លោកសាក្សីបញ្ជាក់ថា លោកធ្លាប់ឃើញ ខៀវ សំផន ម្ដងពេលលោកនៅក្មេង គឺនៅពេលដែល ខៀវ សំផន ជិះឡានម៉ាកស៊ីត្រូអេន ជាមួយ ហ៊ូយន់ ។ លោកបន្ដថា លោកមានកិត្តិយសណាស់ ដែលបានជួប ខៀវ សំផន ដោយផ្ទាល់នៅក្នុងតុលាការ ។ បន្ទាប់មក មេធាវីសួរទៀតថា តើលោកសាក្សីនិងភរិយាធ្លាប់បានឃើញ ខៀវ សំផន នៅមន្ទីរបឹងត្របែកដែរឬទេ? លោកសាក្សីអះអាងថា លោក និងភរិយារបស់លោកមិនដែលឃើញ ខៀវ សំផនផ្ទាល់នៅបឹងត្របែកទេ ។

មេធាវីបានសួរទៀតថា ក្រៅពីការជួបជាមួយការិយាល័យសហចៅក្រមស៊ើបអង្កេត តើលោកសាក្សីមានធ្លាប់បានសម្ភាសន៍ជាមួយនឹងការិយាល័យណាផ្សេងទៀតទេ? លោកសាក្សីបានបញ្ជាក់ថា លោកចាំមិនច្បាស់ចំពោះចំណុចនេះទេ ប៉ុន្ដែលោកគិតថា លោកធ្លាប់បានជួបកាលពីក្នុងឆ្នាំ២០០៧ ។ បន្ទាប់មកមេធាវីបានបង្ហាញឯកសារមួយទៀតដែលជាអត្ថបទទាក់ទងនឹងកិច្ចសម្ភាសន៍រវាងលោកសាក្សី និងសហព្រះរាជអាជ្ញាដែលឯកសារនេះលោកសាក្សីធ្លាប់បានបដិសេធម្ដងរួចមកហើយដោយសារខ្លឹមសារនៃឯកសារនោះលោកយល់ថាផ្ទុយពីអ្វីដែលលោកបាននិយាយ ។

លោកក្នុងឯកសារដែលលោកសាក្សីបដិសេធនោះបានសរសេរថា "អៀង សារី និង ខៀវ សំផន បានមកបឹងត្របែកដើម្បីធ្វើជាអធិបតីនៃកិច្ចប្រជុំនយោបាយ ។ ចំពោះខ្ញុំ ខ្ញុំបានឃើញ អៀង សារី ក្នុងខែតុលា ឆ្នាំ១៩៧៨ ប្រពន្ធខ្ញុំបានឃើញ ខៀវ សំផន នៅទីនោះ" ។ ប៉ុន្ដែលោកបានពន្យល់ថា តាមការពិតប្រពន្ធរបស់លោកបានឃើញ ខៀវ សំផន នៅដើមឆ្នាំ១៩៧៦ ហើយលោកបានជួបជាមួយនឹង អៀង សារី នៅក្នុងឆ្នាំ១៩៧៨ ។ ដូច្នេះលោកមិនដឹងថា ហេតុអ្វីបានជាឯកសារនោះសរសេរដូច្នេះទេ ។ មេធាវីបានបន្ដលើកឡើងទាក់ទងនឹងសៀវភៅ"ខ្ញុំជឿខ្មែរក្រហម" របស់លោកសាក្សីដើម្បីយកមកសួរដេញដោល ។ មេធាវី ហ្គិសសេ បានសួរលោកសាក្សី អ៊ុង ចុងហឿង ថាតើសៀវភៅរបស់លោកសាក្សីចងក្រងឡើងដោយផ្អែកលើប្រភពពីទីណា? លោកបញ្ជាក់ថា ប្រភព គឺលោកយកចេញពីកំណត់ហេតុរបស់លោក និងកំណត់ហេតុភរិយារបស់លោករួមជាមួយនឹងការដាក់ឈ្មោះអ្នកដែលត្រូវបាននាំចូលក្នុងស-២១ ។

មេធាវីការពារក្ដីបានបន្ដបង្ហាញឯកសារស្ដីពីបទសម្ភាសន៍មួយទៀតដែលធ្វើឡើងរវាងឈ្មោះ ប៊ុនរឿន និងលោកសាក្សី ដើម្បីស្នើសុំលោកសាក្សីឲ្យធ្វើការបញ្ជាក់ ។ មេធាវី ហ្គិសេ បានស្នើសុំការពន្យល់ពីលោកសាក្សីទាក់ទងនឹងគោលការណ៍រក្សាការសម្ងាត់ ។ ឆ្លើយបតបសំណើនេះ លោកសាក្សីបានបញ្ជាក់ថា គោលការណ៍រក្សាការសម្ងាត់ គឺជាគោលការណ៍មួយដែលមានសារៈសំខាន់ក្នុងស្មារតីអង្គការ និងជាកត្តាកំណត់ជ័យជម្នះ ។

**សូមបញ្ជាក់ថា** សវនាការសួរដេញដោលសាក្សី អ៊ុង ចុងហឿង បានបញ្ចប់នៅរសៀលថ្ងៃទី ៤ ខែសីហា ឆ្នាំ២០១២ ។

# សវនាការស្តីពីការផ្តល់សក្ខីកម្មរបស់សាក្សី ស សៀក

នៅថ្ងៃទី១៥ដល់ថ្ងៃទី២១ ខែសីហា ឆ្នាំ២០១២ អង្គជំនុំជម្រះ បានបន្តសវនាការសួរដេញដោលសាក្សី ដែលមានរហស្សនាម TCW609 បន្ទាប់ពីសវនាការសួរដេញដោលសាក្សី សួង ស៊ីគឿន ត្រូវបានផ្អាកដោយសារបញ្ហាសុខភាពរបស់សាក្សី ។ សូមបញ្ជាក់ថា ក្នុងអំឡុងពេលសវនាកាសួរដេញដោលសាក្សី ស សៀក អង្គជំនុំជម្រះបានរៀបចំឲ្យមានការសួរឆ្លាស់គ្នាជាមួយសាក្សី សួង ស៊ីគឿន ដោយអង្គជំនុំជម្រះបានធ្វើការសាកសួរសាក្សីតែនៅពេលរសៀលប៉ុណ្ណោះ ។ ក្នុងរយៈពេលសវនាការនេះដែរ មានការចូលរួមពីសំណាក់ប្រជាជនកម្ពុជាដែលមកពីតាមបណ្តាខេត្តមួយចំនួនប្រហែលជាងមួយពាន់នាក់រួមជាមួយនឹងអ្នកសារព័ត៌មាន អ្នកអង្កេតការជាតិ និងអន្តរជាតិទៀតផង ។ គួរកត់សម្គាល់ថា នៅក្នុងអំឡុងពេលសវនាការនេះដែរមិនមានវត្តមានរបស់ជនជាប់ចោទ អៀង សារី នៅក្នុងបន្ទប់សវនាការទេដោយសារជនជាប់ចោទបានស្នើសុំលះបង់សិទ្ធិមិនចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ដោយសារបញ្ហាសុខភាព ។


សាក្សី ស សៀក

នៅក្នុងកិច្ចនីតិវិធីសាកសួរសាក្សី ស សៀក គឺបានផ្តោតសំខាន់ទៅលើចំនុចមួយចំនួនដូចជា ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ការចាប់ខ្លួនបុគ្គលិកនៅក្រសួងឃោសនាការ និងការផ្តល់សក្ខីកម្មរបស់សាក្សីជាមួយសហចៅក្រមស៊ើបអង្កេត ។

### ១) ប្រវត្តិសាវតាររបស់សាក្សី ស សៀក

លោកប្រធានអង្គជំនុំជម្រះបានចាប់ផ្តើមកិច្ចដំណើរការនីតិវិធីសួរដេញដោល ដោយធ្វើការសាកសួរសាក្សីនូវសំណួរមួយចំនួនទាក់ទងនឹងប្រវត្តិសាវតាររបស់សាក្សី បន្ទាប់ពីអង្គជំនុំជម្រះបានបញ្ជាក់ពីសិទ្ធិ និងករណីកិច្ចមួយចំនួនរបស់សាក្សីក្នុងពេលផ្តល់សក្ខីកម្ម ។ ឆ្លើយតបនឹងសំណួររបស់លោកប្រធាន សាក្សីបានបញ្ជាក់ថា ខ្លួនមានឈ្មោះ ស សៀក ដែលមានឈ្មោះថ្មីគឺ ស៊ីម កើតនៅឆ្នាំ១៩៥៦ នៅភូមិត្រពាំងមានជ័យ ឃុំទឹកថ្លា ស្រុកព្រៃវែង ខេត្តព្រៃវែង ។ សព្វថ្ងៃរស់នៅស្រុកសំឡូត ខេត្តបាត់ដំបង ប្រកបមុខរបរជាកសិករ ។ សាក្សីមានឪពុកឈ្មោះ ហែម ជា និងម្តាយ ស សៀ ចំណែកគ្រួសារឈ្មោះ សុទ្ធ ថា ព្រមទាំងមានកូនបីនាក់ ។ បន្ទាប់ពីបានបញ្ចប់ការសាកសួរ លោកប្រធានបានផ្ទេរវេទិកាជូនតំណាងសហព្រះរាជអាជ្ញាដើម្បីធ្វើការសាកសួរបន្ត ។

### ២) ការសួរសាក្សីដោយសហព្រះរាជអាជ្ញា

លោកសហព្រះរាជអាជ្ញា បានបន្តការសាកសួរសាក្សីទាក់ទងនឹងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ស្ថានីយផ្សព្វផ្សាយវិទ្យុ ការងាររបស់សាក្សីនៅក្រសួងឃោសនាការ ការចាប់ខ្លួនបុគ្គលិកនៅក្នុងក្រសួងឃោសនាការ និងកិច្ចប្រជុំផ្សេងៗទៀត ។

### ២.១) ការជម្លៀសប្រជាជន

លោកតំណាងសហព្រះរាជអាជ្ញាជាតិ វេង ហួត បានចាប់ផ្តើមសាកសួរទាក់ទងនឹងការជម្លៀសប្រជាជន ។ សាក្សីបានរៀបរាប់ថា នៅពេលបែកទីក្រុងភ្នំពេញថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ខ្លួនបានរួមដំណើរជាមួយក្រុមសិល្បៈចេញពីអង្គភាពនៅស្រុកស៊ឹង

ត្រង់ដើម្បីមកបម្រើការងារនៅក្នុងក្រសួងឃោសនាការនៅទីក្រុងភ្នំពេញ ។ ពេលធ្វើដំណើរមកតាមផ្លូវខ្លួនបានសម្រាកនៅភ្នំអិដ្ឋវីស ចំនួនបីយប់ ។ នៅពេលឡានរបស់ខ្លួនបានមកដល់ជិតកំពង់ស្ពឺ ខ្លួនបានឃើញ ខៀវ សំផន ជិះឡានជាមួយស្រីៗពីរនាក់ជាអ្នកអានវិទ្យុចល័ត ។ នៅពេលមកដល់ភ្នំពេញនោះ ខ្លួនឃើញមានការជម្លៀសប្រជាជនច្រើនម៉ឺននាក់មកពីខាងមាត់ទន្លេ ។ ឆ្លើយតបនឹងសំណួរបន្ទាប់របស់លោកតំណាងសហព្រះរាជអាជ្ញា សាក្សីបានបញ្ជាក់ថា នៅក្នុងពេលជម្លៀសនោះខ្លួនមិនបានដឹងថា អ្នកណាជាអ្នកគ្រប់គ្រងការជម្លៀសនោះឡើយ ហើយស្ថានភាពនៅពេលជម្លៀសនោះទៀតសោតមានភ្លៀងរលឹមព្រមទាំងមានផ្សព្វផ្សាយពីការរំដោះទីក្រុង ហើយនៅតាមផ្ទះប្រជាជនមានលើកទង់សដើម្បីទទួលយោធាខ្មែរក្រហម ។ បន្ទាប់មក លោកតំណាងសហព្រះរាជអាជ្ញាបានបន្តសំណួរទាក់ទងនឹងក្រសួងឃោសនាការ ដោយសាក្សី សៀក បាន



តំណាងសហព្រះរាជអាជ្ញាជាតិ វេង ហ៊ិត

បញ្ជាក់ថា នៅពេលនោះមាន ហ៊ូ នឹម គឺជាប្រធាន ហើយ ទីវ អុល គឺជាជំនួយការ ។ សាក្សីបានបន្តថា នៅពេលទៅដល់ក្រសួងឃោសនាការ ខ្លួនបានឃើញអ្នកជំនាញខាងបច្ចេកទេស៦នាក់ដែលនៅសល់ពីជំនាន់ចាស់មកប្រាប់ពីរបៀបប្រើប្រាស់ម៉ាស៊ីនក្នុងការចាក់ផ្សាយ ។ ទាក់ទងនឹងការផ្សព្វផ្សាយនេះដែរ សាក្សីបានបន្តថា នៅពេលនោះមានការផ្សាយលើកទឹកចិត្តឲ្យប្រជាជនខំធ្វើការងារ ហើយជាងនេះទៀតក៏មានការផ្សព្វផ្សាយទាក់ទងនឹងការវាយយកកោះត្រល់ដោយសារការឈ្លានពានរបស់វៀតណាម ដែលធ្វើឲ្យប្រជាជនមានការឈឺចាប់នឹងការបាត់បង់ទឹកដីនេះ ។ បន្ទាប់ពីបញ្ចប់ការសាកសួរ លោកសហព្រះរាជអាជ្ញាបានផ្ទេរវេទិកាបន្តទៅឲ្យលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ អាប់ឌុលហាក់ ថាវីក ដើម្បីធ្វើការសាកសួរសាក្សីបន្តទៀត ។

### ២.២) ស្ថានីយផ្សព្វផ្សាយវិទ្យុ

លោកតំណាងសហព្រះរាជអាជ្ញា អាប់ឌុលហាក់ ថាវីក បានបន្តសួរទាក់ទងនឹងមន្ទីរផ្សេងៗទៀតក្រៅពីនៅមន្ទីរស-៦ ។ សាក្សីបានបញ្ជាក់ថា មន្ទីរស-៦ គឺជាកន្លែងសម្រាប់ក្រុមសិល្បៈដែលមានទីតាំងនៅស្រុកស្ទឹងត្រង់ ហើយពេលខ្លួនមកធ្វើការងារនៅទីនោះនៅឆ្នាំ១៩៧៣ ខ្លួនបានថតចម្រៀងយកទៅចាក់ផ្សាយនៅហាណូយ ប្រទេសវៀតណាមទៀតផង ។ សាក្សីបានរៀបរាប់ថា នៅទីនោះក្រៅពីមន្ទីរស-៦ មានមន្ទីរ១៩, មន្ទីរក-១៨ និងមន្ទីរប-២០ដែលនៅជិតគ្នា ។ មន្ទីរប-២០ គឺជាមន្ទីរចែកចាយសម្ភារៈស្បៀងទៅតាមអង្គភាពតូចៗដែលនៅម្តុំស្ថានីយរបស់ខ្លួន ។ ចំណែកមន្ទីរក-១៨ គឺជាមន្ទីរកាត់ដេរដែលមានតែនារីៗ និងជាកន្លែងដាំបន្លែតែប៉ុណ្ណោះ ហើយនៅទីនោះសាក្សីបានឃើញ ខៀវ សំផន នៅក្នុងឱកាសបុណ្យទានម្តងៗ ប៉ុន្តែពេលនោះខ្លួនមិនចាំថា ខៀវ សំផន មាននាទីជាអ្វីនោះឡើយ ។ គួររំឭកថា នៅពេលសហព្រះរាជអាជ្ញាសាកសួរទាក់ទងនឹងជនជាប់ចោទ ខៀវ សំផន ហើយសាក្សីបានបញ្ជាក់ថា ខ្លួនមិនបានដឹងពីតួនាទីរបស់ជនជាប់ចោទ ភ្លាមនោះយើងសង្កេតឃើញជនជាប់ចោទបានញញឹមចំពោះការឆ្លើយរបស់សាក្សី ។ សាក្សីបានបន្តថា នៅពេលនោះខ្លួនបានស្គាល់លោក ទីវ អុល ពេលដែលចុះទៅពិនិត្យមើលក្រុមសិល្បៈស្រុករបស់ខ្លួនដែលទៅសម្តែងនៅភូមិភាគក្នុងឆ្នាំ១៩៧៣ ។ ចំណែក ហ៊ូ នឹម វិញ សាក្សីបានបញ្ជាក់ថា ខ្លួនបានស្គាល់ពេលធ្វើការនៅក្នុងក្រសួងឃោសនាការ ។ សាក្សីបានបញ្ជាក់ថា ការផ្សាយរបស់ស្ថានីយវិទ្យុនោះ គឺធ្វើការផ្សព្វផ្សាយនៅតំបន់ជិតៗតែប៉ុណ្ណោះ ដើម្បីជំរុញស្មារតីរបស់កងទ័ពឲ្យមានភាពក្លាហាន និងខិតខំធ្វើការ ហើយរហូត

មកដល់ថ្ងៃទី១៧ ខែមេសា ស្ថានីយវិទ្យុនោះបានប្តូរទីតាំងមកនៅទីក្រុងភ្នំពេញវិញ ដោយបញ្ឈប់ការផ្សាយវិទ្យុតូច និងចាប់ផ្តើមដំណើរការផ្សព្វផ្សាយ វិទ្យុថ្មីវិញ ។


តំណាងសហព្រះរាជអាជ្ញាជាតិ អាប់ឌុលហាក់ ថារីក

## ២.៣) ការចូលមកដល់ទីក្រុងភ្នំពេញ

លោក ថារីក បានបន្តការសួរទាក់ទងនឹងការធ្វើដំណើរមកដល់ទីក្រុងភ្នំពេញ និងការជួបគ្នាជាមួយ សុន សេន ។ សាក្សីបានបញ្ជាក់ថា នៅពេលខ្លួនបានមកដល់ស្តាតអូឡាំពិច ខ្លួនបានជួបនឹង សុន សេន ហើយសម្រាកនៅស្តាតមួយយប់ទម្រាំនឹងបានបន្តដំណើរទៅកាន់ទីស្នាក់ការក្រសួងឃោសនាការដែលមានទីតាំងនៅសាលាលីសេដេកាត់នៅជិតវត្តភ្នំ ។ សាក្សីបានរៀបរាប់បន្តពីស្ថានភាពនៅក្នុងទីក្រុងភ្នំពេញថា នៅពេលនោះខ្លួនឃើញមានប្រជាជនច្រើនដែលកំពុងជម្លៀស ហើយពេលនោះដែរខ្លួនមិនអាចស្គាល់អ្នកណាជាអ្នកបញ្ជាឲ្យមានការជម្លៀសនោះទេ ។ លោកស្រី សៀក បានរៀបរាប់ថា ពេលទៅដល់ទីតាំងក្រសួងឃោសនាការ ខ្លួនបានធ្វើការនៅក្នុងក្រសួងរហូតដល់ឆ្នាំ១៩៧៧ ទើបផ្លាស់មកធ្វើការនៅមន្ទីររោងពុម្ពដែលនៅក្នុងក្រសួងឃោសនាការដដែល ។ សាក្សីបានរៀបរាប់ថា នៅទីនោះមានបែងចែកជាផ្នែកផ្សេងៗដូចជាផ្នែកអានវិទ្យុ ទូរទស្សន៍ កន្លែងទទួលទូរពុម្ពកន្លែងសិល្បៈ និងរោងពុម្ពជាដើម ។ ក្រោយមកមន្ទីរឃោសនាការ និងរោងពុម្ពបានរំលាយចូលគ្នាទៅជាក្រសួងឃោសនាការ និងអប់រំដែលគ្រប់គ្រងដោយលោកស្រី យុន យ៉ាត ហើយអ្នកដែលមកជំនួស ហ៊ូ នឹម នោះគឺឈ្មោះ ឆយ ។

## ២.៤) ការងារនៅក្រសួងឃោសនាការ

ឆ្លើយតបនឹងសំណួររបស់សហព្រះរាជអាជ្ញាទាក់ទងនឹងការងារនៅក្រសួងឃោសនាការ សាក្សីបានរៀបរាប់ថា នៅទីនោះខ្លួនបានធ្វើការរៀបចំដាក់រូបនៅក្នុងសៀវភៅដែលគេបោះពុម្ពមានដូចជា រូបនារីស្រែអំបិល និងរូបភាពប្រជាជនធ្វើទំនប់ជាដើម ។ បន្ទាប់មកទៀត លោកតំណាងសហព្រះរាជអាជ្ញាបានបង្ហាញឯកសារជាសៀវភៅដើម្បីឲ្យសាក្សីបញ្ជាក់ថា តើសៀវភៅនោះ ដូចគ្នានឹងសៀវភៅដែលខ្លួនបានធ្វើដែរ ឬយ៉ាងណា ហើយឆ្លើយតបនឹងបញ្ហានេះ សាក្សីបានបញ្ជាក់ថា ខ្លួនគ្រាន់តែប្រហែលថា សៀវភៅនោះស្រដៀងគ្នានឹងសៀវភៅដែលខ្លួនបានឃើញពីមុន ។ ឯកសារបន្ទាប់ដែលត្រូវបានដាក់បង្ហាញនោះ គឺទង់បដិវត្តន៍ក្នុងគោលបំណងឲ្យសាក្សីបញ្ជាក់ថា តើទង់នោះសាក្សីជាអ្នកបោះពុម្ពដែរឬយ៉ាងណា? ប៉ុន្តែសាក្សីបានបញ្ជាក់ថា ខ្លួនមិនចាំថា ទង់នោះខ្លួនជាអ្នកធ្វើ ឬមិនមែនដោយសារតែការងារនៅទីនោះមានផ្លាស់វេនគ្នា ។ ទាក់ទងនឹងការងារនៅក្រសួងឃោសនាការក្នុងផ្នែកសិល្បៈវិញ សាក្សីបានបញ្ជាក់ថា ខ្លួនមាននាទីជាអ្នកច្រៀង រាំ និងសម្តែងជាខ្សែវីដេអូ ហើយក្រៅពីនោះទៀត គឺការងារវាយអក្សរលេខ ប៉ុន្តែការងារនេះខ្លួនបានធ្វើម្តងម្កាលតែប៉ុណ្ណោះ ។ នៅពេលនោះប្រធានផ្នែកសិល្បៈឈ្មោះ សៅ ហើយមាន ផែន ជាប្រធានផ្នែកបកប្រែភាសាខ្មែរ ។ បន្ទាប់មក លោកតំណាងសហព្រះរាជអាជ្ញាបានបន្តសំណួរទាក់ទងនឹងស្ថានីយផ្សាយសំឡេងនៅប្រទេសចិន ។ សាក្សីបានបញ្ជាក់ថា កាលនោះ គឺនៅឆ្នាំ១៩៧៣ ខ្លួនមិនបានទៅធ្វើការនៅស្ថានីយនោះទេ ដោយសារខ្លួនបានរៀបការ ហើយនៅបន្តធ្វើការក្នុងក្រសួងឃោសនាការដដែល ។ សាក្សីបានបន្តរៀបរាប់ថា ចំពោះការផ្សព្វផ្សាយតាមវិទ្យុនៅក្នុងឆ្នាំ១៩៧៥ - ១៩៧៩ គឺជាការផ្សព្វផ្សាយដែលជំរុញឲ្យប្រជាជនធ្វើស្រែឲ្យបានពីពីរទៅបីតោនក្នុងមួយហិចតាជាដើម ។ បន្ទាប់មកតំណាងសហព្រះរាជអាជ្ញា

បានសួរសំណួរមួយចំនួន ដែលដកស្រង់ចេញពីឯកសារកំណត់ហេតុរបស់សាក្សី ប៉ុន្តែសំណួរទាំងនោះត្រូវបានសាក្សីបញ្ជាក់ថាខ្លួនមិនបានចាំនោះទេ ។ តំណាងសហព្រះរាជអាជ្ញាបានបន្តដោយធ្វើការសាកសួរទាក់ទងនឹងការផ្សព្វផ្សាយចម្លើយសារភាពរបស់អ្នកទោសវៀតណាម ។ ទាក់ទងនឹងករណីនេះសាក្សីបានបញ្ជាក់ថា ចំពោះឈ្លើយសឹកវៀតណាមដែលចាប់បាននោះ ត្រូវបានសួរយកចម្លើយ ថតរូប និងថត សំឡេងហើយយកមកចាក់ផ្សាយនៅក្នុងវិទ្យុដែលមានឈ្មោះ វ៉ៃ ជាអ្នកបកប្រែភាសាវៀតណាម ហើយក្រោយមកចម្លើយ នោះត្រូវបានគេយកទៅចាក់ផ្សាយ ។

## ២.៥) ការផ្សព្វផ្សាយពីសេចក្តីថ្លែងការណ៍នានា

លោកតំណាងសហព្រះរាជអាជ្ញា ថារីក បានបន្តដោយការលើកយកសេចក្តីប្រកាសរបស់រដ្ឋាភិបាលរួបរួមជាតិកម្ពុជាធ្វើឡើងដោយ ហ៊ូ នឹម រដ្ឋមន្ត្រីក្រសួងឃោសនាការ និងព័ត៌មាន ដែលនិយាយអំពីជោគជ័យរបស់បក្ស ប៉ុន្តែសាក្សីបានបញ្ជាក់ថា ខ្លួនមិនបានចាំចំពោះកំណត់ហេតុទាំងនោះឡើយ ។ តំណាងសហព្រះរាជអាជ្ញាបានបង្ហាញឯកសារមួយទៀតជាសេចក្តីថ្លែងការណ៍របស់ ខៀវ សំផន ប៉ុន្តែឆ្លើយតបនឹងសំណួរនេះ សាក្សីក៏បានបញ្ជាក់ថា ខ្លួនមិនបានចូលរួមស្តាប់ការធ្វើសុន្ទរកថានោះឡើយ ។

## ២.៦) ការបាត់ខ្លួនបុគ្គលិកនៅក្រសួងឃោសនាការ

សាក្សីបានរៀបរាប់ថា ជាទូទៅខ្លួនបានទៅចូលរួមប្រជុំជីវភាពមួយអាទិត្យម្តង ឬពីរអាទិត្យម្តង ហើយក្រៅពីនោះខ្លួនក៏បានទៅចូលរួមប្រជុំទិតៀនដែលនៅពេលនោះមានការនិយាយដើម្បីជាការរិះគន់កែលំអគ្នាតែប៉ុណ្ណោះ ហើយមានពេលមួយខ្លួនបានទៅចូលរួមដើម្បីនិយាយពីការដកពិសោធន៍ការងារដូចជាការកែលំអពីរបៀបហាត់រាំនៅក្នុងក្រុមសិល្បៈក្រោមវត្តមានរបស់ ហ៊ូ នឹម ។ សាក្សីបានបន្ថែមថា នៅពេលនោះ ហ៊ូ នឹម មិនបាន



កុយ ធួន និងក្រុមសិល្បៈ (រូបថតមជ្ឈមណ្ឌលឯកសារកម្ពុជា)

ចូលរួមប្រជុំយូរនោះទេ ដោយសារមានគេទូរស័ព្ទមកហៅគាត់ឲ្យទៅធ្វើការ ប៉ុន្ដែចាប់ពីពេលនោះមក ខ្លួនមិនដែលឃើញ ហ៊ូ នឹម ត្រលប់មកធ្វើការនៅក្រសួងឃោសនាការនោះវិញឡើយ ។ ចំពោះ កុយ ធួន វិញសាក្សីបានបញ្ជាក់ថា ខ្លួនបានស្គាល់ពេលទៅសម្ដែងសិល្បៈនៅភូមិភាគឧត្ដរ ប៉ុន្ដែក្រោយមកខ្លួនបានឮដំណឹងថា កុយ ធួន បានបាត់ខ្លួន ។ ចំពោះការចាប់ខ្លួនបុគ្គលិកផ្សេងៗទៀតនៅក្រសួងឃោសនាការវិញ សាក្សីបានរៀបរាប់ថា នៅពេលនោះមានរថយន្ដមកពីកន្លែងផ្សេងៗ និងរថយន្ដនៅក្នុងក្រសួងដែលមកចាប់ខ្លួនបុគ្គលិកទាំងនោះ ប៉ុន្ដែដោយឡែកពេលមានការចាប់ខ្លួនប្រពន្ធរបស់ ហ៊ូ នឹម គឺមានរថយន្ដមកពីខាងយោធាមកដឹក ។ បន្ទាប់មកទៀត តំណាងសហព្រះរាជអាជ្ញាបានបន្ដសួរទាក់ទងនឹងការចាប់ខ្លួនសមាជិកគ្រួសាររបស់សាក្សី ប៉ុន្ដែនៅត្រង់ចំណុចនេះ គួរកត់សម្គាល់ថា សាក្សីមានការរន្ធត់ចិត្តយំនៅក្នុងបន្ទប់សវនាការ ហើយភ្លាមៗនោះលោកប្រធានបានធ្វើការកត់សម្គាល់ថា ដោយសារសាក្សីមានការរន្ធត់ចំពោះសំណួរដែលពាក់ព័ន្ធនឹងការបាត់ខ្លួនរបស់សមាជិកដែលធ្វើការជាមួយខ្លួន ដូច្នេះលោកប្រធានបានប្រកាសផ្អាកកិច្ចដំណើរការនីតិវិធីមុនកាលកំណត់១០ នាទីដោយសវនាការនេះត្រូវបានបន្ដនៅថ្ងៃបន្ទាប់ទៀត ។

## ២.៧) ការថតសម្លេងនៃសេចក្ដីថ្លែងការណ៍របស់មេដឹកនាំមួយចំនួន

នៅក្នុងកិច្ចដំណើរការសវនានៅថ្ងៃបន្ទាប់នេះដែរ តំណាងសហព្រះរាជអាជ្ញា អាប់ឌុលហាក់ ថាវីក បានបន្ដការសាកសួរដោយលើកឡើងទាក់ទងនឹងកំណត់ហេតុរបស់សាក្សីដែលបានធ្វើជាមួយសហចៅក្រមស៊ើបអង្កេតទាក់ទងនឹងការថតសម្លេងក្នុងការណែនាំអ្វីមួយរបស់មេដឹកនាំមួយចំនួនដែលបានយកមកចាក់ផ្សាយនៅក្រសួងឃោសនាការ ។ ឆ្លើយតបនឹងសំណួរនេះសាក្សីបានបញ្ជាក់ថា នៅពេលនោះមានការថតសម្លេងមេដឹកនាំមួយចំនួនពិតមែន ប៉ុន្ដែខ្លួនមិនចាំថាសម្លេងនោះជារបស់អ្នកណាឡើយ ហើយខ្លួនក៏មិនចាំថាសម្លេងថតនោះនិយាយអំពីអ្វីនោះដែរ ។

## ២.៨) សំបុត្ររបស់ ហ៊ូ នឹម

ឆ្លើយតបនឹងសំណួររបស់សហព្រះរាជអាជ្ញាទាក់ទងនឹងសំបុត្ររបស់ ហ៊ូ នឹម ដែលរៀបរាប់ពីការ ប្រជុំជាមួយក្រុមសិល្បៈ សាក្សីបានបញ្ជាក់ថានៅពេលនោះខ្លួនបានទៅចូលរួមប្រជុំដែលនិយាយពីបទពិសោធន៍ការងារដូចជា ខាងសិល្បៈ និងខាងផ្សព្វផ្សាយជាដើម ។ សហព្រះរាជអាជ្ញាបានលើកឡើងបន្ដអំពីលិខិតដែលសរសេរដោយ ហ៊ូ នឹម ដែលក្នុងនោះមានរៀបរាប់អំពីការរៀបចំកិច្ចប្រជុំខួបលើកទីពីរនៃជ័យជម្នះរបស់បក្ស ហើយនៅពេលនោះ ប៉ាំង បានទូរស័ព្ទហៅ ហ៊ូ នឹម ។ ប៉ុន្ដែទាក់ទងនឹងបញ្ហានេះ សាក្សីបានបញ្ជាក់ថា ខ្លួនមិនចាំពីព្រឹត្តិការណ៍នៃការប្រជុំនោះទេ ហើយខ្លួនក៏មិនស្គាល់ ប៉ាំង ដែរ ។

## ៣) ការសួរសាក្សីដោយមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី



មេធាវី ប៉ិនន យេ

## ៣.១) ការងារនៅក្រសួងឃោសនាការ

បន្ទាប់ពីបញ្ចប់ការសាកសួរសាក្សីដោយតំណាងសហព្រះរាជអាជ្ញា លោកប្រធានអង្គជំនុំជម្រះបានផ្ទេរវេទិកាជូនមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីដើម្បីធ្វើការសាកសួរបន្ដ ។ លោកស្រីមេធាវី ប៉ែននី យេ បានចាប់ផ្ដើមធ្វើការសាកសួរអំពីការងាររបស់សាក្សី ។ ឆ្លើយតបនឹងបញ្ហានេះ សាក្សីបានបញ្ជាក់ថា ខ្លួនធ្វើការជាអ្នកចម្រៀងនៅឆ្នាំ១៩៧៥ដល់១៩៧៧ ទើបផ្លាស់ទៅធ្វើ

នៅមន្ទីរពេទ្យពុទ្ធវិញ ។ សាក្សីបានបន្ថែមថា នៅពេលសម្តែងម្តងៗ ខ្លួនត្រូវតែទន្ទេញឲ្យចាំសាច់រឿងជាមុន ប៉ុន្តែបើពេលថតសម្លេងវិញ គឺត្រូវអានផ្ទាល់តែម្តង ។ ចំពោះចម្រៀងដែលខ្លួនច្រៀងនៅពេលនោះ គឺមានតែចម្រៀងដែលមាននិយាយរៀបរាប់ពីជ័យជម្នះរំដោះទីក្រុង និងការលើកទឹកចិត្តឲ្យប្រជាជនធ្វើការងារ ។ សាក្សីបានបញ្ជាក់ថា នៅពេលនោះមានអ្នកនិពន្ធច្រើននាក់រួមទាំងអ្នកពិការភ្នែកផង ដូច្នេះខ្លួនបានជួយចម្លង និងកត់ត្រាការនិពន្ធនោះឡើងវិញ ។ សាក្សីបានបន្តថា ទាំងផ្នែកនិពន្ធ និងចម្រៀង គឺស្ថិតនៅក្រោមក្រសួងឃោសនាការទាំងអស់ ហើយមានតែចម្រៀងដែលផលិតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យប៉ុណ្ណោះ ដែលអាចយកមកចាក់ផ្សាយបាន ។

### ៣.២) ការបាត់ខ្លួនបុគ្គលិកនៅក្រសួងឃោសនាការ

ឆ្លើយតបនឹងសំណួររបស់មេធាវី សាក្សីបានបញ្ជាក់ថា បន្ទាប់ពីមានការចាប់ខ្លួន ហ៊ូ នឹម ក្រោយមក ឆយ គឺជាអ្នកមកជំនួស ហ៊ូ នឹម ដោយទទួលខុសត្រូវគ្រប់ផ្នែកនៅក្នុងក្រសួង ។ ក្រោយពីគ្រប់គ្រងនៅក្នុងក្រសួងមួយរយៈខ្លួនបានឮដំណឹងថា ឆយ ក៏ត្រូវបានចាប់ខ្លួនជាបន្តទៀតក្រោយពេលខ្លួនបានផ្លាស់មកធ្វើការនៅពេទ្យពុទ្ធ ។ មេធាវីបានលើកឡើងបន្តទាក់ទងនឹងឈ្មោះបុគ្គលិកមួយចំនួនដែលធ្វើការនៅក្នុងក្រសួង ។ ពាក់ព័ន្ធនឹងឈ្មោះទាំងនោះ សាក្សីបានរៀបរាប់ថា ហាន គឺជាអ្នកនិពន្ធ កែអត្ថបទជាសេចក្តីជូនដំណឹងមុនពេលចាក់ផ្សាយតាមវិទ្យុជាដើម ។ ចំណែក ហាន់ គឺជាបញ្ញាជនដែលទទួលការអប់រំមកពីសូវៀត មាននាទីជាអ្នកលេងភ្លេង និងនិពន្ធបទចម្រៀង ហើយ ហាន់ បានបាត់ខ្លួនពីក្រសួងមុនពេលខ្លួនចេញទៅធ្វើការនៅមន្ទីរពេទ្យពុទ្ធទៅទៀត ដោយមិនដឹងមូលហេតុ ។ សាក្សីបានបញ្ជាក់ថា ម៉ន គឺជាជំនួយការនៅក្នុងក្រុមរបស់ ហាន់ ហើយក្រោយមក ម៉ន ក៏ត្រូវបានចាប់ខ្លួនដែរ ។ ចំណែក សៅ គឺជាអ្នកទទួលខុសត្រូវខាងសិល្បៈរួម ហើយក្រោយមក សៅ ក៏បានផ្លាស់ចេញពីក្រសួងដែរ ។ មេធាវីបានបន្តសំណួរទាក់ទងនឹងការផ្លាស់ប្តូរទីកន្លែងរបស់សាក្សីនៅឆ្នាំ១៩៧៨ ។ សាក្សីបានបង្ហួរទឹកភ្នែកនៅក្នុងបន្ទប់សវនាការដោយរៀបរាប់ថា ខ្លួនបានរៀបការតាំងពីឆ្នាំ១៩៧៦ជាមួយបុគ្គលិកដែលធ្វើការនៅក្នុងក្រសួងជាមួយគ្នា ហើយក្រោយមកមានកូនស្រីមួយ ប៉ុន្តែគ្រួសារខ្លួនត្រូវបានបញ្ជូនចេញពីក្រសួង ដោយគ្មានដំណឹងហើយចំណែកខ្លួនត្រូវបានគេបញ្ជូនឲ្យទៅរៀនសូត្រនៅវត្តបុទុមនិងធ្វើការងារស្រោចបន្លែនៅទីនោះ ។

### ៣.៣) ការរៀបការ

លោកស្រីមេធាវីបានបន្តការសាកសួរទាក់ទងនឹងការរៀបការ ។ សាក្សីបានបញ្ជាក់ថា នៅជំនាន់នោះការរៀបការរបស់ខ្លួន គឺមានការអនុញ្ញាតពីអង្គការដែលជាឪពុកម្តាយ ហើយពេលនោះដែរ គឺមានគ្រួសារប្រាំមួយគូរៀបការក្នុងពេលជាមួយគ្នា ។ ទាក់ទងនឹងការរៀបការនេះ លោកប្រធានបានធ្វើការរំឭកដល់មេធាវីកុំឲ្យសួរសំណួរចាកឆ្ងាយពីអង្គហេតុដែលត្រូវយកមកពិភាក្សាទាក់ទងនឹងការជម្លៀសនៅក្នុងដំណាក់កាលពីមួយ និងដំណាក់កាលទីពីរតែប៉ុណ្ណោះ ។

### ៣.៤) ទិដ្ឋភាពក្រោយពេលជម្លៀស

បន្ទាប់មក លោកស្រីមេធាវីបានបញ្ចប់ការសាកសួរដោយផ្ទេរវេទិកាបន្ទាប់ជូនលោកមេធាវីជាតិ ពេជ អង្គ ដើម្បីធ្វើការសាកសួរបន្ត ។ លោកមេធាវីបានសួរសំណួរមួយចំនួនទាក់ទងនឹងស្ថានភាពនៅទីក្រុងភ្នំពេញក្រោយពេលជម្លៀសដោយសាក្សីបានបញ្ជាក់ថា នៅពេលនោះខ្លួនបានឃើញតែទាហានប៉ុណ្ណោះមិនមានប្រជាជនរស់នៅទេ ។ សាក្សីបានបន្តថា ចាប់តាំងពីខ្លួនបានមកដល់ទីក្រុងភ្នំពេញរហូតដល់ឆ្នាំ១៩៧៦ ខ្លួនមិនដែលដើរទៅណាទេ គឺនៅតែធ្វើការនៅក្នុងក្រសួងប៉ុណ្ណោះ ។ មុនពេលបញ្ចប់ការសាកសួរ លោកមេធាវីបានបន្តសួរទាក់ទងនឹងការងាររបស់គ្រួសារសាក្សីនៅក្នុងរបបខ្មែរក្រហម ដោយមេធាវីអះអាងថាគ្រួសារក្រោយរបស់សាក្សីមានតួនាទីជានិរសាររបស់ជនជាប់ចោទម្នាក់ដែលអាចដឹងពីការចាប់ខ្លួនមនុស្សចូលទៅមន្ទីរស-២១ ប៉ុន្តែបញ្ហានេះសាក្សីបានបញ្ជាក់ថា ខ្លួនមិនដែលបានដឹងពីប្រវត្តិគ្រួសាររបស់ខ្លួនឡើយ ។

### ៤) ការសួរសាក្សីដោយចៅក្រម ហ្សង់ម៉ាក ឡាវ៉ីញ

បន្ទាប់ពីបញ្ចប់ការសាកសួរដោយមេធាវីដើមបណ្តឹងរដ្ឋប្បវេណី លោកចៅក្រមបានចាប់ផ្តើមសាកសួរសាក្សីពីការជួបជាមួយ ខៀវ សំផន ។ សាក្សីបានបញ្ជាក់ថា នៅពេលនោះខ្លួនបានជួប ខៀវ សំផន នៅស្រែវាលក្រោយមកនៅអគ្គិសនី និងនៅក្រសួងឃោសនាការ ។ បន្ទាប់មកលោកចៅក្រមបានសាកសួរទាក់ទងនឹង

អាកប្បកិរិយារបស់ជនជាប់ចោទនៅពេលជម្លៀស ។ សាក្សីបានបញ្ជាក់ថា ក្នុងពេលនោះជនជាប់ចោទមានចរិតចាស់ទុំ និងមិនត្រេកត្រអាលនឹងការរំដោះនោះទេ ។ លោកចៅក្រមបានបន្តដកស្រង់សម្តីរបស់ជនជាប់ចោទពីការរំដោះទីក្រុងដែលបង្ហាញពីអារម្មណ៍ក្រៀមក្រំរបស់ជនជាប់ចោទ ប៉ុន្តែសាក្សីបានបញ្ជាក់ថា ខ្លួនមិនអាចយល់ពីអារម្មណ៍របស់ជនជាប់ចោទនោះទេ ដូច្នេះខ្លួនមិនអាចធ្វើការសន្និដ្ឋានពីស្ថានភាពនោះបានឡើយ ។ ទាក់ទងនឹងសេចក្តីថ្លែងការណ៍មួយចំនួនរបស់ ខៀវ សំផន វិញ សាក្សីបានបញ្ជាក់ថា ខ្លួនមិនចាំពីការផ្សព្វផ្សាយទាំងនោះទេ ហើយខ្លួនក៏បានស្តាប់សេចក្តីថ្លែងការណ៍ទាំងនោះដែរ ។ លោកចៅក្រមបានលើកយកកំណត់ហេតុរបស់គណៈអចិន្ត្រៃយ៍ ដែលមានឈ្មោះមេដឹកនាំមួយចំនួនដូចជា ប៉ុល ពត, ភាស់ ឬ ហ៊ូ នឹម, ទូច និងអ្នកផ្សេងទៀតដែលការផ្សាយនោះទាក់ទងនឹងមនោគមវិជ្ជា និងការតស៊ូវណ្ណៈជាដើម ។ បន្ទាប់មក លោកបានលើកឡើងពីកំណត់ហេតុទាក់ទងនឹងការណែនាំក្នុងការបោះឆ្នោត ប៉ុន្តែបញ្ហាទាំងនេះសាក្សីបានបញ្ជាក់ថា ខ្លួនមិនបានដឹងនោះទេ ។

### ៥) ការសួរសាក្សីដោយមេធាវីការពារក្តីទាំងបីក្រុម

### ៥.១) ក្រុមមេធាវីការពារក្តី នួន ជា

លោកមេធាវីអន្តរជាតិ ហ្សាស្តី ប៉ៅ បានចាប់ផ្តើមដោយការលើកឡើងពីការសម្ភាសន៍របស់សាក្សីជាមួយចៅក្រមស៊ើបអង្កេតទាក់ទងនឹងគោលនយោបាយដែលនិយាយថា ប្រជាជនខ្មែរម្នាក់អាចសម្លាប់ជនជាតិវៀតណាម៣០នាក់ ប៉ុន្តែសំណួរនេះត្រូវបានសាក្សីបានបញ្ជាក់ថា ខ្លួនមិនចាំពីអ្វីដែលខ្លួនបានផ្តល់បទសម្ភាសន៍ពីមុននោះទេ ។ ទាក់ទងនឹងបញ្ហានេះដែរ លោកមេធាវីបានលើកយកសេចក្តីដកស្រង់ត្រង់ចំណុចដដែលមកបញ្ជាក់ ហើយសាក្សីបានបញ្ជាក់ថា ខ្លួនបានដឹងពីការផ្សព្វផ្សាយដែល



ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញថ្ងៃទី១៧មេសា ឆ្នាំ១៩៧៥ (រូបភាពមជ្ឈមណ្ឌលឯកសារកម្ពុជា)

ទាក់ទងនឹងការអប់រំទាហាននៅតាមវិទ្យុដែរ នៅពេលនោះ ។ មុនពេលបញ្ចប់ការសាកសួររបស់ខ្លួន លោកមេធាវី បានផ្ទេរវេទិកាសាកសួរជូនសហភាគារបស់ខ្លួនគឺលោក សុន អរុណ ។ លោក សុន អរុណ បានបន្តដោយសាកសួរសាក្សីនូវសំណួរមួយចំនួនទាក់ទងនឹងការចូលធ្វើបដិវត្តន៍ ហើយសាក្សីបានបញ្ជាក់ថា ខ្លួនបានចូលធ្វើបដិវត្តន៍នៅឆ្នាំ១៩៧២ ដោយបន្ថែមថា កាលនោះខ្លួននៅក្មេងចូលចិត្តច្រៀងអាយ៉ៃ ហើយមានគណៈស្រុកឈ្មោះ ពុំ បានមកប្រាប់ខ្លួនថា គេត្រូវការអ្នកចេះសិល្បៈ ហើយពេលនោះខ្លួនក៏បានចូលរួមក្នុងក្រុមសិល្បៈស្រុកនៅខេត្តព្រៃវែងដោយខ្លួនឯង ។ មេធាវីបានបន្តសួរទាក់ទងនឹងការផ្លាស់មនុស្សចេញពីមន្ទីរឃោសនាការដោយសាក្សីបានបញ្ជាក់ថា ខ្លួនធ្វើការនៅក្រសួងឃោសនាការ ហើយដល់ឆ្នាំ១៩៧៧ ខ្លួនត្រូវបានដកទៅមន្ទីររោងពុម្ពគឺនៅមន្ទីរ២៧ ។ សាក្សីបានបន្តរៀបរាប់ពីការបាត់ខ្លួនរបស់ ហ៊ូ នឹម ដោយបញ្ជាក់ថា ហ៊ូ នឹម បានបាត់ខ្លួននៅក្រោយពេលនិយាយទូរស័ព្ទរួច ។ ក្រោយពីការបាត់ខ្លួន ហ៊ូ នឹម មកគឺមាន ឆយ ជាអ្នកមកជំនួស ។ សាក្សីបានបន្តថា នៅពេលនោះខ្លួនមិនមែនជាអ្នកអានវិទ្យុទេ គឺខ្លួននៅតែខាងសិល្បៈតែប៉ុណ្ណោះ ដោយសារខ្លួនមិនចេះអក្សរច្រើន ។

### ៥.២) ក្រុមមេធាវីការពារក្តី អៀង សារី

លោក ម៉ៃឃើល កាណាវ៉ាស បានចាប់ផ្តើមដោយលើកឡើងពីការផ្តល់សក្ខីកម្មរបស់សាក្សីជាមួយចៅក្រមស៊ើបអង្កេតដែលបញ្ជាក់ថា សាក្សីបានឃើញ អៀង សារី ដើម្បីឲ្យសាក្សីបញ្ជាក់ ។ សាក្សីបានរៀបរាប់ថា ពេលនោះខ្លួនបានផ្តល់បទម្ភាសន៍មែន ហើយសហចៅក្រមស៊ើបអង្កេតបានអានឲ្យខ្លួនស្តាប់ពីកំណត់ហេតុទាំងនោះដែរ ប៉ុន្តែដោយសារខ្លួនមានការហត់នឿយខ្លាំងនោះ ខ្លួនមិនចាំថានៅក្នុងពេលសម្ភាសន៍នោះខ្លួនបាននិយាយអ្វីខ្លះនោះទេ ប៉ុន្តែត្រង់ចំណុចនេះខ្លួនគ្រាន់តែបានឮថា អៀង សារី គឺជារដ្ឋមន្ត្រីក្រសួងការបរទេស ប៉ុន្តែខ្លួនមិនបានឃើញជនជាប់ចោទផ្ទាល់ភ្នែកនោះឡើយ ។ នៅត្រង់ចំណុចនេះលោកមេធាវី កាណាវ៉ាស បានធ្វើការកត់សម្គាល់ថា ចម្លើយដែលសាក្សីផ្តល់ឲ្យសហចៅក្រមស៊ើបអង្កេត គឺខុសគ្នានឹងការផ្តល់សក្ខីកម្មរបស់សាក្សីដែលនេះអាចជាការផ្តល់ព័ត៌មានខុសរបស់សាក្សី ឬជាកំហុសក្នុងពេលសរសេររបស់សហចៅក្រមស៊ើបអង្កេត ។ បន្តមកទៀតលោកមេធាវីបានសួរសំណួរមួយចំនួនទាក់ទងនឹងការចូលរួមប្រជុំនៅក្នុងគណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍ ប៉ុន្តែទាក់ទងនឹងចំណុចនេះ សាក្សីបានបញ្ជាក់ថា ខ្លួនមិនចាំពីព្រឹត្តិការណ៍ទាំងនោះឡើយ ។ មេធាវីបានសួរនូវសំណួរមួយចំនួនទៀត ប៉ុន្តែសំណួរទាំងនោះមិនត្រូវបានសាក្សីផ្តល់ចម្លើយនោះទេ ដោយសារសាក្សីមិនចាំពីព្រឹត្តិការណ៍ និងបទសម្ភាសន៍ដែលធ្វើឡើងជាមួយសហចៅក្រមស៊ើបអង្កេត ។

### ៥.៣) ក្រុមមេធាវីការពារក្តី ខៀវ សំផន

លោក គង់ សំអុន បានបន្តការសួរទាក់ទងនឹងពេលដែលសាក្សីបានជួប ខៀវ សំផន មុនឆ្នាំ ១៩៧៥ ។ សាក្សីបានបញ្ជាក់ថា ខ្លួនបានជួប ខៀវ សំផន នៅពេលប្រារព្ធពិធីបុណ្យចូលឆ្នាំកាលពីឆ្នាំ១៩៧៤តែម្តងប៉ុណ្ណោះ ហើយនៅក្នុងកម្មវិធីបុណ្យនោះក៏មានការទទួលបាយទឹកនំចំណីជាដើម ។ សាក្សីបានបញ្ជាក់ថា នៅឆ្នាំ១៩៧៥ពេលដែលខ្លួនមកនៅភ្នំពេញ ខ្លួនបានជួប ខៀវ សំផន ដែលកំពុងជិះឡាន ហើយមាននារីពីរនាក់ឈ្មោះ និមល និង យេត បានរួមដំណើរមកជាមួយដែរ ហើយខ្លួនចេញមកតាមក្រោយជាមួយក្រុមសិល្បៈ ។ បន្ទាប់មក លោកមេធាវីបានបន្តសួរដោយលើកឡើងពីការធ្វើបទសម្ភាសន៍ជាមួយសហចៅក្រមស៊ើបអង្កេតដែលថា ខៀវ សំផន នៅជាប់ជាមួយសម្តេច សីហនុ ហើយសាក្សីបានទទួលស្គាល់ចំពោះចម្លើយដែលខ្លួនផ្តល់ឲ្យនោះ ។ បន្ទាប់មក មេធាវីអន្តរជាតិ អានតា ហ្គីសេ្ស បានបន្តការសាកសួរទាក់ទងនឹងការផ្តល់បទសម្ភាសន៍ជាមួយចៅក្រមស៊ើបអង្កេត ដែលសាក្សីបានបញ្ជាក់ថា នៅពេលនោះខ្លួនអស់កម្លាំងនិងមិនអាចចាំពីអ្វីដែលខ្លួនបានឆ្លើយនោះបានទេ ។ លោកមេធាវីបានលើកឡើងនូវការជួបគ្នារវាងសាក្សី និងខៀវ សំផន ដោយសាក្សីបានបញ្ជាក់ថា ខ្លួនបានឃើញ ខៀវ សំផន ពិតមែន ប៉ុន្តែមិនបានដឹងថា ខៀវ សំផន បានធ្វើដំណើរចេញទៅទីណាទៀតនោះទេ ។ មេធាវីបានបន្តសួរទាក់ទងនឹងការធ្វើដំណើរចូលទីក្រុងភ្នំពេញ ហើយសាក្សីបានបញ្ជាក់ថា នៅពេលនោះខ្លួនបានឃើញ ខៀវ សំផន ក្នុងថ្ងៃដែលខ្លួនបានទៅដល់ទីតាំងនៃក្រសួងឃោសនាការ ។

បន្ទាប់មក អង្គជំនុំជម្រះបានបញ្ចប់ការសាកសួរសាក្សី ស សៀក និងប្រកាសបន្តស្តាប់សក្ខីកម្មរបស់សាក្សីឈ្មោះ គឹម វុន ជាបន្តទៀត ។

**ពិនិត្យ និងផ្ទៀងផ្ទាត់ដោយ វ៉ាន់ថាន់ ពោដារ៉ា**

## ពន្យល់ពាក្យសំខាន់ៗ

ប-១ : មន្ទីរនៃក្រសួងការបរទេស ។

ប-៣០, ៣១, ៣២ : ជំរំអប់រំកែប្រែសម្រាប់បញ្ញវន្ត អ្នកការទូត និងនិស្សិត ដែលផ្ញើមាតុភូមិនិវត្តន៍ ។ មានទីតាំងស្ថិតនៅបឹងត្របែកក្នុងទីក្រុងភ្នំពេញ ដែលត្រូវបានប្តូរឈ្មោះដោយភ្ជាប់លេខកូដអក្សរ“ប” បន្ទាប់ពីបានផ្ទេរការគ្រប់គ្រងពីមន្ទីរ៨៧០ មកឲ្យក្រសួងការបរទេស ដែលពីមុនត្រូវបានគេស្គាល់ថាជាមន្ទីរក-១៥, ក-១៦ និង ក-១៧ ។

ស-២១ : មន្ទីរសន្តិបាលស-២១ គឺជាមន្ទីរសន្តិសុខសម្ងាត់របស់នគរបាលដែលមានទីតាំងនៅទីក្រុងភ្នំពេញ ។


## មជ្ឈមណ្ឌលឯកសារកម្ពុជា

ប្រអប់សំបុត្រលេខ១១១០, ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥

ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨

អ៊ីម៉ែល : *dccam@online.com.kh*

គេហទំព័រ : *www.dccam.org*

ឬ *www.cambodiatribunal.org*



គម្រោងនេះទទួលជំនួយហិរញ្ញវត្ថុពីមូលនិធិ *John D. and Catherine T. MacArthur Foundation and British Embassy-Cambodia* ។


| ល.រ | ឈ្មោះដើម | ឈ្មោះបដិវត្ត | លេខសម្ងាត់ | ប្រភពឯកសារ |
|---|---|---|---|---|
| ១ | សាឡុត ស | ប៉ុល ពត, បងប៉ុល, បងទី១, | ៨៧០, ៨៧ | D427, E1/56.1 |
| ២ | ឡុង រិទ្ធ | នួន ជា, បងនួន, បងទី២ | (អត់ដឹង) | D427 |
| ៣ | គីម ត្រាង | អៀង សារី, វ៉ាន់ | (អត់ដឹង) | D427, E1/21.1 |
| ៤ | ខៀវ សំផន | ហែម, ខាង, ណន | (អត់ដឹង) | D427 |
| ៥ | សុន សេន | ខៀវ, ឃឹម | ៨៩, ៦២ | E1/54.1 |



**ឆាយ ឈុនលី**

បរិញ្ញាបត្រច្បាប់ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។



**លឹម ជ័យច័ត្ត**

បរិញ្ញាបត្រច្បាប់ និងបរិញ្ញាប័ត្រសេដ្ឋកិច្ច ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងជាជ័យលាភីថ្នាក់ជាតិ ក្នុងការប្រកួតសវនាការប្រឌិតឆ្នាំ២០១០ ។



**ឌី សុជាតា**

បរិញ្ញាបត្រច្បាប់ សិក្សាជាភាសាអង់គ្លេស ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។



**ចាន ប្រាថ្នា**

បរិញ្ញាបត្រច្បាប់ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។

សង្កេតការណ៍ ១
ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម




សង្កេតការណ៍ ២
ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម




សង្កេតការណ៍ ៣
ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម




សង្កេតការណ៍ ៤
ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម




សង្កេតការណ៍ ៥
ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម




សង្កេតការណ៍ ៨
ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម




សង្កេតការណ៍ ៦
ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម




សង្កេតការណ៍ ៧
ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម




សង្កេតការណ៍ ៩
ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម




សង្កេតការណ៍ ១០
ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម




សង្កេតការណ៍ ១១
ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម




សង្កេតការណ៍ ១២
ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម




សង្កេតការណ៍ ១៣
ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម




សង្កេតការណ៍ ១៤
ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម




មជ្ឈមណ្ឌលឯកសារកម្ពុជា រក្សាសិទ្ធិខែកញ្ញា ឆ្នាំ២០១២